សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន កម្រិតបរិញ្ញាបត្រ

កញ្ចប់សមត្ថភាពទី១
ចំណេះដឹងឯកទេសបរិញ្ញាបត្រ

# មុខវិជ្ជា៖ ទ្រឹស្តីប្រវត្តិសាស្ត្រ



# មុខវិជ្ជា៖
# ទ្រឹស្តីប្រវត្តិសាស្ត្រ

កញ្ចប់សមត្ថភាពទី ១
ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

ទ្រឹស្តីប្រវត្តិសាស្ត្រ គឺជាមុខវិជ្ជាទ្រឹស្តីដែលមានគោលដៅណែនាំអ្នកសិក្សាស្វែងយល់ពីមូលដ្ឋានគ្រឹះទ្រឹស្តីប្រវត្តិសាស្ត្រសំខាន់ៗដូចជា មធ្យោបាយឬវិធីសាស្ត្រដែលប្រវត្តិវិទូទាំងឡាយ កំណត់និយមន័យនិងព្រំដែនសិក្សាប្រវត្តិសាស្ត្រ វិភាគភស្តុតាងប្រវត្តិសាស្ត្រ បែងចែកប្រភពឯកសារដើម និងទីពីរ និងបង្កើតនិទានកថាប្រវត្តិសាស្ត្រ។

**លទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុកទី ១៖ រៀបរាប់ប្រវត្តិវិទូល្បីៗ និងអ្នកប្រាជ្ញពាក់ព័ន្ធសំខាន់ៗ
លទ្ធផលសិក្សារំពឹងទុកទី ២៖ យល់ពីទស្សនៈនានាស្តីពីទ្រឹស្តីប្រវត្តិសាស្ត្រ
លទ្ធផលសិក្សារំពឹងទុកទី ៣៖ បែកចែកយ៉ាងច្បាស់នូវប្រភពព័ត៌មាន និងឯកសារ
លទ្ធផលសិក្សារំពឹងទុកទី ៤៖ ប្រៀបធៀបទ្រឹស្តីនិងវិធីសាស្ត្រសរសេរប្រវត្តិសាស្ត្រ
លទ្ធផលសិក្សារំពឹងទុកទី ៥៖ វាយតម្លៃនិងផ្តល់យោបល់ដល់គ្នា ក្នុងន័យស្ថាបនា

**របាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%
២. ការចូលរួមសកម្មភាពសិក្សា ២០%
៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%
៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖ លំហាត់បែងចែកប្រភពឯកសារ

កិច្ចការទី ២៖ កិច្ចការក្រុម ឆ្លុះបញ្ចាំងទ្រឹស្តី

កិច្ចការទី ៣៖ ប្រឡងត្រីមាស

កិច្ចការទី ៤៖ ប្រឡងឆមាស

# **អារម្ភកថា**

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំ ឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីវិក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃ ចន្ទ ៦រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## គណៈកម្មការ

### ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ប៉ាល់ ដែល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអោ អឌ្ឍារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រីង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

### ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សុត្រា** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **មាក គារមេរ៉ាន** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ជ័យ ចាន់រឿន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ម៉ម សុជាតិ** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **សុត ទិសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **ឃុន គឹមលាង** | ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោកស្រីបណ្ឌិត | **ស៊ុំ កល្យាណ** | អនុប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **ហង់ ស៊ីម** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **ដួង ប៉េងអាន** | អ្នកសម្របសម្រួលកម្មវិធីមធ្យមសិក្សា មហាវិទ្យាល័យអប់រំ |
| ១០. កញ្ញា | **ហុង ឡៃហៀក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **សើ ពន្លក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

### ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអោ អឌ្ឍារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រីង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ង៉ោ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈុក ច័ន្ទនាយ៉ា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សារ៉ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

### ៤. ការីកុំព្យូទ័រ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ារ៉ាឌី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

២. លោក **ឌន សំណាង** បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្ត ទំនាក់-ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជា ឯកទេសប្រវត្តិវិទ្យាប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*
*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសប្រវត្តិវិទ្យាកម្រិតបរិញ្ញាបត្រ**

- ❖ ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរាណ
- ❖ ប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប
- ❖ ទ្រឹស្តីប្រវត្តិសាស្ត្រ
- ❖ ប្រវត្តិសាស្ត្រពិភពលោក
- ❖ ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍
- ❖ ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង
- ❖ សន្លឹកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា

- ❖ ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា

**(២) ចំណេះដឹងវិធីគរុកោសល្យ សាស្ត្របង្រៀន និងការអប់រំប្រវត្តិវិទ្យាកម្រិតមធ្យមសិក្សា**

- ❖ វិធីសាស្ត្របង្រៀន
- ❖ វិធីសាស្ត្រវាយតម្លៃ
- ❖ ការស្រាវជ្រាវប្រតិបត្តិ
- ❖ ប្រឹក្សាគរុកោសល្យ
- ❖ បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង**

- ❖ អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ❖ ការអនុវត្តកម្មវិធីស្វ័យសិក្សារូបវិទ្យា ពីទីថ្នាក់៧-ទី១២
- ❖ របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនរូបវិទ្យាប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនរូបវិទ្យា និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្តាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome (PLO) លទ្ធផលសិក្សាកម្មវិធីអប់រំ

## កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្តោតលើបណ្តុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្រ្តបង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្តងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធន៍អនុវត្តជាក់ស្តែងកន្លងមក ។

| បណ្តុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្រ្តបង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យ វិធីសាស្រ្តបង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំចំនួន ៣ក្រេឌីត*

## លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្តុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ប្រវត្តិសាស្រ្តកម្ពុជាសម័យបុរាណ | ៣ |
| | ប្រវត្តិសាស្រ្តកម្ពុជាសម័យទំនើប | ៣ |
| | ទ្រឹស្តីប្រវត្តិសាស្រ្ត | ៣ |
| | ប្រវត្តិសាស្រ្តពិភពលោក | ៣ |
| | ប្រវត្តិសាស្រ្តអាស៊ីអាគ្នេយ៍ | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត១ (ចងចាំ) | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |

| | | |
|---|---|---|
| | សន្និកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្និកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |
| | ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និង ការអប់រំមធ្យមសិក្សា (២០%) | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ* | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សា គរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្តីពីការអនុវត្តស្តង់ដាយុទ្ធសាស្ត្រ សហគមន៍សាលារៀន | ៣ |
| **សរុប** | | **៦៣** |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**




## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ

២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

### ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average-GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point-P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value-C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |

| | | | |
|---|---|---|---|
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួល

ពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹងវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែងដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ
ប្រភពហិរញ្ញប្បទាន៖ គម្រោងកែលម្អការអប់រំចំណេះទូទៅ

# ប្រវត្តិសាស្ត្រ
# ទ្រឹស្តី និងអនុវត្តន៍



រៀបរៀងដោយ
ចា លាងអាង
២០២១

CAMBODIA
RESEARCH CREATIVITY INNOVATION

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

# ប្រវត្តិសាស្ត្រ
# ទ្រឹស្តី និងអនុវត្តន៍

រៀបរៀងដោយ
ថា លាងអាង
២០២១

CAMBODIA
RESEARCH CREATIVITY INNOVATION

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
# មហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ
# ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

## គណៈកម្មការនិពន្ធ

១. លោក **ឋា លាងអាង** សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

## គណៈកម្មការត្រួតពិនិត្យ

១. លោកបណ្ឌិត **វង់ សុធារ៉ា** ប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
២. លោក **ណុប សុខា** អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
៣. លោក **គួង គានី** សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
៤. លោក **អ៊ី ប៊ុនលី** សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ ៥៣% នៅឆ្នាំ ២០០៤ មកនៅទាបជាង ១០% នៅឆ្នាំ ២០១៩ ។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំ ឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាព ក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវ ជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ ៥% នៃការវិនិយោគ ទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង ២ នេះមានប្រជាជនប្រមាណ២០% នៃប្រជាជន ពិភពលោក។ ប្រទេសចំនួន ៦ ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០% នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី ៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជាត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២ នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labor and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សុំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។

សមត្ថភាពទាំងនេះ អាចកើតឡើង នៅពេលពលរដ្ឋកម្ពុជាមានឱកាស ក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្តគឺជាចលករនៃការរៀនរបស់សិស្ស។ ជាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយ ពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំគឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទី ដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជា ស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែក លើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិនិងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង ២,២ លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន ៤៤០ ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើន ជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើបចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និង

សាធារណៈជនកម្ពុជា ដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ដែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថល ដែលមានភាពសម្បូរបែប ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្ដិសិទ្ធិ និងផ្ដល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្ដល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាព ជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម ៤.០ (Digitalization for IR.៤.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី ២១ (២1st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្ម ទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈ និងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច ២ ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធ

អេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណាងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# របស់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា ឡើយ។

# អារម្ភកថា

សៀវភៅនេះ ត្រូវបានរៀបរៀងឡើង ក្រោមការឧបត្ថម្ភគាំទ្ររបស់មូលនិធិស្រាវជ្រាវ គំនិតផ្តួចផ្តើម និងនវានុវត្តន៍ សម្រាប់ទុកជាសៀវភៅសិក្សាគោល ដើម្បីបម្រើឲ្យការរៀន និងបង្រៀនមុខវិជ្ជា «ទ្រឹស្តីប្រវត្តិសាស្ត្រ» នៅក្នុងដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សៀវភៅនេះផ្តល់ជូនអ្នកសិក្សានូវទ្រឹស្តីប្រវត្តិសាស្ត្រល្បីៗ និងគោលការណ៍អនុវត្តន៍នានា ដើម្បីស្វែងយល់ពីប្រវត្តិសាស្ត្រ អោយកាន់តែច្បាស់ថែមទៀត ។ បន្ថែមពីលើនេះទៀត និស្សិតក៏នឹងបានសិក្សានិងអនុវត្តន៍ជំនាញពាក់ព័ន្ធសម្រាប់សម្រេចជោគជ័យក្នុងជីវិតថ្នាក់ឧត្តមសិក្សា ផងដែរ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ថា លាងអាង ជាសាស្ត្រាចារ្យ ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃមហាវិទ្យាល័យសង្គមសាស្ត្រ និង មនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង ជាអ្នករៀបរៀងសៀវភៅសិក្សាគោល ដែលមានចំណងជើង ថា «ប្រវត្តិសាស្ត្រ៖ ទ្រឹស្ដី និងការអនុវត្តន៍» សម្រាប់ប្រើប្រាស់ក្នុងវគ្គ«ទ្រឹស្ដីប្រវត្តិសាស្ត្រ»។ ខ្ញុំបាទសូមសម្ដែងនូវ គារវកិច្ចដ៏ខ្ពង់ខ្ពស់ និងសូមគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្ដល់ថវិកាមកក្រសួងអប់រំ ដើម្បីបង្កើតជាមូលនិធិសម្រាប់គាំទ្រ ដល់ការសរសេរសៀវភៅសិក្សាសម្រាប់កម្រិតឧត្តមសិក្សារបស់ខ្ញុំបាទនេះ។

- ក្រសួងអប់រំ យុវជន និងកីឡា ដែលមាន ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ជួន ណារ៉ុន ជាប្រមុខ ដែលលោកបានដឹកនាំបង្កើតមូលនិធិស្រាវជ្រាវគំនិតច្នៃប្រឌិតនិងនវានុវត្តន៍ឡើង ដើម្បីគាំទ្រទាំងស្រុងដល់ដំណើរ ការសរសេរសៀវភៅនេះ ដែលជាចំណែកមួយក្នុងបេសកកម្មកំណែទម្រង់វិស័យអប់រំឧត្តមសិក្សារបស់លោក។

- ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលក្នុងនាមលោកជា តំណាងមូលនិធិ លោកបានយកអស់កម្លាំងការចិត្ត ជួយចាត់ចែងនិងជ្រោមជ្រែងយ៉ាងពេញទំហឹង ព្រមទាំងផ្ដល់ជា អនុសាសន៍និងដំណោះស្រាយនានា ដើម្បីជំនះនូវរាល់ឧបសគ្គ ដែលកើតមានក្នុងដំណើរការសរសេរសៀវភៅនេះ។

- ឯកឧត្តមបណ្ឌិត ជេត ជាលី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានយកអស់ កម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មមាញឹកនិងមានតម្លៃរបស់លោកក្នុងការជួយលើកទឹកចិត្ត ជួយខ្នះខ្នែង ដោះស្រាយ និងផ្ដល់អនុសាសន៍ដ៏ត្រឹមត្រូវ ក៏ដូចជាបង្កលក្ខណៈងាយស្រួលនានា ទាំងផ្នែករដ្ឋបាល និងទាំង ផ្នែកបច្ចេកទេស ដើម្បីឲ្យដំណើរការរៀបរៀងសៀវភៅនេះបានប្រព្រឹត្តទៅដោយរលូនរហូតចប់ចុងចប់ដើម។

- លោក លួន ពេជ្របូរី និង អស់លោក-លោកស្រី ជាក្រុមការងារសម្របសម្រួលទាំងអស់ របស់ មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានយកអស់កម្លាំងកាយចិត្ត ជួយឈឺឆ្អាលក្នុង ការដោះស្រាយបញ្ហាប្រឈមនានាយ៉ាងសស្រាក់សស្រាំជាទីបំផុត ដោយមិនត្អូញត្អែរ និងមិនខ្លាចនឿយហត់ ដើម្បីឲ្យ ការសរសេរសៀវភៅនេះប្រព្រឹត្តទៅដោយរលូន។

- ឯកឧត្តមបណ្ឌិត ស៊្រី ថារិទ្ធ អ្នកសម្របសម្រួលសាលាក្រោយឧត្តម និង លោកបណ្ឌិត សុខ សិរី អនុប្រធានការិយាល័យស្រាវជ្រាវ ដែលតែងជួយឈឺឆ្អាល ជួយសម្របសម្រួល និងផ្ដល់សេវាសម្រាប់ការប្រជុំ បច្ចេកទេសនានាតាមអនឡាញតាំងពីដើមរៀងមក។

- អស់លោក-លោកស្រី ជាសមាជិក-សមាជិកាគណៈកម្មការអភិវឌ្ឍសៀវភៅសិក្សា ក៏ដូចជាគណៈកម្មការ ត្រួតពិនិត្យសៀវភៅសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយផ្ដល់ជាតុចូលដល់សៀវភៅនេះឲ្យ កាន់តែមានគុណភាពប្រសើរថែមទៀត។

- ជាចុងក្រោយ និងជាពិសេស លោក ធូ រេណូ ប្រធានការិយាល័យស្រាវជ្រាវ នៃសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ ដែលតែងជួយផ្ដល់ជាតុចូលចំពោះរាល់ឯកសារការងារ ទាំងផ្នែករដ្ឋបាលនិងទាំងផ្នែកបច្ចេកទេស លោកថែមទាំងជួយសម្រួលរាល់បញ្ហាប្រឈមនានា យ៉ាងដឹតដល់បំផុត ដោយមិនប្រកាន់ពេលវេលា និងដោយចិត្ត ជ្រះថ្លា រហូតការសរសេរសៀវភៅនេះទទួលបានជោគជ័យជាស្ថាពរ៕

# មាតិកា

បុព្វកថា ..... i
សេចក្តីបញ្ជាក់ ..... vi
អារម្ភកថា ..... vii
សេចក្តីថ្លែងអំណរគុណ ..... viii
មាតិកា ..... ix
**ជំពូកទី ១ ទ្រឹស្តីប្រវត្តិសាស្ត្រ** ..... ១
**មេរៀនទី ១ ៖ និយមន័យ និងការប្រើប្រាស់ប្រវត្តិសាស្ត្រ** ..... ១
១.១. និយមន័យទ្រឹស្តី និងប្រវត្តិវិទ្យា ..... ១
១.២. ប្រវត្តិវិទូដំបូងៗ ..... ២
១.២.១. ហេរ៉ូដូទឹស (Herodotus) ..... ៣
១.២.២. ស៊ូស៊ីឌីឌីស (Thucydides) ..... ៣
១.២.៣. ហេរូណូហ្វុន (Xenophon) ..... ៤
១.២.៤. សាលឹស (Gaius Sallustius Crispus) ..... ៤
១.២.៥. ស៊ីសេរ៉ូ (Cicero, Marcus Tullius) ..... ៥
១.២.៦. លីវី (Livy Titus Livius) ..... ៥
១.២.៧. តាស៊ីតឹស (Tacitus , Cornelius) ..... ៥
១.២.៨. បេដ៏ (Bede , St) ..... ៦
១.២.៩. ម៉ាគីយ៉ាវែល្លី (Machiavelli, Niccolo) ..... ៦
១.២.១០. អេដវឺត ហ្គីប្បុន (Gibbon , Edward) ..... ៦
១.២.១១. ម៉ាកូឡៃ (Macaulay, Thomas Babington) ..... ៦
១.២.១២. កាលីល៍ (Carlyle , Thomas) ..... ៦
១.២.១៣. វ៉ុលទែរ (Voltaire, Francois- Marie Arouet) ..... ៧
១.២.១៤. រូសូ ហ្សង់ហ្សាក់ (Rousseau, Jean Jacques) ..... ៧
១.៣. សម្រង់ទស្សនៈនានាស្តីពីប្រវត្តិសាស្ត្រ ..... ៧
១.៤. ទំនាក់ទំនងមុខវិជ្ជាប្រវត្តិវិទ្យា និងមុខវិជ្ជាដទៃទៀត ..... ១២
១.៤.១. ប្រវត្តិវិទ្យា និងបុរេប្រវត្តិសាស្ត្រ (History and Prehistory) ..... ១២
១.៤.២. វិជ្ជាការសរសេរប្រវត្តិសាស្ត្រ (Historiography) ..... ១៣
១.៤.៣. ការកំណត់និយមន័យនៃវិជ្ជាការសរសេរប្រវត្តិសាស្ត្រ ..... ១៤
១.៤.៤. សំណួរត្រូវសិក្សាស្វែងយល់ ( Questions Studied) ..... ១៤
១.៤.៥. វិជ្ជាការសរសេរប្រវត្តិសាស្ត្របែបត្រិះរិះពិចារណា (Criticalhistoriography) ..... ១៤
១.៤.៦. មុខវិជ្ជាសិក្សាពាក់ពន្ធ័មួយចំនួនទៀត ..... ១៥
**មេរៀនទី ២ ៖ ទេវកថា និង ទ្រឹស្តីប្រវត្តិសាស្ត្រក្រិកបុរាណ** ..... ១៧
២.១. និយមន័យទេវកថា និងគោលដៅ ..... ១៧
២.២. ទេវកថាខ្មែរ និងទេវកថាពិភពលោក ..... ១៧
២.២.១. ទេវកថាខ្មែរ ..... ១៧

២.២.២. ទេវកថាពិភពលោក ..... ១៩
២.៣. ទ្រឹស្តីប្រវត្តិសាស្ត្រក្រិកបុរាណ ..... ១៩
២.៣.១. លោក ហេរ៉ូដូទឹស ..... ២១
២.៣.២. លោក ស៊ូស៊ីឌីឌីស ..... ២៦
**មេរៀនទី ៣ ៖ ទ្រឹស្តីប្រវត្តិសាស្ត្របែបសាសនា និង ទ្រឹស្តីប្រវត្តិសាស្ត្រចិនបុរាណ** ..... ៣៣
៣.១. ទ្រឹស្តីប្រវត្តិសាស្ត្របែបសាសនា ..... ៣៦
ការប្រៀបធៀបប្រវត្តិសាស្ត្របែបសាសនា និងប្រវត្តិសាស្ត្រក្រិកបុរាណ ..... ៣៦
៣.២. ទ្រឹស្តីប្រវត្តិសាស្ត្រចិនបុរាណ ..... ៣៧
លក្ខណៈពិសេសមួយចំនួននៃការសរសេរប្រវត្តិសាស្ត្រចិន ៖ ..... ៣៨
៣.៣. សេចក្តីសន្និដ្ឋាន ..... ៤០
**មេរៀនទី ៤ ៖ ទ្រឹស្តីប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រ** ..... ៤២
៤.១. សញ្ញាណដើម ..... ៤២
៤.២. លោក លេអូផុលដ៍ វុន រ៉ែងឃ័រ ..... ៤២
៤.៣. លំហាត់សង្ខេបមេរៀន ..... ៤៤
៤.៤. អំនានប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ ..... ៤៤
**មេរៀនទី ៥ ៖ ទ្រឹស្តីប្រវត្តិសាស្ត្របែបម៉ាក្សស៊ីសនិយម** ..... ៤៦
៥.១. ប្រវត្តិម៉ាក្សស៊ីស ..... ៤៦
៥.២. វិធីសរសេរប្រវត្តិសាស្ត្របែបម៉ាក្សស៊ីសនិយម ..... ៤៧
៥.៣. សទ្ទានុក្រមទ្រឹស្តីម៉ាក្សស៊ីសនិយម ..... ៥០
៥.៤. ស្នាដៃលោក កាលម៉ាក្ស «សេចក្តីប្រកាសបក្សកុម្មុយនីស្ត៍» ..... ៥១
៥.៥. ឧទាហរណ៍នៃទ្រឹស្តីប្រវត្តិសាស្ត្របែបកាល់ម៉ាក្សនិយម ..... ៥៧
«ទស្សនៈខ្មែរក្រហមចំពោះប្រវត្តិសាស្ត្រ» ..... ៥៧
**មេរៀនទី ៦ ៖ ទ្រឹស្តីប្រវត្តិវិទ្យាបែបសង្គមសាស្ត្រ** ..... ៥៩
៦.១. សេចក្តីផ្តើម ..... ៥៩
៦.២. ប្រវត្តិសាស្ត្រខាងលើ និងប្រវត្តិសាស្ត្រខាងក្រោម ..... ៦០
៦.៣. ក្រុមកាលប្រវត្តិ ..... ៦០
៦.៤. ប្រវត្តិមនោគតិ ..... ៦១
៦.៥. ប្រវត្តិសាស្ត្រទាំងមូល ..... ៦១
**មេរៀនទី ៧ ៖ ទ្រឹស្តីប្រវត្តិវិទ្យាក្រោយសម័យទំនើប** ..... ៦៤
៧.១. សេចក្តីផ្តើម ..... ៦៤
៧.២. ប្រវត្តិសាស្ត្រក្រោយសម័យទំនើបនិយមជាអ្វី? ..... ៦៤
៧.៣. អំណានអត្ថបទប្រវត្តិសាស្ត្រ ..... ៦៩
៧.៣.១. អត្ថបទទី ១ ..... ៦៩
៧.៣.២. អត្ថបទទី ២ ..... ៧១
៧.៣.៣. អត្ថបទទី ៣ ..... ៧៣
**មេរៀនទី ៨ ៖ ការប្រៀបធៀបទ្រឹស្តីប្រវត្តិសាស្ត្រនានា** ..... ៧៥

៨.១. លំហាត់ប្រៀបធៀប ..... ៧៨
៨.២. តារាងប្រៀបធៀបទ្រឹស្តី ..... ៧៩
៨.៣. មូលហេតុនៃជម្រើសទ្រឹស្តីរបស់អ្នក ..... ៧៩
**មេរៀនទី ៩ ៖ ប្រវត្តិសាស្ត្រ និងពិភពក្រៅពីបស្ចឹមលោក** ..... ៨៣
៩.១. លទ្ធផលនៃការសិក្សាទ្រឹស្តីប្រវត្តិសាស្ត្រអឺរ៉ុប ..... ៨៩
៩.២. ការអនុវត្តន៍ទ្រឹស្តី ..... ៩០
៩.៣. ការពិភាក្សា និងជជែកវែកញែក ..... ៩០
៩.៤. ដំណើរការនៃការជជែកវែកញែក ..... ៩១
៩.៥. ការវាយតម្លៃរួម ..... ៩១
**ជំពូកទី ២ ចំណេះដឹងនិងចំណិនសិក្សាវគ្គទ្រឹស្តីប្រវត្តិសាស្ត្រ** ..... ៩២
**មេរៀនទី ១០ ៖ វិធីសាស្ត្ររៀនប្រវត្តិសាស្ត្រអោយមានប្រសិទ្ធិភាពខ្ពស់** ..... ៩២
១០.១. តើប្រវត្តិវិទូកំពុងព្យាយាមធ្វើអ្វីខ្លះ? ..... ៩២
តើប្រវត្តិសាស្ត្រអាចអប់រំយើងយ៉ាងដូចម្តេចខ្លះ ? ..... ៩២
ប្រវត្តិសាស្ត្រនិងពិភពលោកបច្ចុប្បន្ន ..... ៩៣
តើប្រវត្តិវិទូបំពេញកិច្ចការរបស់ខ្លួនយ៉ាងដូចម្តេច? ..... ៩៣
១០.២. វិធីសាស្ត្រអានកិច្ចការប្រវត្តិសាស្ត្រ ..... ៩៤
១០.៣. វិធីសាស្ត្រអានសៀវភៅពុម្ភគោល ..... ៩៥
១០.៤. វិធីសាស្ត្រកត់ចំណាំមេរៀន នៅក្នុងថ្នាក់ ..... ៩៦
**មេរៀនទី ១១ ៖ ការចង់ដឹងនៃមនុស្ស និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ** ..... ៩៧
១១.១. ប្រភពចំណេះដឹង ..... ៩៩
ក. ចំណេះដឹងបានពីប្រពៃណី ..... ៩៩
ខ. អាជ្ញាព្រឹត្តិ ..... ១០០
គ. ចំណេះដឹងបានពីបទពិសោធន៍ ..... ១០១
ឃ. អព្ភន្តញ្ញាណ ..... ១០១
ង. សនិទាននិយម-តក្កវិទ្យា ..... ១០១
ច. វិទ្យាសាស្ត្រ ..... ១០១
១១.២. កំហុសឆ្គងក្នុងដំណើរការចង់ដឹងរបស់មនុស្ស ..... ១០២
១១.៣. ក្រមសីលធម៌ក្នុងដំណើរការស្រាវជ្រាវ ..... ១០៥
**មេរៀនទី ១២ ៖ វិធីសាស្ត្រសង្ខេបមេរៀន** ..... ១០៦
១២.១. សេចក្តីផ្តើម ..... ១០៦
១២.២. ដំណាក់កាលទាំង ៩ ..... ១០៦
១. មាតិកា និងសំណួរ ..... ១០៦
២. បំបែក(បំបាក់) ដើម្បីគ្រប់គ្រង ..... ១០៦
៣. អានលឿន ..... ១០៦
៤. អានសកម្មឡើងវិញ ..... ១០៦
៥. មួយប្រយោគម្តងៗ ..... ១០៧

៦. សរសេរ «ប្រយោគគោល» ..... ១០៧
៧. រៀបចំសរសេរ ..... ១០៧
៨. ត្រួតពិនិត្យខ្លឹមសារ ..... ១០៧
៩. កែតម្រូវឡើងវិញ ..... ១០៨
១២.៣. លំហាត់អនុវត្តន៍ ..... ១១២
កថាខ័ណ្ឌគំរូ៖ ..... ១១២
តែងសេចក្តីគំរូ ..... ១១៤
សេចក្តីណែនាំសម្រាប់សរសេរកិច្ចការសង្ខេបសៀវភៅជាក្រុម ..... ១១៦
ទម្រង់វាយតម្លៃកិច្ចការសង្ខេប និងបទបង្ហាញក្រុម ..... ១១៧
វិធីសាស្ត្រធ្វើបទបង្ហាញ និងដំណាក់កាលត្រួតពិនិត្យនិងវាយតម្លៃកិច្ចការក្រុម ..... ១១៩
**មេរៀនទី ១៣ ៖ វិធីបែងចែកប្រភពឯកសារ** ..... ១២៣
១៣.១. ប្រភពឯកសារដើម ..... ១២៣
១៣.២. ប្រភពឯកសារទីពីរ ..... ១២៣
១៣.៣. លំហាត់បែងចែកប្រភពឯកសារ ..... ១២៤
១៣.៣.១. លំហាត់ទី ១ ..... ១២៤
១៣.៣.២. លំហាត់ទី ២ ..... ១២៥
១៣.៣.៣. លំហាត់ទី ៣ ..... ១២៦
**មេរៀនទី ១៤ ៖ វិធីសាស្ត្រចុះឯកសារយោង** ..... ១២៧
១៤.១. តើខ្ញុំគួរប្រើប្រភេទឯកសារបែបណា នៅកម្រិតសាកលវិទ្យាល័យ? ..... ១២៧
១៤.២. តើខ្ញុំអាចអោយអ្នកអានដឹងពីប្រភពឯកសារខ្ញុំប្រើដោយរបៀបណាខ្លះ? ..... ១២៧
១៤.២.១. លេខយោងខាងក្រោម ..... ១២៧
១៤.២.២. លេខយោងខាងចុង ..... ១២៨
១៤.២.៣. លេខយោងខាងក្នុងអត្ថបទ ..... ១២៨
១៤.២.៤. ឯកសារគន្ថនិទ្ទេស ..... ១២៨
១៤.៣. តើខ្ញុំត្រូវចុះលេខយោងក្នុងកាលៈទេសៈណាខ្លះ? ..... ១២៨
១៤.៣.១. សម្រង់ផ្ទាល់ ..... ១២៨
១៤.៣.២. ស្ថិតិ ..... ១២៨
១៤.៣.៣. ការពិតដែលអ្នកអានមិនដឹង ..... ១២៩
១៤.៣.៤. គំនិតឬបដិមតិរបស់អ្នកដទៃ ..... ១២៩
១៤.៤. តើខ្ញុំត្រូវដាក់ព័ត៌មានអ្វីខ្លះក្នុងលេខយោង? ..... ១២៩
១៤.៤.១. ការចុះសៀវភៅជាឯកសារយោង ..... ១២៩
១៤.៤.២. ការចុះសៀវភៅមានអ្នកនិពន្ធច្រើនជាឯកសារយោង ..... ១២៩
១៤.៤.៣. ការចុះជំពូកណាមួយនៃសៀវភៅកម្រងអត្ថបទជាឯកសារយោង ..... ១២៩
១៤.៤.៤. ការចុះអត្ថបទកាសែតឬទស្សនាវដ្តីស្រាវជ្រាវជាឯកសារយោង ..... ១៣០
១៤.៤.៥. ការចុះឯកសារអ៊ីនធឺណែតជាឯកសារយោង ..... ១៣០
១៤.៤.៦. ការចុះប្រភពឯកសារនៅក្នុងប្រភពឯកសារផ្សេងជាឯកសារយោង ..... ១៣០

១៤.៥. លំហាត់ចុះឯកសារយោង ........ ១៣១
១៤.៦. តើគន្លនិទ្ទេសគឺជាអ្វី? ........ ១៣១
**សេចក្តីសង្ខេបសៀវភៅ** ........ ១៣៣
**បញ្ជីគន្លនិទ្ទេស** ........ ១៣៧

# ជំពូកទី ១ ទ្រឹស្ដីប្រវត្តិសាស្ត្រ

## មេរៀនទី ១ ៖ និយមន័យ និងការប្រើប្រាស់ប្រវត្តិសាស្ត្រ

### ១.១. និយមន័យទ្រឹស្ដី និងប្រវត្តិវិទ្យា

*«ទ្រឹស្ដីហៀរកែង អនុវត្តន៍ជាក់ស្ដែងគ្មាន»។*

ពំនោលដែលគេលឺជាញឹកញាប់នេះ ចង់សំដៅលើនរណាម្នាក់ដែលពូកែតែខាងនិយាយ នរណាម្នាក់ដែលមិនខ្វះពាក្យសំដីនិយាយ តែមិនបានធ្វើសកម្មភាពពិតជាក់ស្ដែងឡើយ។ ក្នុងន័យនេះ ទ្រឹស្ដីគឺជាពាក្យសំដី ។ ក្នុងវគ្គសិក្សានេះ ទ្រឹស្ដីគឺជាអំណះអំណាង គំនិត ទស្សនៈរបស់នរណាម្នាក់ចំពោះអ្វីមួយ។

តាមធម្មតា ប្រវត្តិសាស្ត្រ ជារឿងរ៉ាវពិតរបស់មនុស្ស ពីអតីតកាល ដោយរាប់ចាប់ពីពេលមានប្រព័ន្ធអក្សរសរសេរ។ ប៉ុន្តែ បើពិភាក្សាតាមបែបភាសាវិទ្យា វាអាចមានន័យច្រើន ។ ខាងក្រោមនេះ គឺជាអត្ថន័យនៃពាក្យ «ប្រវត្តិសាស្ត្រ» យោងតាមអំបូរភាសានីមួយៗ (etymology) ។ នៅក្នុងភាសាខ្មែរ បើយោងតាមវចនានុក្រមសម្ដេចសង្ឃរាជ **ជួន ណាត** ប្រវត្តិសាស្ត្រ គឺជា គម្ពីរ ក្បួនសម្ដែងពីពង្សាវតា ឬ អំពីរបាក្សត្រ អំពីសន្តិវង្ស (Nath, ១៩៦៧)។

ពាក្យថា «History» (ប្រវត្តិសាស្ត្រ) បានលេចឡើងក្នុងភាសាអង់គ្លេស នៅឆ្នាំ១៣៩០ នៃគ្រិស្ដ៍សករាជ ដែលមានន័យថា«ទំនាក់ទំនងឧប្បត្តិហេតុ ឬ រឿងរ៉ាវនានា» ។ មែនទែនទៅ វាមានប្រភពពីភាសាបារាំងចាស់ «*Histos*», ពីភាសាឡាតាំង «*Historia*» ដែលមានន័យថា «ការពិព័ណនា ឬ កំណត់ត្រា» ។ ដោយឡែក ពាក្យចុងក្រោយនេះ មានប្រភពកំណើតពីភាសាក្រិកបុរាណ «ἱστορία» (*Historia*) ដែលមានន័យថា ការរៀនសូត្រ ឬ ការចង់ដឹង តាមរយៈការសាកសួរ, ប្រវត្តិសាស្ត្រ, កំណត់ត្រា, និង រឿង ការពិព័ណនា។ ក្នុងភាសាដដែល វាអាចចេញពីកិរិយាស័ព្ទ «ιστορειν» (*historeîn*) ដែលមានន័យថា «សាកសួរ(រកព័ត៌មាន)» ។

ដោយឡែក ពាក្យនេះក្លាយមកពីពាក្យ «ἵστωρ» (*histor*) មានន័យថា «មនុស្សឆ្លាត» ឬ «សាក្សី» ឬ «តុលាការវិនិច្ឆ័យ» ។ ពាក្យនេះត្រូវបានប្រើប្រាស់ដំបូង ក្នុងកំណាព្យលើកតម្កើងព្រះរបស់ក្រិកបុរាណ(The Homeric Hymns), ពាក្យសម្បថ«Heraclitus», ពាក្យសម្បថកូនទាហានអាថែន (ephebes' oath) និង ពីក្នុងសិលាចារឹក«Boiotic» ដែលនៅក្នុងន័យច្បាប់ វាមានថា «តុលាការវិនិច្ឆ័យ» «សាក្សីឃើញផ្ទាល់ភ្នែក» ឬ ពាក្យដែលមានន័យប្រហាក់ប្រហែលនេះ ។

ពាក្យ «ἵστωρ» (*histor*) ច្បាស់ណាស់ មានកំណើតចេញពីអំបូរភាសាប្រ៉ូតូ-ឥណ្ឌូ-អឺរ៉ុប«*Wid-tor*», ពីពាក្យឬស *Wied-* ដែលមានន័យថា «ដឹង ឬ ឃើញ» ហើយបន្សល់ទុកក្នុងវាក្យស័ព្ទក្នុងភាសាមួយចំនួននៅអឺរ៉ុប ដូចជា ពាក្យ *Wit* ក្នុងភាសាអង់គ្លេស, ពាក្យ Vision និង Video ក្នុងភាសាឡាតាំង, ពាក្យ *veda* ក្នុងភាសាសំស្ក្រឹត និង ពាក្យ *Videti* និង *vedeti* ក្នុងភាសាស្លាវ ជាដើម ។ តាមពិតទៅ ដូចគ្នានឹងវិស័យវិទ្យាសាស្ត្រ និង

ទស្សនៈវិទ្យាដែរ, ពាក្យ «ιστορία» (*Historia*) គឺជាពាក្យកំលាយ ដែលបានសាយភាយដំបូងនៅក្រិកបុរាណ និង តំបន់នានាដែលទទួលរងឥទ្ធិពលក្រិកផងដែរ ។

ក្នុងភាសាអង់គ្លេស នាមជ្ឈឹមសម័យ អត្ថន័យ ជាទូទៅរបស់វាប្រែក្លាយទៅជា «រឿងរ៉ាវ» ។ ការកំណត់ន័យ តូចចង្អៀតរបស់វា ថាជា «កំណត់ត្រាព្រឹត្តិកការណ៍ពីអតីតកាល» ដូចការកំណត់របស់លោកហេរ៉ូដូទឹស បានលេច ឡើង នៅចុងសតវត្សរ៍ទី ១៥ ។ នៅក្នុងភាសាអាឡឺម៉ង់ បារាំង និង ភាសាផ្សេងៗក្រៅពីភាសាអង់គ្លេស ភាពខុស ប្លែកពីគ្នានេះហាក់ដូចជាពុំមានទេ ហើយពាក្យនេះដែរត្រូវបានគេប្រើសំរាប់មានន័យថា «ប្រវត្តិសាស្ត្រ» ផង និង «រឿងរ៉ាវ» ផង ។ ការកំណត់ន័យ ថាជា «ការកត់ត្រាដោយមានក្បួនខ្នាតត្រឹមត្រូវ (systematic account)» ដោយ មិនមានការយោងទៅដល់ពេលវេលាពិសេសណាមួយ កើតឡើងនៅក្នុងសតវត្សរ៍ទី ១៦ ប៉ុន្តែ បច្ចុប្បន្ន មិនត្រូវបាន គេបន្តប្រើប្រាស់ទៀតឡើយ ។ គុណនាម *Historical* (នៃប្រវត្តិសាស្ត្រ) បានលេចឡើងយ៉ាងច្បាស់តាំងពីឆ្នាំ ១៥៦១ ហើយពាក្យ *Historic(ជាប្រវត្តិសាស្ត្រ)* បានលេចឡើងតាំងពីឆ្នាំ ១៦៦៩ ។ ពាក្យថា ប្រវត្តិវិទូ (*Historian*) ក្នុងន័យជា «អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ» បានលេចឡើងក្នុងឆ្នាំ ១៥៣១ ។ ពាក្យនេះមានខ្លឹមសារ ខ្ពស់ជាងពាក្យថា អ្នកកត់ត្រាព្រឹត្តិការណ៍ប្រចាំឆ្នាំ (Annalist) ឬ អ្នកចុះបញ្ជីកាលប្បវត្តិ(Chronicler) ដែល កត់ត្រារាល់ព្រឹត្តិការណ៍ ដែលបានកើតឡើង ដោយមិនមានការវិភាគអ្វីទាំងអស់ ។

## ១.២. ប្រវត្តិវិទូដំបូងៗ

បណ្តាប្រវត្តិវិទូដំបូងៗបង្អស់ គឺជាជនជាតិក្រិក កាលសម័យបុរាណ ក្នុងនោះមានដូចជា លោក ហេរ៉ូដូទឹស (Herodotus), លោក ស៊ូស៊ីឌីឌីស (Thucydides), លោក ហ្សេណូហ្វូន(Xenophon), ដែលសុទ្ធ សឹងតែជាប្រវត្តិវិទូដ៏ចំណានបំផុត ។ ចំណែក បណ្តាប្រវត្តិវិទូជនជាតិរ៉ូម៉ាំងគួរអោយកត់សម្គាល់ មានដូចជា លោក សាលឹស (Sallust), លោក ស៊ីសេរ៉ូ (Cicero), លោក លីវី (Livy), និង លោក តាក់ស៊ីតឹស (Tacytus) ។ សំណេរ ប្រវត្តិសាស្ត្របែបគ្រិស្តសាសនាដំបូង(វិធីសាស្ត្រសរសេរប្រវត្តិសាស្ត្រ) បានទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីប្រវត្តិវិទូ ជនជាតិជ្វីហ រីឯនៅក្នុងមជ្ឈឹមសម័យ មានការកត់ត្រាទុកនូវលំដាប់ព្រឹត្តិការណ៍សុទ្ធសាធ ដូចជាកំណត់ត្រារបស់ ព្រះតេជគុណ បេដ៏ (Bede) ជាដើម ។ អ្នកប្រាជ្ញនាដើមសម័យបុនសម័យ បានអនុវត្តន៍នូវគោលការណ៍ ប្រវត្តិសាស្ត្រ ដោយប្រើការត្រិះរិះពិចារណានិងរែកញែកច្រើនជាងមុន ដែលជាហេតុនាំអោយមានស្នាដៃដ៏ល្អគ្មាន ផ្ទឹមរបស់លោក នីកូឡូ ម៉ាគីយ៉ាវែល្លី (Niccolo Machiavelli) នៅសតវត្សរ៍ទី ១៦ ។ សករាជពន្លឺ នាសតវត្សរ៍ទី១៨ បានរួមបញ្ចូល ទាំងការសិក្សាជាមូលដ្ឋានគ្រឹះរឹងមាំទៅលើនិន្នាការប្រែប្រួល ក្នុងសង្គមមនុស្ស ដែលត្រូវបានឆ្លុះ បញ្ចាំងអោយឃើញនៅក្នុងស្នាដៃរបស់លោក អេដវឺឌ ហ្គីប្បុន (Edward Gibbon ) ។ ក្នុងសតវត្សរ៍ទី ១៩ ប្រវត្តិសាស្ត្រត្រូវបានអភិវឌ្ឍឡើងជាមុខវិជ្ជាជាន់ខ្ពស់ (Academic discipline) នៅក្នុងកម្រិតសាកលវិទ្យាល័យ ក្នុងនោះស្នាដៃប្រវត្តិវិទូ ដែលត្រូវបានគេនិយមអានជាងគេ គឺ ស្នាដៃរបស់លោក ថូម៉ាស់ បេប៊ីងថុន ម៉ាកូឡៃ (Thomas Babington Macaulay) និង លោក ថូម៉ាស់ កាលីល៍ (Thomas Carlyle) ។ ទំហំនៃការសិក្សា គោលការណ៍សរសេរប្រវត្តិសាស្ត្រត្រូវបានពង្រីកឡើងនៅសតវត្សរ៍ទី ២០ ក្រោមឥទ្ធិពលមុខវិជ្ជាផ្សេងៗទៀតរួម មានសង្គមវិទ្យា នរៈវិទ្យា ចិត្តវេជ្ជវិទ្យា (Psychiatry) ហើយបច្ចេកវិទ្យាថ្មីៗ ដូចជា កុំព្យូទ័រសម្រាប់វិភាគទិន្នន័យ ក៏ ត្រូវបានគេណែនាំអោយប្រើប្រាស់ដែរផង។

ខាងក្រោមនេះ គឺជាបញ្ជីប្រវត្តិវិទូល្បីៗមួយចំនួន រួមទាំងស្នាដៃគម្រូរបស់ពួកគេ ៖

### **១.២.១. ហេរ៉ូដូទីស** (Herodotus)

ជាប្រវត្តិវិទូជនជាតិក្រិក លោក ហេរ៉ូដូទីស (៤៨៤ - ៤២៥ មុនគ.ស.) មានកំណើតនៅតំបន់ហាលីកាណាសូស (Halicarnassus) ។ ដោយសារហេតុផលនយោបាយ គាត់ត្រូវបានគេនិរទេសខ្លួនទៅកាន់តំបន់សាម៉ូស (Samos) បន្ទាប់មកទៀតទៅ ដល់ក្រុងអាថែន(Athens) ហើយចុងបញ្ចប់ទៅដល់ក្រុងធូរី (Thurii) ក្នុងប្រទេសអ៊ីតាលី ។ កំណត់ត្រាក្នុងសៀវភៅចំនួន ៩ ក្បាល របស់គាត់ ស្ដីអំពី សង្គ្រាម រវាង ប្រទេសក្រិក និង ពែក្ស (Persia) បានរៀបរាប់ពីព័ត៌មានចែដន្យជាច្រើន ដែលត្រូវបានកត់ទុក ក្នុងពេល គាត់កំពុងធ្វើដំណើរ ។

សង្គ្រាមក្រិក-ពែរ្ស៖ ជាស៊េរីនៃជំលោះជាបន្តបន្ទាប់រវាងជនជាតិក្រិកនិងពែរ្ស។ ការឈ្លានពានរបស់ពែរ្សទៅលើប្រទេសក្រិកបានចាប់ផ្ដើមនៅឆ្នាំ ៤៩៩ មុនគ្រឹស្ដ៍សករាជ នៅពេលដែលបណ្ដាទីក្រុងក្រិក នៅអ៊ីយ៉ូនៀបានងើបបះបោរប្រឆាំងនឹងអធិរាជពែរ្ស ហើយត្រូវបានកំទេចដោយ ដារីយូទី ១ ។ នៅឆ្នាំ ៤៩០ កងទ័ពពែរ្សត្រូវចាញ់ក្រោមដៃកងទ័ពអាថែន នៅសមរភូមិម៉ារ៉ាតុន។ អធិរាជ ដារីយុស បានចូលទីវង្គត់ ក្នុងឆ្នាំ ៤៨៦ ហើយនៅឆ្នាំ ៤៨០ ហ្សឺក្សឺស ទី១ បានដឹកនាំកងទ័ពច្រើនសម្បើម ឆ្លងកាត់ច្រកតូចចង្អៀតមួយ។ កងទ័ពក្រិក និងពែរ្សបានពើបប្រយុទ្ធគ្នានៅឯច្រកថែម៉ូពីលែ (Thermopylae) ជាសមរភូមិដែលកងទ័ពស្ប៉ាតា ក្រោមការដឹកនាំរបស់ស្ដេច លីអូនីដាស ទី១ (Leonidas I) បានចេញទៅវាយទប់ ដោយវីរភាព។ បន្ទាប់មក ហ្សឺក្សឺស បានវាយប្រហារបុរីអាទីកា (Attica) ចំណែកបុរីអាថែនត្រូវបានគេបោះបង់ចោល។ នៅសមរភូមិសាឡាមីស កងទ័ពពែរ្សត្រូវបានបរាជ័យ ដោយកងនាវាក្រិកដែលបញ្ជា ដោយមេបញ្ជាការ ថែមីស្តូក្លីស (Themistocles) ហើយត្រូវបរាជ័យម្ដងទៀតនៅសមរភូមិ ផ្លាតាអេ (៤៧៩) ។ នៅឆ្នាំ ៤៤៩ កងទ័ពពែរ្សបានបាត់បង់ក្ដីសង្ឃឹមក្នុងការយកឈ្នះប្រទេសក្រិក។

### **១.២.២. ធូស៊ីឌីឌីស** (Thucydides)

ជាប្រវត្តិវិទូក្រិក លោកធូស៊ីឌីឌីស (៤៦០ - ៤០០ មុនគ.ស.) ដែលបានរស់នៅក្នុងជំនាន់ជាមួយលោកហេរ៉ូដូទីស ដែរ បាននិពន្ធសៀវភៅប្រវត្តិសាស្រ្តសង្គ្រាមប៉េឡូប៉ូណេសៀន (Peloponnesian) ទាំង ៨ ភាគរបស់លោក គួរអោយកត់សម្គាល់សម្រាប់វិភាគលើសង្គ្រាមនោះ ។

សង្គ្រាម ប៉េឡូប៉ូនេសៀន (៤៣១-៤០៤ មុនគ្រឹស្ដ៍សករាជ ) ជម្លោះរវាងក្រុងអាថែននិងស្ប៉ាតា និងសម្ព័ន្ធមិត្តរបស់ពួកគេ ដែលទីបំផុត ស្ប៉ាតា បានទទួលជោគជ័យ។ កងទ័ពថ្មើរជើង ដ៏ខ្លាំងក្លារបស់ ស្ប៉ាតា បានលុកលុយក្រុងអាថែន នៅឆ្នាំ ៤៣១ ខណៈពេលដែលក្រុងអាតែននៅក្រោមគ្រប់គ្រងរបស់ ពែរីក្លីស បានចេញវាយប្រហារនៅឯសមុទ្រ។ សង្គ្រាមត្រូវបានបញ្ចប់នៅពេលក្រុងអាថែនដែលកំពុងត្រូវបានឡោមព័ទ្ធ ព្រមចុះចាញ់ស្ប៉ាតានៅក្រោមបញ្ជាការរបស់ លីសានដ័រ (Lysander) (៣៩៥ មុនគ្រឹស្ដ៍សករាជ) ដែលជាឧត្តមនាវីនិងអ្នកនយោបាយស្ប៉ាតា។ គាត់បានដឹកនាំបញ្ជាកងនាវា ដែលបានកម្ទាត់កងទ័ពអាថែន នៅសមរភូមិ ណូទីអៀម (Notium) (៤០៧) និង អេហ្គូស្ប៉ូតាមី (Aegospotami) (៤០៥) ដែលនាំ ឈានទៅដល់ចុងបញ្ចប់នៃសង្គ្រាមប៉េឡូប៉ូនេសៀន ។

### ១.២.៣. ហ្សេណូហ្វុន (Xenophon)

លោកហ្សេណូហ្វុន (៤៣០ - ៣៥៤ មុនគ.ស.) ជាប្រវត្តិវិទូនិងទាហានក្រិកដែលបានក្លាយជាសិស្សជំនិតម្នាក់របស់សូក្រាត ។ នៅឆ្នាំ ៤១០ គាត់បានដឹកនាំទាហានស៊ីឈ្នួលជនជាតិក្រិកមួយក្រុម ដែលមានចំនួន ១០,០០០ នាក់ ដោយជោគជ័យ នៅក្នុងការនាំទ័ពដកថយ ដោយធ្វើដំណើរកាត់តាមចក្រភពពែក្ស ក្រោយពេលអតីតមេបញ្ជាការរបស់ពួកគេឈ្មោះ ស៊ីរុស(Cyrus) ត្រូវបានគេសម្លាប់នៅក្នុងសមរភូមិ ។ ជោគជ័យដ៏ក្លាហាននេះបានក្លាយជាប្រធានបទមួយនៃ ស្នាដៃដ៏ល្បីល្បាញរបស់គាត់គឺ អាណាបាស៊ីស (*Anabasis*) ។ ស្នាដៃផ្សេងទៀត រួមមានដូចជា *អនុស្សាវរីយ៍គួរចងចាំ* (*Memorabilia*), ខមាលទោស(*Apology*) និងកម្រងកិច្ចសន្ទនាជេញជោល (Symposium) ដែលសហការជាមួយទស្សនៈវិទូ សូក្រាត ។

### ១.២.៤. សាលឺស (Gaius Sallustius Crispus)

ជាអ្នកនយោបាយ និងប្រវត្តិវិទូរ៉ូម៉ាំង លោក សាលឺស (៨៦ - ៣៤ មុនគ.ស.) ត្រូវបានគេ បណ្តេញចេញពីព្រឹទ្ធសភា ដោយរងការចោទប្រកាន់ថាអសីលធម៌ ។ គាត់បានគាំទ្រ ជូលៀស ស៊ីហ្ស៊ឺ (Julius Caesar) នៅក្នុងសង្គ្រាមប្រឆាំងនឹង ផុមពី (Pompey) ហើយបានក្លាយជាអភិបាលក្រុង នូមីឌៀ (*Numidia*) ។ គាត់ត្រូវបានគេចោទប្រកាន់អំពីអំពើពុករលួយ អំពើអយុត្តិធម៌ហើយចូលនិវត្តន៍ពីនយោបាយនៅឆ្នាំ ៤៤ មុន គ.ស ។

ស៊ីហ្ស៊ឺ (គៃយុស) ជូលៀស (១០០-៤៤ មុនគ្រឹស្តសករាជ) មេទ័ពនិងជារដ្ឋបុរសរ៉ូម៉ាំង កើតពីគ្រួសារអភិជន គាត់បានចងសម្ព័ន្ធភាពដ៏ពេញនិយម ដោយអាពាហ៍ពិពាហ៍ជាមួយកូនស្រីរបស់ ចិណ្ណា (Cinna) គឺ នាងកនីលៀ (Cornelia) ក្នុងឆ្នាំ ៨៤ ។ ក្រោយមរណភាពរបស់នាងក្នុងឆ្នាំ ៦៨ គាត់បានរៀបការជាមួយ ប៉ុមប៉េអ៊ីយ៉ា (Pompeia) ដែលគាត់បានលែងលះគ្នានៅឆ្នាំ ៦២ ហើយក្នុងឆ្នាំ ៥៩ គាត់បានរៀបការជាមួយ កាល់ប៉ូនៀ (Calpurnia) ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ៦០ ស៊ីហ្ស៊ឺ បានរួមដៃជាមួយ ផុមពី និង ក្រាស៊ុស ក្នុងសម្ព័ន្ធភាពជោគជ័យត្រីភាគីដំបូង(ឆ្នាំ៦០), ក្លាយជាកុងស៊ុល (ឆ្នាំ៥៩), ហើយបន្ទាប់មកជាអភិបាលតំបន់ ហ្គោល។ ការត្រួតត្រារបស់ស៊ីហ្ស៊ឺ នៅហ្គោល (ឆ្នាំ៥៨-៥០) និងយុទ្ធនាការរបស់គាត់នៅទឹកដីអង់គ្លេស (ឆ្នាំ៥៥, ៥៤) បានធ្វើអោយគាត់ក្លាយជាវីរបុរសដ៏ពេញនិយម។ នៅពេលដែលសម្ព័ន្ធភាពជោគជ័យត្រីភាគីបានបញ្ចប់ (ឆ្នាំ៥០) ព្រឹទ្ធសភាបានស្នើសុំស៊ីហ្ស៊ឺ អោយលាឈប់ពីតំណែងកងទ័ពរបស់គាត់។ គាត់បានបដិសេធហើយបានឆ្លងទន្លេរូប៊ីសៀចូលទៅក្នុងប្រទេសអ៊ីតាលី (ឆ្នាំ៤៩) បានចាប់ផ្តើមសង្គ្រាមស៊ីវិល។ ស៊ីហ្ស៊ឺបានយកឈ្នះ ផុមពី នៅសមរភូមិ ផាសាលឺស (Pharsalus) (ឆ្នាំ៤៨) ហើយបានចំណាយពេលមួយរយៈ ក្នុងជូរវងារ នៅអាឡិចសាន់ឌ្រាជាមួយព្រះនាងក្លេអូប៉ាត្រា(Cleopatra) រហូតបានក្លាយជាគូស្នេហ៍របស់គាត់។ ក្រោយមក គាត់បានកម្ចាត់ កងទ័ពដែលនៅសេសសល់របស់ ផុមពី នៅឯសមរភូមិ តាបស៊ុស (Thapsus) (ឆ្នាំ៤៦) និង មុណ្ឌ (Munda) (ឆ្នាំ៤៥) បន្ទាប់មក គាត់បានត្រលប់ទៅទីក្រុងរ៉ូម ហើយបានកាន់តំណែងជា«មេដឹកនាំផ្តាច់ការ» វិញ។ នៅពាក់កណ្តាលខែមិនា (១៥ មីនា ៤៤) ស៊ីហ្ស៊ឺត្រូវបានធ្វើឃាត ដោយពួកសាធារណរដ្ឋ រួមមានប្រុទុស (Brutus) និង កាស៊ីអ៊ុស (Cassius) ដែលបារម្ភខ្លាចថាគាត់នឹងឡើងសោយរាជ្យជាអធិរាជ។

ផុមពី (១០៦-៤៨ មុនគ្រឹស្តសករាជ) មេទ័ព និងជារដ្ឋបុរសរ៉ូម៉ាំង ដែលគេហៅថា Pompeius Magnus (ផុមពី ដ៏អស្ចារ្យ) ។ ក្នុងអាយុ ៦០ ឆ្នាំគាត់បានចូលរួមជាមួយ ជូលៀស ស៊ីហ្ស៊ឺ (Julius Caesar) និង ក្រាស៊ុស (Crassus) ក្នុងសម្ព័ន្ធភាពជោគជ័យត្រីភាគីដំបូង ដោយរៀបការជាមួយកូនស្រីរបស់ស៊ីហ្ស៊ឺ ឈ្មោះ ជូលៀ (Julia) (ឆ្នាំ៥៤) ក្នុងឆ្នាំ ៥៩ ប៉ុន្តែក្នុងឆ្នាំ ៥០ គាត់បានគាំទ្រការទាមទាររបស់ព្រឹទ្ធសភាសុំ ស៊ីហ្ស៊ឺ អោយលាឈប់ពីកងទ័ព

របស់គាត់។ នៅក្នុងសង្គ្រាមស៊ីវិលបន្តបន្ទាប់មក ផុមពី ត្រូវបានកម្ចាត់ដោយ ស៊ីហ្សឺនៅសមរភូមិ ផារ៉ាសាឡូស (ឆ្នាំ ៤៨ ) ហើយបានភៀសខ្លួនទៅប្រទេសអេហ្ស៊ីបជាកន្លែងដែលគាត់ត្រូវបានគេធ្វើឃាត។

នុមីឌៀ (Numidia) ជានគរចំណាស់មួយ នៅទ្វីបអាហ្វ្រិក, ស្ថិតនៅភាគខាងលិចនៃនគរ កាថេច (Carthage) ។ ប្រជាជន បឺរបឺរ របស់នគរនេះ ក្រុមពនេចរ រហូតដល់កកើតនគរ ម៉ាសាស៊ីសាស (Masinissa) (កំឡុងឆ្នាំ ២៤០-១៤៩ មុនគ្រឹស្តសករាជ) បានធ្វើអោយមានការរីកចម្រើនកសិកម្ម និងនគរូបនីយកម្ម។ បន្ទាប់ពីគាំទ្រ ផុមពី ប្រឆាំងនឹង ជូលៀស ស៊ីហ្ស៊ឺ (៤៦ មុនគ្រឹស្តសករាជ) នគរ នុមីឌៀ បានបាត់បង់រាជាធិបតេយ្យរបស់ខ្លួន ហើយបានក្លាយជាផ្នែកមួយនៃខេត្តមួយនៃចក្រភពរ៉ូម៉ាំង នាប៉ែកទ្វីបអាហ្វ្រិក។

**១.២.៥. ស៊ីសេរ៉ូ** (Cicero, Marcus Tullius)

ជារដ្ឋបុរសរ៉ូម៉ាំងម្នាក់ លោក ស៊ីសេរ៉ូ (១០៦ - ៤៣ មុនគ្រឹស្តសករាជ) ត្រូវបានគេជ្រើសរើសអោយធ្វើជាកុងស៊ុលនៅឆ្នាំ ៦៣ មុនគ.ស ។ ការប្រហារជីវិតជនដែលបានរួមគំនិតក្បត់ ដោយគ្មានការវិនិច្ឆ័យទោស បណ្ដាលអោយគាត់បាត់បងការគាំទ្រ ហើយគាត់ត្រូវបានគេនិរទេស នៅឆ្នាំ ៥៨ មុនគ្រឹស្តសករាជអស់រយៈពេល ១៨ ខែ ។ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល គាត់បានគាំទ្រ ផុមពី (Pompey) ប្រឆាំងទល់នឹងស្តេច ស៊ីហ្ស៊ឺ ។ ក្រោយពេលស្ដេច ស៊ីហ្ស៊ឺ ត្រូវបានគេធ្វើគត់ នៅឆ្នាំ ៤៤ មុនគ.ស គាត់បានវាយប្រហារជាច្រើនលើក លើ អង់តូនី (Anthony) ហ្វីលីពីក (Phillippics) ជាហេតុធ្វើអោយគាត់ត្រូវបានគេចាប់ខ្លួន និងសម្លាប់ ។ ជាវាគ្មិនដ៏ចំណាស់បំផុត នៅប្រទេសរ៉ូម៉ាំង គាត់បានសរសេរអត្ថបទជាច្រើនស្តីអំពី «សិល្បៈនៃការនិយាយ» និងកិច្ចការទស្សនៈវិទ្យា ។

**១.២.៦. លីវី** (Livy Titus Livius)

ជាប្រវត្តិវិទូរ៉ូម៉ាំង លោក លីវី (៥៩ - ១៧ មុនគ្រឹស្តសករាជ) ត្រូវបានគេស្គាល់ជាទូទៅដោយសារស្នាដៃប្រវត្តិសាស្ត្ររ៉ូម៉ាំងមួយចំនួនធំ តាំងពីកំណកំណើតដំបូងរបស់វា តាមរយៈរឿងនិទាន រហូតដល់សម័យកាលដែលទ្រុសុស (Drusus) ស្លាប់នាឆ្នាំ ៩ មុនគ្រឹស្តសករាជ។ សៀវភៅដើមរបស់គាត់ចំនួន ៣៥ ក្បាល តែប៉ុណ្ណោះ ដែលនៅសេសសល់គង់វង្ស ក្នុងចំណោមសៀវភៅដើមទាំងអស់របស់គាត់ចំនួន ១៤២ ក្បាល ។

**១.២.៧. តាស៊ីតឹស** (Tacitus , Cornelius)

ជាប្រវត្តិវិទូ និងជាវាគ្មិនជនជាតិរ៉ូម៉ាំង លោក តាស៊ីតឹស (៥៦ - ១២០ គ្រឹស្តសករាជ) បានក្លាយជាកុងស៊ុល នៅឆ្នាំ ៩៧ គ្រឹស្តសករាជ ។ នៅចន្លោះឆ្នាំ ១១២ - ១១៣ គ្រឹស្តសករាជ គាត់បានក្លាយជាអភិបាល នៅអាស៊ី ។ នៅឆ្នាំ ៩៨ គាត់បានសរសេរស្នាដៃអំពីប្រវត្តិសាស្ត្រ ប្រភពនិងស្ថានភាពកុលសម្ព័ន្ធ ហ្សឺម៉ែនៀ (Germania) និងប្រវត្តិរូបលោក អាហ្គ្រីកូឡា (Agricola) ។ ស្នាដៃខាងក្រោយនេះ គឺជា ព័ត៌មានស្តីអំពីអាជីពរបស់ឪពុកក្មេកគាត់ ។ ស្នាដៃដ៏សំខាន់របស់គាត់ គឺផ្នែកប្រវត្តិសាស្ត្រ និងកំណត់ត្រាប្រវត្តិសាស្ត្រប្រចាំឆ្នាំដែលជាការស៊ើបអង្កេតលើប្រវត្តិសាស្ត្ររ៉ូម៉ាំង កំឡុងឆ្នាំ ៦៩ - ៩៦ គ្រឹស្តសករាជ និង ១៤ - ៦៨ គ្រឹស្តសករាជ ។

អាហ្គ្រីកូឡា, ហ្គេណាស ជូលៀស (៤០-៩៣ គ្រឹស្តសករាជ) អភិបាលរ៉ូម៉ាំងនៅអង់គ្លេស និងជាឪពុកក្មេករបស់អ្នកសរសេរជីវប្រវត្តិរបស់គាត់ គឺតាស៊ីតឹស។ ត្រូវបានបញ្ជូនទៅគ្រប់គ្រងអង់គ្លេសនៅឆ្នាំ ៧៨ បន្ទាប់ពីកាន់តំណែងកងពលមុន ៗ នៅទីនោះគាត់បានធ្វើតាមគោលនយោបាយរ៉ូម៉ាំងឧបនីយកម្ម ការរុករក និងការពង្រីកទឹកដី មុនពេលគាត់ត្រូវបានគេកោះហៅទៅវិញនៅឆ្នាំ ៨៤ គ្រឹស្តសករាជ។

**១.២.៨. បេដ៍** ( Bede , St )

ជាប្រវត្តិវិទូជនជាតិអង់គ្លេស ដែលត្រូវគេស្គាល់ជា ព្រះតេជគុណ បេដ៍ ( ៦៧៣ - ៧៣៥ គ្រឹស្ដ័សករាជ ) ។ ក្រោយឆ្នាំ ៦៨២ គាត់បានរស់នៅព្រះវិហារចារ៉ូវ ( Jarrow ) នៅ Northumberland ។ ស្នាដៃប្រវត្តិសាស្ត្រគ្រិស្តសាសនិកអង់គ្លេស របស់គាត់ ( ៧៣១ គ្រឹស្ដ័សករាជ ) ត្រូវបានសរសេរជាភាសាឡាតាំង និងក្រោយមកត្រូវបានបកប្រែជាភាសាអង់គ្លេស គឺជាប្រភពប្រវត្តិសាស្ត្រអង់គ្លេស ដ៏សំបូរបែប ជាពិសេសកំឡុងរយៈពេលដំបូងៗនៃសម័យអង់គ្លូ-សាក់សុង ( សតវត្សរ៍ ៥ - ៨ ) ។ គាត់ជាអ្នកនិពន្ធស្នាដៃប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ និងវេយ្យាករណ៍ជាច្រើនក្បាល ។

**១.២.៩. ម៉ាគីយ៉ាវែល្លី** ( Machiavelli, Niccolo )

ជាអ្នកទ្រឹស្ដីនយោបាយជនជាតិអ៊ីតាលី លោក ម៉ាគីយ៉ាវែល្លី ( ១៤៦៩ - ១៥២៧ គ្រឹស្ដ័សករាជ ) បានបំរើការអោយសាធារណៈរដ្ឋហ្វ្ល័រ៉ងទីន ( Florentine ) ក្នុងតួនាទីជារដ្ឋបុរស និងអ្នកការទូត ពីឆ្នាំ ១៤៩៨ ដល់ ១៥១២ នៃគ្រឹស្ដ័សករាជ។ នៅពេលមានការកាន់កាប់អំណាចរបស់ក្រុមគ្រួសាររបស់មេឌីស៊ី( Medici )ឡើងវិញ គាត់ត្រូវបានគេនិរទេសខ្លួន ។ នៅក្នុងស្នាដៃ «ព្រះអង្គម្ចាស់ - The Prince» ដែលត្រូវបាននិពន្ធនាឆ្នាំ ១៥១៣ គាត់បានជំរុញអោយគេប្រើ *មធ្យោបាយគ្រប់បែបយ៉ាង* ដើម្បីធ្វើអោយរដ្ឋមានស្ថេរភាព ។

**១.២.១០. អេដវីឌ ហ្គីប្បុន** ( Gibbon , Edward )

ជាប្រវត្តិវិទូអង់គ្លេស លោក អេដវីឌ ហ្គីប្បុន កើតនៅ ឆ្នាំ ១៧៣៧ និងស្លាប់ឆ្នាំ ១៧៩៤ នៃគ្រឹស្ដ័សករាជ។ ការលើកឡើងស្ដីអំពីគ្រិស្ដ័សាសនា នៅក្នុងស្នាដៃរបស់គាត់ ដែលមានចំណងជើងថា«ប្រវត្តិសាស្ត្រនៃការចុះអន់ថយ និងការដួលរលំនៃចក្រភពរ៉ូម៉ាំង» ក្នុងឆ្នាំ ១៧៧៦ - ១៧៨៨ គ្រឹស្ដ័សករាជបានធ្វើអោយមានមតិចំរូងចំរាស់ជាច្រើន ។

**១.២.១១. ម៉ាកូឡៃ** ( Macaulay, Thomas Babington )

ជាប្រវត្តិវិទូជនជាតិអង់គ្លេស និងបាននិពន្ធស្នាដៃសាកល្បងខ្លី លោក ម៉ាកូឡៃ ( ១៨០០ - ១៨៥៩ គ្រឹស្ដ័សករាជ ) បានចូលរួមចំណែកក្នុងទស្សនាវដ្ដី Edinburgh Review និងបានកាន់ការងារក្នុងសភា អស់រយៈពេលយ៉ាងយូរ ។ សន្ដានចិត្តរបស់គាត់ទៅលើសមាជិក «គណៈបក្សកំណែទម្រង់» ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងស្នាដៃ «ប្រវត្តិសាស្ត្រនៃប្រទេសអង់គ្លេស» របស់គាត់ដែលមាន ៥ ភាគ និពន្ធនៅឆ្នាំ ១៨៤៩ - ១៨៦១ គ្រឹស្ដ័សករាជ ។

**១.២.១២. ការលីល៍** ( Carlyle , Thomas )

ជាប្រវត្តិវិទូជនជាតិស្កុត លោក ការលីល៍ ( ១៧៩៥ - ១៨៨១ គ្រឹស្ដ័សករាជ ) បាននិពន្ធស្នាដៃសាកល្បងខ្លីៗមួយចំនួន ។ ស្នាដៃរបស់គាត់ ដែលមានចំណងជើងថា «Sartor Resartus» ដែលត្រូវអាចប្រែសម្រួលជាភាសាខ្មែរថា «ជាងកាត់ដេរសោរ៉េឡើងវិញ» គឺជាកម្រងប្រលោមលោកចម្រុះ, ទស្សនៈវិទ្យា, និងប្រវត្តិរូប និងត្រូវបានបោះពុម្ព នៅឆ្នាំ១៨៣៦ នៃគ្រឹស្ដ័សករាជ ហើយបន្ទាប់មកស្នាដៃសំខាន់របស់គាត់ ក៏ត្រូវបានសម្រេចផងដែរនោះគឺ «បដិវត្តន៍បារាំង» បោះពុម្ពនៅឆ្នាំ ១៩៣៧ គ្រឹស្ដ័សករាជ ។

**១.២.១៣. វ៉ុលទែរ** (Voltaire, Francois- Marie Arouet)

ជាទស្សនៈវិទូបារាំង និងជាសីលវិទូ ក្នុងយុគសម័យត្រចះត្រចង់ «សករាជពន្លឺ» លោក វ៉ុលទែរ ហ្វ្រង់ស្វ័រ ម៉ារី អារូអេត៍ (១៦៩៤ - ១៧៧៨ គ្រឹស្ត៍សករាជ) ធ្វើយុទ្ធនាការដើម្បីប្រឆាំងនឹងអំពើអយុត្តិធម៌ និងការមិនចេះអត់អោនដល់គ្នា ។ ស្នាដៃរបស់គាត់មានដូចជារឿងចំអក់ខ្លីៗ៖ «ភាពស្មោះត្រង់» (Candide» នាឆ្នាំ១៧៥៩, «សន្ធិសញ្ញានៃការអត់ឱន» (Traite de la tolerance) នាឆ្នាំ ១៧៦៣, វចនានុក្រមទស្សនៈវិជ្ជា (Dictionnaire philosophique) នាឆ្នាំ ១៧៥៤ និង ប្រវត្តិស្តេច ភីទ័រ មហារាជ (Peter the Great) និង ស្តេចល្វីស (Louis) ទី ១៥ ។

**១.២.១៤. រូស្សូ ហ្សង់ហ្សាក់** (Rousseau, Jean Jacques)

ជាទស្សនៈវិទូបារាំង និងជាអ្នកនិពន្ធសព្វវចនានុក្រម លោក រ៉ូសូ (១៧១២ ១៧៧៨ គ្រឹស្ត៍សករាជ) បាននិពន្ធសៀវភៅដែលមានចំណងជើងថា «សេចក្តីថ្លែងអំពីប្រភព និងមូលដ្ឋាននៃអសមធម៌ក្នុងចំណោមមនុស្ស» (Discourse on the Origin and Foundations of Inequality amongst Men» នៅក្នុងឆ្នាំ ១៧៥៤ គាត់បានអះអាងថា សារជាតុល្អឥតខ្ចោះរបស់មនុស្ស ត្រូវបានបំពុល ដោយសង្គមពុករលួយ ។ លោក អេមីល៍ (Emile) ដែលជាអ្នកនិពន្ធប្រលោមលោកបែបអប់រំ នាឆ្នាំ ១៧៦២ បានពង្រីកទស្សនៈនេះបន្ថែមទៀត ។ ស្នាដៃនយោបាយបែបនេះ ដូចជា «កិច្ចសន្យាសង្គម» (Du Contrat Social» នាឆ្នាំ ១៧៦២ ទទួលបានប្រជាប្រិយភាពក្នុងចំណោមជនបដិវត្តន៍ ។

## ១.៣. សម្រង់ទស្សនៈនានាស្តីពីប្រវត្តិសាស្ត្រ

ខាងក្រោមនេះ ការដកស្រង់ពំនោលល្បីៗស្តីពីប្រវត្តិសាស្ត្រ ដោយរួមបញ្ចូលទាំងឈ្មោះរបស់វាគ្មិន ឬអ្នកនិពន្ធនីមួយៗ ផងដែរ ។ ចូរអានដោយយកចិត្តទុកដាក់ ហើយសាកល្បងស្វែងយល់ពីខ្លឹមសារគោល ដោយសម្រេចថាតើអ្នកស្របតាមដែរឬទេ? ហេតុអ្វី?

**១. ស៊ីសេរ៉ូ** (Cicero)

«មូលហេតុឬដើមហេតុនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រណាមួយ គឺជារឿងគួរអោយចាប់អារម្មណ៍ខ្លាំងជាងព្រឹត្តិការណ៍នោះទៅទៀត ។»

The causes of events are ever more interesting than the events themselves.

**២. រ៉ូប៊ឺត ហៃលលីន** (Robert A. Heinlein)

«មនុស្សជំនាន់ណាមួយ ដែលមិនអើពើនឹងប្រវត្តិសាស្ត្រ ច្បាស់ជាមិនមានទាំងអតីតកាល និងទាំងអនាគតឡើយ ។»

A generation which ignores history has no past and no future.

**៣. វៀល ឌុយរ៉ង់** (Will Durant)

«មេរៀនប្រវត្តិសាស្ត្រជារឿយៗ ល្អបានតែនិយាយ តែមិនដែលត្រូវគេអនុវត្តឡើយ ។»
One of the lessons of history is that nothing is often a good thing to do and always a clever thing to say.

៤. **មហាត្មះ គន្ធី** ( Mahatma Gandhi )

«ការជឿថាអ្វីដែលមិនបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រ នឹងមិនអាចកើតឡើងសោះ គឺជាការជជែកការមិនជឿលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ។»

To believe what has not occurred in history will not occur at all, is to argue disbelief in the dignity of man.

៥. **វីល្លៀម ស្ពេកស្ពៀរ** ( William Shakespeare )
«តែងមានប្រវត្តិសាស្ត្រក្នុងជីវិតមនុស្សទាំងអស់។»
There is a history in all men's lives.

៦. **ក្លារ៉េន ដារ៉ូវ** ( Clarence Darrow )
«ប្រវត្តិសាស្ត្រកើតឡើងច្រំដែល ។ នោះហើយជាបញ្ហាធ្ងន់ធ្ងររបស់ប្រវត្តិសាស្ត្រ។»

"History repeats itself. That's one of the things wrong with history."

៧. **ម៉ាក ថ្វេន** ( Mark Twain )

«ប្រវត្តិសាស្ត្រពោរពេញទៅដោយភស្តុតាង ដែលបញ្ជាក់ថា សច្ចៈភាពមិនពិបាកកប់ចោលទេ ប៉ុន្តែការភូតកុហកដ៏ជំនាញ ស្ថិតនៅជាអមតៈ។»

History is strewn thick with evidence that a truth is not hard to kill, but a lie, well told, is immortal.

៨. **អនាមិក**
«ចូរកុំភ្លេចអំពីសារៈសំខាន់នៃប្រវត្តិសាស្ត្រ ។ ប្រការដែលអ្នកមិនដឹងអំពីអ្វីដែលបានកើតឡើងមុនពេលអ្នកបានចាប់កំណើតលើផែនដីនេះ បានន័យថាអ្នកនៅតែជាកូនក្មេង(ដែលមិនដឹងអី) ជារៀងរហូត។»
Never forget the importance of history. To know nothing of what happened before you took your place on earth, is to remain a child for ever and ever.

៩. **ជេមស៍ អង់តូនី ហ្វ្រូដ** ( James Anthony Froude )

កាតព្វកិច្ចដំបូងរបស់ប្រវត្តិវិទូ គឺត្រូវប្រុងប្រយ័ត្ននឹងអារម្មណ៍អាណិតអាសូរ ឬមនោសញ្ចេតនាផ្ទាល់ខ្លួនរបស់គាត់។»

The first duty of a historian is to be on guard against his own sympathies.

១០. **ឈេស្ទ័រតេន** ( G. K. Chesterton )

«រឿងប្រឌិត គឺជារឿងប្រវត្តិសាស្ត្រច្រើនជាងការពិត ព្រោះការពិតប្រាប់យើងអំពីមនុស្សត្រឹមម្នាក់ ឯរឿងប្រឌិតប្រាប់យើងអំពីមនុស្សមួយលាននាក់។»

Fable is more historical than fact, because fact tells us about one man and fable tells us about a million men.

១១. **ភ្លូតាគ៍** ( Plutarch )

«ការមិនអើពើនឹងជីវិតរបស់មនុស្សដ៏ល្បីល្បាញបំផុត ពីសម័យបុរាណ ប្រៀបដូចជាការបន្តនៅជាកុមារភាពជារៀងរហូត ។»

To be ignorant of the lives of the most celebrated men of antiquity is to continue in a state of childhood all our days.

១២. **វីនស្តុន ឈឺចហ៊ៀល** ( Winston Churchill )

«ចំពោះខ្ញុំ ខ្ញុំគិតថាជាការប្រសើរខ្លាំងសម្រាប់គ្រប់ភាគីទាំងអស់ ដែលបន្សល់ទុកអតីតកាលសម្រាប់ប្រវត្តិសាស្ត្រ ជាពិសេសកាន់តែល្អ នៅពេលខ្ញុំស្នើសុំសរសេរប្រវត្តិសាស្ត្រខ្លួនឯង។»

For my part, I consider that it will be found much better by all parties to leave the past to history, especially as I propose to write that history myself.

១៣. **ចច វ៉ាស៊ីនតោន** ( George Washington )

«យើងមិនគួរក្រឡេកងាកមើលក្រោយទេ លុះត្រាតែក្នុងគោលដៅទាញយកមេរៀននានាដែលមានប្រយោជន៍ពីកំហុសកាលអតីតកាល និងដើម្បីដកស្រង់យកបទពិសោធន៍ដ៏ថ្លៃថ្លា។»

We should not look back unless it is to derive useful lessons from past errors, and for the purpose of profiting by dearly bought experience.

១៤. **ហ្វ្រង់ស៊ីស ប៊ែឃេន** ( Francis Bacon )

ក. «ប្រវត្តិសាស្ត្រធ្វើអោយ មនុស្សកាន់តែមានប្រាជ្ញា; កវីនិពន្ធកាន់តែមោះមុត; គណិតវិទ្យាកាន់តែសំបូរគន្លឹះឬល្បិច; ទស្សនៈវិជ្ជាធម្មជាតិកាន់តែមានន័យជ្រៅ; សីលធម៌កាន់តែស៊ីជ្រៅ; តក្កវិទ្យានិងវោហាស័ព្ទកាន់តែយល់និងនិយាយបានងាយ ។»

Histories make men wise; poets, witty; the mathematics, subtle; natural philosophy, deep; moral, grave; logic and rhetoric, able to contend.

ខ. «តួនាទីពិតប្រាកដនៃប្រវត្តិសាស្ត្រ ត្រូវបង្ហាញព្រឹត្តិការណ៍ពិតៗ ដោយមានការប្រឹក្សាយោបល់ ហើយទុកមនុស្សម្នាក់ៗធ្វើការសង្កេតនិងការសន្និដ្ឋានដោយខ្លួនឯង ។»

It is the true office of history to represent the events themselves, together with the counsels, and to leave the observations and conclusions thereupon to the liberty and faculty of every man's judgment.

**១៥. អាប្រាហាម លីនឃិន** ( Abraham Lincoln )

«បងប្អូនជនរួមជាតិទាំងអស់ យើងមិនអាចរត់ចេញពីប្រវត្តិសាស្ត្រឡើយ។»

Fellow citizens, we cannot escape history.

**១៦. ថូម៉ាស ខារលីល៍** ( Thomas Carlyle )

ក. «ប្រវត្តិសាស្ត្ររបស់ពិភពលោក គ្រាន់តែជាជីវប្រវត្តិរបស់បុរសដ៏អស្ចារ្យប៉ុណ្ណោះ។»

The history of the world is but the biography of great men.

ខ. «មនុស្សដែលសប្បាយរីករាយ គឺជាមនុស្សដែលមិនមានឈ្មោះក្នុងកំណត់ត្រា នៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ។»

Happy the people whose annals are blank in history-books

**១៧. វ៉ល់ធ័រ រ៉ាលេហ៍** ( Walter Raleigh )

«ប្រវត្តិវិទូដែលចង់សរសេរសកម្មភាពនានារបស់មនុស្ស គួរតែបញ្ជាក់ការពិតដ៏សាមញ្ញ ហើយកុំនិយាយអ្វីមួយ ដោយសេចក្តីស្រឡាញ់ ឬការស្អប់ឡើយ ។ ហើយក៏ត្រូវជ្រើសរើសឱកាសនេះសម្រាប់សរសេរ ដូចដែលវាអាចស្របច្បាប់ ដើម្បីគិតពីអ្វីដែលពួកគេចង់បានហើយសរសេរអ្វីដែលពួកគេគិតថាជាសុភមង្គលដ៏កម្រមួយនៃពេលវេលា។»

Historians desiring to write the actions of men, ought to set down the simple truth, and not say anything for love or hatred; also to choose such an opportunity for writing as it may be lawful to think what they will, and write what they think, which is a rare happiness of the time.

**១៨. ហឺម៉ាន់ ហេស្ស៍** ( Hermann Hesse )

«អ្នកត្រូវចាត់ទុកប្រវត្តិសាស្ត្រពិភពលោក ជាគណិតវិទូធ្វើលំហាត់គណិត ដែលមិនមានអ្វីផ្សេង ក្រៅពីច្បាប់និងរូបមន្ត គ្មានសច្ចៈភាព គ្មានអ្វីល្អនិងអាក្រក់ គ្មានពេលវេលា គ្មានម្សិលមិញ គ្មាន

ថ្ងៃស្អែក គ្មានអ្វីទាំងអស់ ក្រៅពីបច្ចុប្បន្នភាពរហូត ។»

You treat world history as a mathematician does mathematics, in which nothing but laws and formulas exist, no reality, no good and evil, no time, no yesterday, no tomorrow, nothing but an eternal, shallow, mathematical present.

**១៩. ការល ម៉ាក្ស** ( Karl Marx )

«ប្រវត្តិសាស្ត្រនៃគ្រប់សង្គមទាំងអស់ គឺជាប្រវត្តិនៃការតស៊ូវណ្ណៈ ។»

The history of all hitherto existing society is the history of class struggles.

**២០. រ៉ាល្ហ៍ វ៉ាល់ដូ អេមើសុន** ( RALPH WALDO EMERSON )

«គ្មានប្រវត្តិសាស្ត្រសុក្រឹតនោះទេ គឺមានតែប្រវត្តិរូបផ្ទាល់ខ្លួន។»

There is properly no history; only biography.

**២១. អ៊ី. អេ. ហ្វ្រីមែន** ( E. A. FREEMAN )

«ប្រវត្តិសាស្ត្រជានយោបាយពីអតីត ហើយនយោបាយគឺជាប្រវត្តិនាពេលបច្ចុប្បន្ន។»

History is past politics, and politics is present history.

**២២. ហេហ្គល** ( G. W. F. HEGEL )

«អ្វីដែលបទពិសោធន៍និងប្រវត្តិសាស្ត្របង្រៀនយើងគឺថា ប្រជាពលរដ្ឋនិងរដ្ឋាភិបាលមិនដែលរៀនអ្វីពីប្រវត្តិសាស្ត្រ ឬក៏ប្រព្រឹត្តិតាមគោលការណ៍ ដែលស្តែងចេញដោយមានហេតុផលត្រឹមត្រូវពីប្រវត្តិសាស្ត្រឡើយ ។»

What experience and history teach is this—that people and governments never have learned anything from history, or acted on principles deduced from it.

**២៣. ហ្វ្រីឌ្រីច វ៉ុន ស្ឈីល័រ** ( FRIEDRICH VON SCHILLER )

«អ្វីប្រវត្តិសាស្ត្រពិភពលោក គឺជាការវិនិច្ឆ័យរបស់ពិភពលោក។»

The world's history is the world's judgement.

**២៤. វ៉ុលធែរ** ( VOLTAIRE )

«ប្រវត្តិសាស្ត្រគ្មានអ្វីក្រៅពីផាកសំដែងនៃអំពើឧក្រិដ្ឋ និងសំណាងអាក្រក់ឡើយ ។»

Indeed, history is nothing more than a tableau of crimes and misfortunes.

**២៥. ចច អ៊ីលីយ៉ូត** (GEORGE ELIOT)

«ស្រ្តីរីករាយបំផុត ក៏ដូចជាជាតិដែលសប្បាយបំផុតដែរ មិនមានប្រវត្តិសាស្រ្តនោះទេ។»

The happiest women, like the happiest nations, have no history.

## ១.៤. ទំនាក់ទំនងមុខវិជ្ជាប្រវត្តិវិទ្យា និងមុខវិជ្ជាដទៃទៀត

### ១.៤.១. ប្រវត្តិវិទ្យា និងបុរេប្រវត្តិសាស្ត្រ (History and Prehistory)

ជាលក្ខណៈប្រពៃណី ការសិក្សាប្រវត្តិសាស្រ្តត្រូវបានកំណត់ត្រឹមជាពាក្យពេជន៍សរសេរនិងនិយាយតគ្នា តែប៉ុណ្ណោះ ។ យ៉ាងណាមិញ ការកកើតឡើងជាវិជ្ជាដែលមានវិជ្ជាជីវៈច្បាស់លាស់និងការបង្កើតជា មុខវិជ្ជាដែលមានលក្ខណៈវិទ្យាសាស្រ្តថ្មី នាសតវត្សរ៍ទី ១៩ និង ២០ បាននាំអោយមានរលកពត៌មាន ឬមុខវិជ្ជាថ្មីៗ ដែលប្រកួតប្រជែងនឹងទស្សនៈជាប្រពៃណីចំពោះប្រវត្តិសាស្រ្ត ។ បុរាណវិទ្យា, នរៈវិទ្យា,និងវិទ្យាសាស្រ្តសង្គមផ្សេងទៀត បាននិងកំពុងតែផ្តល់ព័ត៌មាន ហើយនិងទ្រឹស្តីថ្មីៗ ស្តីអំពីប្រវត្តិសាស្រ្តមនុស្សជាតិ ។ ប្រវត្តិវិទូចាស់គំរិលមួយចំនួន បានចោទសួរថា តើការសិក្សាថ្មីៗទាំងនេះ ពិតជាប្រវត្តិសាស្រ្តដែរឬទេ ប្រសិនបើវាមិនត្រូវបានកំណត់ដោយពាក្យពេជន៍សរសេរ(ដែលផ្ទុយពីមុខវិជ្ជាប្រវត្តិសាស្រ្តដែលផ្អែកលើប្រភពសំណៃរជាចំបង) ។ បច្ចេកពាក្យថ្មី «បុរេប្រវត្តិសាស្រ្ត» ត្រូវបានគេបង្កើតឡើង ដើម្បីគ្រប់ដណ្តប់លើមុខវិជ្ជាថ្មីទាំងនោះ ដែលផ្តល់ព័ត៌មាន ឬព្រឹត្តិការណ៍មុនពេលមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ ។

នៅក្នុងសតវត្សរ៍ទី ២០ ការបែងចែករវាងមុខវិជ្ជាប្រវត្តិសាស្រ្ត និងបុរេប្រវត្តិសាស្រ្តបានក្លាយជាបញ្ហាពិភាក្សាដ៏ក្តៅគគុក ។ ការិះគន់បានកើតឡើង ដោយសារតែមុខវិជ្ជាប្រវត្តិសាស្រ្ត បានមិនបានត្រួតពិនិយ្តនិងសិក្សាលើអរិយធម៌មួយចំនួនដូចជា អរិយធម៌អាហ្វ្រិកម្តុំអនុតំបន់សាហារ៉ា (Sub-Saharan Africa) និងអរិយធម៌អាមេរិកមុនសម័យការមកដល់របស់គ្រីស្តុប កូឡុំ។ លើសពីនេះទៅទៀត បុរេប្រវត្តិវិទូ ដូចជា លោក វេរ ហ្គ័រដុនឈីលដេ និងបុរាណវិទូប្រវត្តិសាស្រ្ត ដូចជាលោក ជេម ឌីតហ្ស៍ (James Deetz) បានចាប់ផ្តើមប្រើប្រាស់បុរាណវិទ្យា ដើម្បីពន្យល់អំពីព្រឹត្តិការណ៍សំខាន់ៗ ដែលពីមុនមក ជាផ្នែកដែលស្ថិតក្នុងការសិក្សាប្រវត្តិសាស្រ្ត ។ ប្រវត្តិវិទូបានចាប់ផ្តើមអង្កេតមើលលើសពី ការរៀបរាប់ប្រវត្តិសាស្រ្តនយោបាយ ជាប្រពៃណី ដោយប្រើប្រាស់គោលការណ៍ថ្មី ដូចជា ប្រវត្តិសេដ្ឋកិច្ច វប្បធម៌ និង សង្គម ដែលសុទ្ធតែពឹងផ្អែកលើប្រភពឯកសារ និងភស្តុតាងផ្សេងៗ ។ ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ កំពែងដ៏រឹងមាំខ័ណ្ឌចែករវាងប្រវត្តិសាស្រ្ត និងបុរេប្រវត្តិសាស្រ្ត បាននិងកំពុងចាប់ផ្តើមសឹករិចរិលបន្តិចម្តងៗ ។

មានទស្សនៈយល់ឃើញផ្សេងៗគ្នាស្តីអំពីកំណកំណើតប្រវត្តិវិទ្យា ។ អ្នកខ្លះជឿជាក់ថាប្រវត្តិវិទ្យា បានចាប់ផ្តើម តាំងពីសហវត្សរ៍ ទី ៣ ឬ ៤ មុនគ្រីស្ត៍សករាជមកម្លេះ ស្របគ្នានឹងកំណើតអក្សរជ្រុងៗ (cuneiform)*1* ។ អក្សរជ្រុងៗនេះ ត្រូវបានសរសេរលើបន្ទះដីឥដ្ឋ ដោយតួអក្សរនីមួយៗត្រូវបានចារដោយចុងត្រែង ដែលគេហៅថា ស្ទីឡូ (ឬប៊ិក)។ សញ្ញាដែលបន្សល់ដោយស្ទីឡូ មានរាងជ្រុងៗ នៅខាងជ្រុង ម្លោះហើយបានជាគេហៅថា អក្សរជ្រុង។

*១* ចូរមើលរូបភាពទី២០ អក្សរជ្រុងៗ ក្នុងផ្នែកឧបសម្ព័ន្ធនៅខាងក្រោយ រូបភាពទី ២០ ។

អក្សរពួក Sumerian បានយកលំនាំតាមប្រព័ន្ធអក្សរ នៃភាស អាណាចក្រ អាកាឌៀន (Akkadian) អ៊ីឡាមីត (Elamite) ហ៊ីតទី (Hittite) និងឡូវៀន (Luwian) ហើយវាបានជះឥទ្ធិពលពលដល់តួអក្សរជាតិពៃរ្យ បុរាណ និង អ៊ុហ្គារីទិក(Ugaritic) ។

សម្រាប់អ្នកដទៃទៀត ប្រវត្តិសាស្ត្រក្លាយជាបច្ចេកពាក្យទូទៅសម្រាប់មុខវិជ្ជា ដែលសិក្សាអ្វីៗទាំងអស់ក្នុងអតីតកាលរបស់មនុស្សជាតិ (ប៉ុន្តែ យ៉ាងនេះក្តី ក៏មានរបាំងសម្រាប់មុខវិជ្ជាប្រវត្តិវិទ្យាមួយទៀត គឺជាមុខវិជ្ជាថ្មីដូចជា «មហាប្រវត្តិសាស្ត្រ» (Big History) ដែលរៀបរាប់តាំងពីកំណកំណើតភពផែនដីផងដែរ។

ប្រភពព័ត៌មាន ដែលអាចផ្តល់ពន្លឺអតីតកាល ដូចជាប្រវត្តិផ្ទាល់មាត់ឬ ទំលាប់ប្រាប់ពីមាត់មួយទៅមាត់មួយទៀត ភាសាវិទ្យា និងហ្សេនេទិចវិទ្យា ត្រូវបានទទួលស្គាល់ដោយប្រវត្តិវិទូទូទៅជាច្រើនផងដែរ។ យ៉ាងណាមិញ បុរាណវិទូ កំណត់ភាពខុសគ្នារវាងប្រវត្តិសាស្ត្រនិងបុរេប្រវត្តិសាស្ត្រ ដោយផ្អែកលើឯកសារជាលាយលក្ខណ៍អក្សរ នៅក្នុងតំបន់ដែលគេកំពុងសិក្សា ។ ភាពខុសគ្នានេះ នៅតែមានសារៈសំខាន់សំរាប់បុរាណវិទូ ដោយហេតុថា ការដែលមានកំណត់ត្រាជាអក្សរ អាចបណ្តាលអោយមានសក្តានុពលនិងបញ្ហាបកស្រាយផ្សេងៗគ្នា ។

### **១.៤.២. វិជ្ជាការសរសេរប្រវត្តិសាស្ត្រ** (Historiography)

ពាក្យ«វិជ្ជាការសរសេរប្រវត្តិសាស្ត្រ» (Historiography) មានក៏អត្ថន័យទាក់ទងនឹងប្រវត្តិសាស្ត្រផងដែរ ។ វាអាចត្រូវបានគេសំដៅទៅលើប្រវត្តិនៃការសិក្សាប្រវត្តិសាស្ត្រ វិធីសាស្ត្រ និងការអនុវត្តន៍ជាក់ស្តែង (ប្រវត្តិនៃប្រវត្តិវិទ្យា) ។ វាក៏សំដៅទៅលើផ្នែកពិសេស ឬសម័យណាមួយនៃការសរសេរប្រវត្តិសាស្ត្រ ។ ឧទាហរណ៍ «វិជ្ជាការសរសេរប្រវត្តិសាស្ត្រសម័យមជ្ឈឹម កំឡុងទសវត្សរ៍ឆ្នាំ ១៩៦០» ចង់សំដៅទៅលើ «ប្រវត្តិសាស្ត្រមជ្ឈឹមសម័យដែលត្រូវបានសរសេរឡើងកំឡុងទសវត្សរ៍ឆ្នាំ ១៩៦០» ។ វិជ្ជាការសរសេរប្រវត្តិសាស្ត្រ ក៏អាចត្រូវប្រើប្រាស់ក្នុងន័យថាជា «ទ្រឹស្តីប្រវត្តិសាស្ត្រ» ឬ វិជ្ជាសិក្សាអំពីការសរសេរប្រវត្តិសាស្ត្រ និងការចងចាំប្រវត្តិសាស្ត្រ ។ ក្នុងន័យជាការវិភាគគំរឹតធំ ទៅលើការពិពណ៌នាអំពីអតីតកាល អត្ថន័យទីបី នេះអាចជាប់ទាក់ទងទៅនឹងអត្ថន័យពីរខាងដើម ដោយសារការវិភាគតែងតែផ្តោតជាសំខាន់លើការពិពណ៌នា ការបកស្រាយ ទស្សនៈពិភពលោក ការប្រើប្រាស់ភស្តុតាង ឬ វិធីសាស្ត្របង្ហាញ របស់ប្រវត្តិវិទូផ្សេងៗទៀត ។

ដោយឡែកពាក្យ វិជ្ជាការសរសេរប្រវត្តិសាស្ត្រ គឺបច្ចេកស័ព្ទមួយ ដែលមានន័យច្រើន ខុសៗគ្នាតាមសម័យទីកន្លែង និងតាមអ្នកសង្កេតម្នាក់ៗ ដូចច្នេះ ហើយវាមិនអាចមានន័យតែមួយដាច់តែឯងនោះទេ ។ ជាទូទៅ វិជ្ជាសិក្សាប្រវត្តិវិទ្យាមានការទាក់ទងនឹងការសិក្សាពីការសរសេរប្រវត្តិសាស្ត្រ ដោយសង្កេតលើកត្តាផ្សេងៗ ដូចជារបៀបរបបនៃសរសេរប្រវត្តិសាស្ត្រ វិធីបកស្រាយ និងសម្ភារៈសង្កេតតែងតែផ្លាស់ប្តូរពីសម័យកាលមួយទៅសម័យកាលមួយទៀត ប៉ុន្តែវាក៏អាចសំដៅទៅលើរឿងរ៉ាវទាំងមូលនៃកិច្ចការប្រវត្តិសាស្ត្រផងដែរ ។

វិជ្ជាសរសេរប្រវត្តិសាស្ត្រ ជារឿយៗតែងត្រូវបានបែងចែកជាប្រធានបទតូចបន្តទៀត ដូចជា «វិជ្ជាការសរសេរប្រវត្តិសាស្ត្រក្រិកបុរាណ» ឬ «វិជ្ជាការសរសេរប្រវត្តិសាស្ត្របែបសាសនា» ឬ«វិជ្ជាការសរសេរប្រវត្តិសាស្ត្រចិនបុរាណ» ឬ «វិជ្ជាការសរសេរប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ» ជាដើម ។ មានបែបបទ គោលការណ៍ ឬស្ទីល ក៏ដូចជាផ្នែកជាច្រើននៃប្រវត្តិសាស្ត្រ ដូចជា ប្រវត្តិសាស្ត្រផ្ទាល់មាត់ និងប្រវត្តិសាស្ត្របែបសង្គម ។ ដោយចាប់ផ្តើមនៅសតវត្សរ៍ទី ១៩ ជាមួយនឹងការកើនឡើងនៃប្រវត្តិវិទូដែលមានការសិក្សាជាន់ខ្ពស់ កម្រងស្នាដៃដែលទាក់ទងនឹងវិជ្ជាការសរសេរប្រវត្តិសាស្ត្រជាច្រើនត្រូវបានចារឡើងក្នុងក្របខ័ណ្ឌកិច្ចការចាស់ៗ ដូចជាស្នាដៃដើមរបស់លោក E.

H. Carr ដែលមានចំណងជើងថា «អ្វីទៅជាប្រវត្តិសាស្ត្រ?» និពន្ធនិងបោះពុម្ពដំបូងក្នុងឆ្នាំ ១៩៦១ និង «Meta-history» ដែលជាស្នាដៃរបស់លោក Hayden White ក្នុងឆ្នាំ ១៩៧៤ ។

### ១.៤.៣. ការកំណត់និយមន័យនៃវិជ្ជាការសរសេរប្រវត្តិសាស្ត្រ

មានបញ្ហាពីរសំខាន់ដែលពាក់ព័ន្ធនឹងវិជ្ជាការសរសេរប្រវត្តិសាស្ត្រ ។ បញ្ហាទីមួយ ការសិក្សានៃការវិវត្តន៍របស់វា នៅក្នុងវប្បធម៌ និងសម័យកាលផ្សេងៗគ្នា ។ បញ្ហាទីពីរ គឺថាការសិក្សាជាន់ខ្ពស់លើឧបករណ៍ដែលបាននិងកំពុងត្រូវបានគេប្រើប្រាស់ រួមមាន វិធីសាស្ត្រប្រវត្តិសាស្ត្រផងដែរ ។

ពាក្យ «វិជ្ជាការសរសេរប្រវត្តិសាស្ត្រ» អាចត្រូវបានគេប្រើប្រាស់សំដៅទៅលើរចនាសម្ព័ន្ធពិសេសណាមួយនៃការសរសេរប្រវត្តិសាស្ត្រ ដែលត្រូវបានសរសេរក្នុង អំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ អាចត្រូវបានចាត់ទុកថាជាគោលការណ៍បែបវិធីសាស្ត្រ និងគំនិតស្តីអំពីប្រវត្តិសាស្ត្រមជ្ឈឹមសម័យ ដែលត្រូវបានអភិវឌ្ឍ នៅក្នុងអំឡុងទសវត្សរ៍នោះ ។

លោក Conal Furay និង លោក Michael J .Salevouris បានកំណត់វិជ្ជាការសរសេរប្រវត្តិសាស្ត្រថាជា «ការសិក្សាអំពីវិធីសាស្ត្រសរសេរប្រវត្តិសាស្ត្រ តាំងពីដើមរៀងមក ពោលគឺជាប្រវត្តិនៃការសរសេរប្រវត្តិសាស្ត្រ ។ ពេលសិក្សាអំពី«វិជ្ជាការសរសេរប្រវត្តិសាស្ត្រ» អ្នកមិនចាំបាច់សិក្សាអំពីព្រឹត្តិការណ៍នាអតីតកាលដោយផ្ទាល់ឡើយ ប៉ុន្តែអ្វីដែលសំខាន់សម្រាប់អ្នក គឺ សិក្សាអំពីការបកស្រាយផ្សេងៗ ទៅលើព្រឹត្តិការណ៍ទាំងនោះ នៅក្នុងស្នាដៃប្រវត្តិវិទូនីមួយៗ ។ (Conal Furay និង Michael J. Salevouris, ១៩៨៨:២២៣) ។

### ១.៤.៤. សំណួរត្រូវសិក្សាស្វែងយល់ ( Questions Studied)

សំណួរទូទៅមួយចំនួនសម្រាប់ការសិក្សាវិជ្ជាការសរសេរប្រវត្តិសាស្ត្រមានដូចជា ៖

១. ភាពទុកចិត្ត (Reliability) នៃប្រភពពត៌មាន ដែលប្រើប្រាស់ ពិសេសទៅលើភាពជាអ្នកនិពន្ធ (Authorship) ការជឿជាក់លើអ្នកនិពន្ធ (Credibility) និងសភាពដើម ឬ ការបង្ខូចខ្លឹមសារអត្ថបទ (authenticity or corruption) ។

២. ប្រពៃណីឬ គម្រោងនៃវិជ្ជាកាសរសេរប្រវត្តិសាស្ត្រ ( Historiographical tradition or framework) ៖ អ្នកប្រវត្តិសាស្ត្រគ្រប់រូបប្រើប្រាស់វិធីសាស្ត្រសរសេរប្រវត្តិសាស្ត្រមួយឬច្រើន ក្នុងនោះអាចជាទ្រឹស្តីម៉ាក្សិសនិយម ឬ កាលប្បវត្តិ (Annales school) ជួនកាល ប្រវត្តិសាស្ត្រទាំងមូល (Total History) ឬប្រវត្តិនយោបាយ ។

៣. បញ្ហាសីលធម៌ ៖ កិច្ចការឬស្នាដៃមានកិរុទ្ធភាព និងមានការសរសើរខ្លាំងក្លាពេក។

៤.គំនិតសើរើនិយម ទល់នឹង ការបកស្រាយបែបចាស់គំរិល ។

### ១.៤.៥. វិជ្ជាការសរសេរប្រវត្តិសាស្ត្របែបត្រិះរិះពិចារណា (Criticalhistoriography)

បញ្ហាទាក់ទងនឹងវិជ្ជាការបែបនេះ រួមមានប្រធានបទដូចជា៖

- អ្វីគួរត្រូវបានចារក្នុងប្រវត្តិសាស្ត្រ?

- តើប្រវត្តិសាស្ត្រវិទូអាចសរសេរអះអាងអ្វីមួយជា«សច្ចៈភាព»និង«ការពិត»ដោយវិធីណា?
- តើស្នាដៃផ្សេងៗ (ប្រលោមលោក សៀវភៅសិក្សា ខ្សែភាពយន្ត ល្ខោននិងឆាកកំប្លែង) ដែលពត៌មានប្រវត្តិសាស្ត្របានផ្តិតទុកអាចមានឥទ្ធិពលយ៉ាងណាលើអត្ថន័យរបស់វា?
- តើបញ្ហាទ្រឹស្តីចំណេះដឹងអ្វីខ្លះ ដែលប្រវត្តិសាស្ត្រពឹងលើបណ្ណសារដ្ឋានអាចមាន?
- តើប្រវត្តិទូទៅអាចបង្កើតអោយមាន «ភាពមិនលំអៀង» ដោយរបៀបណាបើពួកគេមានប្រវត្តិឬគំនិតផ្ទាល់ខ្លួនបែបនេះ?
- តើអ្វីទៅដែលជាចំណងទាក់ទងរវាងទ្រឹស្តីប្រវត្តិសាស្ត្រនឹងការអនុវត្តន៍ជាក់ស្តែង?
- តើអ្វីទៅជា «គោលដៅ»របស់ប្រវត្តិវិទ្យា ?

### ១.៤.៦. មុខវិជ្ជាសិក្សាពាក់ពន្ធ័មួយចំនួនទៀត

- បុរាណវិទ្យា (Archaeology) ៖ ការសិក្សាអំពីបុរេប្រវត្តិសាស្ត្រនិងប្រវត្តិវប្បធម៌មនុស្សជាតិ តាមរយៈកំណាយ ការចងក្រងឯកសារ និងការវិភាគលើសម្ភារៈ ដែលនៅសេសសល់ និងទិន្នន័យ ដែលមាននៅជុំវិញវត្ថុទាំងនោះ ។
- ប្រវត្តិការិយាល័យវិទ្យា (Archontology) ៖ ជាមុខវិជ្ជាសិក្សាអំពីប្រវត្តិការិយាល័យ តួនាទីសំខាន់ៗក្នុងអង្គការរដ្ឋ អង្គការអន្តរជាតិ នយោបាយ សាសនា និងអង្គការសង្គមផ្សេងៗទៀត ។
- ប្រវត្តិសិល្បៈ(Art History) ៖ ជាការសិក្សាអំពី ការផ្លាស់ប្តូរផ្នែកសិល្បៈ និងក្នុងបរិបទសង្គមសិល្បៈ ។
- មហាប្រវត្តិសាស្ត្រ (Big History) ៖ ជាការសិក្សាអំពីប្រវត្តិសាស្ត្រក្នុងមាត្រដ្ឋានដ៏ធំ ក្នុងរយៈពេលយូរលង់ណាស់មកហើយ ចាប់ពីព្រឹត្តិការណ៍បន្ទុះ Big Bang រហូតដល់ពេលអនាគត តាមរយៈគោលការណ៍ពហុមុខវិជ្ជា ។
- កាលប្បវត្តិវិទ្យា (Chronology) ៖ ជាវិទ្យាសាស្ត្រកត់ត្រាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងពេលណាមួយ ។
- ប្រវត្តិវប្បធម៌ (Cultural History) ៖ ជាវិជ្ជាសិក្សាអំពីវប្បធម៌កាលពីអតីតកាល ។
- ប្រវត្តិការទូត (Diplomatic History) ៖ ជាវិជ្ជាសិក្សាពីទំនាក់ទំនងអន្តរជាតិ ពីអតីតកាល ។
- ប្រវត្តិសេដ្ឋកិច្ច (Economic History) ៖ ជាវិជ្ជាសិក្សាពីសេដ្ឋកិច្ច កាលពីអតីតកាល ។
- អនាគតវិទ្យា (Futurology) ៖ ជាវិជ្ជាសិក្សាពីអនាគត ស្រាវជ្រាវពីឧបទ្ទេវហេតុផ្សេងៗដើម្បីធ្វើការព្យាករណ៍ឬទស្សទាយពីសង្គម និងលក្ខណៈរបស់ពិភពលោក នាពេលអនាគត ។
- រូបគំនូវិទ្យា (Painter History) ៖ ជាមុខវិជ្ជាសិក្សាពីរូបគំនូរ រូបចម្លាក់ប្រវត្តិសាស្ត្រ ហើយជាពិសេសរូបគំនូរព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ ៗ ។
- ប្រវត្តិយោធា (Military History) ៖ ជាវិជ្ជាសិក្សាពីកិច្ចការយោធា និងសង្គ្រាមក្នុងប្រវត្តិសាស្ត្រ និងសិក្សាពីអ្វីដែលជួនកាលត្រូវបានគេគិតថាជាមែកធាងរបស់យោធាគឺ ប្រវត្តិកងទ័ពជើងទឹក ។
- អក្សរបុរាណវិទ្យា (Paleography) ៖ ជាវិជ្ជាសិក្សាពីប្រព័ន្ធអក្សរបុរាណ ដែលអាចមានន័យស្មើនឹងសិលាចារិកវិទ្យា (Epigraphy) ។

- ប្រវត្តិនយោបាយ (Political History) ៖ ជាវិជ្ជាសិក្សាពីនយោបាយ ពីអតីតកាល ។
- ប្រវត្តិចិត្តសាស្ត្រ (Psychohistory) ៖ ជាវិជ្ជាសិក្សាអំពីហេតុផលផ្នែកចិត្តសាស្ត្រ ដែលនាំអោយកើតមានព្រឹត្តិការណ៍ណាមួយនៅក្នុងប្រវត្តិសាស្ត្រ ។
- ប្រវត្តិនៃវិទ្យាសាស្ត្រ (Historiography of Science) ៖ ជាវិជ្ជាសិក្សាអំពីរចនាសម្ព័ន្ធ និងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ ។
- ប្រវត្តិសាស្ត្រសង្គម (Social History) ៖ ជាវិជ្ជាសិក្សាអំពីសង្គមនាពេលអតីតកាល ។
- ប្រវត្តិសាស្ត្រពិភពលោក (World History) ៖ ជាវិជ្ជាសិក្សាអំពីប្រវត្តិសាស្ត្រ តាមទស្សនៈវិស័យពិភពលោក ។

**គំនូសបំព្រួញប្រៀបធៀប បុរេប្រវត្តិសាស្ត្រ និង ប្រវត្តិសាស្ត្រ**



# មេរៀនទី ២ ៖ ទេវកថា និង ទ្រឹស្តីប្រវត្តិសាស្ត្របុរាណ

## ២.១. និយមន័យទេវកថា និងគោលដៅ

ទេវកថា ជាវិធីសាស្ត្រមួយសម្រាប់ស្វែងយល់ពីអតីតកាល ។ តាំងពីសម័យដើមដំបូង មនុស្សទាំងឡាយតែងតែចាប់អារម្មណ៍លើរឿងរ៉ាវអតីតកាល ដោយសារៈ

- ដើម្បីចង់ដឹងថាតើពួកគេមានកំណើតមកពីណា?
- ដើម្បីរកហេតុផលដែលនាំអោយគេចង់រស់នៅលើពិភពលោក
- ដើម្បីស្វែងយល់ពីព្រះ ឬ អាទិទេពនានា

ទេវកថា ជារឿងរ៉ាវបែបប្រពៃណី ដែលលាយឡំនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ហើយវាមានតួនាទីបើកកកាយពីអាថ៌កំបាំងពិភពលោក បង្ហាញនិងពន្យល់ពីទស្សនៈរបស់ពិភពលោក រួមទាំងការប្រតិបត្តិជំនឿសាសនារបស់ពួកគេ និងបង្ហាញពីបាតុភូតធម្មជាតិ ។ និយមន័យខាងលើបញ្ជាក់អោយឃើញថា ទេវកថា អាចមានន័យប្រហាក់ប្រហែលនឹងនិទានកថា ឬរឿងព្រេង ដែលដំណាលតគ្នាពីមាត់មួយទៅមាត់មួយ ពីមួយជំនាន់ទៅមួយជំនាន់ទៀត ។ ភាពខុសគ្នានៃរឿងទាំងអស់នេះអាចនៅត្រូវការការពិភាក្សាបន្ថែមទៀត ។ តែពេលនេះ យើងនឹងមិនពិភាក្សាវាទេ គ្រាន់តែចង់បញ្ជាក់ថា ទេវកថាអាចត្រូវបានគេហៅផ្សេងគ្នា តាមប្រទេសនីមួយៗ លើពិភពលោក ។

សង្គមនីមួយៗ តែងតែមានទេវកថាឬរឿងនិទានផ្ទាល់ខ្លួន ។ ទេវកថាឆ្លុះបញ្ចាំង បង្ហាញ រុករកការយល់ឃើញរបស់មនុស្ស ។ វាប្រាប់អោយដឹងពីប្រភពកំណើត លក្ខណៈ និងគុណតម្លៃរបស់មនុស្សទាំងនោះ ។ វាក៏មានតួនាទីផ្នែកសាសនា ដូចដែលមនុស្សដំបូងៗ បានរៀបរាប់ពីមូលហេតុសាសនា និងអាថ៌កំបាំងនៃព្រឹត្តិការណ៍អតីតកាល ។

តាមពិតទៅ ទេវកថាមានទំនាក់ទំនងនឹងអតីតកាល ។ ទេវកថាខ្លះត្រូវបានប្រើប្រាស់ដើម្បីអប់រំមនុស្សអំពីអតីតកាល ពីកំណកំណើតពិភពលោក ឬពីដំណើរដើមទងដែលមនុស្សមួយក្រុម បង្កើតបានជាប្រជាជាតិមួយ ឬកន្លែងណាមួយ ។ នៅក្នុងសង្គមដែលមនុស្សមិនទាន់ឬ មិនចេះអក្សរ ទេវកថាត្រូវបានប្រើប្រាស់ជាប្រវត្តិសាស្ត្រមួយបែបសម្រាប់អ្នកមិនចេះអក្សរ វាគ្រាន់តែជារឿងរ៉ាវ ដែលប៉ុនប៉ងប្រាប់ការពិត ។ វាត្រូវនិទានបន្តពីមួយជំនាន់ទៅមួយជំនាន់ និងនិទានប្រាប់តាំងពីកុមារភាព ។

## ២.២. ទេវកថាខ្មែរ និងទេវកថាពិភពលោក

### ២.២.១. ទេវកថាខ្មែរ

**«រឿងដើមកំណើតរន្ទះ»**

«កាលពីព្រេងនាយ មានបិសាចមួយឈ្មោះ**រាមាសូរ** និងនាងអារក្ខទេវីមួយឈ្មោះ **មេខលា** ។ អ្នកទាំងពីរបាននៅបម្រើមហាឫសីដ៏មានឫទ្ធិម្នាក់ ដើម្បីនឹងរៀនវិជ្ជា មន្ត អាគម គាថា ។ បិសាច និងនាង**មេខលា**បានខំរៀនប្រណាំងប្រជែងគ្នាដើម្បីបំពេញចិត្តគ្រូរៀងខ្លួន ហើយអ្នកទាំងពីរប្រកបដោយបញ្ញាវៃក្រៃលែងដូចគ្នា ។ តាបសក៏ស្រឡាញ់អ្នកទាំងពីរនោះស្មើគ្នា ។ ពេលតាបសបានបង្រៀនសិស្សលោកចប់គ្រប់មុខវិជ្ជាហើយ លោកក៏ចង់ល្បង

វិជ្ជាសិស្សមើលថា តើអ្នកណាមួយប៉ិនប្រសប់ជាងគេ ។ ទើបលោកនិយាយទៅកាន់សិស្សថា "បើអ្នកណា យកកែវមួយមានទឹកសន្សើមពេញមកអោយខ្ញុំបាន នោះខ្ញុំនឹងធ្វើទឹកនោះអោយក្លាយទៅជាកែវមនោហរ ហើយដោយគុណភាពនៃរតនវត្ថុនោះ អ្នកម្ចាស់កែវអាចប្រាថ្នាធ្វើអ្វី ឬចង់បានអ្វី ចេះតែបានសម្រេចទាំងអស់" ។

**រាមាសូរ** ក៏យកកែវមួយទៅត្រងទឹកសន្សើមដែលទើនៅស្លឹកឈើ និងស្មៅផ្សេងៗ ។ វាបានខំព្យាយាមធ្វើដូច្នេះ ជាច្រើនព្រឹក ប៉ុន្តែឥតបានផលល្អសោះ ។ ចំណែកឯនាង**មេខលា** ដែលជាស្រីគិតវែងឆ្ងាយក៏រើសយកបណ្តូលឈើមួយយ៉ាងទន់ស្តោតៗ ហើយយកទៅដាក់ផ្អិតលើទឹកសន្សើម ដែលជក់នៅលើស្លឹកឈើ និងនៅលើស្មៅទាល់តែដុំឈើនៅជក់ទឹកពេញទាំងអស់ ។ បន្ទាប់មកនាងមេខលាបានយកដុំឈើនៅទៅច្របាច់ទឹកដាក់ក្នុងកែវ ។ អាស្រ័យដោយហេតុដូច្នេះ នាងក៏រកទឹកសន្សើមដាក់កែវបានពេញ ហើយក៏យកកែវនោះទៅជូនមហាតាបស ។ ហេតុដូច្នេះ បានជានាងអារក្ខទេវីត្រូវបានតាបសសម្គាល់ថា ប៉ិនប្រសប់ជាងបិសាច ។

តាបស ជប់ទឹកសន្សើមនោះអោយកើតទៅជាកែវ ហើយប្រគលទៅអោយនាងមេខលាដោយប្រាប់ថា «កែវនេះ មានគុណភាពខ្លាំងណាស់ បើអ្នកមានបំណងអ្វីមួយ គ្រាន់តែលើកកែវនេះគ្រវីឡើង នោះមួយរំពេច សេចក្តីប្រាថ្នារបស់អ្នកនឹងបានសម្រេចភ្លាម មួយទៀតដោយគុណភាពនៃកែវនេះ អ្នកអាចហោះ កាត់អាកាស កប់ពពកជ្រកអាចម៍ជន្លេន ទៅកាន់កន្លែងណា ក៏បានទាំងអស់» ។

នាងអារក្ខទេវី ក៏ទទួលយកកែវនោះមកលើគ្រវីឡើងលើ ស្រាប់តែហោះរឹងទៅលើមេឃតម្រង់ទៅមហាសាគរ ។

ចំណែកឯ **រាមាសូរ** អាស្រ័យដោយការព្យាយាមដ៏យូរ ក៏រកទឹកសន្សើមដាក់បានពេញកែវ ហើយយកទៅថ្វាយមហាឫសីៗ ពោលថា «ចៅឯងយករបស់នេះមកយឺតយូរពេក ហួសពេលតាត្រូវការ ឥឡូវតាបានអោយរតនវត្ថុនោះ ទៅនាង**មេខលា**ទៅហើយ មន្តអាគមគាថារបស់តា អាចជប់វត្ថុបែបនេះ បានតែមួយដងទេ»។

ពេលបានឮមហាតាបសថាដូច្នេះ រាមាសូរក៏កើតសេចក្តីទោមនស្សពន់ប្រមាណ ហើយក៏ស្រែកយំអណ្តើកអណ្តកយ៉ាងខ្លាំង ។ ដើម្បីលួងចិត្តបិសាច តាបសក៏ប្រាប់ថា «ចូរចៅកុំកើតទុក្ខខ្លាំងពេក ចាំតាអោយពូថៅមួយ ពូថៅនេះអ្នកអាចយកទៅឈ្លោះដណ្តើមយកកែវពីនាងអារក្ខទេវី**មេខលា**បាន ។ នាង**មេខលា**នេះ ចូលចិត្តហោះហើរលេងនៅលើអាកាស ដើម្បីមុជទឹកភ្លៀងដែលមានភ្លៀងម្តងៗ ។ ចូរអ្នកចោលពូថៅនេះទៅលើវា វានឹងបោះចោលកែវដ៏មានតម្លៃនោះ ។ ប៉ុន្តែនៅពេលប្រយុទ្ធគ្នានោះ ចៅឯងឃើញវាលើកកែវឡើងគ្រវី ចូរចៅឯងបិទភ្នែកភ្លាម មុននឹងចោលពូថៅទៅលើវា» ។

ពេលរាមាសូរបានពូថៅមកកាន់នៅនឹងដៃហើយ វាក៏ហោះស្វែងរក នាង**មេខលា** ដើម្បីដណ្តើមកែវមនោហរ ។ ប៉ុន្តែពេលនាងមេខលាបានឃើញរាមាសូរភ្លាម នាងក៏យល់ឃើញថា បិសាចនេះប្រាកដជាមានបំណងធ្វើអាក្រក់មកលើនាងពុំខានឡើយ ទើបនាងលើកកែវគ្រវីឡើង ហោះទៅលើអាកាសវេហាខ្ពស់ក្រៃលែងខ្ពស់ ។

ពេលក្រឡេកឃើញពន្លឺចាំងនៃកែវមានសិល្បិ៍ភ្លាម បិសាចក៏បិទភ្នែកវាជិតរួចគ្រវែងអាវុធវាទៅ ។ អាវុធនោះក៏ហោះយ៉ាងលឿនឮសូរសម្បើមក្រៃលែង ប៉ុន្តែឥតត្រូវនាង**មេខលា**ទេ ។

ចាប់តាំងពីពេលនោះមក ទើបនៅពេលមានភ្លៀងផ្គរគេឃើញចាំងពន្លឺកែវហើយឮសូរសម្លេងយ៉ាងខ្លាំងនៃអាវុធនោះ ។ អាស្រ័យហេតុនេះហើយ បានជាក្នុងភាសាខ្មែរ យើងអោយឈ្មោះដុំថ្មទាំងឡាយណា ដែលមានរាងដូច

ផ្លែពូថៅ ឬចបកាប់ក្បាលស្រួច ឬដូចកាំបិតថា «កាំរន្ទះ» ហើយសន្មតរបស់ទាំងនេះថា ជាព្រួញរបស់យក្សបាញ់ នៅលើមេឃធ្លាក់មកដី ។»

មនុស្សលោក មិនថាក្មេងឬចាស់ប៉ុណ្ណាទេ តែងតែមានចិត្តនឹងឆ្ងល់ ចង់ចេះចង់ដឹងរឿងរ៉ាវ ឬឧបត្តិហេតុនៅជុំវិញខ្លួន ។ ប្រជាជនខ្មែរដូចគ្នាដែរ ឃើញភ្លៀងផ្គរ ផ្លេកបន្ទោរ និងរន្ទះ ចង់ដឹងថាប្រភពនៃដំណើរធម្មជាតិទាំងនេះ ។ មុនសម័យវិទ្យាសាស្ត្រ មនុស្សមិនទាន់យល់ដឹងពីចរន្តអគ្គិសនី ដូច្នេះហើយ ក៏បានបង្កើតជារឿងខាងលើនេះឡើងដើម្បីព្យាយាមពន្យល់ពីដើមកំណើតរន្ទះជាដើម។

### ២.២.២. ទេវកថាពិភពលោក

ឧទាហរណ៍ល្បីមួយស្តីពីទេវកថា គឺមហាគ្រោះទឹកជំនន់ ។ ទេវកថានេះជារឿងពេញនិយមក្នុងវប្បធម៌ជាច្រើន ពិសេសក្នុងពិភពបស្ចឹមប្រទេស ហើយត្រូវគេជឿថា វាបានកើតឡើងជាងបីបួនពាន់ឆ្នាំមុន ។ ទេវកថានេះនិទានពីមហាគ្រោះទឹកជំនន់មួយដែលបានលិចស្ទើរគ្រប់កន្លែងក្នុងពិភពលោកសម័យបុរាណ ។ តាមសាច់រឿងផ្សេងៗ បុរសម្នាក់ត្រូវបានព្រះជាម្ចាស់អោយដំណឹងពីទឹកជំនន់ជាមុន បានធ្វើសំពៅមួយយ៉ាងធំនិងបានប្រមូលយកសត្វគ្រប់ប្រភេទមួយគូៗ ដាក់ក្នុងសំពៅនោះ ។ សត្វទាំងនោះរួចជីវិតពីទឹកជំនន់ និងជាបុព្វបុរសរបស់សត្វគ្រប់ប្រភេទលើភពផែនដីនាពេលបច្ចុប្បន្ន ។ ទេវកថានេះ ត្រូវបានគេប្រើប្រាស់ដោយវិធីសាស្ត្រផ្សេងៗគ្នា ពីមួយជំនាន់ទៅមួយជំនាន់ ។ ប្រវត្តិវិទូ និងទេវកថាវិទូមួយចំនួនអះអាងថា ទេវកថាប្រាប់ការពិត ដែលថាពិតជាមានគ្រោះទឹកជំនន់មួយដ៏ធំកាលពីបុរាណដ៏យូរលង់ណាស់មកហើយ ។ ទេវកថានេះជាការរម្លឹកពីព្រឹត្តិការណ៍នោះ ។ អ្នកផ្សេងទៀត អះអាងថា ទេវកថានេះ ជាការប៉ុនប៉ងរបស់មនុស្សលោក ដើម្បីពន្យល់ពីពិភពលោកជុំវិញពួកគេ ដើម្បីពន្យល់ពីភាពសម្បូរបែបនិងការវិវត្តន៍នៃសត្វគ្រប់ប្រភេទ ។ អ្នកផ្សេង ក្រោយបានអានរឿងនេះហើយ ចាត់ទុកថាជាការព្រមានមួយ ដែលថា គ្រោះមហន្តរាយធម្មជាតិអាចនឹងកើតឡើងគ្រប់ពេលវេលា ។ ចុងក្រោយ អ្នកខ្លះបកស្រាយសាច់រឿងនេះតាមបែបសីលធម៌ ។ ពួកគេអះអាងថាពិភពលោកមុនពេលមានគ្រោះទឹកជំនន់នោះ ពោរពេញដោយអំពើបាបនិងពុករលួយ ហើយព្រះជាម្ចាស់ពន្លិចពិភពលោក ដើម្បីសម្រាប់មនុស្សអាក្រក់ទាំងអស់ ។ មនុស្សល្អតែម្នាក់គត់ បានទទួលការព្រមានជាមុន ហើយគាត់បានជួយសង្គ្រោះជីវិតដែលមិនដឹងអីទាំងអស់ ប៉ុន្តែមនុស្សអាក្រក់ទាំងអស់ត្រូវបាត់បង់ជីវិតក្នុងទឹកជំនន់នោះ ។ ក្នុងអត្ថបទនេះ ទេវកថាស្តីពីទឹកជំនន់អប់រំយើងអោយធ្វើអំពើល្អ បើមិនដូច្នោះព្រះជាម្ចាស់នឹងពន្លិចពិភពលោកទៀត ហើយពេលនោះអ្នកដែលត្រូវស្លាប់អាចជាយើង ។

ទោះជាសង្គមដែលមានការចេះដឹង និងបានចងក្រងឯកសារប្រវត្តិសាស្ត្រជាច្រើនហើយក្តី ក៏នៅតែពឹងផ្អែកលើទេវកថា ។ សង្គមទាំងអស់សព្វថ្ងៃ មានរឿងនិទានផ្ទាល់ខ្លួន ។ ដំណាលពេលដែលអ្នកអាចស្គាល់យ៉ាងងាយ ថារឿងណាជាទេវកថា និទានតពីអតីតកាលដ៏យូរលង់ណាស់មកហើយ ឬពីវប្បធម៌ដទៃ ពេលខ្លះអ្នកពិបាកនឹងញែកអោយដាច់ថារឿងណាជាការពិត ឬ រឿងណាជាទេវកថា ព្រោះវាត្រូវបាននិទានដដែលៗ យ៉ាងទូលំទូលាយ ក្នុងសង្គមរបស់អ្នក ឬអ្នកត្រូវបានគេនិទានប្រាប់តាំងពីក្មេងមកម្លេះ ។

## ២.៣. ទ្រឹស្តីប្រវត្តិសាស្ត្រក្រិកបុរាណ

ទេវកថា ជាមធ្យោបាយតែមួយគត់ ដែលមនុស្សសម័យបុរាណ អាចស្វែងយល់ពីអតីតកាលរហូតមកដល់សម័យកាលក្រិកបុរាណ ។ (*ចំណាំ៖ កាលបរិច្ឆេទ ពីឆ្នាំ ៨០០ ដល់ ៣០០ មុនគ្រីស្តសករាជ ហើយសកម្មភាពភាគច្រើនកើតឡើងកំឡុងឆ្នាំ ៥០០ ដល់ ៣៥០ មុនគ្រីស្តសករាជ*)។

ប្រទេសក្រិកបុរាណជាបណ្តុំរដ្ឋបុរីមានទីតាំងស្ថិតនៅក្នុងតំបន់មួយធំធេង ដែលគ្រប់ដណ្តប់លើប្រទេសក្រិក ទួរគី និងផ្នែកខ្លះនៃសមុទ្រមេឌីទែរ៉ាណេ ក្នុងសម័យបច្ចុប្បន្ន ។ វាមិនមែនជាប្រជាជាតិរួបរួមគ្នាតែមួយនោះទេ ប៉ុន្តែ ជាបណ្តុំនៃរដ្ឋបុរីតូចៗ មានចំនួនប្រជាជនតិចតួច នៅដាច់ដោយឡែកពីគ្នា ។ ភាគច្រើន រុងរឿងខ្លាំង មួយក្នុងចំណោមនោះ គឺរដ្ឋបុរីអាថែន។

បុរីអាថែន រដ្ឋធានីនៃប្រទេសក្រិក ស្ថិតនៅលើវាលទំនាបមួយនៃតំបន់អាគ្នេយ៍នៃប្រទេស។ វាជាមជ្ឈមណ្ឌលរដ្ឋបាលវប្បធម៌ និងសេដ្ឋកិច្ចនៃប្រទេស ហើយភ្ជាប់ទៅនឹងកំពង់ផែនិងឧស្សាហកម្មរបស់ខ្លួន គឺភីរ៉ាអឺស (Piraeus)។ សំណល់ទីក្រុងអាតែនបុរាណជាច្រើនស្ថិតនៅលើបន្ទាយក្រុង (Acropolis) ។ លំអរដោយប្រាសាទប៉ាតេណុង(Parthenon) វាក៏មានប្រាសាទតូច ជាច្រើនទៀត ដូចជាប្រាសាទ អ៊ីយ៉ូនីក អេរីកថឹម(Ionic Erechtheum) និងប្រូពីលៃ (Propylaea) និង ណៃ (Nike)។ នៅទិសពាយ័ព្យផ្សារដែលទើបត្រូវបានស្តារឡើងវិញ នាពេលថ្មីៗនេះ អាហ្គូរ៉ា (ផ្សារ) មានប្រាសាទ ថេមឹម (សតវត្សទី ៥ មុនគ្រឹស្តសករាជ) ប្រហែលជាប្រាសាទបុរាណ ដែលបានថែរក្សាល្អបំផុត។ នៅទិសឥសាន គឺបុរីអាថែន សម័យទំនើប។ ភស្តុតាងប្រវត្តិសាស្រ្ត ចង្អុលបង្ហាញពីការតាំងទីលំនៅ ដែលកើតឡើង នៅសហវត្សទី ៣ មុនគ្រឹស្តសករាជ។ទីក្រុងអាថែន ប្រហែលជាមានកេរ្តិ៍ឈ្មោះល្បីល្បាញដំបូង ក្រោមការគ្រប់គ្រងរបស់ស្តេច ពីស៊ីស្រ្តាទឹស Pisistratus និងបុត្រារបស់ទ្រង់ នៅសតវត្សទី ៦ មុនគ្រឹស្តសករាជ។ នៅកំឡុងឆ្នាំ ៥០៦ រដ្ឋបុរសឈ្មោះ ក្លេស្តែនស៍ (Cleisthenes) បានបង្កើតលទ្ធិប្រជាធិបតេយ្យសម្រាប់អ្នកជាក្នុងបុរីអាថែន។ ក្នុងអំឡុងសតវត្សរ៍ក្រោយមក វាបានក្លាយជារដ្ឋបុរី ក្រិកឈានមុខគេដោយបានវាយឈ្នះកងទ័ពឈ្លានពានពែរ្សដោយមានជំនួយពីកងទ័ពជើងទឹកដ៏មានឥទ្ធិពលរបស់ខ្លួន ។ កំពែងដ៏វែង (The Long Walls) ភ្ជាប់ពីបុរីនេះទៅកាន់បុរី Piraeus និង Parthenon បានបន្សល់ទុកពីសម័យនេះ ។ នៅក្រោមការដឹកនាំរបស់រដ្ឋបុរសពៃរីក្លីស (Pericles)បុរីអាថែនវាបានរីកចម្រើនដល់កម្រិតកំពូល ក្នុងឃ្លាំងបញ្ញាញ្ញាណវាងវៃ ក្នុងនោះរួមមានទស្សនវិជ្ជារបស់សូក្រាត និងរឿងល្ខោនរបស់អេហ្សីលីស សូហ្វូក្លីស និងអឺរីពីឌីស ។ ក្រោយត្រូវបានកម្ចាត់ដោយ បុរីស្ប៉ាតា (Sparta) នៅក្នុងសង្គ្រាមប៉េឡូប៉ូនេសៀន (៤៣១-៤០៤) អាថែនបានរីកឡើងវិញឃឹតៗ ដោយទទួលបានមកវិញនូវឧត្តមភាពបញ្ញារបស់ខ្លួនជាមួយនឹងតួអង្គ ដូចជា ផ្លាតុង អារីស្តូត និងអារីស្តូផាន។ ក្រោយត្រូវបានកម្ចាត់ដោយ ស្តេច ភីលីព នៃម៉ាសេដូនី នៅឆ្នាំ ៣៣៨ មុនគ្រឹស្តសករាជវាស្ថិតនៅក្រោមការគ្រប់គ្រងរបស់រ៉ូមនៅសតវត្សទី ២ មុនគ្រឹស្តសករាជ។ ទីក្រុងនេះបានបន្តរីកចម្រើនហើយទោះបីជាត្រូវបានត្រួតត្រាដោយកុលសម្ព័ន្ធអាឡឺម៉ង់ នៅសតវត្សរ៍ទី ៤ នៃគ្រឹស្តសករាជក៏ដោយនៅតែមានសារៈសំខាន់ខាងការអប់រំហូត ទាល់តែអធិរាជ ចាស្ទីនៀន (Justinian) នៃចក្រភពប៊ីហ្សង់ទីន បានបិទសាលាទស្សនវិជ្ជា នៅឆ្នាំ ៥២៩ នៃគ្រឹស្តសករាជ។ ទីក្រុងនេះបានធ្លាក់ទៅលើក្រុមទាហានបូជនីយកិច្ចនៅឆ្នាំ ១២០៤ និងស្ថិតនៅក្រោមការកាន់កាប់របស់ទួរគី ពីឆ្នាំ ១៤៥៦ ដល់ ១៨៣៣ នៅពេលដែល វាបានក្លាយជារាជធានីនៃប្រទេសក្រិកឯករាជ្យថ្មី។

បើយើងត្រលប់មើលមត៌កអរិយធម៌ក្រិកបុរាណ រយៈពេលជាង ២០០ ឆ្នាំ ប្រហែលជាពីឆ្នាំ ៥៥០ ដល់ ៣៥០ មុនគ្រឹស្ត៍សករាជ ជនជាតិក្រិកបានដើរតួនាទីសំខាន់និងជះឥទ្ធិពលជ្រាលជ្រៅ ដល់ពិភពលោកយើងផ្ទាល់ហូតដល់សព្វថ្ងៃ ។ ពួកគេជាមនុស្សដំបូងដែលប្រើប្រាស់ និងអនុវត្តការគិតគូរពិចារណា ថ្លឹងថ្លែងហេតុផល ក្នុងគ្រប់ទិដ្ឋភាព ជីវិត និងសង្គម ។ ជាលទ្ធផល ពួកគេបានបង្កើតលទ្ធិប្រជាធិបតេយ្យ វិទ្យាសាស្រ្ត គណិតវិទ្យា តារាសាស្រ្ត ទស្សនៈវិទ្យា អក្សរសាស្រ្តទំនើប ល្ខោនទំនើប ការស្រាវជ្រាវវេជ្ជសាស្រ្ត ការបង្កើតប្រវត្តិសាស្រ្តពិតជាលើកដំបូង។

ជនជាតិក្រិកបុរាណ ក៏ដូចជាមនុស្សលោកសម័យមុនពួកគេដែរ ស្វែងយល់ពិភពលោកជុំវិញពួកគេតាមរយៈទេវកថា ។ ទេវកថាក្រិកមានច្រើនអនេក ដោយមានតួអង្គអាទិទេពជាច្រើន ដែលភាគច្រើនមានរូបរាងជាមនុស្ស និងជាប់សាច់ញាតិនឹងគ្នា ។ មានអាទិទេពមនុស្សពាក់ កណ្តាលអាទិទេព វីរៈបុរស និងអង្គផ្សេងទៀតរាប់រយនាក់ ។ រឿងរ៉ាវទេវកថាក្រិក ប្រៀបដូចល្ខោនគ្រួសារ ហើយរញ៉េរញ៉ៃខ្លាំង ។ ជាឧទាហរណ៍ សង្គ្រាមជួលកាល ត្រូវបានពន្យល់ជាជម្លោះរវាងអាទិទេពពីរអង្គ ហើយបានអូសទាញសម្ព័ន្ធភាពមនុស្សពីរក្រុមផ្សេងគ្នាអោយចូលរួមចម្បាំងជំនួសខ្លួន ។

ក៏ដូចជាវប្បធម៌ផ្សេងទៀតដែរ ជនជាតិក្រិកក៏បានប្រើប្រាស់ទេវកថា ដើម្បីពន្យល់ពីអតីតកាល ។ ទេវកថាក្រិកខ្លះ បានពន្យល់លម្អិតពីការបង្កើតរដ្ឋបុរីនានា ខ្លះទៀតពន្យល់ពីមូលហេតុដែលនាំអោយមានសង្គ្រាម ។ ទេវកថាទាំងអស់នេះផ្តោតលើតួអង្គសំខាន់ ជាអាទិ៍ អាទិទេពអាសេណា (Athena) គឺជាអ្នកបង្កើតនិង កសាងរដ្ឋបុរីអាថែន (Athens) ។ ទេវកថាត្រូវប្រើក្នុងផ្នែកសាសនាផង៖ ដោយសារអាទិទេព អាសេណា ត្រូវគេចាត់ទុកថាជាអ្នកថែរក្សាការពារបុរីអាថែន ដូច្នេះ គេក៏ជឿ ដែរថា គ្មានអ្វីអកុសលកើតឡើងនៅទីនោះឡើយ ។ (*ចូរមើលវាសនារបស់បុរីអាថែនក្នុងសង្គ្រាមប៉េឡូប៉ូនេស៊ី*)

ប៉ុន្តែ ជនជាតិក្រិកបុរាណបានអភិវឌ្ឍសមត្ថភាពក្នុងការថ្លឹងថ្លែងហេតុផលផងដែរ ពោលគឺ ចេះត្រិះរិះពិចារណាហេតុផល ។ ពួកគេចេះថ្លឹងថ្លែងហេតុផលផងដែលផ្តោតលើផ្នែកអាណាចក្រឬផ្លូវលោក ច្រើនជាងមុន (ដោយមិនផ្តោតតែលើផ្នែកសាសនាចក្រឬផ្លូវធម៌អាថ៌ខាងក្នុង) ជាហេតុជំរុញអោយពួកគេកសាងស្ថាប័នប្រសើរជាងមុន ដោយមិនយោងទៅតាមបំណង ឬការទាមទាររបស់អាទិទេពឡើយ ។

សមត្ថភាពថ្មីក្នុងថ្លឹងថ្លែងហេតុផល ការរិះគិតប្រកបដោយហេតុផល ត្រូវអនុវត្តក្នុងផ្នែកប្រវត្តិសាស្ត្រដែរ ក្នុងនោះមានអ្នកប្រាជ្ញម្នាក់ ដែលត្រូវគេចាត់ទុកជា «បិតាប្រវត្តិសាស្ត្រ» នោះគឺ លោក ហេរ៉ូដូទឹស (Herodotus) ។

### ២.៣.១. លោក ហេរ៉ូដូទឹស

លោក ហេរ៉ូដូទឹស បានចាប់កំណើត នៅឆ្នាំ ៤៨៤ មុនគ.ស នាទីក្រុង ហេលីកាណាស៊ុស (Helicanassus) ត្រូវនឹងប្រទេសទួរគីសព្វថ្ងៃ ។ ក្នុងជីវិតរបស់គាត់ គាត់ធ្វើដំណើរច្រើន និងបានចំណាយពេលយូរនៅចំ ចំណុចប្រសព្វនៃជីវិតក្នុងចក្រភពក្រិក គឺ រដ្ឋបុរីអាថែន។

លោកហេរ៉ូដូទឹស បានសរសេរសៀវភៅចំនួន ៩ ក្បាល ដែលមានចំណងជើងរួមថា «ប្រវត្តិសាស្ត្រ» ។ ពាក្យ «ប្រវត្តិសាស្ត្រ» ផ្តើមចេញពីប្រភពនោះមក ប៉ុន្តែ នាសម័យនោះពាក្យថាប្រវត្តិសាស្ត្រ (Historia) មានន័យត្រឹមថា «ការចង់ដឹង» ឬ «ការស៊ើបអង្កេត» រកអ្វីមួយ មិនត្រឹមតែអតីតកាលនោះទេ ។ គាត់ចាប់អារម្មណ៍លើប្រធានបទដូចជាសង្គ្រាមរវាងក្រិកនិងពែក្ស ។

នៅក្នុងអារម្ភកថានៃសៀវភៅរបស់គាត់ លោកហេរ៉ូដូទឹសបានអះអាងថា គាត់សរសេរប្រវត្តិសាស្ត្រ ដើម្បី **«រក្សាសមិទ្ធិផលរបស់មនុស្ស»** ។ ច្បាស់ណាស់ថា ឃ្លានេះបញ្ជាក់ប្រាប់យើងថា អ្វីដែលលោកបានចងក្រងមានលក្ខណៈខុសពីទេវកថា ដែលភាគច្រើនផ្តោតតែលើអាទិទេព និងមនុស្សលោកខ្លះៗ គាត់ចង់អោយសមិទ្ធិផលដែលមនុស្សជំនាន់មុនបានធ្វើ មិនត្រូវបានគេបានបំភ្លេច ដូច្នេះ ប្រវត្តិសាស្ត្រត្រូវចារឡើងដើម្បីជាមធ្យោបាយធានាថាមនុស្សជំនាន់ក្រោយបានដឹងពីសមិទ្ធិផលទាំងនោះ ។

លោក ហេរ៉ូដូទឹស សម្អាងលើអ្វីដែលគាត់បានឃើញដោយផ្ទាល់ សម្រាប់សរសេរស្នាដៃ «ប្រវត្តិសាស្ត្រ» របស់គាត់ ។ ហេតុនេះហើយ គាត់បានត្រួសត្រាយផ្លូវសម្រាប់មុខវិជ្ជាប្រវត្តិសាស្ត្រដែលយើងនៅបន្តអនុវត្តរហូតដល់សព្វថ្ងៃ ។ តាមពិតទៅ គាត់បានធ្វើដំណើរទៅកាន់ទីកន្លែងប្រវត្តិសាស្ត្រជាច្រើនដើម្បីសង្កេតមើលទីតាំងភូមិសាស្ត្រ អគារវិមាននានា និងសិល្បៈ និងសង្កេតមើលមនុស្សដែលគាត់ជួបប្រទះ នៅទីកន្លែងទាំងនោះដើម្បីស្វែងរកតម្រុយថាតើមនុស្សពីអតីតកាលមានអាកប្បកិរិយាយ៉ាងដូចម្តេច ។ ចំពោះសាច់រឿងដែលគាត់មិនបានរកភស្តុងតាងបានដោយខ្លួនឯង ដូចជារឿងរ៉ាវដែលបានកើតពីអតីតកាលដល់យូរលង់ណាស់មកហើយ គាត់សម្ភាសសាក្សីនិងប្រភពព័ត៌មានផ្សេងៗ ដោយធ្វើជាប្រវត្តិសាស្ត្រផ្ទាល់មាត់ ។ តាមគំនិតលោក ហេរ៉ូដូទឹស ប្រវត្តិសាស្ត្រត្រូវអាស្រ័យលើអ្នកដំណាលប្រាប់ ដូច្នេះ គាត់តែងតែប្រាប់អ្នកអានអោយដឹងថា អ្នកណាជាអ្នកនិយាយប្រាប់ និងជាគំនិតរបស់អ្នកណាជាដើម ។ នៅក្នុងស្នាដៃរបស់គាត់ទាំងមូល យើងកត់សំគាល់ឃើញពាក្យ «*ជនជាតិពែក្សនិយាយថា*» ឬ «*ជនជាតិអេហ្ស៊ីបនិយាយថា*» ។ល។ នេះមានន័យថាគាត់កំពុងចុះប្រភពឯកសារយោងរបស់គាត់ ។ នេះគឺជាការបោះជំហានមួយយ៉ាងវែង ហេតុដូច្នេះបានជាគាត់ត្រូវគេស្គាល់ជា បិតាប្រវត្តិសាស្ត្រ ។ តាមរយៈការចុះប្រភពឯកសារយោង គាត់ផ្សារភ្ជាប់សំណេររបស់គាត់ទៅនឹងការពិត ដែលអាចនឹងត្រូវប្រវត្តិវិទូនាពេលអនាគតអាចផ្ទៀងផ្ទាត់បាន ។ វាក៏មានន័យផងដែរថា ប្រសិនបើប្រភពព័ត៌មានរបស់គាត់ណាមួយ មិនប្រាប់ពីការពិត អ្នកអានអាចដឹងថា អ្នកណាជាអ្នកភូតកុហក ដូច្នេះ គេនៅតែអាចជឿទុកចិត្តផ្នែកផ្សេងទៀត នៅក្នុងស្នាដៃរបស់គាត់ដដែល ។

លោក ហេរ៉ូដូទឹស មិនត្រឹមតែសរសេរពីអ្វីដែលបានកើតឡើង កាលពីអតីតកាលនោះទេ គាត់ថែមទាំងបានព្យាយាមវិភាគព្រឹត្តិការណ៍ទាំងនោះ និងស្វែងរកមូលហេតុ ដែលជារឿយៗ គាត់ងាកទៅចាប់អារម្មណ៍លើប្រធានបទ ការដាក់ទោសទណ្ឌ និងគំនុំសងសឹក និងអះអាងថា មហិច្ឆតាចង់សងសឹក គឺជាមូលហេតុមួយបណ្តាលអោយមានសង្គ្រាមរវាងក្រិកនឹងពែក្ស ជាញឹកញាប់ ។ លោក ហេរ៉ូដូទឹស ក៏ជឿថា ចរិកអំនួតជ្រុល ឬភាពក្អេងក្អាង ឬ មោទនភាពជ្រុលរបស់មនុស្ស បានបណ្តាលអោយអាទិទេពច្រណែន ។ តួអង្គមនុស្សណាដែលមានសំណាងខ្លាំងពេក ឬមានអំនួតលើខ្លួនឯងពេក នឹងត្រូវធ្លាក់ក្នុងមហន្តរាយដ៏ប្រល័យ ។ តួអង្គនោះអាចនឹងត្រូវគេធ្វើឃាត ឬ បង្កាត់ភ្នក់ភ្លើងសង្គ្រាមមួយទៀត ។ ប្រការនេះ យើងអាចនឹងដឹងថា លោក ហេរ៉ូដូទឹស ជឿជាក់ថា **អ្វីគ្រប់យ៉ាងដែលបានកើតឡើងពីអតីតកាលមានមូលហេតុផ្ទាល់របស់វា** ។ មូលហេតុឬដើមហេតុទាំងនេះហើយជាអ្វីដែលលោកព្យាយាមស្វែងរក ។ បើទោះយើងឥឡូវមិនសូវយល់ស្របនឹងមូលហេតុមួយចំនួន ដែលគាត់បានលើកឡើង, ប្រការដែលគាត់ជឿថា ដើមហេតុនៃព្រឹត្តការណ៍ប្រវត្តិសាស្ត្រអាចត្រូវបានគេរកឃើញ ហើយប្រវត្តិសាស្ត្រអាចត្រូវបានគេស្វែងយល់បានគឺជាការបោះជំហានមួយយ៉ាងវែង ។

យ៉ាងណាមិញ នៅក្នុងស្នាដៃរបស់គាត់ យើងក៏សង្កេតឃើញថា សាច់រឿងខ្លះអាចជារឿងនិទាន ឬទេវកថាផងដែរ ។ នេះបង្ហាញពីឥទ្ធិពលយ៉ាងខ្លាំងនៃទេវកថា នៅក្រិកបុរាណ ។ នេះគឺជារឿងរ៉ាវដែលគ្រប់គ្នាបានដឹង ហើយពេលខ្លះ វាជាសាច់រឿងតែមួយគត់ ដែលពួកគេអាចរកបាន ។ លោក ហេរ៉ូដូទឹស បានដឹងរឿងទាំងនេះ នៅពេលលោកធ្វើការសម្ភាសន៍ ស្រាវជ្រាវ និងបានដាក់បញ្ចូលវាទៅក្នុងស្នាដៃ«ប្រវត្តិសាស្ត្រ»របស់គាត់ ក្នុងនាមជាប្រភពឯកសារមួយផ្សេងទៀត ។

លោក ហេរ៉ូដូទឹស ត្រូវបានគេហៅថា «បិតាប្រវត្តិសាស្ត្រ» ប៉ុន្តែ គាត់មិនបានបង្កើតវិធីសាស្ត្រចុងក្រោយដែលយើងកំពុងប្រើប្រាស់សព្វថ្ងៃនេះទេ ។ សម្រាប់យើងបច្ចុប្បន្ន គាត់សរសេរពាក់កណ្តាលទេវកថា ពាក់កណ្តាលប្រវត្តិសាស្ត្រ ក្នុងនោះគាត់ព្យាយាមសរសេរចង់ក្រងអ្វីដែលពិតជាបានកើតឡើង និងប្រើប្រាស់ប្រភពឯកសារដើម្បី

បង្ហាញថា ព្រឹត្តិការណ៍ទាំងនោះ ពិតជាបានកើតឡើងមែន ។ ដោយឡែក គាត់នៅតែលាយឡំទិដ្ឋភាពខ្លះនៃទេវកថា និងប្រលោមលោក នៅក្នុងស្នាដៃរបស់គាត់ ។

## សម្រង់ស្នាដៃរបស់លោក ហេរ៉ូដូទីស[២] ៖ «ប្រវត្តិសាស្ត្រ»

១ ហេរ៉ូដូទីស មកពីក្រុងហេលីកាណាស៊ូស នៅទីនេះ នឹងបង្ហាញលទ្ធផល «ស៊ើបអង្កេត» របស់គាត់ ដើម្បីធានាថា សមិទ្ធផលរបស់មនុស្សលោកនឹងមិនត្រូវបានគេបំភ្លេចចោល នាពេលអនាគត ហើយសកម្មភាពដ៏ល្អប្រពៃថ្លៃថ្លា (ខ្លះប្រព្រឹត្តដោយជនជាតិក្រិក ខ្លះទៀតដោយមនុស្សព្រៃ) នឹងមិនត្រូវកប់ចោលក្នុងអតីតកាលទទេៗ ហើយជាពិសេសដើម្បីបង្ហាញពីមូលហេតុដែលនាំអោយក្រុមមនុស្សទាំងពីរនេះ មានទំនាស់ហើយឈានដល់សង្គ្រាមពុំរ៉ែជាមួយគ្នា ។

២ បណ្ដាអ្នកប្រាជ្ញជនជាតិពែក្ស បានចោទប្រកាន់ជនជាតិហ្វីនីសិន (Phoenician) ថាជាអ្នកបង្កសង្គ្រាម ។ ពួកហ្វីនីសិន មានដើមកំណើតចេញពីតំបន់ «សមុទ្រក្រហម» ។ ក្រោយពេលពួកគេត្រូវបានបង្ខំអោយចាកចេញទៅកាន់តំបន់សមុទ្រមេឌីទែរ៉ាណេនិងបានបង្កើតភូមិថ្មីនៅទីនោះ ហើយបានចាប់ផ្ដើមធ្វើសាគរពាណិជ្ជកម្មតាមផ្លូវឆ្ងាយៗ ។ ផ្ទុកពេញដោយទំនិញអេហ្សិប និង អាស៊ីរៀន (Assyrian) ពួកគេចូលសំចតក្នុងតំបន់ផ្សេងៗតាមឆ្នេរសមុទ្រនិងក្រុងកំពង់ផែអាហ្គូស៍ (Argos) ដែលជាកំពង់ផែល្បីជាងគេក្នុងប្រទេសក្រិក (Hellas) នាសម័យនោះ ។

៣ នៅកំពង់ផែអាហ្គូស៍ ពួកហ្វីនីសិនបានតាំងលក់ទំនិញរបស់ខ្លួន ហើយប្រហែលប្រាំទៅប្រាំមួយថ្ងៃក្រោយមក ជាពេលដែលទំនិញទាំងនោះលក់ដាច់ជិតអស់ មាននារីស្រស់សោភាជាច្រើនបានមកលេងឆ្នេរខ្សាច់ និងមើលការដាក់តាំងលក់ទំនិញ ។ ក្នុងចំណោមនារីទាំងនោះ មានម្នាក់ជាបុត្រីស្ដេច ដែលបណ្ដាអ្នកនិពន្ធជនជាតិក្រិក និងពែក្ស ហៅថា នាង អ៊ីយ៉ូ (Io) ដែលមានន័យថា បុត្រីរបស់ ស្ដេចអ៊ីណាជូស ។ ខណៈពេលដែលនារីទាំងនោះកំពុងឈរនៅក្បែរកន្សៃសំពៅ ទិញទំនិញដែលខ្លួនចូលចិត្ត ស្រាប់តែនាយសំពៅជនជាតិហ្វីនីសិន ខ្សឹបខ្សៀវគ្នា ហើយស្ទុះសំដៅមកចាប់ក្រុមនារីទាំងនោះ ។ ពួកនាងភាគច្រើនបានរត់គេចខ្លួន លើកលែងតែនាង អ៊ីយ៉ូ និងនារីមួយចំនួនទៀត ដែលត្រូវបានចាប់ខ្លួនយកទៅអេហ្សិប ។

៤ បើយោងតាមកំណត់ហេតុជនជាតិពែក្ស (ជនជាតិក្រិកមានការដំណើររឿងផ្សេងពីនេះ) នេះហើយជាដំណើរដើមទង ដែលនាង អ៊ីយ៉ូ បានទៅដល់អេហ្សិប ហើយនេះជារឿងដំបូងបង្អស់ ក្នុងចំណោមព្រឹត្តិការណ៍អយុត្តិធម៌ ខុសសីលធម៌ជាបន្តបន្ទាប់ ។

៥ ដំណាលក្រោយមកទៀត ជនជាតិក្រិកខ្លះ ដែលពួកពែក្សមិនបានកត់ឈ្មោះទុក (ពួកគេប្រហែលជាជនជាតិក្រិក នៅកោះក្រេតាន់) បានចូលសំចតនៅកំពង់ផែ ទៀរ៍ របស់ពួកហ្វីនីសិន ហើយបានលួចចាប់ជំរិតបុត្រីស្ដេច ព្រះនាង អឺរ៉ូប៉ា (Europa) ។ ការសងសឹកទៅវិញទៅមកក៏បានចាប់ផ្ដើមតាំងពីពេលនោះមក ។

៦ ការបំពានលើកក្រោយមកទៀត គឺជាអំពើបង្កដោយពួកក្រិកដដែល ។ ពួកគេបានបញ្ជូនអ្នកជំនួញប្រដាប់ដោយអាវុធចូលទៅតំបន់អៀ (Aea) ក្នុងក្រុងកុលឈីស (Colchis) តាមដងទន្លេផាលស៊ីស (Phalsis) ។ ដោយ

[២] ដកស្រង់ចេញពីសៀវភៅបកប្រែជាភាសាអង់គ្លេសដោយ (Marincola, Herodotus: The Histories, ២០០៣) ទំព័រទី ៣ ដល់ ៤ ។

មិនសប្បាយចិត្តនឹងជំនួញរបស់ខ្លួននៅទីនោះ ពួកគេបានចាប់ពង្រត់បុត្រីស្ដេច ឈ្មោះនាង មេឌៀ (Medea) ។ ព្រះអង្គបានបញ្ជូនទូតទៅក្រិកដោយទាមទាអោយមានសំណង់ការខូចខាត និងបញ្ជូនបុត្រីមកវិញ ។ ប៉ុន្តែ ការឆ្លើយតបដែលព្រះអង្គទទួលបានគឺថា ក្រិកគ្មានបំណង់សងការខូចខាតនោះទេ ដោយហេតុថា ពួកគេផ្ទាល់មិនបានទទួលសំណងពីការចាប់ជម្រិតព្រះនាង អ៊ីយ៉ូ ពីកំពង់ផែអាហ្គូសដែរ ។

៧ កំណត់ហេតុនេះបានបន្តពណ៌នាថា ៤០ ឬ ៥០ ឆ្នាំក្រោយមក ព្រះអង្គម្ចាស់ ប៉ារីស៍ ដែលជាបុត្រានៃស្ដេចព្រីអាម ហើយដែលបានជម្រុញទឹកចិត្តដោយសាររឿងទាំងអស់ខាងលើ បានទៅចាប់ពង្រត់យកមហេសីម្នាក់ពីប្រទេសក្រិក ដោយជឿជាក់ថា ព្រះអង្គនឹងមិនប្រឈមមុខនឹងទោសទណ្ឌឡើយ ព្រោះថា ពួកក្រិកធ្លាប់បានប្រព្រឹត្តអំពើនេះមុន ។ នេះហើយជាមូលហេតុដែលព្រះអង្គចេញទៅចាប់ជម្រិតយកនាងអេឡែន (Helen) ៕

## សំណួរពិភាក្សា

១. តើព្រឹត្តិការណ៍ទាំងអស់ខាងលើ(៧កថាខ័ណ្ឌ) បានកើតឡើងនៅឆ្នាំណា?

២. តើលោកហេរ៉ូដូទឹស បានសរសេរស្នាដៃ«ប្រវត្តិសាស្ត្រ»របស់គាត់ដើម្បីអ្វី?

៣. តើនរណាលក់ទំនិញអេហ្ស៊ីបនិងអាស៊ីរៀន នៅកំពង់ផែអាហ្គូស?

៤. តើមាននារីប៉ុន្មាននាក់ត្រូវចាប់ពង្រត់ តាមរយៈអត្ថបទខាងលើ? នរណាខ្លះ?

៥. ចូរស្វែងរកមូលហេតុនិងផលវិបាកនៃអំពើចាប់ពង្រត់ទាំងនោះ ។

៦. តើលោកហេរ៉ូដូទឹសបានប្រភពឯកសារមក ពីណាសម្រាប់«ប្រវត្តិសាស្ត្រ»របស់គាត់?

៧. តើអ្នកគិតថា ហេតុអ្វីបានជាលោកហេរ៉ូដូទឹស មិនយកប្រភពឯកសារក្រិក ដើម្បីពន្យល់ពីការមកដល់អេហ្ស៊ីបរបស់ព្រះនាងអ៊ីយ៉ូ?

## ហេតុអ្វីបានជាលោក ហេរ៉ូដូទឹស ត្រូវបានគេចាត់ទុកជាបិតាប្រវត្តិសាស្ត្រ[៣]?

ស្រមោចយក្សជីកមាស, ស្ដេចខ្លាល់ខ្លាំងពេក បញ្ជាអោយបាចទឹកសមុទ្រ រំពាត់ ៣០០ ដង, និងត្រីផ្សោតដែលបានជួយស្រង់ជីវិតកវីដ៏ល្បីផុតពីការលង់ទឹកស្លាប់, ទាំងអស់នេះគ្រាន់តែជារឿងរ៉ាវមួយចំនួន នៅក្នុងស្នាដៃ «ប្រវត្តិសាស្ត្រ» ដោយ លោក ហេរ៉ូដូទឹស (Herodotus) អ្នកនិពន្ធជនជាតិក្រិក តាំងពីសតវត្សទី ៥ មុនគ.ស. មកម្លេះ ។ មិនមែនព្រឹត្តិការណ៍ទាំងអស់ក្នុងអត្ថបទនេះ បានកើតឡើងដូចដែល ហេរ៉ូដូទឹសបានរៀបរាប់នោះទេ ប៉ុន្តែស្នាដៃដ៏ល្បីល្បាញរបស់គាត់បានផ្លាស់ប្ដូរវិធីសាស្ត្រ ដែលអតីតកាលត្រូវបានគេកត់ត្រាទុក ។

មុនសម័យហេរ៉ូដូទឹស អតីតកាលត្រូវបានកត់ត្រាជា បញ្ជីឬកម្រងព្រឹត្តិការណ៍ អមដោយការព្យាយាមពន្យល់តិចតួច ឬគ្មានទាល់តែសោះ ក្រៅពីពន្យល់ថា មូលហេតុនៃព្រឹត្តិការណ៍ទាំងនោះកើតឡើងដោយសារឆន្ទៈរបស់ព្រះ ។ ហេរ៉ូដូទឹសចង់ស្វែងយល់ដឹងអោយបានស៊ីជម្រៅ និងសមហេតុផលជាងនេះ ។ ដូច្នេះ គាត់បានប្រកាន់យកគោលការណ៍ថ្មី ៖ សង្កេតមើលព្រឹត្តិការណ៍ណាមួយពីគោលជំហរនៃភាគីទាំងសង្ខាង ដើម្បីយល់ពីមូលហេតុរបស់ពួកគេនីមួយៗ ។ ថ្វីបើគាត់ជាជនជាតិក្រិច ស្រុកកំណើតរបស់ហេរ៉ូដូទឹស ដែលស្ថិតនៅ ហាលីកាណាស្ស៊ុស

[៣] (Robinson, ២០២១)

(Halicarnassus) គឺជាផ្នែកមួយនៃចក្រភពពែក្ស ។ គាត់បានធំដឹងក្តីឡើង ក្នុងកំឡុងពេលមានសង្គ្រាមជាញឹកញាប់ រវាងជនជាតិពែក្ស ដែលមានវិសាលភាពធំជាងនិងឥទ្ធិពលខ្លាំងជាង ជាមួយនឹងជនជាតិក្រិកដែលតូចជាងឆ្ងាយណាស់, ហើយបានសម្រេចចិត្តស្វែងរកអ្វីគ្រប់យ៉ាង ដែលគាត់អាចធ្វើបាន ស្តីអំពីប្រធានបទនេះ ។

តាមការពិពណ៌នារបស់ហេរ៉ូដូទឹស សង្គ្រាមពែក្សបានចាប់ផ្តើមនៅឆ្នាំ ៤៩៩ មុនគ.ស. នៅពេលបុរីអាថែនបានជួយជ្រោមជ្រែងការបះបោររបស់ជនជាតិក្រិក ដែលកំពុងរស់នៅក្រោមការគ្រប់គ្រងរបស់ពែក្ស ។ នៅឆ្នាំ ៤៩០ មុនគ្រឹស្តសករាជ ស្តេចពែក្ស ព្រះនាម ដារីយុស (Darius) បានបញ្ជូនកងទ័ពទៅវាយសងសឹក ទុកជាការព្រមានដល់បុរីអាថែន ។ ប៉ុន្តែ នៅឯសមរភូមិ ម៉ារ៉ាតុង កងទ័ពអាថែនបានទទួលជ័យជម្នះ ដោយមិនបានរំពឹងទុក ។

ដប់ឆ្នាំក្រោយមក កងទ័ពពែក្ស បានត្រឡប់មកសារជាថ្មី ដោយមានផែនការវាយក្តោបយកឈ្នះប្រទេសក្រិកទាំងមូល ក្រោមការដឹកនាំរបស់បុត្រាស្តេច ដារីយុស, ព្រះនាម ហ្សឺក្ស៊ីស (Xerxes) ។ បើយោងតាមលោក ហេរ៉ូដូទឹស នៅពេលស្តេច ហ្សឺក្ស៊ីស មកដល់, កងទ័ពរាប់លាននាក់របស់ទ្រង់ត្រូវពើបប្រទះនឹងការវាយទប់ទល់របស់កងកម្លាំងក្រិក ក្រោមការដឹកនាំដោយបុរីស្ប៉ាតា ប្រមាណ ៣០០ នាក់ នៅច្រកភ្នំដ៏តូចចង្អៀតមួយ ទែម៉ូពីលែ (Thermopylae) ។

កងទ័ពនិងស្តេចស្ប៉ាតា ព្រះនាម លីអូនីដាស(Leonidas) ត្រូវបានសម្លាប់ ក្រោយវាយទប់និងកាប់សម្លាប់កងទ័ពពែក្សយ៉ាងច្រើនសន្ធឹកសន្ធាប់។ ការពលីដ៏អង់អាចក្លាហាននេះ បានបំផុសស្មារតីតស៊ូប្រយុទ្ធរបស់ជនជាតិក្រិកនៅបុរីដទៃទៀត ។ ប៉ុន្មានសប្តាហ៍ក្រោយមក កងទ័ពជើងទឹកក្រិកបានបោកបញ្ឆោតកងនាវាពែក្សអោយដេញតាម និងចូលទៅប្រយុទ្ធគ្នា នៅក្នុងច្រកដៃសមុទ្រតូចចង្អៀតមួយ នៅជិតក្រុងអាថែន ។ កងទ័ពពែក្សត្រូវបរាជ័យ ស្តេចពែក្សក៏នាំទ័ពដកថយ គ្មានថ្ងៃត្រលប់មកវិញឡើយ ។

ដើម្បីពន្យល់ពីមូលហេតុបណ្តាលអោយសង្គ្រាមទាំងនេះបានផ្ទុះឡើង ក៏ដូចជាមូលហេតុបណ្តាលអោយក្រិកទទួលជ័យជំនះ, លោក ហេរ៉ូដូទឹស បានប្រមូលរឿងពីគ្រប់ទិសទី ក្នុងតំបន់មេឌីទែរ៉ាណេ ។ គាត់បានកត់ត្រានូវសមិទ្ធិផល ឬ សកម្មភាពរបស់ជនជាតិក្រិក និង របស់ជនជាតិផ្សេងក្រៅពីក្រិក មុនពេលវាត្រូវសាត់បាត់បងតាមពេលវេលា ។ សៀវភៅ «ប្រវត្តិសាស្ត្រ» របស់គាត់ បានបើកទំព័រដើមដំបូង ដោយប្រយោគដ៏ល្បីល្បាញ៖ «ហេរ៉ូដូទឹស មកពីក្រុងហេលីកាណាស៊ីស នៅទីនេះ នឹងបង្ហាញលទ្ធផល «ស៊ើបអង្កេត» របស់គាត់។» ដោយចងក្រងសៀវភៅនោះជា«ការស៊ើបអង្កេត» លោក ហេរ៉ូដូទឹស បានអនុញ្ញាតអោយវាមានសាច់រឿងជាច្រើនផ្សេងៗគ្នា ។ រឿងខ្លះមានភាពប្រាកដប្រជា និងសមទំនង ខ្លះទៀតមិនសូវប៉ុន្មានទេ ។ គាត់បានកត់ត្រាការពិភាក្សាជជែកវែកញែកផ្ទៃក្នុង ក្នុងរាជវាំងពែក្ស ប៉ុន្តែ ក៏មានរឿងនិទានស្តីពីពស់អេហ្ស៊ីបចេះហោះ និងវិធីសាស្ត្រដាក់ស្លែងសម្រាប់ចាប់ក្រពើផងដែរ ។ ពាក្យក្រិកសម្រាប់វិធីសាស្ត្រស្រាវជ្រាវបែបនេះ គឺ «ការធ្វើកោសល្យវិច័យ» ជាភាសាអង់គ្លេស autopsy ដែលអាចមានន័យថា «ការសង្កេតដោយខ្លួនឯងផ្ទាល់» ។

លោក ហេរ៉ូដូទឹស គឺជាអ្នកនិពន្ធដំបូងគេ ដែលបានពិនិត្យមើលអតីតកាលដោយបញ្ចូលភស្តុតាងជាក់ស្តែងនានាដែលគាត់ប្រមូលបាន៖ ព័ត៌មានបានពីសាក្សីឃើញផ្ទាល់ភ្នែក ជាភាសាក្រិកបុរាណថា opsis, និងពាក្យចចាមអារាម ជាភាសាក្រិកបុរាណថា akoe និង (រឿងរ៉ាវ)ប្រពៃណី ជាភាសាក្រិកបុរាណថា ta legomena ។ បន្ទាប់មកគាត់បានប្រើការថ្លឹងថ្លែង ហេតុផល ជាភាសាក្រិកបុរាណថា gnome ដើម្បីទាញសេចក្តីសន្និដ្ឋានរួមមួយ អំពីហេតុការណ៍ដែលបានកើតឡើងពិតៗ ។ អ្នកអានដំបូងៗរបស់សៀវភៅនេះ មែនទែនទៅ ភាគច្រើនគឺជាអ្នកស្តាប់

ពោលអង្គុយជុំគ្នា ហើយមានគេអានកោកអោយស្តាប់ បានលឺនិងបានដឹងទាំងអស់គ្នា។ ដើមដំបូង «ប្រវត្តិសាស្ត្រ» ត្រូវបានចងក្រង ដោយបែងចែកជា ២៨ ផ្នែក ដែលផ្នែកនីមួយៗត្រូវចំនាយពេលអានកោកៗ ប្រហែលបួនម៉ោង ។

នៅពេលប្រទេសក្រិកពង្រីកឥទ្ធិពលនិងអំណាចរបស់ខ្លួនកាន់តែខ្លាំងឡើងៗ, ទ្រឹស្តី និងវិធីសាស្ត្រសរសេរប្រវត្តិសាស្ត្ររបស់ហេរ៉ូដូទឹស ក៏បានរីករាលដាល នៅទូទាំងតំបន់ជុំវិញសមុទ្រមេឌីទែរ៉ាណេ ។ ក្នុងនាមជាប្រវត្តិវិទូពិតប្រាកដដំបូង លោក ហេរ៉ូដូទឹស ពិតជាមិនល្អឥតខ្ចោះនោះទេ ។ ( *មិនខុសអីពីទូរស័ព្ទដែលត្រូវបានបង្កើតដំបូងដោយលោក អាឡិចសង់ឌ័រ ហ្គ្រាហាម មិនល្អ មានមុខងារច្រើនដូចទូរស័ព្ទទំនើបស៊េរីចុងក្រោយឡើយ*)។ ជាក់ស្តែង យើងសង្កេតឃើញថា ក្នុងករណីខ្លះ គាត់ហាក់កាន់ជើង ជនជាតិក្រិកជាងជនជាតិពែក្ស និងធាប់ជឿលើរឿងខ្លះដែលគាត់គ្រាន់តែបានលឺគេនិយាយតៗគ្នា ដែលផ្អែកលើព័ត៌មានមិនត្រឹមត្រូវ ។ ទោះយ៉ាងណា ភស្តុតាងដែលគាស់កកាយឃើញនៅសម័យក្រោយៗ ពិតជាបានពន្យល់និងគាំទ្រអំណះអំណាងចម្រូងចម្រាស់ នៅក្នុងស្នាដៃរបស់គាត់ ។ ជាឧទាហរណ៍ មានសត្វកំប្រុកមួយប្រភេទនៅភ្នំហិម៉ាឡាយ៉ាដែលបញ្ចេញកំទេចមាស ពេលវាកាយដី ។ ក្នុងភាសាពែក្សបុរាណ ពាក្យ «marmot» (កំប្រុក) មានសូរប្រហែលនឹងពាក្យដែលប្រែថា ស្រមោច ។ ដូច្នេះ លោក ហេរ៉ូដូទឹស ប្រហែលជាជនរងគ្រោះដោយកំហុសនៃការបកប្រែ ។

ជាការកត់សម្គាល់រួម សម្រាប់អ្នកដែលបានចាប់ផ្តើមសរសេរវិធីសាស្ត្រមួយ ថ្មីទាំងស្រុង លោកហេរ៉ូដូទឹស ពិតជាបានបញ្ចេញថ្វីដៃយ៉ាងល្អគួរអោយកត់សម្គាល់ខ្លាំងណាស់ ។ ប្រវត្តិសាស្ត្រ រហូតមកដល់បច្ចុប្បន្ននេះ តែងតែទទួលរងនូវភាពលំអៀង និងកំហុសនៃប្រវត្តិវិទូ ។ វិធីសាស្ត្រនិងភាពច្នៃប្រឌិតរបស់លោកហេរ៉ូដូទឹស បានធ្វើអោយគាត់ត្រូវបានប្រសិទ្ធិនាមថាជា «**បិតាប្រវត្តិសាស្ត្រ**» ដោយអ្នកនិពន្ធជនជាតិរ៉ូម៉ាំង ឈ្មោះ ស៊ីសេរ៉ូ នាប៉ុន្មានរយឆ្នាំក្រោយមក ។

## ២.៣.២. លោក ស៊ូស៊ីឌីឌីស

ប្រសិនបើលោកហេរ៉ូដូទឹសជាបិតាប្រវត្តិសាស្ត្រនោះ លោក ស៊ូស៊ីឌីឌីស (Thucydides) គឺជាអ្នកអនុវត្តផ្ទាល់ដំបូងបង្អស់ ។ លោកបានចាប់កំណើត ឆ្នាំ ៤៦០ មុនគ្រឹស្តសករាជ និងស្លាប់ក្នុងឆ្នាំ ៤០៤ មុនគ្រឹស្តសករាជ។ លោកបានរស់នៅក្រុងអាថែន និងបានកាន់តួនាទីជាមេបញ្ជាការកងទ័ពជើងទឹក ក្នុងសម័យសង្គ្រាម ។ លោកមិនបានជោគជ័យក្នុងបេសកកម្មនោះទេ ដែលជាហេតុបណ្តាលអោយ គាត់ត្រូវគេនិរទេសខ្លួនអស់រយៈពេល ២០ ឆ្នាំ ។ កំឡុងពេលនោះ គាត់បានសរសេរស្នាដៃប្រវត្តិសាស្ត្ររបស់គាត់ ។

ខុសពី«ប្រវត្តិសាស្ត្រ»របស់លោកហេរ៉ូដូទឹស ប្រវត្តិសាស្ត្ររបស់លោកស៊ូស៊ីឌីឌីស បានពិពណ៌នាយ៉ាងលម្អិតអំពីព្រឹត្តិការណ៍ដែលលោកបានឆ្លងកាត់ផ្ទាល់ ។ វារៀបរាប់ពីសង្គ្រាមប៉េឡូប៉ូនេស៊ី និងជាការព្យាយាមរបស់ស៊ូស៊ីឌីឌីសក្នុងការចង់ក្រងប្រវត្តិសាស្ត្រ«ពិត»ជាក់ស្តែង ។ បទពិសោធន៍របស់លោកក្នុងសង្គ្រាមបានក្លាយជាប្រភពឯកសារមួយដ៏សំខាន់ ។ លើសពីនេះទៅទៀតគាត់ក៏បានសម្ភាសសាក្សីរស់ផងដែរ ។

ខុសពីលោក ហេរ៉ូដូទឹស, លោក ស៊ូស៊ីឌីឌីស ទទួលស្គាល់ថា រឿងដែលសាក្សីប្រាប់មិនសុទ្ធតែជាការពិតទាំងអស់នោះទេ ពោលគឺ រឿងខ្លះដែលគាត់ទទួលបានពិតជាមិនត្រឹមត្រូវឡើយ ហើយសាក្សីទាំងអស់ក៏មិនអាចជឿជាក់ទាំងស្រុងផងដែរ ។ ផ្ទុយទៅវិញ លោកស៊ូស៊ីឌីឌីស បានបន្ថែមបច្ចេកទេសមួយទៀតសម្រាប់គិត និងវិភាគលើប្រភពព័ត៌មានរបស់គាត់ ។ គាត់ប្រើតែប្រភពព័ត៌មានដែលអាចផ្ទៀងផ្ទាត់បាន ហើយក្នុងករណីមិនអាច គាត់

នឹងព្យាយាមវិភាគជាមុនសិន ដើម្បីអោយដឹងថា តើប្រភពព័ត៌មានរបស់គាត់ មានភាពលម្អៀងត្រង់ណា ហើយទាត់ចោលអ្វីដែលជារឿងមិនពិត ។

ចុងបញ្ចប់ លោកស៊ូស៊ីឌីឌីស កម្រិតព្រំដែននៃប្រធានបទសរសេរផងដែរ ។ គាត់សរសេរតែអំពីរឿងដែលគាត់ដឹង ធ្វើដូច្នេះគាត់អាចជៀសវាងមិនសរសេររឿងប្រឌិតឬរឿងនិទាន ។ ដូច្នេះគាត់សរសេរតែអំពីសម័យកាលដែលគាត់រស់នៅ និងស្វែងយល់បាន និង មិនសរសេរពីអតីតកាលដ៏យូរលង់ណាស់មកហើយ ដូចលោកហេរ៉ូដូទឹសឡើយ ។

ដោយផ្អែកលើលោក ហេរ៉ូដូទឹស និងលោក ស៊ូស៊ីឌីឌីស ក្រិកបុរាណបានកំណត់ក្បួនខ្នាតជាគំរូសម្រាប់សរសេរប្រវត្តិសាស្ត្រ ដែលយើងបានដឹងរហូតដល់សព្វថ្ងៃ ៕

ចូរអាននិងវិភាគសំរង់ស្នាដៃប្រវត្តិសាស្ត្រលោកស៊ូស៊ីឌីឌីស ថាតើវាមានលក្ខណៈដូចម្តេចខ្លះ។

## សង្គ្រាមប៉េឡូប៉ូនេស៊ី ៖ រដ្ឋក្រិកពីសម័យដំបូងដល់ការចាប់ផ្តើមសង្គ្រាម[៤]

### សេចក្តីផ្តើម

១ ស៊ូស៊ីឌីឌីស ជាពលរដ្ឋអាថែនមួយរូប បានចងក្រងប្រវត្តិសាស្ត្រនៃសង្គ្រាមរវាងអ្នកតំបន់ប៉េឡូប៉ូនេស៊ី (Peloponnesians) នឹងអ្នកក្រុងអាថែន (Athenians) ដោយចាប់ផ្តើមពីខណៈពេលដែលវាបានផ្ទុះឡើងដំបូង, និងដោយជឿថា វា[នឹងក្លាយ]ជាមហាសង្គ្រាម សែនធំធេង ជាងសម័យមុនៗទាំងអស់ និងមានសារៈសំខាន់ គួរអោយចងក្រងទុក ។ ជំនឿនេះមិនមែនគ្មានមូលដ្ឋាននោះទេ ។ ការត្រៀមរបស់កងទ័ពប្រយុទ្ធគ្រប់ផ្នែក នៃភាគីទាំងសង្ខាង ឈានដល់កម្រិតកំពូល ត្រៀមបានយ៉ាងល្អឥតខ្ចោះបំផុត, ហើយអ្នកដែលជាពូជសាសន៍ក្រិកទាំងអស់ បានចូលដៃជាមួយភាគីណាមួយ នៅក្នុងជម្លោះនេះ, ចំណែកអ្នកដែលពន្យាពេលមិនទាន់ចូលភ្លាមៗ ក៏កំពុងពិចារណាយ៉ាងដិតដល់ ។ ជាការពិត នេះគឺជាខណៈពេលដ៏អស្ចារ្យបំផុត ដែលគេមិនធ្លាប់ជួបប្រទះនៅក្នុងប្រវត្តិសាស្ត្រ មិនត្រឹមតែសម្រាប់ជនជាតិក្រិកប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ពិភពលោកដែលមាន មនុស្សព្រៃរស់នៅ ផងដែរ- ខ្ញុំសឹងតែនិយាយថា សម្រាប់មនុស្សជាតិទាំងមូលហើយ ។ បើទោះជាព្រឹត្តិការណ៍ក្នុងសម័យបុរាណដ៏យូរលង់មកហើយ (សូម្បីតែហេតុការណ៍មុនសង្គ្រាមថ្មីៗមួយចំនួន) មិនអាចត្រូវបានគេដឹងច្បាស់នៅឡើយ ដោយសារពេលវេលាកន្លងហួសយូរណាស់ទៅហើយ ប៉ុន្តែ ភស្តុតាងទាំងឡាយ ដែលការស៊ើបអង្កេតអាចរកបាន ពីក្នុងពេលដ៏យូរ តាមតែអាចធ្វើទៅបាន បានបណ្តាលអោយខ្ញុំជឿទុកចិត្តហើយឈានដល់ការសន្និដ្ឋានមួយថា ទោះនិយាយពីសង្គ្រាម ឬបញ្ហាអ្វីផ្សេងទៀត មិនមានអ្វីធំជាង(មហាសង្គ្រាម)នេះឡើយ ។

២ ជាឧទាហរណ៍ ច្បាស់ណាស់ដែលប្រទេស ឥឡូវត្រូវបានហៅថា ប្រទេសក្រិក កាលពីសម័យបុរាណ មិនមានប្រជាជនមកតាំងលំនៅ នៅឡើយយូរលង់ទេ ។ ផ្ទុយទៅវិញអន្តោប្រវេសន៍បានហូរចូលមកទឹកដីនេះជាញឹកញាប់ ម្លោះហើយ កុលសម្ព័ន្ធជាច្រើន បានបង្ខំចិត្តបោះបង់ទីលំនៅរបស់ខ្លួន ដោយសារសម្ពាធនៃកំណើនប្រជាជនដែលខ្លាំងជាងខ្លួន [ខ្ពង់ខ្ពស់ជាងខ្លួន] ។ ដោយគ្មានទំនាក់ទំនងពាណិជ្ជកម្ម, ដោយមិនមានសេរីភាពក្នុង

[៤] ដកស្រង់ចេញពីសៀវភៅបកប្រែជាភាសាអង់គ្លេសដោយ (Crawley, ២០១៣)ចំណងជើង ប្រវត្តិសាស្ត្រនៃសង្គ្រាមប៉េឡូប៉ូនេស៊ី ទំព័រទី ៦ ដល់ ១៦ ។

ការប្រាស្រ័យទាក់ទង ទោះតាមផ្លូវគោកក្តី ឬសមុទ្រក្តី, ពួកគេចាំបាច់ត្រូវដាំដំណាំ មិនអោយលើសពីតម្រូវការសម្រាប់រស់នៅផ្ទាល់ខ្លួនឡើយ, ម្យ៉ាងដោយសារកង្វះដើមទុន, ហើយម្យ៉ាងទៀត ពួកគេមិនប្រាកដថា នៅពេលណាមានអ្នកក្រៅមកឈ្លានពាន ហើយឆក់ប្លន់អ្វីខ្លះពីពួកគេទេ, អ្វីដែលកាន់តែធ្ងន់ធ្ងរ ពួកគេគ្មានជញ្ជាំងឬកំពែងការពារទេ បើសិនមានការឈ្លានពានមែន), ដោយគិតថា តម្រូវការចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ អាចត្រូវបានផ្គត់ផ្គង់ នៅកន្លែងណាមួយ ក៏ដូចជាកន្លែងណាមួយផ្សេងទៀត, ពួកគេមិនសូវខ្វល់ខ្វាយអំពីការផ្លាស់ប្តូរទីលំនៅរបស់ខ្លួន ដូច្នោះហើយក៏មិនបានកសាងទីក្រុងធំៗ ឬក៏កសាង សមិទ្ធិផលអស្ចារ្យផ្សេងទៀតដែរ ។ ផ្ទៃដីដែលមានជីជាតិជាងគេ តែងតែផ្លាស់ប្តូរម្ចាស់ជារឿយៗ ដូចជាស្រុកដែលឥឡូវនេះត្រូវបានគេហៅថា ទីក្រុងថេសាលី (Thessaly), ប៊ីអូសៀ (Boeotia), ដីមួយភាគធំក្នុងតំបន់ប៉េឡូប៉ូនេស៊ី (Peloponnese) លើកលែងតែផ្នែកអាកាឌៀ (Arcadia) និង តំបន់ដែលមានជីជាតិបំផុតផ្សេងទៀតក្នុងប្រទេសក្រិក ។ ភាពអំណោយផលនៃផ្ទៃដីនេះបានអនុគ្រោះដល់ការពង្រីកអំណាចរបស់បុគ្គលណាម្នាក់ ដូច្នោះហើយបង្កើតជាការបែងចែកតំបន់នានា ដែលឆ្លុះបញ្ចាំងពីប្រភពបែកបាក់ផងដែរ ។ វាក៏បានទាក់ទាញឈ្លានពានពីក្រៅផងដែរ ។ ផ្ទុយទៅវិញ តំបន់អាទីកា (Attica) ដោយសារផ្ទៃដីមិនសូវមានជីជាតិ ហាក់សប្បាយនឹងសេរីភាព មួយរយៈពេលខ្លី គ្មានការបែងចែក, មិនដែលផ្លាស់ប្តូរអ្នកតាំងលំនៅឡើយ ។ ហើយនៅទីនេះ មិនមែនជាឧទាហរណ៍(ដែលមិនគួរអោយជឿ)នៃការអះអាងរបស់ខ្ញុំដែលថា ការធ្វើចំណាកស្រុក គឺជាមូលហេតុដែលតំបន់នេះមិនមានការរីកចម្រើន ដូចនៅតំបន់ផ្សេងទៀត ។ ជនរងគ្រោះធ្ងន់ធ្ងរបំផុតដោយសារសង្គ្រាម ឬដោយសារការបែងចែកបក្ស ពីតំបន់ដទៃទៀតក្នុងប្រទេសក្រិក បានចូលទៅជ្រកកោនជាមួយពលរដ្ឋអាថែន ដែលជាទីសុវត្ថិភាពចុងក្រោយ ហើយ ត្រូវបានដាក់អោយចូលជាពលរដ្ឋអាថែនភ្លាម និងបានធ្វើអោយក្រុងអាថែន ដែលមានចំនួនប្រជាជនច្រើនណែនណាន់តាន់តាប់រួចស្រាប់ហើយអោយកាន់កើនកកកុញកាន់តែច្រើនថែមទៀត រហូតតំបន់អាទីកា មិនអាចទទួលយកពួកគេបាន ហើយត្រូវបញ្ជូនពួកគេទៅកាន់ដែនដីអាណានិគម អ៊ីយ៉ូណៀ ។

៣ ក៏មានកាលៈទេសៈផ្សេងទៀត ដែលបានរួមចំណែកមិនតិចទេ ក្នុងការពង្រឹងជំនឿរបស់ខ្ញុំ ស្តីពីភាពទន់ខ្សោយ នៅសម័យបុរាណ ។ មុនពេលសង្គ្រាម កាដូសេះឈើ ត្រូជិន(Trojan) មិនមានការចង្អុលបង្ហាញអំពីសកម្មភាពរួមណាមួយ នៅក្នុងប្រទេសក្រិកនោះទេ ហើយក៏មិនមានសកម្មភាពទូទៅ ជាសាកលលោកដែរ ។ ផ្ទុយទៅវិញ មុនរជ្ជកាលស្តេចហេឡិន (Hellen) ដែលជាបុត្រារបស់ឌីខេលៀន (Deucalion) មិនមានឈ្មោះ[ប្រទេស]បែបនេះទេ ប៉ុន្តែប្រទេសនេះបានផ្លាស់ប្តូរឈ្មោះទៅតាមកុលសម្ព័ន្ធផ្សេងគ្នា ជា ពិសេស តាមពួកផេឡាសជៀន (Pelasgian) [ដែលរស់នៅតាមឆ្នេរសមុទ្រ អេចៀន] ។ [ប្រទេសក្រិក]មិនទាន់កើតឡើង រហូតដល់សម័យកាលស្តេច ហេឡិន និងបុត្រា បានពង្រីកអំណាចយ៉ាងខ្លាំង នៅ ក្រុងផ្ទីអូទីស (Phtiotis) និងត្រូវបានយាងទៅធ្វើជាសម្ព័ន្ធមិត្ត នៅបុរីដទៃទៀត ហើយបន្តិចម្តងៗ ផ្តើមចេញពីទំនាក់ទំនងនេះ បុរីនីមួយៗ បានទទួលយកឈ្មោះ ហេឡេន (ក្រិកបុរាណ) ហើយពេលវេលាកន្លងហួសទៅ ឈ្មោះនេះក៏ចារិកនៅជាប់រហូតមក ។ ភស្តុតាងដ៏ល្អបំផុតសម្រាប់បញ្ជាក់ដំណើរនេះ ត្រូវបានដុសខាត់ដោយកវីនិពន្ធដ៏ល្បីល្បាញ អូម៉ែរ (Homer) ។ ដោយកើតនៅក្រោយសង្គ្រាមត្រូជិនជាច្រើនឆ្នាំ គាត់មិនដែលហៅពួកគេទាំងអស់នោះ ដោយប្រើឈ្មោះនោះទេ ហើយពួកគេផ្ទាល់ក៏ហៅខ្លួនឯងអញ្ចឹងដែរ លើកលែងតែពួកអ្នកគាំទ្រ អាគីលីស(Achilles) ពីតំបន់ ផ្ទីអូទីស (Phthiotis) ដែលជាជនជាតិ ហេឡេនដើម (ក្រិក) ។ នៅក្នុងកំណាព្យរបស់គាត់ ពួកគេត្រូវហៅថា ដាណាន(Danaans) អាហ្គៀវ(Argives) និងអាខេន(Achaeans) ។ គាត់ក៏មិនបានប្រើពាក្យ មនុស្សព្រៃ ដែរ ដោយសារតែជនជាតិក្រិក មិនទាន់មានលក្ខណៈរួមតែមួយ ហើយក៏មិនទាន់ ត្រូវបានគេស្គាល់ដោយឈ្មោះតែមួយ នៅទូទាំងពិភពលោកដែរ ។ ច្បាស់ណាស់ថា សហគមន៍ក្រិកមួយចំនួន (ដែលរួមបញ្ចូល មិនត្រឹមតែសហគមន៏ដែលទទួលយកឈ្មោះ

នេះ ដំបូងគេ ក្រុងមួយហើយបន្តទៅក្រុងមួយទៀត នៅពេលដែលពួកគេនិយាយយល់គ្នា ប៉ុន្តែថែមទាំងរួមបញ្ចូលអ្នកដែលក្រោយមកទៀត បានសន្មត់យកឈ្មោះនេះ សម្រាប់សំដៅលើក្រុមមនុស្សទាំងមូល) បានកើតឡើង មុនសង្គ្រាមត្រូជិន ត្រូវបានរាំងដោយការលោភលន់អំណាចរបស់ពួកគេ យកខ្លាំងរៀងៗខ្លួន និងអវត្តមាននៃទំនាក់ទំនងជាមួយគ្នា ក្នុងការបង្ហាញសកម្មភាពសមូហភាពណាមួយ ។

៤ ជាការពិត ពួកគេមិនបានបង្រួបបង្រួមគ្នាក្នុងការធ្វើដំណើរផ្សងព្រេងនេះទេ ទម្រាំដល់ពេលដែលពួកគេបានស្គាល់សមុទ្រកាន់តែច្បាស់ ។ ហើយមនុស្សដំបូងបង្អស់ដែលយើងស្គាល់តាមប្រពៃណីថាបាន បង្កើតកងទ័ពជើងទឹក គឺ មីណូស៍ ។ គាត់បានប្រកាសខ្លួនជាម្ចាស់លើផ្ទៃទឹកដែលឥឡូវត្រូវបានគេហៅថាសមុទ្រក្រិក(Hellenic) និងគ្រប់គ្រងលើប្រជុំកោះស៊ីក្លេដ្ស៍ (Cyclades) ជាទីដែលគាត់បានបញ្ជូនអាណានិគមភាគច្រើន ក្នុងកំឡុងពេលដំបូងៗ ដោយបានបណ្តេញពួកការៀនស៍(Carians) និងតែងតាំងកូនប្រុសរបស់គាត់ផ្ទាល់អោយធ្វើជាអភិបាលគ្រប់គ្រង; ហើយដូច្នេះបានគាត់ខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីកំចាត់ចោរសមុទ្រ នៅក្នុងដែនទឹកទាំងនោះ ។ នេះជាជំហានចាំបាច់ ដើម្បីធានាប្រាក់ចំណូលសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ។

៥ កាលពីដើម ជនជាតិក្រិក និងមនុស្សព្រៃ នៅតាមឆ្នេរសមុទ្រ និងបណ្តាកោះនានា នៅពេលដែលទំនាក់ទំនងតាមសមុទ្រកាន់តែងាយស្រួល ហាក់ត្រូវបានល្បួងអោយក្លាយទៅជាចោរសមុទ្រ ក្រោមការដឹកនាំរបស់អ្នកមានឥទ្ធិពលជាងគេ, គោលដៅដើម្បីបម្រើមហិច្ឆិតាផ្ទាល់ខ្លួន និងជួយគាំទ្រដល់ជនទុគ៌តខ្លះដែរ ។ ពួកគេកំណត់គោលដៅទីក្រុងណាមួយដែលគ្មានកំពែងការពារ ឬបណ្តុំភូមិមួយចំនួន ដើម្បីវាយឆក់ប្លន់ ។ ពិតណាស់ នេះបានក្លាយជាប្រភពចម្បងសម្រាប់ជីវភាពរស់នៅរបស់ពួកគេ ដោយមិនមានភាពអាម៉ាស់សម្រាប់សមិទ្ធិផលបែបនេះទេប៉ុន្តែថែមទាំងជាកិត្តិយសទៀតផង ។ អំណះអំណាងនេះ ត្រូវបានឆ្លុះបញ្ចាំង ដោយកិត្តិយសដែលអ្នករស់នៅក្នុងទ្វីបទាំងមូល នៅតែផ្តល់ដល់អ្នកឆក់ប្លន់បានជោគជ័យ និងដោយសំនួរដែលយើងរកឃើញ អ្នកកវីបុរាណ នៅគ្រប់ទីកន្លែង ដែលតំណាងអោយប្រជាជនថាសួរអ្នកដំណើរថា «តើពួកគេគឺជាចោរសមុទ្រឬ?» - ហាក់ដូចជាប្រសិនបើអ្នកដែលត្រូវបានគេសួរសំណួរនេះ នឹងមិនមានគំនិតបដិសេធការចោទប្រកាន់ ឬថា អ្នកសួរចម្លើយចង់ដាក់បន្ទុកពួកគេ ។ ការឆក់ប្លន់ ក៏កើតមាននៅលើដីគោកផងដែរ ។

៦ ហើយសូម្បីតែសព្វថ្ងៃនេះ មានមនុស្សជាច្រើននៅក្រិក នៅតែធ្វើតាមប្រពៃណីចាស់ ឧទាហរណ៍ដូចជាអ្នកស្រុកអូហ្សូលៀន ឡូក្រៀន (Ozolian Locrians), អាតូលៀន (Aetolians), អាខាណានៀន(Acarnanians) និងតំបន់ផ្សេងទៀតក្នុងទ្វីបនេះ, ហើយប្រពៃណីដាក់អាវុធតាមខ្លួននៅតែមានដដែល ក្នុងចំណោមមនុស្សនៅទ្វីបនេះ ដោយសារទម្លាប់ចាស់ ធ្វើចោរសមុទ្រ ។ កុលសម្ព័ន្ធទាំងឡាយក្នុងប្រទេសក្រិកទាំងមូលធ្លាប់ដាក់អាវុធតាមខ្លួន ដោយសារទីលំនៅរបស់ពួកគេគ្មានអ្វីការពារ ហើយការប្រាស្រ័យទាក់ទងគ្នាក៏មិនមានសុវត្ថិភាពទៀត, ពិតណាស់ថា ការបំពាក់អាវុធ គឺជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃជាមួយពួកគេ មិនខុសអីពីក្រុមមនុស្សព្រៃឡើយ ។ ហើយប្រការដែលថា ក្រុមមនុស្សក្នុងតំបន់មួយចំនួនក្នុងប្រទេសក្រិក នៅតែរស់នៅតាមរបៀបចាស់ដដែល បញ្ជាក់ថាក្នុងពេលអតីតកាលណាមួយ ជីវភាពរស់នៅបែបនេះ ជារឿងសាមញ្ញសម្រាប់មនុស្សទាំងអស់ ។ ពួកអ្នករស់នៅបុរីអាថែន គឺជាមនុស្សដំបូងគេ ដែលទម្លាក់អាវុធរបស់ខ្លួនរក្សាទុកដោយឡែក ហើយប្រកាន់យករបៀបរស់នៅស្រួលជាងមុន និងឆើតឆាយជាងមុន ។ មែនទែនទៅ ទើបថ្មីៗនេះទេ ដែលមនុស្សចាស់មានទ្រព្យសម្បត្តិស្តុកស្តម្ភនៅទីនោះ ឈប់ហ៊ឺហាស្លៀកពាក់ខោអាវក្នុងសាច់ក្រណាត់ធ្វើពីសរសៃរុក្ខជាតិ ហើយឈប់ចង់សក់លម្អដោយយកណ្តៀបមាស ដែលជាម៉ូដរាលដាលដល់កុលសម្ព័ន្ធអ៊ីយ៉ូណៀន ពិសេសក្រុមបុរសចាស់ៗ អស់រយៈពេលយ៉ាងយូរ នៅទីនោះ។ ផ្ទុយទៅវិញ ម៉ូដសំលៀកបំពាក់យ៉ាងសាមញ្ញបំផុត ដែលសមស្របតាមគំនិតទំនើប ត្រូវបានផ្តើមដំបូង

ដោយពួក ឡាសេដេម៉ូណៀន (Lacedaemonians) ក្នុងនោះអ្នកមានព្យាយាមសម្របរបៀបរស់នៅរបស់ខ្លួនតាមសាមញ្ញជនទូទៅ ។ ពួកគេក៏បានធ្វើជាគម្រូ ប្រឆាំងនឹងការអាក្រាតកាយជាសាធារណៈ និងការស្រោតលាបប្រេងលើខ្លួន ក្នុងកន្លែងហាត់ប្រាណ ។ ពីមុន សូម្បីតែនៅក្នុងការប្រកួតកីឡាអូឡាំពិក អត្តពលិកដែលចូលរួមប្រកួតប្រជែងស្លៀកពាក់ត្រឹមតែខ្សែក្រវ៉ាត់តែប៉ុណ្ណោះ ។ ហើយពីរបីឆ្នាំក្រោយមក មិនមានការស្លៀកបែបនោះទៀតទេ ។ រហូតមកដល់សព្វថ្ងៃនេះ ក្នុងចំណោមពួកមនុស្សព្រៃខ្លះ ជាពិសេសអ្នកនៅក្នុងទ្វីបអាស៊ី ពេលផ្តល់ពានរង្វាន់ដល់កីឡាប្រដាល់និងចំបាប់ កីឡាករពាក់តែខ្សែក្រវ៉ាត់ ។ ហើយមានចំនុចជាច្រើនទៀតដែលមានលក្ខណៈដូចគ្នា ត្រូវបានរកឃើញក្នុងចំណោមជីវភាពរស់នៅក្នុងពិភពក្រិក និងពិភពមនុស្សព្រៃសម័យបច្ចុប្បន្ន ។

៧ ចំពោះទីក្រុងរបស់ពួកគេ ក្រោយមកទៀត នៅសម័យកាលដែលមានកំណើនគ្រឿងបរិក្ខារនាវាចរណ៍ និងការផ្គត់ផ្គង់មូលធនបានល្អជាងមុន យើងសង្កេតឃើញថា ឆ្នេរសមុទ្រនានាបានក្លាយជាទីតាំងនៃទីប្រជុំជនព័ទ្ធជុំវិញដោយជញ្ជាំង ចំណែកឯជ្រោយនានា ត្រូវបានកាន់កាប់សម្រាប់បម្រើគោលដៅពាណិជ្ជកម្ម និងការការពារប្រឆាំងនឹងប្រទេសជិតខាង ។ ប៉ុន្តែ ទីប្រជុំជនចាស់ៗ តាមព័ត៌មានចោរសមុទ្រ ត្រូវបានសាងសង់ឆ្ងាយពីសមុទ្រ មិនថានៅលើដីកោះ ឬដីគោកនោះទេ ហើយនៅតែស្ថិតនៅទីតាំងចាស់ដដែល ជាពិសេសសម្រាប់ចោរសមុទ្រ ដែលធ្លាប់បានប្លន់គ្នាទៅវិញទៅមក ក៏ដូចជាប្រជាជន នៅតាមឆ្នេរទាំងអស់ មិនថាដើរសមុទ្រឬអត់នោះទេ ។

៨ បណ្តាអ្នកកោះទាំងនោះ ក៏ជាចោរសមុទ្រដ៏អស្ចារ្យដែរ ។ ពួកគេជាអ្នកស្រុក ការៀន(Carians) និងហ្វ៊ីនីសិន (Phoenicians) ដែលផ្ទៃដីភាគមួយភាគធំលើកោះរបស់គេ ត្រូវបានធ្វើអាណានិគម ដូចបានបញ្ជាក់ដោយការពិតដូចតទៅនោះ ។ ក្នុងអំឡុងពេលសម្រិតសម្រាំងលើកោះដេឡូស៍ (Delos) ដោយបុរីអាថែន នៅក្នុងសង្គ្រាម, ផ្នូរខ្មោចទាំងអស់នៅលើកោះ ត្រូវបានគេគាស់ឡើងហើយរកឃើញថា ជាងពាក់កណ្តាលក្នុងចំណោមអ្នកទោសរបស់ពួកគេជាជនជាតិការៀន៖ ពួកគេអាចត្រូវបានកំណត់អត្តសញ្ញាណដោយសារប្រភេទអាវុធត្រូវបានកប់ក្នុងផ្នូរ និងដោយសារវិធីកប់សព, ដែលដូចគ្នានឹងប្រពៃណីជនជាតិកូរៀននៅប្រកាន់ភ្ជាប់នៅឡើយ ។ ប៉ុន្តែ នៅពេលដែល មីណូស៍ បានបង្កើតកងទ័ពជើងទឹកភ្លាម ដោយសារការប្រាស្រ័យទាក់ទងតាមផ្លូវសមុទ្រកាន់ងាយស្រួល គាត់ចាប់ផ្តើមដាក់អាណានិគមនិយមលើកោះភាគច្រើនភ្លាម ហើយបានបណ្តេញឧក្រិដ្ឋជនជាចោរសមុទ្រទាំងនោះចេញ ។ ប្រជាពលរដ្ឋ នៅឆ្នេរសមុទ្រ ភ្លាមៗនោះ បាន[ផ្សារភ្ជាប់ខ្លួននឹងម្ចាស់អាណានិគមដ៏មហាសាល] និងចាប់ផ្តើមធ្វើជំនួញកាន់តែមានទ្រព្យសម្បត្តិច្រើន ហើយជីវិតពួកគេកាន់តែមានលំនឹង ។ ឯខ្លះទៀតបានចាប់ផ្តើមកសាងកំពែងក្រុង ដោយប្រើទ្រព្យសម្បត្តិទើបរកបានថ្មីៗ ។ ដោយចង់បានផលចំណេញ បណ្តាលអោយអ្នកទន់ខ្សោយព្រមនៅក្រោមការគ្រប់គ្រងរបស់អ្នកខ្លាំង អ្នកមានអំណាច ហើយការកាន់កាប់ដើមទុនច្រើនបានជួយអោយអ្នកមានអំណាចជាង បង្ខំបុរីតូចៗអោយចុះចូលជាមួយខ្លួន ។ ហើយ នៅដំណាក់កាលក្រោយៗនៃការវិវឌ្ឍន៍នេះ ដែលពួកគេបានចេញបេសកកម្មប្រយុទ្ធប្រឆាំងនឹងពួកត្រយ (Troy) ។

៩ អ្វីដែលបានជម្រុញអោយ អាហ្គាមេមណុន (Agamemnon) អាចបង្កើនកងទ័ពបាន បើតាមគំនិតខ្ញុំ គឺឧត្តមភាពកម្លាំងរបស់គាត់ ជាជាង ពាក្យសម្បថទីនដារើស (Tyndareus) ដែលបានចងពួកអ្នកគាំទ្រអោយដើរតាមគាត់ ។ ជាការពិតណាស់ ព័ត៌មានដែលត្រូវបានផ្តល់អោយ ដោយពួកប៉េឡូប៉ូនេសៀន (Peloponnesians) ទាំងនោះ ដែលជាអ្នកទទួលនូវប្រពៃណីដ៏គួរអោយទុកចិត្តបំផុតនោះ មានដំណើរដើមទងដូចតទៅ ។ ដំបូងឡើយ ប៉េឡូប្ស៍ (Pelops) ដែលបានមកដល់ជាមួយនឹងប្រជាជនលោភលន់ពីអាស៊ី ដែលមានទ្រព្យសម្បត្តិច្រើន បានក្តោបក្តាប់អំណាចខ្លាំងបំផុត រហូតប្រទេសទាំងមូលត្រូវដាក់ឈ្មោះតាមឈ្មោះគាត់ បើទោះគាត់ជាជនចម្លែកក្តី; ហើយអំណាចដោយសំណាងនេះ ត្រូវបានបង្កើនខ្លាំងថែមទៀត ក្រោមកណ្តាប់ដៃកូនចៅជំនាន់ក្រោយរបស់គាត់ ។

អឺរីស្ទៀស(Eurystheus) ត្រូវបានសម្លាប់នៅក្នុងតំបន់អាទីកា(Attica) ដោយសារដៃ ហេរ៉ាគ្លីដស៍(Heraclids) ។ អាទ្រឹស (Atreus) គឺជាប្អូនប្រុសរបស់ម្តាយគាត់ ដែលបានចាកចេញពីលោកឪពុកគាត់ ដោយសារតែមរណៈភាពរបស់ គ្រីស៊ីភ្វីស (Chrysippus), អឺរីស្ទៀស នៅពេលដែលគាត់បានចាប់ផ្តើមចេញបេសកកម្ម បានចូលរួមជាមួយ មីសែនៀ (Mycenae) និងរដ្ឋាភិបាល ។ ពេលវេលាបានកន្លងផុតទៅយូរហើយ អឺរីស្ទៀស មិនបានត្រឡប់មកវិញទេ, អាទ្រឹសបានធ្វើតាមការចង់បានរបស់ពួកមីសែនៀន ដែលរងឥទ្ធិពលដោយការភ័យខ្លាចពួកហេរ៉ាគ្លីដស៍ - ក្រៅពីនេះ គាត់ហាក់មានអំណាចគួរអោយកត់សម្គាល់ ហើយក៏មិនបានព្រងើយយកចិត្តរាស្ត្រឡើយ ហើយបានកាន់កាប់ ដំបងរាជ្យបន្តពីមីសែនៀ និងដែនដីឯទៀតរបស់ អឺរីស្ទៀស ។ ហើយដូចគ្នានេះដែរ អំណាចកូនចៅជំនាន់ក្រោយរបស់ ប៉េឡុប្ស ខ្លាំងក្លាជាងពូជពង្សរបស់ពែក្សេីស (Perseus) ។ សម្រាប់គ្រប់គ្នាអាហ្គាមេមណុន បានទទួលជោគជ័យ ។ គាត់ក៏មានកងនាវាចម្បាំងខ្លាំងជាងមេដឹកនាំផ្សេងៗក្នុងជំនាន់របស់គាត់ផងដែរ ដូច្នេះ បើតាមគំនិតរបស់ខ្ញុំ ការភ័យខ្លាច គឺជាកម្លាំងចលករខ្លាំងក្លា ដូចការស្រលាញ់សម្រាប់បង្កើតក្រុមបេសកកម្មរួមជាសហព័ន្ធនេះ ។ អនុភាពនៃកងទ័ពជើងទឹករបស់គាត់ ត្រូវបានបង្ហាញ ដោយការពិតដែលថា កម្លាំងទ័ពរបស់គាត់ច្រើនហើយខ្លាំងជាងគេ ចម្លែកកងទ័ព អាខេដៀន (Arcadians) គ្រាន់តែជាទ័ពជំនួយបន្ថែមប៉ុណ្ណោះ; យ៉ាងហោចណាស់ នេះគឺជាអ្វីដែលលោក ហូម័រ បាននិយាយ ប្រសិនបើទឡ្ហីករណ៍របស់គាត់គ្រប់គ្រាន់ ។ ក្រៅពីនេះ បើតាមព័ត៌មានរបស់គាត់ស្តីពីការផ្ទេរដំបងរាជ្យនេះ គាត់ហៅថា «ម្ចាស់ក្នុងចំណោមកោះជាច្រើន និងស្តេចនៃស្តេចអាហ្គូស៍ទាំងអស់។» អាហ្គាមេមណុន គឺជាមហាអំណាចលើទ្វីបទាំងមូល ហើយគាត់មិនអាចធ្វើជាម្ចាស់នៃគ្រប់គ្នាបានទេ លើកលែងតែកោះដែលនៅជិតៗ (ហើយចំនួនទាំងនេះមិនមានច្រើនទេ) បើគ្មានកងទ័ពជើងទឹក ។...

១០ ... បន្ទាប់ពីបានបង្ហាញលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្ញុំ ក្នុងជំនាន់មុនៗ ខ្ញុំយល់ថា វានឹងមានការពិបាកក្នុងការជឿសេចក្តីលម្អិតគ្រប់បែបយ៉ាង ។ របៀបដែលមនុស្សភាគច្រើនពាក់ព័ន្ធនឹងប្រពៃណី សូម្បីប្រពៃណីនៃប្រទេសរបស់ខ្លួន គឺត្រូវទទួលគ្រប់ទិដ្ឋភាពទាំងអស់ ដោយគ្មានការតេស្តអ្វីទាំងអស់ ។ ... មានគំនិតគ្មានមូលដ្ឋានជាច្រើនទៀត ដែលបច្ចុប្បន្នមាននៅក្នុងចំណោមជនជាតិក្រិកដទៃទៀត ដែលមិនបានរសាត់តាមពេលវេលា ។ ឧទាហរណ៍ មានសញ្ញាណដែលថា ស្តេចនៅឡាសេដេម៉ូនៀន (Lacedaemonian) មួយអង្គ អាចបោះឆ្នោតពីរសម្លេង តែពិត បានតែមួយប៉ុណ្ណោះ ។ ហើយថាមានក្រុមហ៊ុនពីតែន (Pitane)តែតាមពិត គ្មាន រឿងបែបនេះទេ ។ មានការឈឺចាប់តិចតួចដែរសម្រាប់មនុស្សខ្លះក្នុងការស៊ើបអង្កេតរកការពិត ផ្ទុយទៅវិញ គេទទួលយករឿងដែលគេដឹងដំបូងថាជាការពិត ដោយមិនចាំបាច់ផ្ទៀង ។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីសន្និដ្ឋានដែលខ្ញុំបានធ្វើដោយសម្អាងលើភស្តុតាង ខ្ញុំជឿជាក់ថា អាចទុកចិត្តបាន ដោយសុវត្ថិភាព ។ ពិតប្រាកដណាស់ [ភស្តុតាងទាំងនោះ] នឹងមិនត្រូវបានរំខានដោយពពួកកវីនិពន្ធដែលចូលចិត្តការបំផ្លើសក្នុងស្នាដៃរបស់ខ្លួន ឬ ដោយការតាក់តែងរបស់អ្នកកត់ត្រាកាលប្បវត្តិ ដែលជ្រើសយកភាពទាក់ទាញ ជាជាងការពិត; ប្រធានបទដែលពួកគេជ្រើសយក [ធំពេក]មិនអាចរកភស្តុតាងណាមកសម្អាង ឬយូរលង់ពេកហួសព្រំដែនប្រវត្តិសាស្ត្រ ផ្ទុយទៅវិញ ត្រូវចាត់ចូលជារឿងព្រេង ។ ដោយងាកចេញពីចំណុចទាំងនេះ យើងពេញចិត្តនឹងបន្តការអង្កេតដោយអាស្រ័យលើទិន្នន័យច្បាស់លាស់បំផុត និងឈានដល់សន្និដ្ឋានពីអតីតកាលយ៉ាងពិតប្រាកដ ដូចដែលអាចរំពឹងទុក ។ ឈានចូលដល់សង្គ្រាមនេះ ៖ ទោះបីជាលក្ខណៈនៃភាគីជម្លោះលើសារៈសំខាន់របស់វា ហើយនៅពេលដែលត្រលប់ទៅសង្កេតមើលព្រឹត្តិការណ៍មុន ការពិនិត្យលើអង្គហេតុនានា នឹងបង្ហាញថាវាជាមហាសង្គ្រាម ធំជាងជំនាន់មុនទាំងអស់ ។

១១ ដោយសំដៅទៅលើសុន្ទរកថានៅក្នុងប្រវត្តិសាស្ត្រនេះ មួយចំនួនត្រូវបានថ្លែងមុនពេលសង្គ្រាមបានចាប់ផ្តើម ហើយខ្លះទៀត ពេលសង្គ្រាមកំពុងបន្ត ។ ខ្លះខ្ញុំបានឮខ្លួនខ្ញុំផ្ទាល់ ឯខ្លះទៀត ខ្ញុំបានទទួលពីកន្លែងផ្សេងៗ ។ ជាការពិត នៅក្នុងគ្រប់ករណីទាំងអស់ មានការពិបាកក្នុងការចាំពាក្យសម្តីគ្រប់ម៉ាត់ ត្បិតការចងចាំរបស់មនុស្សម្នាក់

[មានកំណត់] ។ ដូច្នេះទម្លាប់របស់ខ្ញុំ គឺ ស្នើអោយវាត្និនទាំងនោះនិយាយថាអ្វីដែលពួកគេត្រូវនិយាយឡើងវិញ ក្នុងគ្រប់ឱកាស ជាការពិតណាស់ ដោយប្រកាន់ខ្ជាប់អត្ថន័យដើម តាមតែអាចធ្វើទៅបាន ។ ហើយសម្រាប់ព្រឹត្តិការណ៍ដែលកើតឡើងយូរលង់ណាស់មកហើយ ហួសឆ្ងាយពីប្រភព(ព័ត៌មានដើម)ដែលខ្ញុំអាចរកបាន ខ្ញុំដូចជាមិនជឿលើអារម្មណ៍ ឬទស្សនៈផ្ទាល់ខ្លួនឡើយ ប៉ុន្តែ ម្យ៉ាងទៀត វាអាស្រ័យលើអ្វីដែលខ្ញុំបានឃើញផ្ទាល់នឹងភ្នែក នឹងម្យ៉ាងទៀត ត្រូវអាស្រ័យលើអ្វី ដែលអ្នកដទៃសង្កេតមើលជំនួសខ្ញុំ ដូច្នេះ ភាពត្រឹមត្រូវនៃរបាយការណ៍នេះ ត្រូវបានធ្វើតេស្តផ្ទៀងផ្ទាត់ ដោយលម្អិតបំផុត និងហ្មត់ចត់បំផុត តាមតែអាចធ្វើទៅបាន ។ ការសន្និដ្ឋានរបស់ខ្ញុំ ត្រូវបានធ្វើឡើង ដោយការបញ្ចេញកម្លាំងពលកម្មខ្លះ ក្នុងការផ្ទៀងផ្ទាត់ភាពមិនស៊ីចង្វាក់គ្នានៃរឿងរ៉ាវ ដែលផ្តល់ដោយសាក្សីផ្សេងគ្នា, ភាពខុសៗគ្នាខ្លះបណ្តាលមកពីការចងចាំមិនល្អឥតខ្ចោះ ជួនកាល ដោយសារភាពលំអៀងទៅភាគីម្ខាង ឬម្ខាងទៀត ហួសហេតុពេក ។ អវត្តមាននៃមនោសញ្ចេតនា នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្ញុំ ខ្ញុំបារម្ភបន្តិចបន្តួច ខ្លាចភាពទាក់ទាញ ។ ប៉ុន្តែ ប្រសិនបើវាត្រូវបានវិនិច្ឆ័យថា មានប្រយោជន៍ដោយអ្នកសិក្សាចង់ដឹងទាំងឡាយ ដែលចង់បានចំណេះដឹងពិតប្រាកដនៃអតីតកាល សម្រាប់ជាជំនួយដល់ការបកស្រាយនៃអនាគត ដែលនៅក្នុងដំណើរវិវត្តន៍នៃរឿងរបស់មនុស្សលោក ត្រូវការជាចាំបាច់ នោះខ្ញុំនឹងពេញចិត្តហើយ ។ ជារួម ខ្ញុំបានចងក្រងការងាររបស់ខ្ញុំ មិនមែនសម្រាប់ជាអត្ថបទដើម្បីទទួលសម្លេងទះដៃអបអរសាទរឡើយ ប៉ុន្តែសម្រាប់ទុកជាមរតកក្នុងគ្រប់សម័យកាល ។

# មេរៀនទី ៣ ៖ ទ្រឹស្តីប្រវត្តិសាស្ត្របែបសាសនា និង ទ្រឹស្តីប្រវត្តិសាស្ត្រចិនបុរាណ

បច្ចេកទេស គោលការណ៍ និងវិធីសាស្ត្ររបស់លោក ហេរ៉ូដូទឹស ត្រូវបានបន្តអនុវត្តដោយប្រវត្តិវិទូនានានៅក្នុង ចក្រភពរ៉ូម៉ាំង ដែលជាចក្រភពមួយយ៉ាងធំ គ្រប់ដណ្តប់លើទ្វីបអឺរ៉ុប និងអាហ្វ្រិក ឆ្នេរសមុទ្រមេឌីទែរ៉ាណេ អស់រយៈពេលរាប់រយឆ្នាំ ។ ដោយសរសេរជាភាសាឡាតាំង ប្រវត្តិវិទូទាំងនោះ បានរក្សាការអនុវត្តគោលការណ៍របស់ក្រិកយ៉ាងតឹងរ៉ឹង ដោយចងក្រងប្រវត្តិសាស្ត្រផ្អែកលើប្រភពព័ត៌មានច្បាស់លាស់ និង ចេះវិភាគថ្លឹងថ្លែងហេតុផល ។ ប្រវត្តិវិទូរ៉ូម៉ាំងល្បីៗ មានដូចជា ប៉ូលីបៀស, ដៃអូដូរីស, សាលើស, លីវី, តាក់ស៊ីតឹស, ស្វេតូនៀស និង ភ្លូតាធ៍ ជាដើម។

**ប៉ូលីបៀស** ( Polibius )

លោក **ប៉ូលីបៀស** មានកំណើតជាក្រិក តែបានក្លាយជាជនជាតិរ៉ូម៉ាំង ពេលរ៉ូម៉ាំងវាយគ្រប់គ្រងក្រិក។ គាត់បានទទួលមរតកប្រវត្តិសាស្ត្រក្រិចបុរាណ នៅពេលដែលក្នុងចក្រភពទាំងមូល បានទទួលធាតុនៃមរតកវប្បធម៌ក្រិចផ្សេងទៀត ដោយទទួលស្គាល់ កិត្យានុភាពរបស់ក្រិក និងអនុវត្តតាម តាមរូបភាពឬមធ្យោបាយមួយចំនួន ប៉ុន្តែជៀសមិនផុតពីការបង្កើតទ្រឹស្តីនិងគោលការណ៍ ផ្ទាល់ខ្លួនរបស់ពួកគេ ផងដែរ ។ ប្រាកដណាស់ នោះជាសំណេររបស់ជនជាតិក្រិចនិងជាភាសាក្រិច, លោក ប៉ូលីបៀស ( ឆ្នាំ ២០០ ដល់ ១១៨ មុនគ្រឹស្តសករាជ ) ដែលជាមនុស្សដំបូងបានផ្តល់នូវការយល់ដឹងសំខាន់ៗអំពីការអភិវឌ្ឍន៍នៃរដ្ឋរ៉ូម៉ាំង និងពិភាក្សាអំពីទិដ្ឋភាពនៃសង្គមរ៉ូម៉ាំង ដែលរ៉ូមខ្លួនឯងស្ទើរតែមិនបានកត់សំគាល់ ។ គាត់បានសួរថា៖ «តើនរណាម្នាក់អាចព្រងើយកណ្តើយ ឬខ្ជិលច្រអូស ដែលមិនខ្វល់ពី មធ្យោបាយ និងតើស្ថិតក្រោមរបបបែបណាដែលពិភពលោកស្ទើរតែទាំងអស់ ត្រូវបានសញ្ជ័យយកហើយត្រូវបានគ្រប់គ្រងឬក្រោមការត្រួតត្រារបស់ទីក្រុងរ៉ូមតែមួយ ក្នុងរយៈពេលមិនដល់ ៥៣ ឆ្នាំផងនោះ?» ក្នុងការឆ្លើយសំនួរនេះប៉ូលីបៀសបានធ្វើការប្រៀបធៀបរវាងរ៉ូមនិងក្រិច ដែលក្រិកខ្លួនឯង មិនអាចបង្កើតអាណាចក្រមួយយូរអង្វែង សូម្បីតែក្រោមអំណាចរបស់មហាអធិរាជ អាឡិច សាន់ឌឺ (៣៥៦-៣២៣ មុនគ្រឹស្តសករាជ) ។ មូលហេតុចម្បងនៃភាពជោគជ័យរបស់ទីក្រុងរ៉ូមយោងតាមប៉ូលីបៀស គឺជាចរិតរ៉ូម៉ាំង ដូចដែលបានឆ្លុះបញ្ចាំងពីភាពជារដ្ឋបុរស ស្មារតីសាធារណៈ និងការសម្របសម្រួលចំពោះប្រជាជនដែលចាញ់សង្គ្រាម។

លោក ប៉ូលីបៀស ក៏បានអះអាងដែរថា ស្ថាប័ននយោបាយរ៉ូមមានឧត្តមភាពជាងក្រិក។ លោកបានទទួលយកទ្រឹស្តីវដ្តនៃការថយចុះ និង ការបង្កើតឡើងវិញ នៃរដ្ឋទីក្រុងក្រិក ដែលត្រូវបានពន្យល់ បកស្រាយដោយលោកអារីស្តូត។ ទ្រឹស្តីនេះបានអះអាងថា រដ្ឋបុរីបានអភិវឌ្ឍន៍ដំបូងជារបបផ្តាច់ការ ហើយបានវិវឌ្ឍន៍ ទៅជាសម័យកាលជាបន្តបន្ទាប់ដូចជា រាជានិយម របបផ្តាច់ការ របបអភិជនាធិបតេយ្យ របបគហិបតីនិយម របបលទ្ធិប្រជាធិបតេយ្យ ហើយចុងក្រោយជារបបគ្រប់គ្រងដោយហ្វូងមនុស្ស មុនការស្តារសណ្តាប់ធ្នាប់ នៅក្នុងរបបផ្តាច់ការនិយមជាថ្មីម្តងទៀត ។ ទោះយ៉ាងណាក៏ដោយ វដ្តនេះមិនប្រាកដវិលចុះវិលឡើងដដែលៗទេ ហើយមានគ្រាមួយនោះ ប៉ូលីបៀសជឿជាក់ថាជនជាតិរ៉ូមអាចបញ្ចៀសវាបាន ពីព្រោះរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋរ៉ូម៉ាំង ត្រូវបានលាយបញ្ចូលគ្នា ដែលអនុញ្ញាតឱ្យមានរបបរាជានិយមនឹងធាតុប្រជាប្រិយមួយចំនួន ក៏ដូចជាអភិជនាធិបតេយ្យនៃព្រឹទ្ធសភា។ (ទ្រឹស្តីអំពីអត្ថប្រយោជន៍នៃរដ្ឋាភិបាលចម្រុះគឺដើម្បីមានដំណើរការយូរអង្វែង។) ចុងក្រោយ ប៉ូលីបៀស ជឿជាក់ថាជនជាតិ

រ៉ូម ត្រូវបានអនុគ្រោះដោយ *ពីច* («វាសនា» ឬ«សំណាង») ដែលជាមូលហេតុចម្បងមួយបានទាក់ទាញពិភពលោកអោយស្ថិតក្រោមការគ្រប់គ្រងរបស់រ៉ូម។

ដូច លោក ស៊ូស៊ីឌីឌីស ដែរ លោក ប៉ូលីបៀស ពឹងផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួននិងការសាកសួរសាក្សី ។ ដូច្នេះ គាត់បានស្រាវជ្រាវគន្លងដានរបស់ ឧត្តមសេនីយ៍ក្រុងកាថេជ ឈ្មោះ ហាន់នីបាល់ ឆ្លងកាត់ភ្នំអាល់ ហើយបានសង្កេតមើល ការឡោមព័ទ្ធកាថេជ ក្នុងឆ្នាំ ១៤៦ មុនគ្រឹស្ត៍សករាជ ។ ថ្វីត្បិតតែគាត់ចម្អកដាក់អ្នកប្រវត្តិសាស្ត្រដែលគ្រាន់តែអង្គុយសិក្សាក្នុងបន្ទប់ គាត់ក៏ថ្កោលទោសប្រវត្តិសាស្ត្រតូចតាច នៅគ្រប់ក្រឡុកក្រឡៀននៃពិភពលោក។ ផ្ទុយទៅវិញ ជ័យជំនះនៃទីក្រុងរ៉ូមបានអំពាវនាវឱ្យមានប្រវត្តិសាស្ត្រជាសកលមួយ៖ «រហូតមកដល់ពេលនេះប្រវត្តិសាស្ត្ររបស់ពិភពលោកត្រូវបានចងក្រងជាបន្តបន្ទាប់អំពីរឿងនេះបន្តិច រឿងនោះបន្តិច ដាច់ដោយឡែកពីគ្នា ... ប៉ុន្តែ ចាប់ពីពេលនេះទៅមុខ ប្រវត្តិសាស្ត្រនឹងត្រូវសរសេររួមគ្នា ៖ កិច្ចការឬរឿងរ៉ាវ អ៊ីតាលីនិងលីប៊ីជាប់ពាក់ព័ន្ធជាមួយនឹងអាស៊ីនិងក្រិកហើយមាននិន្នាការរួមគ្នាតែមួយ" ។

### ដៃអូដូរឹស, សាលើស, និង លីវី

ជាអកុសល វិធីសាស្ត្រដែលផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួននិងការនិទានប្រាប់ពីសាក្សីអាចកត់ត្រាគ្រាមួយនៃការសញ្ជ័យយកដោយរ៉ូម៉ាំង ប៉ុន្តែ មិនអាចបង្កើតប្រវត្តិសាស្ត្រសកលបានទេ។ សម្រាប់លោក **ដៃអូដូរឹស** ស៊ីយូលើស នៅសតវត្សរ៍ទី ១ មុន គ្រឹស្ត៍សករាជ ក្នុងចំណោមអ្នកនិពន្ធបុរាណ ស្ទើរតែអាចធ្វើទៅបានហើយ ។ដៃអូដូរឹសបានត្រលប់ទៅឆ្នាំ ៦០ មុនគ្រឹស្ត៍សករាជដើម្បី ចងក្រងប្រវត្តិសាស្ត្រ ជនជាតិអារ៉ាប់ អាស៊ីរៀន អេហ្ស៊ីប អេត្យូពី ក្រិក ឥណ្ឌា រ៉ូម និងស៊ីធៀន ដោយមិនគិត ពីអាម៉ាហ្សូននិងអ្នករស់នៅអាត្លង់ទីសផង។ គាត់គឺជាអ្នកគាំទ្រអំណះអំណាងបុរាណ ដែលថា ផ្កាតុងនិងទស្សនៈវិទូក្រិកដទៃទៀត បានរៀនសូត្រទទួលបានប្រាជ្ញារបស់ពួកគេ ពីជនជាតិ អេហ្ស៊ីប ។

តិចជាងមួយសតវត្សបន្ទាប់ពីប៉ូលីបៀសបានពន្យល់ពីការកើនឡើង នៃរដ្ឋរ៉ូមមក ប្រវត្តិវិទូរ៉ូមនានា បានចាប់ផ្តើមនិយាយអំពីការធ្លាក់ចុះនៃចក្រភពមួយនេះ។ លោក សាលើស (ឆ្នាំ ៨៦ ដល់ ៣៥/៣៤ មុនគ្រឹស្ត៍សករាជ) បានពិពណ៌នាអំពីការសមគំនិតរបស់អភិជនរ៉ូម៉ាំង កាទីលីន នៅក្នុងស្នាដៃ ដែលមានចំណងជើងថា «Bellum Catilinae» (៤៣-៤២ មុនគ្រឹស្ត៍សករាជ សង្គ្រាមកាទីលីន) ចំណែកស្នាដៃរបស់គាត់ មួយទៀត ដែលមានចំណងជើងថា «Bellum *Jugurthinum*» (៤១-៤០ មុនគ្រឹស្ត៍សករាជ សង្គ្រាម *ជូហ្គាថា*) បានផ្តោតលើសង្គ្រាមប្រឆាំងនឹង ជូហ្គាថា ស្តេចនូមីដា (ប្រហែលនៅអាល់ហ្សេរីបច្ចុប្បន្ន)។ មេរៀនរបស់សង្គ្រាមទាំងពីរ បានអោយយើងដឹងថា របបសាធារណរដ្ឋកំពុងតែរលួយខាងក្នុង ដោយសារអំពើពុករលួយនិងភាពក្រអឺតក្រទមនៃអំណាច។ ជាការពិតនៅក្នុងការវិភាគជាប្រព័ន្ធរបស់លោកសាលើស ទីក្រុងរ៉ូមត្រូវបានគេបង្ហាញអោយឃើញថា កំពុងទទួលរងនូវជោគវាសនាទូទៅដូចចក្រភពនានា។

លោក **លីវី** (ឆ្នាំ ៥៩/៦៤ មុនគ្រឹស្ត៍សករាជ ដល់ឆ្នាំ ១៧ នៃគ្រឹស្ត៍សករាជ) ដែលជា ប្រវត្តិវិទូរ៉ូម៉ាំងដ៏អស្ចារ្យម្នាក់ បានរស់នៅនិងឆ្លងកាត់ការដួលរលំនៃរបបសាធារណរដ្ឋនិងការបង្កើតចក្រភពដោយអូហ្គុស ដែលជាអធិរាជរ៉ូមដំបូងគេ។ ដូចសាលើសដែរ លីវីមានទំនោរចង់តម្កើង គុណធម៌ខ្ពង់ខ្ពស់របស់សាធារណរដ្ឋរ៉ូម៉ាំង ។ ប្រវត្តិសាស្ត្រដ៏មហិមារបស់គាត់ ដែលភាគច្រើន បានបាត់បង់ទៅហើយបានចាប់ផ្តើមជាមួយនឹងការបង្កើតទីក្រុងហើយបន្តរហូតដល់ការគ្រប់គ្រងរបស់ អូហ្គុស ។ ដូចកំណាព្យ អេណេដ ដោយកវីរ៉ូម៉ាំងវីរហ្គីលការងាររបស់លីវីបានរំលឹកប្រវត្តិសាស្ត្រដើមរបស់រ៉ូមនៅពេលដែលសាធារណរដ្ឋកំពុងត្រូវបានផ្លាស់ប្តូរទៅជាអាណាចក្រ។

## តាស៊ីតឹស

គ្មាននរណាម្នាក់ដឹងអំពីការវិវត្ត ឬការធ្លាក់ចុះនេះ ជាងលោក តាស៊ីតឹស (៥៦-១២០) នោះទេ ។ ស្នាដៃដ៏អស្ចារ្យរបស់គាត់ចំនួន ពីរក្បាល គឺ Annals ដែលគ្របដណ្តប់ពីឆ្នាំ ១៤-៦៨ នៃ គ្រឹស្តសករាជ និងប្រវត្តិសាស្ត្រ ដែលបានចាប់ផ្តើមពីកំឡុង «ឆ្នាំដ៏ល្បីល្បាញនៃអធិរាជទាំងបួន» និងបានបញ្ចប់ដោយការចូលទីវង្គត់នៃអធិរាជ ដូមីសិន (ឆ្នាំ ៩៦) ផ្តល់នូវកំណត់ហេតុសំខាន់នៃចក្រភព ក្នុងសតវត្សរ៍ទី ១ ។ តាស៊ីតឹសគឺជាស្មេរដែលមាន ស្ទីលរបស់គាត់ផ្ទាល់ ហើយនៅក្នុងគណនីរបស់គាត់ គាត់បានអះអាងថាស្ទីលគឺជាផលិតផលនៃការផ្លាស់ប្តូរប្រវត្តិសាស្ត្រ ជាជាងការសម្រេចចិត្តរបស់អ្នកប្រវត្តិវិទូទាំងស្រុង ។ ស្នាដៃរបស់គាត់ ផ្ទាល់ ប្រហែលជាគួរឱ្យកត់សម្គាល់បំផុតសម្រាប់កាព្យខ្លីៗរបស់គាត់ ។ ឧទាហរណ៍ ក្នុងចំណោមរជ្ជកាល ដែលមានអាយុកាលខ្លី របស់ព្រះចៅអធិរាជ ហ្គាលបា តាស៊ីតឹស បានសរសេរថា៖«Capax imperium, nisi imperasset» («គាត់អាចនឹងមានសមត្ថភាពគ្រប់គ្រង លើកលែងតែគាត់បានគ្រប់គ្រង») ។ ហើយទាក់ទងនឹងគោលការណ៍សន្តិភាពនិយមរបស់រ៉ូម៉ាំង គាត់បានសង្កេតឃើញថា «Solitudinem faciunt, pacem appelant» («ពួកគេបានកំទេចរាបស្មើក្លាយជាវាលខ្សាច់ ហើយហៅវាថាសន្តិភាព») ។

នយោបាយ ដូចដែលត្រូវបានស្គាល់នៅក្នុងសាធារណរដ្ឋ លែងមានទៀតហើយ។ ការសមគំនិតរបស់គ្រួសារអធិរាជ និងអង្គរក្សរបស់ខ្លួន (ឆ្មាំ Praetorian) បានកំណត់ជោគវាសនារបស់ទីក្រុងរ៉ូម។ ជាជាងការបង្កើតការនិទានកថាដ៏សំខាន់អំពី កងកម្លាំង មិនផ្ទាល់ដែលអាចនាំឱ្យមានការអភិវឌ្ឍន៍នេះ, ដូចដែល ប៉ូលីបៀស ឬ សូម្បីតែ សាលើស អាចនឹងធ្វើ, លោក តាស៊ីតឹស ផ្តោតលើចរិតលក្ខណៈរបស់អធិរាជនីមួយៗ។ ដូចអ្នកនិពន្ធបុរាណដទៃទៀត គាត់មិនមានគំនិតអំពីចរិតលក្ខណៈ ដែលកំពុងអភិវឌ្ឍ ពីមួយដំណាក់កាលទៅមួយដំណាក់កាលទៀត ក្នុងជីវិតពួកគេឡើយ ។ ទោះយ៉ាងណាក៏ដោយចរិតលក្ខណៈធម្មជាតិបង្ហាញឱ្យឃើញយ៉ាងច្បាស់ តែនៅក្នុងពេលមានវិបត្តិ ឬនៅពេលដែលការកាន់កាប់អំណាចផ្តាច់ការអនុញ្ញាតឱ្យលក្ខណៈពិសេសដែលនៅសេសសល់របស់វា លេចចេញមក ដូចជាអសមត្ថភាព និងភាពសាហាវឃោរឃៅរបស់អធិរាជ នីរ៉ូ។ ការសង្កត់ធ្ងន់របស់តាស៊ីសទៅលើចរិតទោះបីជាភាពទ្រុឌទ្រោមនៃទ្រឹស្តីចិត្តសាស្ត្ររបស់គាត់បានធ្វើឱ្យគាត់ក្លាយជាអ្នកត្រួសត្រាយប្រវត្តិចិត្តសាស្ត្រ ។ វាក៏បាននាំមកនូវទម្រង់នៃស្នាដៃប្រវត្តិសាស្ត្រស្ទើរតែដូចពហុជីវប្រវត្តិទៅហើយ ។

## ស្វេតូនៀស និង ភ្លូតាធ៍

នេះគឺជាការពិតអំពីជីវិតអធិរាជស៊ីហ្សឺរ ដែលសរសេរដោយលោក ស្វេតូនៀស នៅសតវត្សទី ២ ។ ស្នាដៃរបស់គាត់ រួមមានកំណត់ហេតុអំពីសមិទ្ធផលផ្នែករដ្ឋបាលនិងយោធារបស់អធិរាជនីមួយៗ អមដោយការពិពណ៌នាអំពីចរិតលក្ខណៈនិងជីវិតផ្ទាល់ខ្លួនរបស់ព្រះអង្គ។ ថ្វីត្បិតតែ ស្វេតូនៀស ជាអតីតលេខាអធិរាជ បានទាញយកឯកសារបណ្ណសាររបស់អធិរាជ ក្នុងការតែងនិពន្ធជីវិតរបស់ព្រះអង្គក៏ដោយ ក៏ការងារនេះត្រូវបានគេស្គាល់យ៉ាងច្បាស់ ដោយសារព័ត៌មានលំអិតអំពីរឿងអាស្រូវ ដែលវាផ្តល់ទាក់ទងនឹងជីវិតឯកជនរបស់អធិរាជ។ នៅក្នុងរឿងនេះ គាត់ខុសពីអ្នកសរសេរជីវប្រវត្តិបុរាណដ៏ល្បីបំផុត ដូចជាលោក ភ្លូតាធ ដែលស្នាដៃ ដែលមានចំណងជើងថា *ខ្សែជីវិត* បានបូកសរុបរឿងរ៉ាវជីវិតរបស់ជនជាតិរ៉ូម ២៤ នាក់និងជនជាតិក្រិច ២៤ នាក់ ដែលបានជួបប្រទះបទពិសោធន៍ស្រដៀងគ្នា។ គោលបំណងរបស់គាត់គឺដើម្បីទាញយកមេរៀនសីលធម៌ពីជីវិតរបស់តួអង្គទាំងនេះ។ ប្រសិនបើពួកគេឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ពួកគេខុសៗគ្នានោះ បានន័យថាវាជាផ្នែកមួយនៃផលវិបាកនៃចរិតលក្ខណៈ ប៉ុន្តែភាពទន់ខ្សោយនៃចរិតលក្ខណៈអាច និងគួរតែ ត្រូវបានជំនះ ដោយការប្រកាន់គុណធម៌។

ថ្វីបើមានដើមកំណើតនៅក្នុងគំនិតប្រវត្តិសាស្ត្រក្រិកក៏ដោយ ប្រវត្តិប្រវត្តិសាស្ត្ររ៉ូម៉ាំងមានលក្ខណៈដូចជនជាតិចិនច្រើន ជាងប្រវត្តិសាស្ត្រក្រិក។ ជនជាតិរ៉ូមខ្វះការរំពឹងទុកឬស្រមើស្រមៃ ដែលប្រវត្តិវិទូជនជាតិក្រិកសំបូរ ហើយប្រវត្តិវិទូរបស់ពួកគេបានខិតខំប្រឹងប្រែងបន្តិចបន្តួចដើម្បីទ្រទ្រង់ទ្រឹស្តីធំ ៗ ឬ មធ្យម។ នេះគឺជាហេតុផលមួយដែលធ្វើឱ្យពួកគេពេញចិត្ត អស់រយៈពេលជាយូរមកហើយជាមួយនឹងកំណត់ហេតុប្រចាំឆ្នាំ។ ជនជាតិរ៉ូម៉ាំងសម័យសាធារណរដ្ឋមិនសូវមានការគោរពចំពោះបុព្វបុរសរបស់ខ្លួន ដូចជនជាតិចិនទេ ហើយប្រវត្តិវិទូទាំងពីរក្រុមជឿថា ប្រវត្តិសាស្ត្រគួរតែផ្តល់មេរៀនសីលធម៌។ ជាការពិត នេះគឺជាផ្នែកមួយនៃកេរដំណែលរ៉ូម ដែលបន្សល់ទុកសំរាប់ប្រវត្តិសាស្ត្រគ្រីស្តសាសនា នៅមជ្ឈិមសម័យ។

## ៣.១. ទ្រឹស្តីប្រវត្តិសាស្ត្របែបសាសនា

ប៉ុន្តែ ក្រោយចក្រភពរ៉ូម៉ាំងដួលរលំ ក្នុងឆ្នាំ ៤៧៦ គ្រឹស្តសករាជ សមាសធាតុជាច្រើននៃវប្បធម៌អឺរ៉ុបត្រូវធ្លាក់ចុះ ។ ប្រពៃណីចងក្រងប្រវត្តិសាស្ត្រសមហេតុសមផលរបស់រ៉ូម៉ាំង ក៏ធ្លាក់ចុះដែរ ។ កម្រិតអប់រំធ្លាក់ចុះខ្លាំង ហើយមនុស្សជាច្រើនលើសលុបមិនចេះអក្សរ ។ អ្នកដែលចេះអាន និងសរសេរ និងអាចធ្វើការសិក្សាស្រាវជ្រាវបានខ្លះៗនៅអឺរ៉ុបសម័យមជ្ឈឹម (ចន្លោះ ឆ្នាំ ៤៧៦ ដល់ ១៤៩២ គ្រឹស្តសករាជ) គឺមានតែព្រះសង្ឃឬអាចារ្យសាសនាគ្រឹស្តប៉ុណ្ណោះ ។

ព្រះសង្ឃទាំងនោះសរសេរប្រវត្តិសាស្ត្រ តែអំពីរឿងរ៉ាវជុំវិញព្រះជាម្ចាស់តែប៉ុណ្ណោះ ។ ពួកគេជឿថា ព្រះជាម្ចាស់ គឺជាចំណុចប្រសព្វនៃអ្វីៗគ្រប់បែបយ៉ាងលើពិភពលោក ហើយថា ប្រវត្តិសាស្ត្រមនុស្សលោកគ្មានតួនាទីអ្វីក្រៅពីបញ្ជាក់ពីឆន្ទៈរបស់ព្រះជាម្ចាស់ឡើយ ។

ប្រវត្តិសាស្ត្រនៅអឺរ៉ុបសម័យនោះ ហាក់គ្រាន់តែជាប្រវត្តិរូបរបស់ព្រះសង្ឃ និងអាចារ្យ ហើយត្រូវបានចងក្រងឡើង សម្រាប់តែបញ្ជាក់ថា អ្នកណាជាអ្នកគោរពប្រតិបត្តិសាសនារបស់គេបានខ្ជាប់ខ្ជួនជាង ។ សម្រាប់ប្រភពព័ត៌មាន ព្រះសង្ឃនិងអាចារ្យទាំងនោះ ផ្តោតអារម្មណ៍លើអភិនិហារ សម្តែងដោយព្រះសង្ឃ ឬការស្រមើស្រមៃ ឬការបូជាដល់ព្រះរបស់ពួកគេ ។

ការសរសេរប្រវត្តិសាស្ត្ររបស់ជនមូស្លីម និងជ្វីស ក្នុងសម័យកាលដំណាលគ្នានោះដែរ ៖ ហាក់ដូចជាថា ឆន្ទៈរបស់ព្រះត្រូវបានបំពេញដោយសត្តបុគ្គល ឬ មនុស្សដែលព្រះបានជ្រើសរើស ។ ដូច្នោះហើយ វាជាកាតព្វកិច្ចដ៏ពិសិដ្ឋរបស់មនុស្សលោក ដែលត្រូវកត់ត្រាបំលាស់ប្តូរសង្គម ព្រោះមានតែតាមរយៈការផ្លាស់ប្តូរទាំងនោះហើយ ដែលឆន្ទៈរបស់ព្រះត្រូវបានបង្ហាញ ។

សំណួរ៖ តើសាសនាជះឥទ្ធិពលលើការសំលឹងមើលអតីតកាលរបស់មនុស្សយ៉ាងណា?

### ការប្រៀបធៀបប្រវត្តិសាស្ត្របែបសាសនា និងប្រវត្តិសាស្ត្រក្រិកបុរាណ

| | ប្រវត្តិសាស្ត្រក្រិកបុរាណ | ប្រវត្តិសាស្ត្របែបសាសនា |
|---|---|---|
| មូលហេតុនៃការសរសេរ | ដើម្បីរក្សាសមិទ្ធិផលមនុស្សជំនាន់មុនអោយមនុស្សជំនាន់ក្រោយបានដឹង | - បង្ហាញឆន្ទៈព្រះលើផែនដី<br>- លើកតម្កើងព្រះជាម្ចាស់ |

| | | |
|---|---|---|
| ប្រធានបទ | សង្គ្រាម, នយោបាយ, និងបដិវត្តន៍ | ជីវប្រវត្តិសន្តបុគ្គល, ជីវិត «បុគ្គលព្រះជ្រើសរើស» |
| ប្រភពព័ត៌មាន | កំណត់ត្រាសង្គ្រាម, ផែនទី, សព្វាវុធ | អភិនិហារ, ទំនាយ ឬការប្រមើល, គ្រោះធម្មជាតិ |
| អត្ថន័យក្រោយបានសរសេរចប់ | បង្ហាញពីការវិវត្តន៍របស់មនុស្ស (បើមានកំណត់ត្រាពីមួយជំនាន់ទៅមួយជំនាន់ទៀត យើងអាចសង្កេតមើលឬប្រៀបធៀបការវិវត្តន៍) | - រៀបចំចង់ក្រងរូបភាពអតីតកាល (ឆន្ទៈព្រះនៅគ្រប់អ្វីៗទាំងអស់)<br>- អប់រំសីលធម៌រស់នៅ(សាងបាប បានបាប)<br>- ប្រវត្តិសាស្ត្រជាមេរៀនប្រៀនប្រដៅដោយព្រះ |

ដូច្នេះហើយ ប្រវត្តិវិទូបែបសាសនា ចាប់ផ្តើមសរសេរប្រវត្តិសាស្ត្រដែលដឹងលទ្ធផលរួចស្រាប់ទៅហើយ ពោលគឺបង្ហាញពីភាពអស្ចារ្យរបស់ព្រះជាម្ចាស់ ។

## ៣.២. ទ្រឹស្តីប្រវត្តិសាស្ត្រចិនបុរាណ

ទំនៀមទម្លាប់កត់ត្រាដ៏សំបូរបែប យ៉ាងខ្ជាប់ខ្ជួន និងការសង្កត់ធ្ងន់កាន់តែខ្លាំងឡើងលើប្រវត្តិសាស្ត្រដើម្បីជាការបង្ហាញពីគំរូសីលធម៌ គឺជាលក្ខណៈសម្គាល់នៃវិជ្ជាការសរសេរប្រវត្តិសាស្ត្រចិនដំបូងបំផុត។ ប្រវត្តិវិទូចិនដំបូងគេ ប្រហែលជាអ្នកកត់ត្រារាជកិច្ច។ នៅក្នុងរាជវាំង នៅពេលរចនាសម្ព័ន្ធការិយាធិបតេយ្យក្នុងចក្រភពចិនមានការរីកចម្រើន អ្នកប្រវត្តិសាស្ត្របានកាន់កាប់ធំៗ ក្នុងការិយាល័យជាន់ខ្ពស់។ ប្រវត្តិសាស្ត្រទទួលបានកិត្យានុភាពតាមរយៈគំនិតរបស់ទស្សនវិទូខុងជឺ (៥៥១-៤៧៩ មុនគ្រឹស្តសករាជ) ដែលត្រូវបានគេយល់ច្រលំថាបានសរសេរ «ជុនឈី» (កំណត់ត្រានិទាឃរដូវនិងសរទរដូវ) និង «ស៊ូជូ» (ប្រវត្តិសាស្ត្របុរាណ) ។ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងស្នាដៃទាំងនេះ គំនិតប្រវត្តិសាស្ត្រចិនមានលក្ខណៈផ្តោតលើការអប់រំសីលធម៌ដ៏ជ្រាលជ្រៅ៖ គុណធម៌ត្រូវបានបង្កើតឡើងដោយយកគំរូតាមដូនតារបស់មនុស្សម្នាក់ៗ។ [វិជ្ជាការសរសេរប្រវត្តិសាស្ត្ររបស់ពួកគេ] មានការចាប់អារម្មណ៍ខ្លាំងជាបន្តបន្ទាប់ ទៅលើទម្រង់នៃស្ថាប័នគ្រប់គ្រងរដ្ឋ និងការសង្កត់ធ្ងន់ជាញឹកញាប់លើទ្រឹស្តី «អាណត្តិនៃឋានសួគ៌»៖ ជំនឿដែលថាព្រះមហាក្សត្របានគ្រប់គ្រងដោយរាជក្រឹត្យរបស់ឋានសួគ៌ ដែលនឹងត្រូវដកសិទ្ធិអំណាចមកវិញ ប្រសិនបើទ្រង់បានប្រព្រឹត្តអំពើអាក្រក់។

ការសរសេរប្រវត្តិសាស្ត្រចិន បានចាប់ផ្តើមយូរយារជំណាលគ្នានឹងបណ្តាបស្ចឹមប្រទេសដែរ ។ អត្ថបទប្រវត្តិសាស្ត្រចិនដំបូង ត្រូវបានសរសេរឡើងក្នុងកំឡុងឆ្នាំ ៣០០ មុនគ្រឹស្តសករាជ ។ ប្រវត្តិសាស្ត្រនោះត្រូវមានចំណងជើងថា «**ស៊ីជី** (Shiji)» ដែលអាចមានន័យថាជា **កំណត់ត្រាមហាប្រវត្តិវិទូ** ដែលត្រូវបានសរសេរដោយលោក **ស៊ីម៉ា ឈៀន** (Sima Qian) ។ មែនទែនទៅ ស៊ីជី គឺជាកំណត់ហេតុនៃប្រវត្តិសាស្ត្រចិនទាំងមូល ចាប់តាំងពីសម័យទេវកថា រហូតដល់ពេលបង្កើតរាជវង្សហាននៅឆ្នាំ ២០៦ មុនគ្រឹស្តសករាជ។ រឿងរ៉ាវ ក្នុងកំណត់ត្រាស៊ីជីកាន់តែលម្អិតនៅពេលខិតជិតមកដល់សម័យលោក ស៊ីម៉ា ឈៀន ដោយសារគាត់ អាចសាកសួរសាក្សីដែលបានឃើញផ្ទាល់ភ្នែកពីព្រឹត្តិការណ៍នានា និងប្រើប្រាស់ឯកសារផ្លូវការជាច្រើន។

លើសពីនេះទៅទៀត លោក ស៊ីម៉ា ឈៀន បានសរសេរពីសន្តិវង្ស ដែលទើបតែត្រូវបានផ្តួលរំលំ មុនជំនាន់គាត់ ។ ក្នុងប្រទេសចិន នាសម័យនោះ ត្រូវបានគ្រប់គ្រងដោយអធិរាជមួយអង្គ ដែលគ្រប់គ្រងប្រទេសដោយប្រើប្រព័ន្ធការិយាធិបតេយ្យដ៏ធំមួយ ។ ដើម្បីទទួលបានតួនាទីណាមួយ ក្នុងប្រព័ន្ធការិយាធិបតេយ្យ បេក្ខជនទាំងឡាយ

ត្រូវឆ្លងកាត់ការប្រលងជាច្រើនដំណាក់កាល ប្រកបដោយភាពជោគជ័យ ។ ប្រការនេះជម្រុញអោយមានការអប់រំកម្រិតខ្ពស់ ក្នុងចំណោមវណ្ណៈអភិជន ព្រោះថា ការអប់រំជាឱកាសដើម្បីបានតួនាទី និងអំណាច ។ ផ្នែកមួយនៃរបបការិយាធិបតេយ្យនេះ ត្រូវទទួលខុសត្រូវលើការកត់ត្រារាជកិច្ច ឬប្រវត្តិសាស្ត្រសម្រាប់អធិរាជ ។

គេជឿថា ការចងក្រងប្រវត្តិសាស្ត្រចិន ត្រូវបានចាប់ផ្តើមឡើងនៅពេលដែលអ្នកកត់ត្រាកំណត់ហេតុ ឬពង្សាវតារទាំងនោះ បញ្ចេញបញ្ចូលការបកស្រាយរបស់ខ្លួនបន្ថែម ។

តាមធម្មតាប្រវត្តិសាស្ត្រចិន ត្រូវបានសរសេរអំពីសន្តិវង្សនានា ឬរបារក្សត្រ ។ នៅពេល សន្តិវង្សមួយដួលរលំ សន្តិវង្សថ្មីចាប់ផ្តើមសរសេរពីសន្តិវង្សចាស់ ដោយព្យាយាមស្វែងរកអ្វីដែលពួកគេបានធ្វើដោយត្រឹមត្រូវនិងជោគជ័យខ្លាំង ក៏ដូចជាចងក្រងអ្វីដែលបានធ្វើខុស ។ នោះជាទម្រង់ទូទៅដែលត្រូវបានធ្វើឡើងជាង ២០០០ ឆ្នាំ ។ ប្រវត្តិសាស្ត្រសន្តិវង្សចុងក្រោយ ត្រូវបានសរសេរឡើងនៅដើមសតវត្សរ៍ទី ២០ ដោយ របបសាធារណៈរដ្ឋប្រជាមានិតចិន ។

### រូបត្លុកពន្យល់ពីការផ្លាស់ប្តូររាជវង្សនៅចិនបុរាណ




### លក្ខណៈពិសេសមួយចំនួននៃការសរសេរប្រវត្តិសាស្ត្រចិន ៖

ប្រវត្តិវិទូចិនបុរាណយល់ថា ការកកើត ឬដួលរលំនៃសន្តិវង្សនីមួយៗ គឺជាហុច «អាណត្តិនៃឋានសួគ៌» បន្តគ្នា ។ ប្រវត្តិវិទូចិនជឿថា អធិរាជត្រូវបានឋានសួគ៌ជ្រើសរើសអោយគ្រប់គ្រងនគរ ។

តាមទស្សនៈនេះសន្តិវង្សថ្មីមួយ ត្រូវបានបង្កើតឡើងដោយបុគ្គលណាម្នាក់ ដែលមានសីលធម៌ និងគុណធម៌ខ្ពស់ ។ បន្តិចម្តងៗ ក្នុងសន្តិវង្សនោះ សីលធម៌កាន់តែធ្លាក់ចុះ ពុករលួយ ឬអំពើភ្លើតភ្លើនកាន់តែច្រើនឡើងៗ ។ អំពើអសីលធម៌នៃសន្តិវង្សនោះ អាចត្រូវស្តែងឡើងតាមរយៈគ្រោះធម្មជាតិ ការបះបោរ និងការឈ្លានពានពីសំណាក់បរទេស ។ យូរៗទៅ សន្តិវង្សនោះកាន់តែចុះអន់ខ្សោយ រហូតត្រូវគេផ្តួលរំលំ ហើយក៏កើតមានសន្តិវង្សថ្មីមកជំនួស ។

ទ្រឹស្តីនេះមានជាតុមួយចំនួនជា«វដ្តនៃប្រវត្តិសាស្ត្រ» ។ វដ្តនៃប្រវត្តិសាស្ត្រ គឺជាជំនឿដែលថា ប្រវត្តិសាស្ត្រមានសណ្ឋានជារង្វង់ ឬតែងតែកើតឡើង ច្រំដែលៗ ។ តាមទស្សនៈនេះ គ្មាននរណាម្នាក់អាចគេចចេញពីកង់ប្រវត្តិសាស្ត្រ ដែលតែងតែវិលចុះវិលឡើងដដែលៗ នោះឡើយ ។ ប្រវត្តិសាស្ត្រត្រូវបានចង់ក្រងឡើង ដើម្បីអោយមនុស្សលោកអាចកំណត់ថា ពួកគេកំពុងស្ថិតនៅទីណាក្នុងកង់ប្រវត្តិសាស្ត្រ ហើយព្រឹត្តិការណ៍អ្វីនឹងកើតឡើងជាបន្តបន្ទាប់ ។

ដោយសារប្រវត្តិសាស្ត្រមានសណ្ឋានជារង្វង់ វាហាក់ដូចជាថា មាននរណាម្នាក់ ឬអ្វីមួយ (ក្នុងករណីនេះ ឋានសួគ៌) កំពុងគ្រប់គ្រងប្រវត្តិសាស្ត្រមនុស្សលោក ។

ទ្រឹស្តីនេះ ក៏អះអាងផងដែរថា មានតែមេដឹកនាំពិតប្រាកដតែមួយគត់ ដែលកំពុងត្រួតត្រានគរ ។ ប្រការនេះ អនុញ្ញាតអោយព្រះចៅអធិរាជមានអំណាចធំធេងឥតព្រំដែន ព្រោះថា ព្រះអង្គជាមេដឹកនាំស្របច្បាប់តែមួយគត់ ដែលទទួលសិទ្ធិពីព្រះជាម្ចាស់ ។ នេះជាប្រវត្តិសាស្ត្រដែលបម្រើព្រះចៅអធិរាជ ធ្វើអោយអធិរាជកាន់តែមានអំណាចលើសលុប ។ នេះជាគោលដៅរបស់វា ។

ប៉ុន្តែ វាក៏ជាប្រវត្តិសាស្ត្រ ដែលគាំទ្រអោយមានបដិវត្តន៍ និងទម្លាក់មេដឹកនាំចោលម្សៀតផងដែរ ។ ក្នុងប្រវត្តិសាស្ត្រចិន មេដឹកនាំដំបូងនៃសន្តិវង្សនីមួយៗ តែងតែជាបុគ្គលខ្លាំង និងស្អាតស្អំ ។ បន្តិចម្តងៗ មេដឹកនាំនៃសន្តិវង្សនោះកាន់តែពុករលួយ ហើយអធិរាជចុងក្រោយជាមនុស្សចោលម្សៀត អត់បានការ ពុករលួយ រហូតត្រូវគេផ្តួលរំលំ ព្រោះប្រវត្តិសាស្ត្រទាមទារយ៉ាងដូច្នោះ ។ ប្រវត្តិសាស្ត្របែបនេះ ជម្រុញការទម្លាក់មេដឹកនាំចោលម្សៀត ហើយគាំទ្រពេញទំហឹងចំពោះមេដឹកល្អ ដឹងសុខទុក្ខរាស្ត្រគ្រប់ស្រទាប់វណ្ណៈ ។ នេះជាការក្រើនរម្លឹកអធិរាជនីមួយៗពីទំនួលខុសត្រូវរបស់ខ្លួនចំពោះប្រទេសជាតិ ៖ ប្រសិនបើពួកគេជាមេដឹកនាំអត់កំណើត ពួកគេនឹងត្រូវផ្តួលរំលំជាមិនខាន ព្រោះប្រវត្តិសាស្ត្រមានតម្រូវការបែបនេះ ។

ក៏ដូចជាប្រវត្តិវិទូបែបសាសនាដែរ ប្រវត្តិវិទូចិនចង់ក្រងប្រវត្តិសាស្ត្រដែលគេអាចដឹងលទ្ធផលរួចជាស្រេច (អាណត្តិនៃឋានសួគ៌ត្រូវបន្តពីសន្តិវង្សទៅសន្តិវង្សមួយទៀត) ។ គ្មានការប្រែប្រួលខុសពីនេះ ។

បើសម្លឹងមើលជារួម ប្រវត្តិវិទូចិនបុរាណបានសរសេរផ្តោតលើវត្ថុវិស័យបានយ៉ាងល្អ ។ ថ្វីត្បិតតែពួកគេមិនបានធ្វើការបកស្រាយពីប្រវត្តិសាស្ត្រក៏ដោយ ក៏ពួកគេ មុខជាញឹកញាប់ ត្រូវបានប្រឈម ជាមួយប្រភពឯកសារដែលមានទំនាស់។ ក្នុងករណីបែបនេះជាធម្មតាពួកគេជ្រើសរើសយកប្រភពមួយទោះបីពួកគេមិនដែលយោងទៅប្រភពរបស់ពួកគេ ឬពន្យល់ពីជម្រើស ដែលពួកគេបានជ្រើសរើសក៏ដោយ។ ការរិះគន់ជាប្រវត្តិសាស្ត្រនៅក្នុងប្រទេសចិនត្រូវបានរាំងដោយសីលធម៌ដោយសារតែការអោយតម្លៃប្បធម៌ខ្ពស់លើបុព្វបុរស។ ការជជែកវែកញែកគ្នារបស់ក្រិកនឹងមិនត្រូវប្រទះឃើញនៅចិនឡើយ ។

ទោះយ៉ាងណា នៅប្រហែលឆ្នាំ ៧១០ នៃគ្រឹស្តសករាជ, លីវ ហ្ស៊ីជី(Liu Zhiji, ៦៦១-៧២១)បានសរសេរ

*ស៊ីគុង* (ទស្សនវិស័យប្រវត្តិសាស្ត្រ) ដែលជាការងារទូលំទូលាយដំបូងគេ (ក្នុងចំណោមភាសាទាំងអស់)លើការរិះគន់ជាប្រវត្តិសាស្ត្របែបរិះគន់ ។ សម្រាប់គាត់ ការសរសេរប្រវត្តិសាស្ត្រ មានបេសកកម្មថ្លៃថ្លា និងមានទស្សនៈវិស័យបែបខុងជឺនិយម ខ្លាំងណាស់ ៖

មនុស្សរស់នៅក្នុងរូបរាងកាយរបស់ខ្លួន នៅក្រោមមេឃនិងលើផែនដីហើយជីវិតរបស់គាត់ប្រៀបដូចជាសត្វល្អិតហោះហើរនៅរដូវក្តៅ ដូចជាពន្លឺពណ៌សមួយ ឆ្លះតាមរយៈស្នាមប្រេះនៅក្នុងជញ្ជាំង។ ទោះយ៉ាងណា គាត់ខ្មាស់អៀនក្នុងការគិតថាក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ គុណសម្បត្តិរបស់គាត់នឹងមិនត្រូវបានគេដឹងលឺ ... គ្មាននរណាម្នាក់ដែលមិនចេះនឿយហត់ក្នុងការស្វែងរកកិត្យានុភាពនិងកិត្តិនាម។ ដោយសារហេតុអ្វីទៅ? ពីព្រោះមនុស្សគ្រប់គ្នាមានបេះដូងចង់បានភាពអមត ។ ហើយតើភាពអមតៈ គឺជាអ្វី? មិនត្រឹមតែមានឈ្មោះមួយដែលបានសរសេរនៅក្នុងសៀវភៅមួយឡើយ។

ទស្សនៈរបស់ លីវ ហ្ស៊ីជី មានឥទ្ធិពលយូរអង្វែង។ ជាការពិតគោលការណ៍មួយចំនួនរបស់គាត់នៅតែត្រូវបានណែនាំដល់ ប្រវត្តិសាស្ត្រថ្មីថ្មោងៈ ការសង្ស័យអំពីប្រភពឯកសារ, សេរីភាពពីការជឿស្លុបលើបណ្តាអ្នកប្រាជ្ញល្បីៗ, ភាពចាំបាច់នៃចំណេះដឹងទូលំទូលាយនៃប្រភពឯកសារមុនពេលធ្វើការជ្រើសរើស និងការទទូចលើអំណះអំណាងដែលគាំទ្រដោយភស្តុតាងយ៉ាងទូលំទូលាយ។

## ៣.៣. សេចក្តីសន្និដ្ឋាន

ក្រោយការដួលរលំចក្រភពរ៉ូម៉ាំង ការសរសេរប្រវត្តិសាស្ត្រ ទាំងនៅក្នុងបស្ចឹមប្រទេស និងបូព៌ាប្រទេស បានឆ្លងកាត់សម័យកាលមួយដ៏យូរ ដែលប្រវត្តិសាស្ត្រត្រូវបានសរសេរឡើង ដើម្បីតែរក្សាស្ថានភាពអោយនៅដដែលពោល គឺរក្សាការពារអំណាចនយោបាយនិងសាសនា ដែលមានស្រាប់ ។ នៅទ្វីបអឺរ៉ុប ព្រះសង្ឃប្រើប្រាស់ប្រវត្តិសាស្ត្រដើម្បីបង្ហាញមហិទ្ធិឫទ្ធិរបស់ព្រះជាម្ចាស់ ឯនៅក្នុងប្រទេសចិន ប្រវត្តិវិទូនានាសរសេរវង្ហនៃប្រវត្តិសាស្ត្រដែលគាំទ្រអំណាចលើសលុបរបស់ព្រះចៅអធិរាជលើនគរចិន ហើយដែលគ្រើនរម្លឹកពីទំនួលខុសត្រូវរបស់ព្រះអង្គចំពោះប្រទេសជាតិ ៕

### គំនូសបំព្រួញ៖ អក្សរចិន សម្គាល់ស្តេចឬអធិរាជ




តាមតួអក្សរចិន ព្រះរាជា គឺជាអ្នកភ្ជាប់ទំនាក់ទំនងឋានសួគ៌ នឹងមនុស្សលើផែនដី ។

**គំនូសបំព្រួញ៖ វដ្តនៃសន្តិវង្សនីមួយៗ ក្នុងប្រទេសចិនបុរាណ**



# មេរៀនទី ៤ ៖ ទ្រឹស្តីប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រ

## ៤.១. សញ្ញាណដើម

១ ប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រ (Scientific History) គឺជាទ្រឹស្តីមួយ ដែលមានឧត្តមានុភាព[៥] សម្រាប់ប្រវត្តិវិទ្យា តាំងពីដើមសតវត្សរ៍ទី១៨ ដល់ ដើមសតវត្សរ៍ទី ១៩ ។ ទ្រឹស្តីនេះថ្លែងថា ប្រវត្តិវិទ្យា គឺជាវិទ្យាសាស្ត្រ ដែលផ្អែកលើ**គោលការណ៍យថាភូត**[៦] ។ ដូច្នេះហើយប្រវត្តិវិទូ អាចស្វែងយល់អំពីអតីតកាលបានតាមរយៈ ការធ្វើការសិក្សាស្រាវជ្រាវ ។ ការស្រាវជ្រាវនេះនឹងចង្អុលបង្ហាញអោយប្រវត្តិវិទូដឹងនូវ អ្វីដែលបានកើតឡើងយ៉ាង «ពិតប្រាកដ» ដែលបន្ទាប់មកទៀត ប្រវត្តិវិទូនឹងបង្ហាញវាដល់សារធារណៈជនទូទៅ ។

## ៤.២. លោក លេអូផូលដ៍ វុន រ៉ែងឃ័រ

២ លោក លេអូផូលដ៍ វុន រ៉ែងឃ័រ (Leopold Von Ranke) (១៧៩៥ - ១៨៨៦ នៃគ្រិស្តសករាជ) គឺជាប្រវត្តិវិទូជនជាតិអាឡឺម៉ង់ មែនទែនទៅ គាត់ក៏ជាទស្សនៈវិទូស្តីពីប្រវត្តិសាស្ត្រដ៏មានឥទ្ធិពលបំផុត ប្រចាំសតវត្សរ៍ទី ១៩ ។

៣ តាមពិត លោក រ៉ែងឃ័រ ធ្លាប់ជាអ្នកប្រវត្តិសាស្ត្របែប*សាសនានិយម* ដែលគោលបំណងសំខាន់ក្នុងការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ ត្រូវបង្ហាញពីតួនាទីព្រះជាម្ចាស់ នៅក្នុងពិភពលោកយើងនេះ ។ ម្យ៉ាងទៀត គាត់ក៏ធ្លាប់ជាអ្នកប្រវត្តិសាស្ត្របែប*មនុស្សនិយម*(ដូចលោកហេរ៉ូដូទឹសដែរ) ដែលជាប្រវត្តិវិទូខិតខំរកអោយឃើញ និងបង្ហាញនូវអ្វីដែលជាសមិទ្ធិផលរបស់មនុស្សលោក ។ នៅក្នុងក្របខ័ណ្ឌប្រវត្តិសាស្ត្របែបនេះ សេចក្តីសន្និដ្ឋាន (ឬលទ្ធផលនៃការស្រាវជ្រាវ)ត្រូវបានគេដឹងរួចជាស្រេចហើយ ពោលគឺស្ទើរតែរកឃើញលទ្ធផលមុនធ្វើការស្រាវជ្រាវទៅទៀត ។

៤ លោក រ៉ែងឃ័រ បានបដិសេធន៍ចោលនូវវិធីសាស្ត្រស្រាវជ្រាវនិងចងក្រងប្រវត្តិសាស្ត្របែបនេះ ។ គាត់យល់ឃើញថា ប្រវត្តិវិទូត្រូវតែយកប្រភពឯកសារដើមមកសិក្សាអោយច្បាស់ និងទាញសេចក្តីសន្និដ្ឋានតាមអ្វីដែលប្រភពព័ត៌មានទាំងនោះចង្អុលបង្ហាញ ។

៥ នៅក្នុងស្នាដៃដំបូងរបស់គាត់ ដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រនៃប្រជាជាតិភាសាឡាតាំង និងអាឡឺម៉ង់ ឆ្នាំ ១៤៩៤ ដល់ ១៥១៤» បោះពុម្ពឆ្នាំ ១៨២៤ លោក រ៉ែងឃ័រ បានសរសេរអារម្មណ៍កថា ដោយក្នុងនោះលោកបានប្រកាសថា ប្រវត្តិសាស្ត្រមិនចាំបាច់វិនិច្ឆ័យលើព្រឹត្តិការណ៍អតីតកាល សម្រាប់អប់រំមនុស្សបច្ចុប្បន្ន ដើម្បីប្រយោជន៍ អនាគតកាលនោះទេ ប៉ុន្តែត្រូវបង្ហាញតែ «អ្វីដែលបានកើតឡើងយ៉ាងពិតប្រាកដ» ។ នេះគឺជាការអះអាងដែលមិនធ្លាប់មានពីមុនមកស្តីពីវត្ថុវិស័យភាព ឬ **យថាហេតុ** ។

៦ លោករ៉ែងឃ័រ បានថ្លែងថា៖ «ខាងក្រុមយើង យើងមានទស្សនៈផ្សេង ចំពោះប្រវត្តិសាស្ត្រ ។ វាគឺជាសច្ចៈភាពសុទ្ធសាធ (Naked Truth) ដោយឥតមានការបញ្ចេញបញ្ចូលបន្ថែម, ជាការសិក្សាស្រាវជ្រាវដោយផ្ចិតផ្ចង់លើប្រធានបទពិសេសណាមួយ, ជាអ្វីផ្សេងក្រៅពីស្នាព្រហស្តរបស់ព្រះ ជាការបដិសេធន៍ចោលនូវការប្រឌិត

[៥] អានុភាពខ្ពង់ខ្ពស់ ឬខ្លាំងក្រៃ ។
[៦] តាមសេចក្តីពិត តាមដំណើរដែលកើតមានឡើងប្រាកដ ។ (Nath, ១៩៦៧)

ខុសពីការពិតទាំងឡាយ ទោះបីជាវាមានទំហំតូចប៉ុណ្ណាក៏ដោយ និងជាការមិនទទួលស្គាល់នូវភាពស្រមើស្រម៉ៃរវើរវាយផ្សេងៗ ។»

៧ លោក រ៉េងឃ័រ មិនទទួលស្គាល់តួនាទីប្រវត្តិវិទូ ក្នុងការបកស្រាយរបស់ប្រវត្តិសាស្ត្រទេ ។ នេះបានជះឥទ្ធិពលលើមូលហេតុរបស់គាត់ក្នុងការសរសេរប្រវត្តិសាស្ត្រ៖ តួនាទីតែមួយគត់ ដែលគាត់បានកំណត់នោះ គឺប្រវត្តិសាស្ត្រត្រូវបង្ហាញការពិតពីអតីតកាល ។ គាត់មិនជឿថា ប្រវត្តិសាស្ត្រ អាច ឬ គួរតែ ត្រូវបានគេប្រើប្រាស់សម្រាប់អប់រំទូន្មានមនុស្សលើបញ្ហាអ្វីមួយអំពីបច្ចុប្បន្ន ឬអនាគត ឡើយ ។

៨ ទោះជាយ៉ាងណា ប្រការនេះនាំអោយមានចម្ងល់លើទ្រឹស្តីរបស់គាត់ថា តើយើងអាចដឹងថាអ្វីដែលបានកើតឡើង «យ៉ាងពិតប្រាកដ» នៅក្នុងពេលអតីតកាលបានយ៉ាងដូចម្តេច ? នេះគឺជាផ្នែកមួយនៃ**ដំណើរការជ្រើសរើស**ដែលប្រវត្តិវិទូទាំងអស់ ត្រូវធ្វើឡើងចំពោះអតីតកាល ។

៩ យ៉ាងណាមិញ លោក រ៉េងឃ័រ មិនចង់អោយប្រវត្តិវិទូយករឿងឬបញ្ហាផ្ទាល់ខ្លួនមកលាយឡំនឹងព្រឹត្តិការណ៍អតីតកាលដែលគេកំពុងតែសិក្សានោះឡើយ ។ លោក រ៉េងឃ័រ កម្រនឹងប្រើប្រាស់ពាក្យ «ខ្ញុំ» ក្នុងសំណេររបស់គាត់ណាស់ ដោយចូលចិត្តបង្ហាញស្នាដៃរបស់គាត់ ក្នុងលក្ខណៈជាការនិទានសាច់រឿងដោយផ្សារភ្ជាប់នឹងការពិត មិនមែនជាការបកស្រាយទេ ។ គាត់បានសរសេរថា គាត់ចង់បំបាំងខ្លួនគាត់ ហើយចង់ត្រឹមតែរៀបរាប់ពីបញ្ហា (ដែលកំពុងសិក្សា) អោយវាមើលទៅមានលក្ខណៈ**សុក្រិត**គួរជាទីទុកចិត្ត ។

១០ តើយើងអាចជ្រើសយកព្រឹត្តិការណ៍ណាមួយ ដែលថាមានសារៈសំខាន់សមល្មម សម្រាប់អោយយើងសរសេរ? តើការដែលយើងធ្វើការជ្រើសរើសយកព្រឹត្តិការណ៍ណាមួយមកសរសេរ មិនមែនជាការបកស្រាយលើប្រធានបទ (ដែលលោក រ៉េងឃ័រ ហាមមិនអោយប្រវត្តិវិទូបកស្រាយ) ឬក៏យ៉ាងណា ? ជាឧទាហរណ៍ យើងដឹងហើយថា លោក ហេរ៉ូដូទឹស បានសរសេររៀបរាប់ពី សង្គ្រាមនិងបញ្ហានយោបាយ ដោយសារគាត់ចង់បង្ហាញអោយឃើញទិដ្ឋភាពអស្ចារ្យ ឬ សមិទ្ធិផលរបស់មនុស្សលោក ដូច្នេះ ប្រាកដណាស់ អ្វីដែលប្រវត្តិវិទូនានាបានជ្រើសរើសយកមកសរសេរ សុទ្ធតែមានសារៈសំខាន់ទាំងអស់ ។

១១ លើសពីនេះទៀត លោក រ៉េងឃ័រ មិនអនុញ្ញាតអោយជ្រើសរើសយកប្រភពព័ត៌មាន ដោយការចៃដន្យទេ ។ អ្វីដែលនៅសេសសល់ពីអតីតកាល, អ្វីដែលប្រវត្តិវិទូអាចយកមកប្រើប្រាស់បាន គឺជារបស់ចៃដន្យរួចទៅហើយ នោះគឺ អ្វីៗក៏ដោយអោយតែមិនត្រូវបានបំផ្លិចបំផ្លាញពីអតីតកាល ។ ប្រវត្តិវិទូមិនដឹងច្បាស់ថាអ្វីដែលបានកើតឡើង «យ៉ាងពិតប្រាកដ» នោះទេ ដោយសារតែពួកគេមិនបានកើតទាន់សម័យកាល ដែលព្រឹត្តិការណ៍ណាមួយបានកើតឡើង ។ ដូច្នេះ មធ្យោបាយតែមួយគត់ ដែលពួកគេអាចស្វែងយល់ពីអតីតកាលបាន គឺមានតែតាមរយៈប្រភពព័ត៌មាន ។ ប្រសិនបើប្រភពព័ត៌មានទាំងនេះ មិនតំណាងអោយអ្វីដែលបានកើតឡើង «យ៉ាងពិតប្រាកដ» ទេ ប្រវត្តិវិទូក៏មិនអាចស្វែងរកការពិតបានដែរ ។

១២ «ប្រវត្តិវិទ្យាខុសពីវិទ្យាសាស្ត្រដទៃទៀតដោយសារវាក៏ជាសិល្បៈផងដែរ ។ ប្រវត្តិវិទ្យា គឺជាវិទ្យាសាស្ត្រនៃការប្រមូល(ទិន្នន័យ) ស្វែងរក(ព័ត៌មាន) និងទម្លុះទម្លាយរកការពិត តែវាជាសិល្បៈដោយសារវាចងក្រងឡើងវិញនិងពណ៌នាការពិត ដែលត្រូវបានគេរកឃើញ និងទទួលស្គាល់ ។»

**តើអ្វីទៅដែលលោក រ៉ែងឃ័រ គិតថា ជាសច្ចៈភាព នៃអតីតកាល?**

១៣ លោក រ៉ែងឃ័រ ជឿថាប្រវត្តិសាស្ត្របានបង្ហាញយើងនូវឌ្ឍនភាពឬការវិវត្តន៍ជាហូរហែររបស់មនុស្សលោក ។ នេះគឺជាមនោគតិនៃប្រវត្តិសាស្ត្រ រាងបណ្តោយ (Linear Conception of History) ពោលវាជាគំនិតដែលចែងថា ប្រវត្តិសាស្ត្រ មានចលនាវិវត្តន៍ពីកន្លែងមួយទៅកន្លែងមួយទៀត។ គាត់ជឿថា«មិនអាចប្រកែកបានយើងត្រូវបង្ខំអោយជឿថា គោលបំណងនិងកិច្ចខិតខំប្រឹងប្រែងមនុស្សជាតិ ត្រូវបានទទួលរងឥទ្ធិពលនៃព្រឹត្តិការណ៍នានា យ៉ាងស្ងប់ស្ងាត់ ដោយមិនដឹងខ្លួន និងឥតឈប់ឈរ។»

១៤ គាត់ជឿថាមានរចនាសម្ព័ន្ធ ឬមាន«សច្ចៈភាព» ដែលប្រវត្តិវិទូអាចរកឃើញ បើគេសង្កេត និងពិនិត្យអោយបានស៊ីជម្រៅ ។ នេះគឺជាទិសដៅនៃប្រវត្តិសាស្ត្រ ។ ប្រវត្តិសាស្ត្រមានទិសដៅរបស់វាផ្ទាល់ ហើយព្រឹត្តិការណ៍របស់មនុស្សជាតិត្រូវតាមបណ្តោយទិសដៅនោះ ។ ដូច្នេះ មនុស្សមិនមានអំណាចគ្រប់គ្រងលើទិសដៅប្រវត្តិសាស្ត្រឡើយ នេះគឺជាកម្លាំងរបស់វាផ្ទាល់ ។ វាសឹងតែមានជីវិតផ្ទាល់ខ្លួន បានន័យថា វាមានធន្ទៈឬកម្លាំងទាញជីវិតមនុស្សជាតិ និងព្រឹត្តិការណ៍ផ្សេងៗ អោយទៅស្របទិសដៅរបស់វា ។

១៥ ដោយសារតែស្នាដៃដ៏មានឥទ្ធិពលរបស់លោក រ៉ែងឃ័រ បានទូន្មានអោយប្រវត្តិវិទូទាំងអស់មិនគួរលាយទ្បំរឿងផ្ទាល់ខ្លួន មកនិយាយក្នុងការចងក្រងប្រវត្តិសាស្ត្រ (តែបើជៀសមិនផុត អាចនិយាយតិចតួចបានហើយ) វិធីសាស្ត្រសរសេរប្រវត្តិសាស្ត្រភាគច្រើន គឺជាដំណើរការនៃការលុបបំបាត់ភាពលម្អៀង[៧]៕

## ៤.៣. លំហាត់សង្ខេបមេរៀន

ចូរអានអត្ថបទមេរៀនខាងលើ ហើយសង្ខេបកថាខ័ណ្ឌនីមួយៗដោយសរសេរពាក្យគន្លឹះ(ខ្លីៗ) នៅរឹមទំព័រក្បែរកថាខ័ណ្ឌទាំងនោះ ។ ជាចុងក្រោយ ចូរ**សរសេរសង្ខេបមេរៀន**ទាំងមូលត្រឹម**មួយកថាខ័ណ្ឌ** ដោយប្រើប្រាស់ពាក្យគន្លឹះខាងលើ ។ ការធ្វើលំហាត់នេះ អាចជួយនិស្សិតត្រៀមលក្ខណៈធ្វើកិច្ចការក្រុម អោយមានប្រសិទ្ធភាព និងប្រសិទ្ធផល ។ និស្សិតអាចស្វែងយល់ពីវិធីសាស្ត្រសង្ខេបមេរៀននៅមេរៀនទី ១២ ក្នុងជំពូកទី ២ ។

ទន្ទឹមនឹងនេះ មើលគន្លឹះនិងគម្រូ ក្នុងការសរសេរកថាខ័ណ្ឌ និងតែងសេចក្តី និងវិធីសាស្ត្រធ្វើបតបង្ហាញផងដែរ ។

## ៤.៤. អំនានប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ[៨]

១ «វាជាមហិច្ឆតារបស់ប្រជាជាតិទាំងអស់ ដែលមានវប្បធម៌អក្សរសាស្ត្ររីកចម្រើន ចង់មានការអធិប្បាយ[៩] ស្របគ្នានិងច្បាស់លាស់ស្តីពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ ហើយវាមានតម្លៃមិនអាចកាត់ថ្លៃបាន ចំពោះគ្រប់ជាតិសាសន៍ក្នុងការទទួលបាននូវការអធិប្បាយបែបនោះ ដែលនឹងគ្របដណ្តប់ព្រឹត្តិការណ៍គ្រប់យុគសម័យ (epochs), ដែលជាការពិតឥតក្លែងក្លាយ, ទោះផ្អែកលើការស្រាវជ្រាវហ្មត់ចត់ តែអាចទាក់ទាញចិត្តអ្នកអាន ។ មានតែតាមវិធីនេះទេ

---

[៧] ជាការវិនិច្ឆ័យក្តីដោយអគតិ ទោះលម្អៀងដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ឬភយាគតិ ។

[៨] លោក លេអូផូលដ៍ វុន រ៉ែងឃ័រ, ផ្អែកអារម្មណ៍កថា *ប្រវត្តិសាស្ត្រអង់គ្លេសពិសេសក្នុងសតវត្សរ៍ទី ១៧, ភាគ ១*។

[៩] សេចក្តីពន្យល់មានអាងឬព័ស្តុតាង ។ (Nath, ១៩៦៧)

ទើបប្រជាជាតិមួយអាចមានសតិសម្បជញ្ញៈខ្ពស់ត្រចះត្រចង់ និងរួមគ្នាជាផ្លូងមួយ តាមរយៈដំណើររឿងនោះ និងអាចស្គាល់ជាតិកំណើត ការរីកចម្រើន និងអត្តញ្ញាណរបស់ខ្លួន ។

២ ប៉ុន្តែ យើងអាចឆ្ងល់ថា តើរហូតមកដល់ពេលនេះ កិច្ចការឬស្នាដៃដ៏មានសារៈសំខាន់ និងទូលំទូលាយបែបនេះ ត្រូវបានបង្កើតឡើងហើយឬនៅ ហើយតើគេអាចនឹងបង្កើតវាបានឬទេ ? តើអ្នកណាអាចអនុវត្តការសិក្សាស្រាវជ្រាវស៊ីជម្រៅ (ដូចជាវឌ្ឍនភាពនៃការសិក្សា ដែលឥឡូវនេះ ត្រូវគេចាត់ទុកថាសំខាន់)លើឯកសារដែលមានយ៉ាងច្រើនសម្បើម ដោយមិនបាត់បង់វិសាលភាពរបស់វា ដែរឬទេ? ជាថ្មីម្តងទៀត តើនរណាអាចមានកម្រិតយល់ដឹងចាំបាច់សម្រាប់ស្វែងរកភាពយុត្តិធម៌ដល់សម័យកាលនានា ដោយឆ្លុះបញ្ចាំងពីសកម្មភាពឬព្រឹត្តិការណ៍ផ្នត់គំនិត និងស្តង់ដាសីលធម៌ ក្នុងសម័យកាលនីមួយៗ (ដោយធានាតុល្យភាពរវាងយុគសម័យនីមួយៗ) និងសម្រាប់ស្វែងយល់ពីទំនាក់ទំនងសម័យនីមួយៗទៅនឹងប្រវត្តិសកលលោកទាំងមូល?

៣ យើងត្រូវតែពេញចិត្តនឹងផ្នែកនេះ ក៏ដូចជាផ្នែកដទៃទៀត ប្រសិនបើយើងអាច ឬខំរក្សាភាពល្អឥតខ្ចោះដែលយើងចង់បាន ។ ប្រវត្តិសាស្ត្រដែលត្រូវបានចងក្រងឡើង យ៉ាងផ្ចិតផ្ចង់បំផុត នឹងត្រូវទទួលងារជាកិច្ចការល្អបំផុត។

៤ នៅពេលអ្នកនិពន្ធណាម្នាក់ សម្រេចយករឿងអតីតកាលនៃប្រជាជាតិបរទេសណាមួយជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវរបស់គាត់ គាត់នឹងមិនគិតចង់សរសេរប្រវត្តិសាស្ត្រជាតិនោះអោយបានលម្អិតឡើយ ។ សំរាប់អ្នកនិពន្ធបរទេស កិច្ចការនេះមិនអាចសម្រេចបានឡើយ ។ ប៉ុន្តែ ស្របតាមទស្សនៈផ្ទាល់របស់គាត់ គាត់នឹងសំលឹងមើលសម័យកាលណា ដែលមានឥទ្ធិពលខ្លាំងបំផុត លើការអភិវឌ្ឍន៍របស់មនុស្សជាតិទាំងមូល ។ ដើម្បីជួយអោយគាត់ស្វែងយល់កាន់តែច្បាស់ពីសម័យកាលដែលគាត់ជ្រើសរើស គាត់អាចនឹងរៀបរាប់ពីសម័យកាលផ្សេង ដែលបានកើតឡើងមុន ឬ ក្រោយសម័យកាលនោះ ។

៥ មានការទាក់ទាញពិសេស ក្នុងការតាមដានប្រវត្តិសាស្ត្រនៃប្រជាជាតិអង់គ្លេស ពីមួយសតវត្សរ៍ទៅមួយសតវត្សរ៍ទៀត, ក្នុងការពិចារណាពីភាពបដិបក្ខនៃជាតុផ្សេងៗរួមផ្សំកើតជាជាតិ និងពីជោគវាសនានិងអង្គការចាត់តាំងរបស់សហគមន៍ប្រជាជាតិបស្ចឹមប្រទេសនានា ។ ប៉ុន្តែត្រូវទទួលស្គាល់ជាស្រេចថា បើនិយាយពីសារៈសំខាន់ទូទៅ គ្មានសម័យកាលណាផ្សេងៗទៀត អាចប្រៀបផ្ទឹមនឹងសម័យកាល ដែលពោរពេញដោយសង្គ្រាមសាសនា និងជំលោះនយោបាយ នៅក្នុងសតវត្សរ៍ ទី ១៦ និង ១៧ ឡើយ ...

៦ ... នៅពេលយើងសម្លឹងមើលសណ្ឋានផែនដី រយៈកម្ពស់នៃអ្វីមួយ (ដែលតឹកតាងបញ្ជាក់ពីថាមពលនៃរូបធាតុដើមនិងសកម្ម) បានទាក់ទាញការកត់សម្គាល់ពិសេសរបស់យើង ។ យើងស្ងើចសរសើរដល់ភ្នំធំៗ ដែលផុសឡើងខ្ពស់ហួសតំបន់ទំនាបដែលជាទីលំនៅដ្ឋានរបស់មនុស្ស ។ ដូចគ្នានេះដែរ នៅក្នុងក្របខ័ណ្ឌប្រវត្តិសាស្ត្រ យើងត្រូវបានទាក់ទាញដោយយុគសម័យដែលពោរពេញការរួមកម្លាំងគ្នា ហើយបានបង្កើតជារដ្ឋនិងរាជាណាចក្រនានា, ការបែកបាក់គ្នា នៅពេលមានសង្គ្រាម បញ្ហាចាក់ស្រេះរាប់ពាន់ដែលអាចបណ្តាលអោយមានការបង្កើតអ្វីមួយផ្សេងទៀត ដែលជះឥទ្ធិពលលើលក្ខណៈក្នុងយុគសម័យបន្តបន្ទាប់...

៧ ... ហើយតើយើងអាចកត់សម្គាល់ភាពចៃដន្យជាច្រើននៃការទាស់ទែងខ្វែងគំនិតគ្នានិងនិន្នាការ ដែលយើងជាប់ពាក់ព័ន្ធ នាពេលបច្ចុប្បន្នដោយរបៀបណា? ប៉ុន្តែ នេះមិនមែនជាគោលបំណងរបស់យើងទេ ដែលត្រូវទាញសន្និដ្ឋានរឿងនេះ ... ការដែលដាក់ផលប្រយោជន៍ពេលបច្ចុប្បន្ន ក្នុងការងាររបស់ប្រវត្តិវិទូ ជារឿយៗហាក់ដូចជាដាក់កម្រិតលើលទ្ធផលស្រាវជ្រាវ ... ៕»

# មេរៀនទី ៥ ៖ ទ្រឹស្តីប្រវត្តិសាស្ត្របែបម៉ាក្សស៊ីសនិយម

## ៥.១. ប្រវត្តិម៉ាក្សស៊ីស

ម៉ាក្សស៊ីសនិយម គឺជាទ្រឹស្តីមួយដែលបង្កើតឡើងដោយលោក កាល ម៉ាក្ស អំឡុងពាក់កណ្តាលសតវត្សរ៍ទី ១៩ នៃគ្រឹស្ត័សករាជ ។ វាជាទ្រឹស្តីមួយ ក្នុងចំណោមទ្រឹស្តីនយោបាយនានា ដែលមានឥទ្ធិពលបំផុតនៅក្នុងប្រវត្តិសាស្ត្រ និងបន្តអត្ថិភាពរហូតដល់សព្វថ្ងៃ ។ វាជាទ្រឹស្តីដែលយកប្រវត្តិសាស្ត្រធ្វើជាមូលដ្ឋានគ្រឹះ ។ វិធីសរសេរប្រវត្តិសាស្ត្របែបម៉ាក្សស៊ីសនិយម បានក្លាយជាក្បួនខ្នាតដ៏ពេញនិយមមួយសម្រាប់សរសេរប្រវត្តិសាស្ត្រ ពិសេសនៅអំឡុងឆ្នាំ ១៩០០ - ១៩៦០ ។

កាល ម៉ាក្ស គឺជាជនបដិវត្តន៍, សង្គមវិទូ, ប្រវត្តិវិទូ, និងសេដ្ឋកិច្ចវិទូ ជនជាតិអាឡឺម៉ង់ ។ គាត់កើតនៅប្រទេសអាឡឺម៉ង់ នាឆ្នាំ ១៨១៨, ស្លាប់នៅទីក្រុងឡុងដ៏ នាឆ្នាំ ១៨៨៣ ។ កិច្ចការរបស់គាត់ ដែលល្បីបំផុត មានដូចជា **សេចក្តីប្រកាសបក្សកុម្មុយនីស្ត៍** (១៨៤៨) និង **មូលធននិយម** (១៨៦៧) ។ ស្នាដៃនេះ គឺជាមូលដ្ឋានគ្រឹះនៃទ្រឹស្តីសេដ្ឋកិច្ច នយោបាយ និងប្រវត្តិសាស្ត្រ ដែលត្រូវបានគេហៅថា ម៉ាក្សស៊ីសនិយម ។

ជាគោលការណ៍ ទ្រឹស្តីម៉ាក្សស៊ីសនិយម គឺជាទស្សនៈវិជ្ជាដែលពិភាក្សាលើទំនាក់ទំនងរវាងវណ្ណៈ(សង្គម) នីមួយៗ ។ លោក កាលម៉ាក្ស ជឿជាក់ថា រហូតដល់សម័យគាត់ មានវណ្ណៈបី ៖ មានវណ្ណៈខ្ពស់ ឬ**វណ្ណៈអភិជន,** វណ្ណៈកណ្តាល ឬ **វណ្ណៈគហិបតី,** និង វណ្ណៈទាប ឬ**វណ្ណៈអធន** ដែលរួមមានដូចជា កសិករស៊ីឈ្នួល កម្មករ ឬខ្ញុំកញ្ជះ ។

តាមធម្មតា ពួកអភិជន គឺជាម្ចាស់ដីធំៗ ។ ពួកគេមានទ្រព្យសម្បត្តិស្តុកស្តម្ភណាស់ ។ ចំណែក ពួកវណ្ណៈគហិបតី ជាទូទៅ គឺជាម្ចាស់ហាងទំនិញ ម្ចាស់រោងចក្រ ពាណិជ្ជករ និងអ្នកធ្វើការងារផ្សេងទៀតដែលរកចំណូលបានទៀងទាត់ ។ ពួកគេរស់នៅក្នុងភាពហ៊ឺហា ។ វណ្ណៈទាំងពីរនេះគ្រប់គ្រង**មធ្យោបាយផលិតកម្ម** រួមគ្នា ។ នេះមានន័យថា ពួកគេជាម្ចាស់ដីធ្លី និងរោងចក្រ ជាទីដែលចំណីអាហារ និងផលិតផលផ្សេងៗទៀតត្រូវបានផលិត ។ ពួកគេជាអ្នកគ្រប់គ្រងសេដ្ឋកិច្ច ទាំងមូល ។

វណ្ណៈទាបជាងគេ គឺជាពលករ ។ ពួកគេអាចស៊ីឈ្នួល ធ្វើជាកសិករសម្រាប់ពួកអភិជន ឬ ធ្វើជាកម្មកររោងចក្ររបស់ពួកគហិបតី ។ លោក កាល ម៉ាក្ស ហៅអ្នកធ្វើស្រែចំការថា **កសិករ(ឈ្នួល)** ឬ **ខ្ញុំកញ្ជះ** ។ ទាំងនេះគឺជាពាក្យបញ្ជាក់ថា ពួកគេគ្មានអំណាចអ្វីឡើយ ហើយស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងពីថៅកែឬម្ចាស់ ។ លោក កាល ម៉ាក្ស បានហៅកម្មកររោងចក្រ និងពលករក្នុងវណ្ណៈទាបផ្សេងទៀត ដែលរស់នៅ ក្នុងទីក្រុងថា **ពលជីព** ។

លោកជឿថា ប្រព័ន្ធសង្គមចាស់នេះ មិនមានភាពយុត្តិធម៌ទាល់តែសោះ ។ គាត់គិតថាមិនយុត្តិធម៌ទេ ដែលមនុស្សមួយចំនួន មានដីធ្លី និងរោងចក្រទាំងអស់ តែមិនបានបញ្ចេញពលកម្ម ខណៈដែលអ្នកដទៃ ប្រឹងប្រែងធ្វើការខ្លាំង តែរស់នៅក្នុងភាពក្រីក្រដដែល ។ គាត់បានយល់ថា ប្រការដែលពួកម្ចាស់ដីធ្លីឬថៅកែរោងចក្រ អោយប្រាក់កំរៃតិចតួចដល់កម្មករ ហើយក្លាយជាអ្នកមានស្តុកស្តម្ភ ដោយសារតែផលិតផលទាំងឡាយ ដែលកម្មករទាំងនោះផលិត ហៅថា **ការកេងប្រវ័ញ្ច** ។ គាត់ហៅ វណ្ណៈអ្នកមានថាជា **ប៉ារ៉ាស៊ីត** ដែលរស់នៅដោយសារអ្នកដទៃ ។

លោក កាល ម៉ាក្ស គិតថា ប្រព័ន្ធដែលជញ្ជក់យកផលប្រយោជន៍ពីអ្នកដទៃបែបនេះ មិនអាចគង់វង្សនៅស្ថិតស្ថេរបានឡើយ ។ តាមទស្សនៈរបស់គាត់ ពលករអាចភ្ញាក់លើកនិងយល់តម្លៃផ្ទាល់ខ្លួន ហើយទាមទារយកអំណាច

កាន់តែខ្លាំង ។ នេះអាចឈានទៅរកការធ្វើបដិវត្តន៍ ដែលអាចនឹងទម្លាក់ប្រព័ន្ធវណ្ណៈបច្ចុប្បន្ន ។ ក្រោយបដិវត្តន៍ជោគជ័យ ពលករនឹងកាន់កាប់មធ្យោបាយផលិតកម្ម ដោយខ្លួនឯង ចំណែកឯពួកវណ្ណៈធំៗនឹងត្រូវធ្វើសមាហរណ៍កម្មក្នុងប្រព័ន្ធ (សង្គម នយោបាយ និងសេដ្ឋកិច្ច)ថ្មី ហើយក្លាយជាពលករម្តង ដោយបញ្ចេញកម្លាំងពលកម្មដោយខ្លួនឯង ឬបើមិនដូច្នេះទេ ពួកគេនឹងស្លាប់ដោយឯកឯង ។ នេះគឺជាគោលដៅចុងក្រោយរបស់ទ្រឹស្តីម៉ាក្សស៊ីសនិយម ។

## ៥.២. វិធីសរសេរប្រវត្តិសាស្ត្របែបម៉ាក្សស៊ីសនិយម

មូលដ្ឋានគ្រឹះនៃការសរសេរប្រវត្តិសាស្ត្របែបម៉ាក្សស៊ីសនិយម អាចត្រូវបានរកឃើញ នៅក្នុងសៀវភៅ «*សេចក្តីប្រកាសបក្សកុម្មុយនីស្ត*» ។ លោក កាល ម៉ាក្ស បានសរសេរអះអាងថា៖

**«ប្រវត្តិសាស្ត្រនៃគ្រប់សង្គមទាំងអស់ គឺជាប្រវត្តិនៃការតស៊ូវណ្ណៈ»** ។

លោកជឿថា ប្រវត្តិសាស្ត្រមានទ្រង់ទ្រាយរួមមួយ ដែលមិនអាចផ្លាស់ប្តូរបានឡើយ ។ ប្រវត្តិសាស្ត្រនឹងជាប្រវត្តិសាស្ត្រនៃការតស៊ូវណ្ណៈជានិច្ច ដោយមិនអាចងាកចេញពីនេះឡើយ ។ ប្រការនេះមានន័យថា ទោះបីជាប្រវត្តិវិទូបែបម៉ាក្សស៊ីសនិយម កំពុងស្រាវជ្រាវពីអ្វីក៏ដោយ ក៏ពួកគេត្រលប់ទៅផ្តោតលើទំនាក់ទំនងសេដ្ឋកិច្ចនឹងវណ្ណៈសង្គម ។ នេះក៏ដោយសារតែលោក ជឿថាទំនាក់ទំនងវណ្ណៈសង្គមស្ថិតនៅផ្នែកខាងក្រោមនៃគ្រប់អ្វីទាំងអស់៖ វាគឺជា**មូលដ្ឋានគ្រឹះ** (base)។ អ្វីផ្សេងទៀត ដែលមិនស្ថិតក្នុងផ្នែកមូលដ្ឋានគ្រឹះខាងក្រោមនេះ គឺជាផ្នែកនៃ**ដំបូលលើ** (superstructure) ។ ផ្នែកលើនេះរួមបញ្ចូលទាំង វប្បធម៌ សាសនា និងនយោបាយ ។

តាមទស្សនៈគាត់ វិស័យទាំងបីនេះ គឺជាលទ្ធផលនៃស្ថានភាពទំនាក់ទំនងសេដ្ឋកិច្ចនឹងវណ្ណៈសង្គម ហើយត្រូវពឹងយ៉ាងខ្លាំងលើសេដ្ឋកិច្ច ។ បើសិនសេដ្ឋកិច្ចប្រែប្រួល ផ្នែកទាំងនេះនឹងត្រូវប្រែប្រួលផងដែរ ។

ដូច្នេះហើយទើបលោក កាល ម៉ាក្ស យល់ថា ទំនួលខុសត្រូវរបស់ប្រវត្តិវិទូគឺ ត្រូវស្វែងយល់ ចងក្រង និងរៀបរាប់អំពីការតស៊ូវណ្ណៈ ពីសម័យមួយទៅសម័យមួយទៀត ដោយបង្ហាញថាតើសេដ្ឋកិច្ចមានលក្ខណៈប្រែប្រួលយ៉ាងដូចម្តេចខ្លះ ហើយវណ្ណៈសង្គមរួមចំណែកយ៉ាងដូចម្តេចដែរ ។

ក្រោយបដិវត្តន៍បានជោគជ័យ លោក កាល ម៉ាក្ស យល់ថា ប្រវត្តិសាស្ត្រអាចនឹងមិនមានអត្ថិភាពឡើយ ៖ «ប្រវត្តិសាស្ត្រទាំងអស់សុទ្ធតែជាប្រវត្តិនៃការតស៊ូវណ្ណៈ» ។ ក្រោយបដិវត្តន៍ នឹងមិនមានការតស៊ូវណ្ណៈទៀតទេ ។ ដូច្នេះ នឹង**មិនមានប្រវត្តិសាស្ត្រ**ឡើយ ។

## សំណួរពិភាក្សា

១. តើលោក កាល ម៉ាក្ស ជានរណា? ចូររៀបរាប់ប្រវត្តិរបស់គាត់ត្រួសៗ ។

២. តាមគំនិតគាត់ តើសង្គមមនុស្សត្រូវបានបែងចែកជាប៉ុន្មានវណ្ណៈ? អ្វីខ្លះ?

៣. ដូចម្តេចដែលហៅថា «**មធ្យោបាយផលិតកម្ម**»? ចូរលើកឧទាហរណ៍ជាក់ស្តែងបញ្ជាក់ ។

៤. តើវណ្ណៈណាខ្លះ គ្រប់គ្រងមធ្យោបាយផលិតកម្ម? ហើយវាមានផលវិបាកអ្វីខ្លះដល់សង្គម?

៥. តើទ្រឹស្តីប្រវត្តិសាស្ត្ររបស់គាត់បានចែងយ៉ាងដូចម្តេចខ្លះ? ចូរពន្យល់ ។

៦. តើក្រោយការធ្វើបដិវត្តន៍ មានប្រវត្តិសាស្ត្រទៀតដែរឬទេ? ហេតុអ្វី?

៧. ចំពោះទ្រឹស្តីម៉ាក្សីសនិយម តើវិស័យណាមួយក្នុងចំណោមនេះ(សេដ្ឋកិច្ច នយោបាយ សង្គម និងវប្បធម៌) មានសារៈសំខាន់ជាងគេ? ហេតុអ្វី?

**ក្រាហ្វិកទំនាក់ទំនងមូលដ្ឋានគ្រឹះនិងដំបូល**



**រូបភាពតុក្កតាបញ្ឆោតបញ្ឆោតប្រព័ន្ធមូលធននិយម**



### ៥.៣. សទ្ទានុក្រមទ្រឹស្តីម៉ាក្សស៊ីសនិយម

- **វណ្ណៈអភិជន** (Aristocracy)៖ ម្ចាស់ដីធ្លីធំៗ ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ។
- **មូលដ្ឋានគ្រឹះ** (Base)៖ ទំនាក់ទំនងរវាងសេដ្ឋកិច្ចនឹងវណ្ណៈសង្គម ដែលជាមូលដ្ឋានគ្រឹះនៃគ្រប់សង្គមមនុស្សទាំងអស់។
- **វណ្ណៈគហបតី** (Bourgeois) ៖ ថៅកែហាង ម្ចាស់រោងចក្រ ពាណិជ្ជករ និងពពួកជនផ្សេងទៀត ក្នុងវណ្ណៈកណ្តាល ដែលរកបានប្រាក់ចំណេញបានទៀតទាត់ ។
- **ការកេងប្រវ័ញ្ច** (Exploitation)៖ ការទាញយកផលប្រយោជន៍ សំរាប់បុគ្គលផ្ទាល់ខ្លួន ដោយវិធីមិនល្អ ឬភាពអយុត្តិធម៌ ។
- **មធ្យោបាយផលិតកម្ម** (Means of Production)៖ ឧបករណ៍ ឬសម្ភារៈ ត្រូវការជាចាំបាច់សម្រាប់ផលិតទំនិញលក់នៅលើទីផ្សារ ឧទាហរណ៍ដូចជា ដីធ្លី រោងចក្រ ... ជាដើម ។
- **ប៉ារ៉ាស៊ីត** (Parasitic)៖ ពពួកសត្វ (ឬមនុស្ស) រស់នៅដោយសារអ្នកដទៃ ។
- **កសិករឈ្នួល** (Peasant)៖ មនុស្សក្រីក្រស៊ីឈ្នួលធ្វើស្រែចំការអោយអ្នកដទៃ ។
- **ពលជីព** (Proletariat)៖ កម្មកររោងចក្រ ឬអ្នកស៊ីឈ្នួលនៅទីក្រុង ស្ថិតក្នុងវណ្ណៈទាប ។
- **ខ្ញុំកញ្ជះ** (Serf) ៖ កសិករទាសករធ្វើការងារនៅលើដីអ្នកដទៃ ។
- **ដំបូល** (Superstructure) ៖ ទ្រង់ទ្រាយខាងលើគ្រឹះ ឬ ជាអ្វីៗដែលកើតពីទំនាក់ទំនងសេដ្ឋកិច្ច រួមទាំងនយោបាយ វប្បធម៌ និងសាសនា។

**លោក ការលម៉ាក្ស**



## ៥.៤. ស្ពាដៃលោក ការលម៉ាក្ស «សេចក្តីប្រកាសបក្សកុម្មុយនីស្ត»

### ជំពូកទី ១៖ វណ្ណៈគហបតី និងវណ្ណៈកម្មករ

១ «ប្រវត្តិសាស្ត្រនៃគ្រប់សង្គមទាំងអស់ គឺជាប្រវត្តិសាស្ត្រនៃការតស៊ូវណ្ណៈ ។ អ្នកជានឹងអ្នកងារ, ពួកអភិជន (patrician) នឹង ប្រជារាស្ត្រក្រីក្រ (plebeian), ម្ចាស់ដីនឹងខ្ញុំកញ្ជះ មេជាង(guild-master) នឹងកូនជាង (journeyman) ឬហៅជារួមថា អ្នកជិះជាន់គេនឹងអ្នកត្រូវគេជិះជាន់ តែងតែតស៊ូប្រឆាំងនឹងគ្នាយ៉ាងមុះមុត ឥតឈប់ឈរ ខ្លះដោយស្ងប់ស្ងាត់ ខ្លះដោយបើកចំហរ ។ ការតស៊ូប្រយុទ្ធប្រឆាំងនឹងគ្នានេះ អាចនឹងត្រូវបញ្ចប់ ដោយការកសាងសង្គមសារជាថ្មីតាមមាគ៌ាបដិវត្តន៍ ឬដោយវិនាសកម្មនៃភាគីតស៊ូទាំងសង្ខាង ។

២ នៅយុគដំបូងនៃប្រវត្តិសាស្ត្រ យើងសង្កេតឃើញថា ស្ទើរតែគ្រប់ទីកន្លែងមានការរៀបចំសង្គមបែបស៊ាំញ៉ាំ ដោយបែងចែកជាវណ្ណៈផ្សេងៗ ឬលំដាប់សក្តិជាច្រើនថ្នាក់ (manifold) ។ នៅក្រុងរ៉ូមបុរាណ មានលំដាប់ថ្នាក់ដូចជា ពួកអភិជន ពួកអ្នកចម្បាំង ប្រជារាស្ត្រក្រីក្រ និងខ្ញុំកញ្ជះ ចំណែក នៅមជ្ឈឹមសម័យ មានដូចជា ពួកស្តេចត្រាញ់សក្តិភូមិ បរិវារ មេជាង កូនជាងចាស់ កូនជាងថ្មី និងខ្ញុំកញ្ជះ ។ ស្ទើរតែគ្រប់វណ្ណៈទាំងអស់ត្រូវគោរពតាមលំដាប់សក្តិសង្គម ៖ វណ្ណៈខាងក្រោមត្រូវស្តាប់បង្គាប់វណ្ណៈខាងលើៗ ។

៣ សង្គមគហបតីនាសម័យទំនើប ដែលបានចាប់បដិសន្ធិឡើង ក្រោយពីវិនាសកម្មនៃសង្គមសក្តិភូមិ មិនបានបញ្ចប់ជម្លោះវណ្ណៈឡើយ ។ ផ្ទុយទៅវិញ វាបានបង្កើតឡើងនូវវណ្ណៈថ្មី លក្ខណៈជិះជាន់ថ្មី និងរូបភាពថ្មីនៃការតស៊ូនៅលើទីកន្លែងចាស់ ។

៤ យ៉ាងណាមិញ ក្នុងយុគសម័យយើងនេះ ដែលជាយុគនៃវណ្ណៈគហបតី មានលក្ខណៈមួយពិសេស៖ វាបានធ្វើអោយការតស៊ូវណ្ណៈកាន់តែងាយ ។ សង្គមទាំងមូលកាន់តែបែកបាក់ជាពីរក្រុមធំៗ ដែលប្រឈមមុខដាក់គ្នាកាន់តែខ្លាំងឡើង គឺវណ្ណៈគហបតី និងវណ្ណៈកម្មករ (ទីក្រុង) ។

៥ ចេញពីខ្ញុំកញ្ជះសម័យមជ្ឈឹម រីកចម្រើនជាអ្នកទីក្រុងដំបូងៗបំផុត ។ ចេញពីអ្នកក្រុងទាំងអស់នេះ វិវត្តន៍ចេញជាសារជាតុដំបូងនៃវណ្ណៈគហបតី ។

៦ ការរុករកឃើញទ្វីបអាមេរិក នាវាចរណ៍វិលជុំទ្វីប បានបើកឱកាសបន្ថែមសម្រាប់វណ្ណៈគហបតីដែលកំពុងតែកើនឡើង ។ ទីផ្សារតេណ្ឌាខាងកើតនិងចិន, ការដាក់នឹមអាណានិគមលើទ្វីបអាមេរិក, ការធ្វើពាណិជ្ជកម្មជាមួយប្រទេសក្រោមអាណានិគម, កំនើនទំនិញនិងមធ្យោបាយដោះដូរ ដ៏សំបូរបែប សុទ្ធសឹងជាកត្តាញុាំងអោយមានសន្ទុះពាណិជ្ជកម្ម នាវាចរណ៍ និងឧស្សាហកម្មដ៏ផុសផុល ។ ទន្ទឹមនឹងនេះ ក៏បង្កអោយមានកម្លាំងបដិវត្តន៍យ៉ាងខ្លាំងក្លា នៅក្នុងប្រព័ន្ធសង្គមសក្តិភូមិដ៏រង្គោះរង្គើផងដែរ ។

៧ ប្រព័ន្ធសក្តិភូមិសម័យឧស្សាហកម្ម ដែលផលិតកម្មឧស្សាហកម្មទាំងឡាយត្រូវបានផលិតផ្តាច់មុខដោយសមាគមជំនាញវិជ្ជាជីវៈ(guilds) ដែលស្និទ្ធស្នាលនឹងខ្លួន លែងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ផលិតទំនិញបំពេញតម្រូវការទីផ្សារថ្មីៗទៀតឡើយ ។ ប្រព័ន្ធផលិតទំនិញដោយគ្រឿងយន្ត បានចូលមកបំពេញតួនាទីជំនួសវា ។ ពពួកមេជាងនៃសមាគមជំនាញវិជ្ជាជីវៈនានា ត្រូវបានប្រព័ន្ធផលិតកម្មថ្មី ផាត់ចេញពីខ្សែសង្វាក់ផលិតកម្ម ដោយ

វណ្ណៈកណ្តាលជាប់ពាក់ព័ន្ធនឹងគ្រឿងយន្ត, ហើយការបំណែងចែកការងារតាមក្រុមជំនាញ ក៏ត្រូវផុតរលត់ ជំនួសដោយ បំណែងចែកការងារថ្មី ទៅតាមកន្លែងផលិតក្នុងរោងកម្មន្តសាល ។

៨ ទន្ទឹមនឹងនេះ ទីផ្សារនានា បន្តរីកធំឡើងៗ តម្រូវការទំនិញ កាន់តែខ្ពស់ជាងមុន ។ សូម្បីតែរោងចក្រកម្មន្តសាល ដែលផលិតទំនិញដោយគ្រឿងយន្ត ក៏មានលទ្ធភាពផលិតអោយបានគ្រប់គ្រាន់តាមតម្រូវការទីផ្សារដែរ ។ មិនយូរប៉ុន្មាន គ្រឿងម៉ាស៊ីនដំណើរការ ដោយចំហាយទឹក បានធ្វើអោយមានសន្ទុះផលិតផលឧស្សាហកម្មយ៉ាងខ្លាំងក្លា (សម័យបដិវត្តន៍ឧស្សាហកម្ម) ។ ទីកន្លែងផលិតកម្មទំនិញត្រូវត្រូវជំនួសដោយឧស្សាហកម្មទំនើបធំៗ, ឧស្សាហកម្មរបស់វណ្ណៈកណ្តាល ជំនួសដោយមហាសេដ្ឋីឧស្សាហកម្ម ដែលជាមេដឹកនាំនៃកម្លាំងឧស្សាហកម្មទាំងមូល និងជាគហបតីសម័យទំនើប ។

៩ ឧស្សាហកម្មទំនើបបានបង្កើតទីផ្សារពិភពលោក ដែលត្រូវត្រួសត្រាយផ្លូវ ដោយការរុករកទ្វីបអាមេរិក ។ ទីផ្សារនេះបានធ្វើអោយមានការរីកចម្រើនយ៉ាងខ្លាំងខាងវិស័យពាណិជ្ជកម្ម នាវាចរណ៍ និងទំនាក់ទំនងផ្លូវគោក ។ ការរីកចម្រើននេះ ជាបន្តបន្ទាប់ បានឆ្លើយតបនឹងការពង្រីកវិស័យឧស្សាហកម្មហើយដោយតាមសមាមាត្រនៃការរីកដុះដាលនៃឧស្សាហកម្ម, វិស័យពាណិជ្ជកម្ម នាវាចរណ៍ ចរាចរផ្លូវដែកក៏កាន់តែរីកចម្រើន, ហើយដោយតាមសមាមាត្រនៃការរីកធំធាត់នៃ វណ្ណៈគហបតី ដើមទុនរកស៊ីក៏កាន់តែកើនឡើងដែរ ហើយរុញវណ្ណៈដែលនៅសេសសល់ពីមជ្ឈិមសម័យផ្ទប់ជញ្ជាំង ។

១០ ដូចច្នេះហើយ យើងសង្កេតឃើញថាពួកគហបតីសម័យទំនើប ជាផ្លែផ្កា ដែលឆ្លងកាត់ការវិវឌ្ឍន៍យ៉ាងយូរ, ជាផ្លែផ្កានៃបដិវត្តន៍បែបផែនផលិតកម្មនិងការដោះដូរទំនិញជាបន្តបន្ទាប់ ។

១១ រាល់ជំហាននៃការវិវឌ្ឍន៍វណ្ណៈគហបតី អំណាចនយោបាយនៃវណ្ណៈនេះ ក៏ត្រូវបានពង្រឹងផងដែរ ។ (ដំបូងជា)វណ្ណៈមួយ ដែលត្រូវបានជិះជាន់ក្រោមការគ្រប់គ្រងរបស់ពួកអភិជនសក្តិភូមិ, (បន្ទាប់មកទៀតជា) សមាគមប្រដាប់អាវុធនិងស្វ័យគ្រប់គ្រង នៅសង្កាត់នានាក្នុងមជ្ឈឹមសម័យ, ឥឡូវជាសាធារណរដ្ឋឯករាជ្យទំនើប (ដូចជានៅអ៊ីតាលី និងអាឡឺម៉ង់), ខ្លះទៀត ជា «តតិយសសរស្តម្ភ[10]» នៃរាជាណាចក្រ ដែលតម្រូវអោយបង់ពន្ធថ្វាយព្រះរាជា ដូចជា នៅបារាំងជាដើម, ក្រោយមកទៀត នៅក្នុងសម័យផលិតកម្មដោយគ្រឿងយន្ត ពួកគេបម្រើក្នុងរបបរាជានិយមផ្តាច់ការ ឬ ពាក់កណ្តាលសក្តិភូមិ ក្នុងតួនាទីកម្លាំងស្នូលសម្រាប់ទប់ទល់នឹងពួកអភិជនមួយចំនួន ហើយជាទូទៅ ជាទីពឹងសម្រាប់រាជានិយមធំៗ ។ ហើយទីបំផុត ចាប់តាំងពីមានការបង្កើត ឧស្សាហកម្មទំនើបនិងទីផ្សារពិភពលោកមក ពួកគហបតីបានក្តោបក្តាប់គ្រប់គ្រងសម្រាប់ខ្លួនឯង ក្នុងនាមជារដ្ឋទំនើបនិងជាតំណាង ដែលគ្រប់គ្រងនយោបាយផ្តាច់មុខ ។ ការប្រតិបត្តិរបស់រដ្ឋទំនើប តាមពិតទៅជា គណៈកម្មការសម្រាប់គ្រប់គ្រងកិច្ចការទូទៅ សម្រាប់វណ្ណៈគហបតីទាំងមូល ។ ជាលក្ខណៈប្រវត្តិសាស្ត្រ ពួកគហបតីមានតួនាទីបដិវត្តន៍ខ្លាំងបំផុត ។

១២ ពេលមានឱកាស ពួកគហបតី តែងតែផ្តាច់ទំនងបែបសក្តិភូមិបិតាធិបតេយ្យ (Patriarchal) ដ៏ផូរផង់ ។ ដោយឥតស្តាយស្រណោះ ពួកគេផ្តាច់ចំណងសក្តិភូមិនានា ដែលចង់ភ្ជាប់មនុស្សទៅនឹង«អ្នកធំពីធម្មជាតិ» ហើយមិនបន្សល់ទុកនូវទំនាក់ទំនងផ្សេងៗរវាងមនុស្សនឹងមនុស្ស ដោយគិតតែប្រយោជន៍ផ្ទាល់ខ្លួនគ្រប់ពេល ពោលគឺគិតតែ «ប្រាក់សុទ្ធ» តែម្តង ។ វាបានជាន់ពន្លិច បរមសុខក្នុងជំនឿសាសនា, វីរៈភាពអង់អាចរបស់ «អ្នកចម្បាំង»,

[10] ប្រទេសបារាំងសម័យបុរាណ(មុនសម័យបដិវត្តន៍ឆ្នាំ ១៧៨៩)ត្រូវបានបែងចែកជាបីសរសរស្តម្ភដែលគាំទ្រព្រះរាជា៖ បឋមសសរស្តម្ភមានដូចជាក្រុមអាចារ្យឬសង្ឃកាតូលិក, ទុតិយសសរស្តម្ភមានដូចជាអភិជននិងក្រុមរាជវង្សានុវង្សនិងតតិយសសរស្តម្ភសំដៅលើមនុស្សដទៃក្រៅពីពីរខាងដើមពោលគឺប្រជារាស្ត្របារាំងទាំងមូល (នៅទីក្រុងនិងជនបទ) ។

ការបញ្ចេញមនោសញ្ចេតនាអវិជ្ជា អោយលិចលង់ក្នុងភាពអាត្មានិយមដ៏ជ្រៅ ។ វាបានបំបែកតម្លៃបុគ្គលទៅជាតម្លៃដោះដូរដូចទំនិញ,និងបានជំនួសសេរីភាពបុគ្គលផ្សេងៗទៅជាសេរីភាពរួមមួយ នោះគឺពាណិជ្ជកម្មសេរី ។ ជារួម ការកេងប្រវ័ញ្ច ដោយការបំភាន់ក្នុងផ្នែកសាសនានិងនយោបាយ ត្រូវជំនួសដោយការកេងប្រវ័ញ្ចស្រស់ៗ ដោយគ្មានការអៀនខ្មាស់ ដោយផ្ទាល់ ដោយគ្មានសំចៃឡើយ ។

១៣ ពួកគហបតីបានដកធព្វណ្ណរង្សីនៃមុខរបរផ្សេងៗដែលមានសេចក្តីថ្លៃថ្នូរនិងគួរជាទីមោទន និងការគោរព ។ វាបានបំលែងគ្រូពេទ្យ មេធាវី អាចារ្យ កវី និងអ្នកវិទ្យាសាស្ត្រទៅជាកម្មករស៊ីប្រាក់កម្រៃ ។

១៤ ពួកគហបតីបានបំបែកបំបាក់មនោសញ្ចេតនាគ្រួសារ និងបានកាត់បន្ថយទំនាក់ទំនងក្នុងគ្រួសារអោយនៅត្រឹមតែទំនាក់ទំនងលុយកាក់ ...

១៥ ... វណ្ណៈគហបតីមិនអាចមានអត្ថិភាពបានទេ បើមិនធ្វើបដិវត្តសម្ភារៈផលិតកម្មជាហូរហែរម្លោះហើយទំនាក់ទំនងផលិតកម្ម ក៏ប្រែប្រួល ចំណែកទំនាក់ទំនងក្នុងសង្គមទាំងមូលក៏ប្រែប្រួលតាមនោះដែរ ។ ផ្ទុយទៅវិញការអភិរក្សចង្វាក់ផលិតកម្មចាស់ក្នុងទ្រង់ទ្រាយដើម គឺជាលក្ខខណ្ឌដំបូងសម្រាប់អត្ថិភាពនៃវណ្ណៈឧស្សាហកម្មចាស់ៗទាំងឡាយ ។ ការធ្វើបដិវត្តផលិតកម្មជាបន្តបន្ទាប់, ចលាចលស្ថានភាពសង្គមទាំងអស់ ដោយមិនគ្មានអន្តរាគមន៍, ភាពមិនប្រាកដ និងកោលាហលជាប្រចាំសុទ្ធសឹងជាលក្ខណៈពិសេសបែងចែកយុគសម័យគហបតីខុសពីយុគសម័យមុនៗ។ គ្រប់ទំនាក់ទំនងបិតបេរដែលអាចគាំងយ៉ាងឆាប់រហ័ស រួមជាមួយនឹងបុរេវិនិច្ឆ័យនិងគំនិតបុរាណទាំងអស់ត្រូវបានលុបបំបាត់ ហើយទំនាក់ទំនងថ្មីទាំងអស់ បែរជាហួសសម័យ មុនពេលវាបានចាក់ឬស ។ រាល់ទំនាក់ទំនងដែលរឹងមាំបានរលាយក្លាយជាខ្យល់ អ្វីៗទាំងអស់ដែលបរិសុទ្ធត្រូវបានបំពុល ហើយមនុស្សត្រូវបានបង្ខំអោយប្រឈមមុខនឹងសតិសម្បជញ្ញៈ, លក្ខខណ្ឌជីវិតពិតប្រាកដ និងទំនាក់ទំនងនឹងអ្នកដទៃ ។

១៦ តំរូវការទីផ្សាររីកចម្រើនឥតឈប់ឈរសម្រាប់លក់ផលិតផលរបស់ខ្លួន បានរុញច្រានពួកគហបតីចេញទៅពាសពេញសកលលោកទាំងមូល ។ វាត្រូវតែចាក់គ្រឹះនៅគ្រប់ទីកន្លែង, បោះទីតាំងនៅគ្រប់ទីកន្លែង និងបង្កើតបណ្តាញគ្រប់ទីកន្លែងដែរ ។

១៧ តាមរយៈការធ្វើអាជីវកម្មរបស់ខ្លួន លើទីផ្សារពិភពលោក ពួកគហបតីបានផ្តល់លក្ខណៈសកលដល់ផលិតកម្មនិងការប្រើប្រាស់ នៅគ្រប់ប្រទេសទាំងអស់ ។ ចំពោះការអាក់អន់ចិត្តខ្លាំងរបស់ក្រុមប្រតិកិរិយា ក៏ព្រោះវាបានគាស់រំលើងជើងក្រោមរបស់ឧស្សាហកម្ម របស់ប្រជាជាតិដែលវាបានឈរជើង ។ ឧស្សាហកម្មជាតិចាស់ៗត្រូវបានបំផ្លិចបំផ្លាញ ឬត្រូវបានបំផ្លាញជារៀងរាល់ថ្ងៃ ។ វាត្រូវបានជំនួសដោយឧស្សាហកម្មថ្មី ដែលវត្តមានដំបូងរបស់វា បានក្លាយជាសំណួរស្លាប់និងរស់ សម្រាប់ប្រទេសដែលមានអរិយធម៌ទាំងអស់, ជំនួសដោយឧស្សាហកម្មដែលលែងដំណើរការដោយវត្ថុធាតុដើមក្នុងស្រុក ប៉ុន្តែ ប្រើវត្ថុធាតុដើមដែលបានមកពីតំបន់ដាច់ស្រយាល, ឧស្សាហកម្មដែលផលិតផល ត្រូវបានប្រើប្រាស់មិនត្រឹមតែនៅក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅគ្រប់ច្រកល្ហកលើពិភពលោកផងដែរ ។ ជំនួសអោយ អោយតម្រូវការចាស់ ដែលពេញចិត្តត្រឹមតែផលិតផលក្នុងប្រទេស យើងរកឃើញតម្រូវការថ្មី ដែលចង់បានផលិតផលពីតំបន់ឆ្ងាយៗ ។ ជំនួសអោយភាពស្វ័យផ្គត់ផ្គង់ និងការនៅដាច់ដោយឡែកតែក្នុងស្រុកនិងជាតិណាមួយ យើងមានបណ្តាញទំនាក់ទំនងគ្រប់ទិសទី និងការពឹងអាស្រ័យគ្នាជាសកលរវាងប្រជាជាតិនានា ។ ដូចគ្នាផងដែរក្នុងផ្នែកសម្ភារៈ និងក្នុងការបង្កើតបញ្ញា ។ ការបង្កើតបញ្ញាញាណរបស់ប្រជាជាតិនីមួយៗក្លាយជាទ្រព្យសម្បត្តិរួម ។ ការគិតជាតិតែម្ខាងនិងភាពចង្អៀតចង្អល់ កាន់តែតិចទៅៗ ហើយពីអក្សរសិល្ប៍ក្នុងស្រុកនិងថ្នាក់ជាតិជាច្រើនសន្ធឹកសន្ធាប់ បានបង្កើតជាអក្សរសិល្ប៍សកលលោក។

១៨ ពួកគហិបតី តាមរយៈការរីកចម្រើនយ៉ាងឆាប់រហ័សនៃឧបករណ៍ផលិតគ្រប់ប្រភេទ, តាមរយៈមធ្យោបាយសម្របសម្រួលការប្រាស្រ័យទាក់ទងដ៏ទូលំទូលាយ បានណែនាំអរិយធម៌ដល់គ្រប់ប្រជាជាតិទាំងអស់ សូម្បីតែជាតិអន់ថយបំផុតក៏ដោយ... វាបង្ខំអោយប្រទេសទាំងអស់ ទោះកំពុងវេងឈឺចាប់ជិតផុតពូជ អនុម័តរបៀបរបបផលិតកម្មរបស់គហិបតី, វាតម្រូវអោយពួកគេណែនាំនូវអ្វីដែលវាហៅថាអរិយធម៌នៅក្នុងចំណោមពួកគេ ដោយជម្រុញអោយក្លាយទៅជាគហិបតីដោយខ្លួនឯង ។ ជារួម វានិម្មិតពិភពលោកថ្មីមួយដោយយកតាមគម្រូរបស់ខ្លួន ។

១៩ ពួកគហិបតីបានដាក់ប្រទេសអោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីក្រុងនានា ។ វាបានបង្កើតទីក្រុងដ៏ធំសម្បើមជាច្រើន, បានបង្កើនចំនួនប្រជាពលរដ្ឋក្នុងទីក្រុងយ៉ាងច្រើនផងដែរ បើប្រៀបធៀបជាមួយនឹងតំបន់ជន, ម្លោះហើយវាបានជួយសង្គ្រោះមនុស្សជាច្រើនពីភាពអន់ថយនៃជីវិតជនបទ ។ វាបានធ្វើអោយប្រទេសទាំងមូលពឹងផ្អែកលើទីក្រុង ដូចគ្នានេះដែរ វាបានធ្វើអោយប្រទេសអន់ថយនិងទន់ខ្សោយ ពឹងផ្អែកលើប្រជាជាតិដែលមានអរិយធម៌រីកចម្រើន, ប្រទេសជាតិពោរពេញដោយកសិករពឹងផ្អែកលើប្រទេសគហិបតី, បូព៌ាប្រទេសពឹងលើបស្ចឹមប្រទេស ...

២០ ពួកគហិបតី ក្នុងកំឡុងពេលមួយរយឆ្នាំនៃការគ្រប់គ្រងរបស់ខ្លួន បានបង្កើតកម្លាំងផលិតកម្មដ៏ធំសម្បើមនិងកាន់តែច្រើនជាងជំនាន់មុនៗបូកបញ្ចូលគ្នា ។ ការបង្ក្រាបកម្លាំងធម្មជាតិអោយស្ថិតក្រោមកម្លាំងមនុស្សជាតិ, គ្រឿងម៉ាស៊ីន, និងការប្រើប្រាស់គីមីសាស្ត្រក្នុងវិស័យឧស្សាហកម្មនិងកសិកម្ម, វិស័យនាវាចរដែលដើរដោយចំហាយទឹក, ផ្លូវដែក, ទូរលេខអគ្គីសនី, ការកាប់ឆ្ការព្រៃដាំដំណាំ លើទ្វីបទាំងអស់, ការជីកស្ទឹងបង្ហូរទឹកពីទន្លេ, ចំនួនប្រជាជនទាំងមូលហាក់ឡើង - ទាំងអស់នេះ គឺជាអ្វីដែលសតវត្សរ៍មុនបានទស្សន៍ទាយថា កម្លាំងផលិតកម្មបែបនេះ ត្រូវផ្អាកក្នុងរង្វង់កម្លាំងពលកម្មសង្គម ?

២១ ដូច្នេះ យើងសង្កេតឃើញថា៖ មធ្យោបាយនៃការផលិតនិងការដោះដូរ ដែលជាមូលដ្ឋានគ្រឹះរបស់វណ្ណៈគហិបតី ត្រូវបានបង្កើតឡើង នៅក្នុងសង្គមសក្តិភូមិ ។ នៅដំណាក់កាលជាក់លាក់ណាមួយក្នុងការអភិវឌ្ឍមធ្យោបាយនៃការផលិតនិងការដោះដូរទាំងនេះ, លក្ខខណ្ឌដែលសង្គមសក្តិភូមិ បានបង្កើត និងដោះដូរ, ការរៀបចំបែបសក្តិភូមិក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ពោល ទំនាក់ទំនងនៃកម្មសិទ្ធិរបស់សក្តិភូមិ លែងត្រូវគ្នាជាមួយនឹងកម្លាំងផលិតកម្ម ដែលបានរីកធំធាត់រួចទៅហើយ ផ្ទុយទៅវិញ ពួកគេត្រូវបានបែងចែកជាច្រើនផ្នែក ។ ពួកគេត្រូវបានបំបែក ពួកគេត្រូវតែខ្ទាត់ខ្ទាយ ។

២២ ការប្រកួតប្រជែងសេរី បានចូលទៅទីតាំងរបស់ពួកគេ អមដោយធម្មនុញ្ញសង្គម និងនយោបាយ ដែលប្រែប្រួលទៅតាមជាក់ស្តែង និងដោយឥទ្ធិពលសេដ្ឋកិច្ចនិងនយោបាយរបស់វណ្ណៈគហិបតី ។

២៣ ចលនាស្រដៀងគ្នានេះកំពុងតែកើតឡើង នៅចំពោះមុខភ្នែករបស់យើងផ្ទាល់ ។ សង្គមគហិបតីសម័យទំនើប ដែលទំនាក់ទំនងរបស់ខ្លួនទៅនឹងផលិតកម្ម, ការដោះដូរ, និងកម្មសិទ្ធិ, សង្គមមួយ ដែលបានបង្កើតឡើងនូវមធ្យោបាយផលិតកម្មនិងការដោះដូរ ដ៏មហិមាបែបនេះ គឺប្រៀបដូចជា អាបធ្មប់ដែលមិនអាចគ្រប់គ្រងអំណាចលើពិភពលោកដែលខ្លួនបានប្រើមន្តអាគមខាបឡើង ។ អស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមកហើយ ប្រវត្តិសាស្ត្រនៃឧស្សាហកម្មនិងពាណិជ្ជកម្ម គឺជាប្រវត្តិនៃការបះបោររបស់កម្លាំងផលិតកម្មសម័យទំនើប ប្រឆាំងនឹងលក្ខខណ្ឌផលិតកម្មទំនើប, ប្រឆាំងនឹងទំនាក់ទំនងកម្មសិទ្ធិ ដែលជាលក្ខខណ្ឌសម្រាប់អត្ថិភាពនិងការគ្រប់គ្រប់របស់គហិបតី ...

៧៤ ...អាវុធដែលពួកគហបតីបានវាយពួកសក្តិភូមិអោយរាបដល់ដី ឥឡូវបានងាកមកប្រឆាំងនឹងពួកគេវិញ ។ ពួកគហបតីមិនត្រឹមដុតដែកធ្វើគ្រឿងសញ្ញាវុធប្រល័យខ្លួនឯងនោះទេ តែថែមទាំងបានបង្កអត្ថិភាពអ្នកដែលកាន់អាវុធទាំងនោះ- វណ្ណៈធ្វើពលកម្មទំនើប ពោលគឺ ក្រុមពលករ ។

៧៥ តាមសមាមាត្រនឹងពួកគហបតី, ដើមទុនត្រូវបានបង្កើនឡើង, ឯវណ្ណៈពលករ ដែលជាវណ្ណៈបញ្ចេញកម្លាំងធ្វើការងារទំនើប ក៏កើនឡើងតាមសមាមាត្រនេះដែរ ។ តាមពិតទៅ ពួកគេ មានជីវភាពរស់នៅអត្តខាត់ណាស់ កេព្រឹក ខ្វះល្ងាច ហើយអាចរកការងារធ្វើបានលុះត្រាតែដើមទុនកើនឡើងដែរ ។ កម្មករទាំងនេះដែលត្រូវលក់កម្លាំងពលកម្មខ្លួនឯង ប្រៀបដូចជាផលិតផលមួយដូច្នេះដែរ ហើយមិនខុសពីផលិតផលពាណិជ្ជកម្មដទៃទៀត ពួកគេត្រូវរងផលប៉ះពាល់ដោយសារការប្រែប្រួលក្នុងការប្រកួតប្រជែងគ្រប់បែបយ៉ាង និងដោយសារការប្រែប្រួលទីផ្សារ ។

៧៦ ដោយសារការប្រើប្រាស់គ្រឿងម៉ាស៊ីនគ្រប់បែបយ៉ាង រួមនឹងការបែងចែកកម្លាំងពលកម្ម ការងាររបស់កម្មករបាត់បង់បុគ្គលិកលក្ខណៈទាំងអស់ ហើយជាលទ្ធផលបាត់បងភាពទាក់ទាញឬតម្លៃផ្ទាល់ខ្លួន ។ ពួកគេបានក្លាយទៅជាឧបករណ៍អេឡិចត្រូនិចនៃម៉ាស៊ីនណាមួយ ឬគ្រាន់តែជាគ្រឿងបន្លាស់ដ៏សាមញ្ញបំផុត ងាយស្រួលបំផុត ឬគ្រាន់តែចាប់ខ្មៅខ្ទង់ដដែលៗ ... ឧស្សាហកម្មទំនើបបានផ្លាស់ប្តូររោងសិប្បកម្មតូចៗរបស់ចៅហ្វាយចាស់ៗ ទៅជារោងចក្រឧស្សាហកម្មធំៗសម្រាប់ពួកមូលធននិយម ។ កម្មករទាំងហ្វូងៗ ពពាក់ពពូនចូលរោងចក្រ ត្រូវបានគេរៀបចំតាមរបៀបយោធា... ពួកគេមិនត្រឹមតែជាទាសកររបស់វណ្ណៈគហបតីប៉ុណ្ណោះទេ និងជារបស់រដ្ឋគហបតី ពួកគេថែមទាំងជាទាសករ ប្រចាំថ្ងៃ ប្រចាំម៉ោង របស់ម៉ាស៊ីន និងមេការ ជាពិសេសជារបស់ម្ចាស់រោងចក្រគហបតីនីមួយៗ ។ ប្រព័ន្ធផ្តាច់ការនេះ ប្រកាសទទួលបានផលចំណេញកាន់តែខ្លាំង កាន់តែបើកចំហរ, អារម្មណ៍តូចចិត្ត ជូរចត់ ស្អប់ខ្ពើមក៏មានកាន់តែច្រើន ...

៧៧ ... ស្រទាប់ខាងក្រោមនៃវណ្ណៈកណ្តាល រួមមានពាណិជ្ជករតូចៗ អ្នកលក់ដូរតូចតាច និងអ្នកជំនួញដែលចូលនិវត្តន៍ទាំងអស់ សិប្បករ និងកសិករ - ពួកគេទាំងអស់នេះ បន្តិចម្តងៗ បានធ្លាក់ខ្លួនទៅក្នុងវណ្ណៈពលករ ... ម្យ៉ាងដោយសារជំនាញឬឯកទេសរបស់ពួកគេលែងប្រើការបាន ដោយសារមធ្យោបាយនៃផលិតកម្មថ្មីៗ ។ ដូច្នេះ វណ្ណៈពលករត្រូវបានចាត់ចូលពីគ្រប់ថ្នាក់នៃប្រជាជនទាំងអស់។

៧៨ វណ្ណៈពលករបានឆ្លងកាត់វិវត្តន៍ជាច្រើនដំណាក់កាល ។ ចាប់ពីពេលចាប់កំណើតឡើង ពួកគេចាប់ផ្តើមការតស៊ូជាមួយវណ្ណៈគហបតី ។ ដំបូង ការតស៊ូបានធ្វើឡើងដោយកម្មករម្នាក់ៗដោយខ្លួនឯង បន្ទាប់មកបានរាលដាលដល់អ្នកធ្វើការក្នុងវិជំនួញណាមួយ ក្នុងទីតាំងណាមួយប្រឆាំងនឹងគហបតីណាមួយដែលបានកេងប្រវញ្ចពួកគេដោយផ្ទាល់ ។ ការវាយប្រហាររបស់ពួកគេមិនបានតម្រង់ទៅលើលក្ខខណ្ឌនៃផលិតកម្មដែលកំណត់ដោយគហបតី ប៉ុន្តែសំដៅទៅលើឧបករណ៍ផលិតកម្មតែម្តង ។ ពួកគេបានបំផ្លាញផលិតផលនាំចូលដែលបាននឹងកំពុងជំនួសកម្លាំងពលកម្មរបស់ខ្លួន វាយកម្ទេចគ្រឿងម៉ាស៊ីន ដុតរោងចក្រ ជារួម ពួកគេព្យាយាមស្តារឡើងវិញនូវមុខមាត់ពលករសម័យមជ្ឈឹម ដោយកម្លាំងបាយ ។

៧៩ ដល់ដំណាក់កាលនេះ ពលករនៅតែបង្កើតជាក្រុមតូចៗ រប៉ាត់រប៉ាយពេញផ្ទៃប្រទេសនិងបែកបាក់សាមគ្គីដោយសារតែការប្រកួតប្រជែងគ្នាឯង ... ដូច្នេះ ចលនាប្រវត្តិសាស្ត្រទាំងមូលត្រូវបានប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃរបស់គហបតី ។ ជ័យជម្នះទាំងអស់ដែលទទួលបាន គឺជាជ័យជម្នះសម្រាប់ពួកគហបតី ។

៣០ ប៉ុន្តែជាមួយនឹងការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ពលករមិនត្រឹមតែកើនឡើងប៉ុណ្ណោះទេ តែថែមទាំងបានរួមកម្លាំងគ្នាកាន់តែច្រើន ឥទ្ធិពលកាន់តែខ្លាំង ហើយការជឿជាក់ក៏ខ្លាំងដែរ ។ ផលប្រយោជន៍និងលក្ខខណ្ឌជីវភាពរស់នៅផ្សេងៗគ្នារបស់វណ្ណៈពលករកន្លងមក ត្រូវបានធ្វើអោយស្មើភាពគ្នាកាន់តែខ្លាំងឡើង ដោយអាស្រ័យតាមសមាមាត្រចំនួនគ្រឿងម៉ាស៊ីនដែលលុបបំបាត់បំណែងចែកកម្លាំងពលកម្ម ហើយប្រាក់ឈ្នួលត្រូវបានកាត់បន្ថយក្នុងកម្រិតទាបដូចគ្នា ស្ទើរតែគ្រប់ទីកន្លែង ។ ការប្រកួតប្រជែងកាន់តែខ្លាំងរវាងពួកគហបតី និងវិបត្តិពាណិជ្ជកម្មដែលជាផលវិបាក បានធ្វើអោយប្រាក់ឈ្នួលរបស់កម្មករកាន់តែប្រែប្រួលខ្លាំង ។ ការកែលំអរគ្រឿងម៉ាស៊ីនអោយកាន់តែរីកចម្រើនកាន់តែលឿន ធ្វើអោយជីវភាពរស់នៅពួកគេកាន់តែអស្ថេរភាព ។ ការប៉ះទង្គិចគ្នារវាងកម្មករនិយោជិតម្នាក់ៗនិងគហបតីម្នាក់ៗ កាន់តែឆ្លុះបញ្ចាំងពីការប៉ះទង្គិចរវាងវណ្ណៈទាំងពីរ ។ នៅពេលនោះ កម្មករចាប់ផ្តើមរួមគ្នាជាផ្លូងតែមួយ (សហជីពពាណិជ្ជកម្ម) ដើម្បីប្រឆាំងនឹងពួកគហបតី ។ ពួកគេបានរួមគ្នាជាមួយគ្នាដើម្បីរក្សាអត្រាប្រាក់ឈ្នួល ។ ពួកគេបង្កើតសមាគមអចិន្ត្រៃយ៍ ដើម្បីសម្របសម្រួលការបះបោរម្តងម្កាល ម្តងនៅទីនេះម្តងនៅទីនោះ ការតវ៉ាបានផ្ទុះចេញជាកុបកម្ម ។

៣១ យូរៗម្តង កម្មករនិយោជិតទទួលបានជ័យជំនះ ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។ ផ្លែផ្កាពិតប្រាកដនៃការតស៊ូរបស់ពួកគេ មិនអាស្រ័យលើជ័យជំនះខ្លីៗនោះទេ ប៉ុន្តែអាស្រ័យលើសហជីពកម្មករដែលកាន់តែរីកច្រើនឡើងៗ ... ការបញ្ចូលកម្មករទាំងនេះអោយក្លាយជាវណ្ណៈតែមួយ ហើយក្រោយមក បានក្លាយជាគណបក្សនយោបាយមួយបានកើតឡើងជាថ្មីម្តងទៀត កាន់តែខ្លាំង កាន់តែរឹងមាំ, កាន់តែមហិមាជាងមុន ។ ពួកគេទាមទារការទទួលស្គាល់ផលប្រយោជន៍កម្មករជាផ្លូវច្បាប់ ដោយឆ្លៀតឱកាសពីការបែកបាក់ផ្ទៃក្នុងពួកគហបតី ...

៣២ ការប៉ះទង្គិចគ្នារវាងវណ្ណៈនានានៃសង្គមចាស់ កាន់តែបណ្តោយអោយវណ្ណៈពលកររីកធំធាត់បន្ថែមទៀត ។ ពួកគហបតីត្រូវជាប់ផុងក្នុងការប្រយុទ្ធគ្នាជាហូរហែ... ក្នុងចំណោមវណ្ណៈទាំងអស់ដែលប្រឈមមុខដោយផ្ទាល់ជាមួយពួកគហបតីសព្វថ្ងៃ គឺមានតែវណ្ណៈពលករតែមួយគត់ ដែលជាវណ្ណៈបដិវត្តន៍ពិតប្រាកដ ។ វណ្ណៈផ្សេងទៀតត្រូវខ្ទាត់ព្រាត់ ហើយនៅទីបំផុត ក៏រលាយបាត់ទៅដោយសារវិស័យឧស្សាហកម្មទំនើប ។ វណ្ណៈពលករ គឺជាផលិតផលសំខាន់ និងពិសេស របស់វាផ្ទាល់ ...

៣៣ ... ចលនាប្រវត្តិសាស្ត្រពីមុនទាំងអស់ គឺចលនាក្រុមមនុស្សភាគតិចឬបម្រើផលប្រយោជន៍ក្រុមទាំងនោះ ។ ចលនាពលករគឺជាចលនាសតិសម្បជញ្ញៈ ឯករាជ្យម្ចាស់ការដោយក្រុមមនុស្សភាគច្រើន ។ វណ្ណៈពលករដែលស្ថិតក្នុងស្រទាប់ទាបបំផុតនៃវណ្ណៈសង្គមបច្ចុប្បន្ន មិនអាចកើត, មិនអាចក្រោកឡើងខ្លួនឯងបាន ដោយរុះរើស្រទាប់វណ្ណៈក្នុងសង្គមផ្លូវការទាំងមូលឡើងវិញនោះទេ ...

៣៤ ... លក្ខខណ្ឌចាំបាច់សម្រាប់អត្ថិភាព និងសម្រាប់ឥទ្ធិពលវណ្ណៈគហបតី គឺការបង្កើតនិងការបង្កើនដើមទុន។ លក្ខខ័ណ្ឌសម្រាប់ដើមទុន គឺ ពលកម្មប្រាក់ឈ្នួល ។ ឯពលកម្មប្រាក់ឈ្នួលត្រូវអាស្រ័យទាំងស្រុងលើការប្រកួតប្រជែងគ្នារវាងកម្មករ ។ ភាពជឿនលឿននៃឧស្សាហកម្មដែលជម្រុញដោយមិនស្ម័គ្រចិត្តពីពួកគហបតី បានជំនួសការនៅដាច់ដោយឡែកៗពីគ្នានៃកម្មករដោយសារការប្រកួតប្រជែង ដោយជំនួសមកវិញនូវការរួមកម្លាំងបដិវត្តន៍របស់កម្មករតាមរយៈសមាគម ។ ដូច្នេះ ការអភិវឌ្ឍន៍ឧស្សាហកម្មសម័យទំនើប បានវាយបំបែកគ្រឹះដែលពួកគហបតីបានផលិត និងយកចំណេញពីផលិតផលទាំងនោះ ។ ដូច្នេះ ផលិតផលពិសេសជាងគេដែលពួកគហបតីបានផលិតនោះគឺ «ចបជីកដីកផ្នូរ» ខ្លួនឯង ។ ការដួលរលំរបស់ពួកគេ និងជ័យជម្នះនៃវណ្ណៈពលករ ក៏មិនអាចជៀសមិនផុតបានឡើយ ៕ »

## ៥.៥. ឧទាហរណ៍នៃទ្រឹស្តីប្រវត្តិសាស្ត្របែបកាល់ម៉ាក្សនិយម

### «ទស្សនៈខ្មែរក្រហមចំពោះប្រវត្តិសាស្ត្រ»

យើងដឹងហើយថា ប្រវត្តិសាស្ត្រពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះជនបដិវត្តន៍ម៉ាក្សិសនិយមព្រោះថា «ប្រវត្តិសាស្ត្រនៃគ្រប់សង្គមទាំងអស់ គឺជាប្រវត្តិនៃការតស៊ូវណ្ណៈ ។» នេះមានន័យថា ជនម៉ាក្សស៊ីសនិយម ប្រើប្រវត្តិសាស្ត្រដើម្បីជាលេសសម្រាប់ខ្លួនដណ្តើមអំណាចពីបច្ចាមិត្រ ដោយហេតុថា ចំពោះពួកគេ ប្រវត្តិសាស្ត្រតម្រូវអោយមានការតស៊ូវណ្ណៈ ។

ដូច្នេះហើយ ប្រវត្តិសាស្ត្រមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ខ្មែរក្រហម ។ ខ្មែរក្រហមគឺជាអង្គការនយោបាយម៉ាក្សិសនិយម ដោយយកគម្រូតាមទ្រឹស្តីម៉ាក្សលេនីននិយម ដែលជាឫសគល់នៃទ្រឹស្តីម៉ាក្សិសនិយម ។ ទ្រឹស្តីនេះត្រូវបានលូតលាស់ ដុះខ្នែង ដំបូង នៅប្រទេសរុស្ស៊ី នៅសម័យមុនបដិវត្តន៍កុម្មុយនីស្ត៍ នាឆ្នាំ១៩១៧ ។ ទោះបីទ្រឹស្តីនោះមានលក្ខណៈប្លែកពីម៉ាក្សិសនិយមបន្តិច តែទ្រឹស្តីទាំងពីរនេះមានលក្ខណៈដូចគ្នាច្រើន ចំពោះវិធីសរសេរប្រវត្តិសាស្ត្រ ។

ពេលពួកគេងាកមើលអតីតកាលរាប់ពាន់ឆ្នាំកន្លងមក ពួកមេខ្មែរក្រហមមើលឃើញតែទិដ្ឋភាពនៃការតស៊ូវណ្ណៈនៅក្នុងប្រទេសកម្ពុជា ដ៏យូរលង់ណាស់មកហើយ ។ ពួកគេសង្កត់ធ្ងន់ទៅលើការតស៊ូបះបោររបស់កសិករនៅសម័យអាណានិគមបារាំង និងបង្ហាញរឿងរ៉ាវទាំងនេះ ដើម្បីបំផុសបំផុលអោយមានចលនាបដិវត្តន៍មុះមុត ដែលអាចឈានទៅដល់ការបដិវត្តន៍ចុងក្រោយ ។ តាមរយៈសកម្មភាពបែបនេះ ពួកគេអាចបង្ហាញខ្លួនជាបក្សដ៏មានឥទ្ធិពលខ្លាំងក្លា ដែលមានប្រវត្តិជាយូរយារណាស់មកហើយ ។ ពួកគេអះអាងថា បក្សនយោបាយនេះកើតចេញពីប្រជាជន និងធ្វើអ្វីគ្រប់យ៉ាងសម្រាប់បុព្វហេតុនៃប្រជាជន។

តាមការពិត ការស្រាវជ្រាវប្រវត្តិសាស្ត្រថ្មីៗបានបង្ហាញថា នេះមិនមែនជាប្រវត្តិសាស្ត្រពិតឡើយ ។ ប្រវត្តិវិទូនានាបានបង្ហាញថា ការបះបោរភាគច្រើនត្រូវបានដឹកនាំដោយសមាជិករាជវង្ស ដែលចង់ដណ្តើមរាជបល្ល័ង្កសម្រាប់ខ្លួនឯងប៉ុណ្ណោះ ។ ការបះបោរផ្សេងទៀតត្រូវបានដឹកនាំដោយវណ្ណៈជាន់ខ្ពស់ខ្មែរ ដែលគិតថាវត្តមានរបស់បារាំងបានបន្ទាបសីលធម៌ខ្មែរបុរាណ ។ កុំស្មឹមថា ពួកគេក្រោកឡើងប្រឆាំងនឹងព្រះមហាក្សត្រ ដើម្បីទាមទារសិទ្ធិសេរីភាពជាងមុនអោយពួកកសិករ ។ នេះគ្រាន់តែជារឿងនិទាន ដែលខ្មែរក្រហមប្រឌិតឡើងដើម្បីបម្រើផលប្រយោជន៍បក្សពួករបស់គេប៉ុណ្ណោះ ។

ខ្មែរក្រហមប្រើប្រាស់ប្រវត្តិសាស្ត្រ ដើម្បីពង្រឹងសម្ព័ន្ធភាពអន្តរជាតិរបស់ខ្លួន ។ ប្រវត្តិបក្សរបស់ពួកគេផ្ទាល់ត្រូវបានផ្លាស់ប្តូរច្រើនលើកច្រើនសារ ដើម្បីសម្របតាមសម្ព័ន្ធមិត្តបរទេស ។ ដូច្នេះ ទើបខ្មែរក្រហមក្រោមការដឹកនាំរបស់ប៉ុលពត បានអះអាងថា បក្សរបស់ខ្លួនត្រូវបានបង្កើតឡើងដោយគ្មានជំនួយច្រើនពីវៀតណាម ដែលជាសត្រូវរបស់ប្រទេសចិន ចិនដែលជាអ្នកគាំទ្រដ៏ធំបំផុតរបស់ខ្មែរក្រហម ។ យ៉ាងណាមិញ ក្រោយសម័យប៉ុលពត នៅពេលដែលបក្សកុម្មុយនិស្ត៍ បានចងសម្ព័ន្ធភាពជាមួយវៀតណាម, ទំនាក់ទំនងប្រពៃណី ជាមួយពួកសង្គមនិយមវៀតណាម បានជះឥទ្ធិពលលើការវិវត្តន៍របស់ខ្មែរក្រហម និងកម្ពុជាប្រជាធិបតេយ្យ ។

លើសនេះទៅទៀត ប្រវត្តិសាស្ត្រក៏អាចត្រូវបានគេក្រឡៃដើម្បីបំពេញតម្រូវតាមថ្នាក់ដឹកនាំនាសម័យកាលខ្លះផងដែរ ។ នេះមានន័យថានៅពេលមេដឹកនាំផ្លាស់ប្តូរ ប្រវត្តិបក្សកុម្មុយនីស្ត៍ក៏ផ្លាស់ប្តូរតាមហ្នឹងដែរ ។ តួនាទីនៃមេដឹកនាំថ្មី និងសម្ព័ន្ធមិត្តថ្មីរបស់ខ្លួនតែងត្រូវគេចាត់ទុកថាមានសារៈសំខាន់ ។ ផ្ទុយទៅវិញ តួនាទីមេដឹកនាំចាស់

និងសម្ព័ន្ធមិត្តរបស់ពួកគេត្រូវបានគេបន្ទោសបង្អាប់យ៉ាងខ្លាំង ។ ហេតុការណ៍ទាំងនេះ បានកើតឡើង នៅពេលដែល ប៉ុល ពត កាន់កាប់ចលនាខ្មែរក្រហម និងក្រុមរបស់គាត់ដួលរលំ ។ (ពោលគឺពេល ប៉ុល ពត មានអំណាច តួនាទីរបស់ចលនានេះ និងសម្ព័ន្ធមិត្តចិនត្រូវបានលើកតម្កើង តែពេល ប៉ុល ពត បាត់បង់អំណាច ពួកគេទាំងពីរត្រូវបានគេថ្កោលទោស ។) ដូច្នេះ គេអាចសង្កេតឃើញយ៉ាងច្បាស់ថា ប្រវត្តិសាស្ត្រត្រូវបានពួកកុម្មុយនីស្ត៍ប្រើជាឧបករណ៍ដណ្តើមយកអំណាច ។ ប្រវត្តិសាស្ត្រជាអ្វីមួយដែលអាចជុសខាត់ និងផ្លាស់ប្តូរសម្រាប់តម្រូវតាមថ្នាក់ដឹកនាំសម័យណាមួយ ដែលពួកគេមានអំណាច ហើយនឹងផ្លាស់ប្តូរសម្រាប់បម្រើសម័យបច្ចុប្បន្ន ។

ស្របពេលខ្មែរក្រហមជឿថា «ប្រវត្តិសាស្ត្រនៃគ្រប់សង្គមទាំងអស់ គឺជាប្រវត្តិសាស្ត្រនៃការតស៊ូវណ្ណៈ» ពួកគេក៏ជឿដែរថា នៅពេលបដិវត្តន៍ទទួលបានជោគជ័យ ប្រវត្តិសាស្ត្រលែងមានទៀតហើយ ។ ហេតុនេះទើប ប៉ុល ពត និងចលនារបស់ខ្លួនផ្លាស់ប្តូរកាលបរិច្ឆេទឆ្នាំ ១៩៧៥ ទៅ **ឆ្នាំ 0 (សូន្យ)** សម្រាប់សម្គាល់ព្រឹត្តិការណ៍នៅក្នុងសង្គមថ្មីមួយ ដែលកើតឡើងនៅ **ក្រៅទំព័រប្រវត្តិសាស្ត្រ** (outside of history) ។ ពោលវាគឺជាអ្វីមួយ ដែលកើតក្រោយប្រវត្តិសាស្ត្រ ។ នេះឆ្លុះបញ្ចាំងថា ជនម៉ាក្សីសនិយមជឿជាក់ថា ប្រវត្តិសាស្ត្រមានគោលដៅមួយច្បាស់លាស់ ។ នោះគឺរំដោះប្រជាជនចេញពីរបបមូលធននិយម (ប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយដែលពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសណាមួយ ត្រូវបានគ្រប់គ្រងដោយឯកជន សម្រាប់ការចំណេញផ្ទាល់ខ្លួន ជាជាងគ្រប់គ្រងដោយរដ្ឋ) ។ នៅពេលដែលការរំដោះនេះទទួលបានជោគជ័យ ប្រវត្តិសាស្ត្រក៏ត្រូវបានបញ្ចប់ ។ នេះជាមធ្យោបាយដ៏គួរអោយចាប់អារម្មណ៍សម្រាប់ក្រលេកមើល និងស្វែងយល់អំពីប្រវត្តិសាស្ត្រ ដែល**មានចំណុចចាប់ផ្តើម និងចុងបញ្ចប់** ។

# មេរៀនទី ៦ ៖ ទ្រឹស្តីប្រវត្តិវិទ្យាបែបសង្គមសាស្ត្រ

## ៦.១. សេចក្តីផ្តើម

មេរៀននេះ ស្វែងយល់ពីការរួមចំណែកនៃប្រវត្តិសាស្ត្របែបសង្គម ក្នុងការចងក្រងប្រវត្តិសាស្ត្រ។ ជារឿយៗ កាលពីអតីតកាល ប្រវត្តិសាស្ត្របែបសង្គម ត្រូវបានគេចាប់អារម្មណ៍តិចតួចណាស់, ភាគច្រើនផ្តោតលើទិដ្ឋភាពនៃបទពិសោធន៍របស់មនុស្សដែលមិនសំខាន់ បើប្រៀបធៀបទៅនឹងបញ្ហា ដែលមានទម្ងន់ដូចជានយោបាយ។ ដោយឡែក ប៉ុន្មានឆ្នាំចុងក្រោយនេះ មានកំណើនយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការសិក្សាយ៉ាងទូលំទូលាយ ក្នុងក្របខ័ណ្ឌ ប្រវត្តិសាស្ត្រសង្គម ។ លើសពីនេះទៀត ការសង្ស័យយ៉ាងជ្រាលជ្រៅក្នុងចំណោមប្រវត្តិវិទូ (ដែលថាសង្គមវិទូព្យាយាមពន្យល់ច្បាប់ជាសកល), បានចាប់ផ្តើមថមថយវិញ នៅពេលដែលពួកគេបានរកឃើញគុណតម្លៃនៃគំនិតវិភាគបែបសង្គម ក្នុងការបកស្រាយភស្តុតាងប្រវត្តិសាស្ត្រ។ ជាលទ្ធផល របៀបវារៈនៃសំណេរប្រវត្តិសាស្ត្រ ត្រូវបានពង្រីកនិងមានការកើនឡើងនៃការចាប់អារម្មណ៍លើប្រធានបទ ដូចជា ការកំសាន្ត ភាសា ពិធីសាសនា និងទំនៀមទម្លាប់ ដែលបានកំណត់ជីវិតសង្គមរបស់យើង។

គ្មានប្រធានបទណា ដែលទាក់ទាញចំណាប់អារម្មណ៍ជាងវណ្ណៈសង្គមនោះទេ ហើយនៅក្នុងផ្នែកបន្តបន្ទាប់យើងពិនិត្យមើលវិធី ដែលអ្នកប្រវត្តិសាស្ត្រសង្គម បានរកឃើញគំនិតនៃគុណតម្លៃក្នុងការបែងចែកវណ្ណៈសង្គម ។ ចំណាប់អារម្មណ៍ដំបូងត្រូវបានធ្វើឡើងដោយសំណេររបស់ម៉ាក្ស ដែលបានដាក់វណ្ណៈសង្គមនៅកណ្តាលឆាក។ សញ្ញាណនេះ បានបង្ហាញឱ្យឃើញនូវផ្លែផ្កាច្រើនគួរសម ជាពិសេស នៅក្នុងការសាកសួររកសច្ចៈភាពប្រវត្តិសាស្ត្រ ដែលទាក់ទងនឹងការផ្លាស់ប្តូរទំនាក់ទំនងសង្គម។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះហើយ ភាគច្រើន ស្ថិតនៅក្រោមឥទ្ធិពលរបស់អ្នកប្រាជ្ញប្រវត្តិសាស្ត្រស្រ្តីនិយម និងប្រវត្តិវិទូក្រោយសម័យអាណានិគម, វណ្ណៈសង្គមត្រូវបានជំនួសដោយ ភេទ និងពូជសាសន៍។

នៅក្នុងផ្នែកចុងក្រោយ នឹងពិភាក្សាអំពីគំនិតរៀបចំមួយផ្សេងទៀតនៃប្រវត្តិសាស្ត្រសង្គម គឺគ្រួសារ។ ក្នុងការទទួលស្គាល់យ៉ាងពេញទំហឹងអំពី វត្តមានយូរអង្វែងរបស់វា និងស្ទើរតែមានលក្ខណៈសកល អ្នកសង្គមវិទ្យានិងប្រវត្តិវិទូសង្គមបានចាប់អារម្មណ៍លើគ្រួសារ ជាយូរណាស់មកហើយ ។ ទោះយ៉ាងណាក៏ដោយមានវិធីសាស្ត្រផ្សេងៗគ្នា ដែលនាំមុខទិដ្ឋភាពខុសៗគ្នានៃបទពិសោធន៍គ្រួសារ ហើយជាញឹកញាប់នាំឱ្យមានការសន្និដ្ឋានខុសៗគ្នាអំពីតួនាទីគ្រួសារ នៅក្នុងសង្គមអតីតកាលនិងបច្ចុប្បន្ន ។

មែនទែន ប្រវត្តិវិទ្យាសង្គមសាស្ត្រ មិនមែនជាវិធីសាស្ត្រថ្មីសម្រាប់ចងក្រងប្រវត្តិសាស្ត្រនោះទេ ប៉ុន្តែ ជាទស្សនទានថ្មីចំពោះអ្វីដែលបង្កើតបានជាប្រវត្តិសាស្ត្រផ្ទាល់ ។ ចាប់តាំងពីសម័យក្រិកបុរាណ ប្រវត្តិវិទូនានាបានផ្តោតអារម្មណ៍ជាពិសេសទៅលើនយោបាយ និង សង្គ្រាម ។ ពួកគេចងក្រងប្រវត្តិសាស្ត្រដោយការសិក្សាស្រាវជ្រាវអំពីជីវិតមេដឹកនាំនយោបាយនិងយោធា ដោយចង់ដឹងថាតើពួកគេមានទំនាក់ទំនងនឹងគ្នាយ៉ាងម៉េច ហើយតើពួកគេបានធ្វើការសម្រេចចិត្តយ៉ាងដូចម្តេច ដែលបណ្តាលអោយមានសង្គ្រាម និងបដិវត្តន៍ ដែលប្រវត្តិវិទូបាននិងកំពុងសិក្សា ។ វាត្រូវបានចារិកជាគោលការណ៍ប្រវត្តិសាស្ត្រជាពេញនិយមខ្លាំងដោយលោក រ៉ែងឃ័រ (Ranke) ដែលបានអះអាងថា ប្រវត្តិវិទូគួរតែផ្តោតអារម្មណ៍ខ្លាំងទៅលើព្រឹត្តិការណ៍ធំៗ នៅក្នុងអតីតកាល ឬយុគសម័យដែលព្រឹត្តិការណ៍សំខាន់ៗជាច្រើន បានកើតឡើង ។

ប្រវត្តិវិទូសង្គមសាស្ត្រ បានទទួលយកគោលការណ៍ប្រវត្តិសាស្ត្ររបស់លោកវ៉ែងយ័រនិងបានបន្ថែមទស្សនៈដ៏ជ្រាលជ្រៅរបស់គោលការណ៍ម៉ាក្សិសនិយម ។ ជាលទ្ធផល ពួកគេបានអះអាងថា ការប្រែប្រួលផ្នែកសេដ្ឋកិច្ចមានសារៈសំខាន់ជាងការប្រែប្រួលផ្នែកនយោបាយ ព្រោះការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច (ដែលជាគ្រឹះនៃអ្វីគ្រប់យ៉ាង) នឹងបណ្តាលអោយមានការផ្លាស់ប្តូរនយោបាយ ដោយផ្ទាល់ (បម្លាស់ប្តូរនៅដំបូលខាងលើ) ។

ពួកគេសង្កេតទៅលើទំនាក់ទំនងរវាងវណ្ណៈនានា ហើយកត់សម្គាល់ឃើញថា បដិវត្តន៍និងនយោបាយ មិនតែងតែត្រូវបានដឹកនាំដោយ មនុស្សវណ្ណៈខ្ពស់ និងគោលនយោបាយរបស់ពួកគេនោះទេ ផ្ទុយទៅវិញ មនុស្សវណ្ណៈទាប រួមមាន កសិករ ពលករ ជាដើម ក៏មានអំណាចផងដែរ ដោយសារឥទ្ធិពលរបស់ពួកគេលើសេដ្ឋកិច្ច ។

## ៦.២. ប្រវត្តិសាស្ត្រខាងលើ និងប្រវត្តិសាស្ត្រខាងក្រោម

ប្រវត្តិវិទូសង្គមសាស្ត្រ បានងាកទៅចាប់អារម្មណ៍លើមូលហេតុវែងឆ្ងាយ ដែលនាំអោយមានការប្រែប្រួលគ្រឹះសេដ្ឋកិច្ច ។ ពួកគេប្តេជ្ញាចិត្តលែងតាមដាន «ប្រវត្តិសាស្ត្រខាងលើ» (from above)ដែលវាហាក់ដូចជាត្រូវបានបង្កើតឡើងដោយអ្នកមានអំណាចខ្លាំង ធ្វើសកម្មភាពនយោបាយ ។ ពួកគេសង្កេតតាមដាន «ប្រវត្តិសាស្ត្រខាងក្រោម» (from below) ដែលជាប្រវត្តិនៃប្រជាពលរដ្ឋសាមញ្ញដែលជាកម្លាំងសេដ្ឋកិច្ចដ៏ធំបំផុត ។

ប្រវត្តិសាស្ត្របែបនេះ តម្រូវអោយប្រវត្តិវិទូចេះសង្កេតអោយបានស៊ីជម្រៅនិងទូលំទូលាយ ក្នុងសង្គមជាក់ស្តែង ។ គួរកត់សម្គាល់ថា កន្លងមក ពួកគេខិតខំស្វែងរកមូលហេតុដែលនាំអោយមានបដិវត្តន៍ និងបម្លាស់ប្តូរនយោបាយ តាមរយៈលក្ខណៈចរិតនៃមេដឹកនាំ ព្រះរាជា អ្នកនយោបាយ និងមេដឹកនាំបដិវត្តន៍, ប៉ុន្តែ ឥឡូវពួកគេស្វែងរកមូលហេតុបម្លាស់ប្តូរទាំងនោះ តាមរយៈទំនាក់ទំនងនៃវណ្ណៈទាំងឡាយវិញម្តង ។ ពួកគេគិតថា វណ្ណៈទាំងអស់ជាអ្នកបង្កអោយមានការប្រែប្រួល មិនមែនបុគ្គលដោយឡែកណាមួយទេ ។ ដូច្នេះហើយ ជំនួសអោយការសង្កេតតែលើខ្សែជីវិតបុគ្គលសំខាន់ៗមួយក្រុមតូច ពួកគេត្រូវតែសង្កេតលើក្រុមកម្មករទាំងមូល ។ ប្រការនេះមានន័យថា ប្រវត្តិវិទូត្រូវតែសំឡឹងមើលការផ្លាស់ប្តូរនៅក្នុងក្រុមមនុស្សទាំងមូល ។ ពួកគេរកមើលការផ្លាស់ប្តូរនៅក្នុងសង្គមទូលំទូលាយជាងមុន ដោយមិនសំលឹងមើលជំនឿឬគំនិតរបស់បុគ្គលនីមួយៗឡើយ ។ ពួកគេសង្កេតមើលបម្លាស់ប្តូរទាំងអស់នេះ ក្នុងកម្រិតវប្បធម៌ ។

## ៦.៣. ក្រុមកាលប្បវត្តិ

ប្រវត្តិវិទូសង្គមសាស្ត្រល្បីល្បាញដំបូងគេ គឺជាក្រុមកាលប្បវត្តិ (Annales School) ក្នុងប្រទេសបារាំង ។ នេះជាប្រវត្តិវិទូមួយក្រុម ដែលបញ្ចូលសមាសធាតុខ្លះនៃមុខវិជ្ជាដទៃទៀតដូចជា សង្គមវិទ្យានិងនរៈវិទ្យា សម្រាប់ការសិក្សារបស់ខ្លួនលើវិស័យសេដ្ឋកិច្ច និងវប្បធម៌ ជាបន្តបន្ទាប់ ។ ទោះបីជាក្រុមនេះត្រូវគេស្គាល់ជាក្រុមទស្សនៈវិជ្ជាមួយក៏ពិតមែន វាមិនត្រូវបានបង្កើតជាផ្លូវការឡើយ ។ តាមពិតទៅ វាសំដៅទៅលើប្រវត្តិវិទូមួយក្រុម ដែលជាប់ពាក់ព័ន្ធនឹងការបោះពុម្ព ទស្សនាវដ្តីស្រាវជ្រាវជាន់ខ្ពស់មួយឈ្មោះ «វស្សប្បវត្តិ ប្រវត្តិសេដ្ឋកិច្ច និងសង្គម» *(The Annales d'histoire economique et sociale)* ។

វិធីសាស្ត្រនៃក្រុមសិក្សាស្រាវជ្រាវនេះ មានច្បាស់លាស់ក្នុងឧទាហរណ៍មួយចំនួន ។ ជាស្ថាបនិក និងជានិពន្ធនាយកវស្សប្បវត្តិនេះផងដែរ លោក លូសៀន ហ្វេបវ្រឺ (Lucien Febvre) បានស៊ើបអង្កេតក្នុងសតវត្សរ៍ទី១៦

ដែលជាសម័យកាលមួយត្រូវបានលោក វ៉ែងយ័រ បានធ្វើការសិក្សាស្រាវជ្រាវកាលពី ១៥០ ឆ្នាំមុន ។ ប៉ុន្តែ ផ្ទុយពីលោក វ៉ែងយ័រ ដែលបានស៊ើបអង្កេតបុគ្គលិកលក្ខណៈផ្ទាល់របស់អ្នកនយោបាយនិងជនបដិវត្តន៍, លោក ហ្វេបវ្រឺ សង្កេតលើទិដ្ឋភាពវប្បធម៌ដ៏ទូលំទូលាយ ដែលជះឥទ្ធិពលលើបុគ្គលិកលក្ខណៈរបស់ពួកគេ ។ គាត់បានអះអាងថា បើមិនមានការប្រែប្រួលក្នុង ផ្នែកវប្បធម៌ទូទៅ បុគ្គលម្នាក់ៗក៏មិនមានគំនិត ឬមិនអាចបង្កើតទ្រឹស្តីផ្សេងៗ ដែលនាំទៅរកការផ្លាស់ប្តូរផ្នែកនយោបាយនោះដែរ ។ ដោយលើកយកបញ្ហាសាសនាជាឧទាហរណ៍ស្រាប់ គាត់បានអះអាងថា បុគ្គលម្នាក់ៗ មិនអាចដឹកនាំចលនាវប្បធម៌ឆ្ពោះទៅលទ្ធិបដិសេធន៍អត្ថិភាពរបស់ព្រះអាទិទេពឡើយ ប៉ុន្តែ គាត់បន្តអះអាងថា ការប្រែប្រួលផ្នែកវប្បធម៌និងសង្គម ជាបន្តបន្ទាប់ បានបណ្តាលអោយបុគ្គលទាំងនោះលែងជឿអត្ថិភាពព្រះអាទិទេព ។

ប្រវត្តិវិទូសង្គមសម្លឹងមើលហួសពីរង្វង់ព្រំដែននៃព្រឹត្តិការណ៍ដោយឡែកណាមួយ ហើយសម្លឹងរកកម្រងមូលហេតុប្រទាក់ក្រឡាគ្នា ដែលបណ្តាលអោយព្រឹត្តិការណ៍នោះកើតមានឡើង ។ ពួកគេមិនសង្កេតមើលតែព្រឹត្តិការណ៍បដិវត្តន៍តែមួយទេ ប៉ុន្តែមើលកម្រងផ្នត់គំនិតបដិវត្តន៍នានាមុនផ្ទុះបដិវត្តន៍ ។ ពួកគេជឿថា នៅពីក្រោយព្រឹត្តិការណ៍ប្រចាំថ្ងៃក្នុងជីវិតរបស់យើង មានចរន្តបទដ្ឋានវប្បធម៌និងសង្គមកាន់តែជ្រៅ ដែលជះឥទ្ធិពលលើយើងគ្រប់គ្នា ។

## ៦.៤. ប្រវត្តិមនោគតិ

ពួកគេក៏ចាប់អារម្មណ៍ក្នុងការសង្កេតមើលប្រវត្តិមនោគតិផងដែរ ។ មនោគតិ ដែលអាចត្រូវនឹងពាក្យបារាំង Mentalité និងភាសាអង់គ្លេស Mentality សំដៅលើដំណើររបស់ចិត្ត ឬ ដំណើរប្រព្រឹត្តទៅនៃចិត្តគំនិតខាងក្នុងរបស់មនុស្ស (Nath, ១៩៦៧) ។ ជារួម វាសំដៅទៅគំនិត មតិ ជំនឿ ការជម្រុញចិត្តនិងការយល់ដឹងរបស់មនុស្សចំពោះពិភពលោក ។ វាមានន័យស្មើនឹងការសម្លឹងមើលអ្វីដែលមនុស្សគិតអំពីពិភពលោកនៅជុំវិញពួកគេ ។ ប្រវត្តិវិទូវិស្សប្បវត្តិ បានគិតថា មនោគតិនេះ មានសារៈសំខាន់ក្នុងការស្វែងរកមូលហេតុនៃព្រឹត្តិការណ៍ទាំងឡាយ ។ តាមរយៈការសង្កេតមើលកត្តាជម្រុញទឹកចិត្ត និងឧត្តមគតិ (របស់មនុស្ស) ប្រវត្តិវិទូអាចឈានដល់កម្រិតថ្មីមួយទៀតសម្រាប់ស្វែងយល់ពីអតីតកាល ។

## ៦.៥. ប្រវត្តិសាស្ត្រទាំងមូល

ប្រវត្តិវិទូសង្គមសាស្ត្រជឿជាក់ថា រាល់សមាសធាតុផ្សេងៗនៃអតីតកាល គឺជាផ្នែកនៃប្រវត្តិសាស្ត្រ ។ ផ្ទុយពីលោក វ៉ែងយ័រ ដែលយល់ថា ព្រឹត្តិការណ៍នានា ជាអ្វីគ្រប់យ៉ាងដែលប្រវត្តិវិទូចាំបាច់ត្រូវតែសង្កេតមើល, ហើយក៏ខុសពីជនម៉ាក្សិសនិយម ដែលយល់ឃើញថា ប្រវត្តិសាស្ត្រមានត្រឹមតែការតស៊ូវណ្ណៈ, ប្រវត្តិវិទូសង្គមសាស្ត្រព្យាយាមស្វែងយល់ពីទិដ្ឋភាពធំទូលាយជាង ។ ពួកគេយល់ឃើញថា ព្រឹត្តិការណ៍នានានិងវប្បធម៌ដែលជម្រុញព្រឹត្តិការណ៍ទាំងនោះ រួមទាំងមនោគតិរបស់មនុស្ស គឺជាផ្នែកទូលំទូលាយនៃប្រវត្តិសាស្ត្រទាំងមូល (Total history) ដែលសង្កេតលើអ្វីៗគ្រប់យ៉ាង ។ នេះហើយជាប្រវត្តិសាស្ត្រ ដែលប្រវត្តិវិទូបែបសង្គមសាស្ត្រព្យាយាមចងក្រង ។

ការព្យាយាមចងក្រងប្រវត្តិសាស្ត្រទាំងមូល ដែលរួមបញ្ចូលវប្បធម៌ ការជម្រុញទឹកចិត្តរបស់មនុស្សជាដើម ... តម្រូវអោយប្រវត្តិវិទូទាំងឡាយស្វែងរកប្រភពព័ត៌មានថ្មីៗបន្ថែមទៀត ។ ដើម្បីរក អោយឃើញនូវទស្សនៈរបស់

មនុស្សចំពោះពិភពលោក ក៏ដូចជាវប្បធម៌ ប្រវត្តិវិទូបានសម្លឹងមើលប្រភពព័ត៌មានដទៃទៀត ដូចជា សិល្បៈ អក្សរសាស្ត្រ ស្ថាបត្យកម្ម និងភស្តុតាងជាក់ស្តែង ដូចជា សំលៀកបំពាក់ គ្រឿងសង្ហារឹម កំណត់ហេតុប្រចាំថ្ងៃ វត្ថុសិល្បៈបុរាណ កំណត់ត្រាសាធារណៈ (បញ្ជាក់កំណើត អាពាហ៍ពិពាហ៍ និងមរណភាព) និងភស្តុតាងបណ្ណាសារដទៃទៀតផងដែរ ។ ប្រវត្តិវិទូសង្គមសាស្ត្របើកទូលាយព្រំដែនប្រភពឯកសារ ឬព័ត៌មានថ្មីមួយ ហើយចង្អុលបង្ហាញដល់ប្រវត្តិវិទូនានាថាត្រូវអានឬពិនិត្យមើល និងបកស្រាយប្រភពព័ត៌មានទាំងនោះយ៉ាងដូចម្តេច ដើម្បីពន្យល់យើងអំពីសង្គម និងវប្បធម៌ ក្នុងអតីតកាល ។គោលការណ៍ប្រវត្តិសាស្ត្រនេះ ត្រូវបានប្រវត្តិវិទូសង្គមសាស្ត្រអនុវត្តតាម ក្នុងកំឡុងពេលជាច្រើនឆ្នាំបំផុត នៅក្នុងសតវត្សរ៍ទី ២០ ។

វិធីសាស្ត្រថ្មីៗក្នុងប្រវត្តិសាស្ត្រសង្គម បានបើកការជជែកដេញដោល និងពិចារណានូវសំណួរសំខាន់ៗ មួយចំនួន សម្រាប់យើងទាំងអស់គ្នា ។ ទីមួយ គឺជាសំណួរពាក់ព័ន្ធនឹងទ្រឹស្តី។ តាមធម្មតា អ្នកប្រវត្តិសាស្ត្រមិនសូវចាប់អារម្មណ៍លើទ្រឹស្តី ដោយធ្វើការយ៉ាងម៉ឺងម៉ាត់ជាមួយភស្តុតាង ពួកគេមានទំនោរចង់ឃើញតួនាទីរបស់ពួកគេជាអ្នកកត់ត្រារឿងប្រវត្តិសាស្ត្រពិតៗ ដោយបន្សល់ទុកនូវផ្នែកអរូបី នៃទ្រឹស្តីខ្លះ ដល់អ្នកប្រាជ្ញក្នុងវិទ្យាសាស្ត្រសង្គម។ ទំនោរនោះបានផ្លាស់ប្តូរហើយ។ ប្រវត្តិវិទូទទួលស្គាល់កាន់តែច្រើនឡើងថាទ្រឹស្តីតែងតែចង្អុលបង្ហាញបន្ថែមទៅលើសំណេររបស់ពួកគេ ហើយថាមានរឿងជាច្រើនដែលត្រូវរៀនពីកិច្ចការក្នុងមុខវិជ្ជាផ្សេងៗ ដូចជា សង្គមវិទ្យា នរវិទ្យា និងភូមិវិទ្យា។ ការទទួលយកយ៉ាងទូលំទូលាយនៃសញ្ញាណមួយចំនួនដូចជា វណ្ណៈសង្គម រចនាសម្ព័ន្ធសង្គម ស្មារតីសុន្ទរកថា អត្តសញ្ញាណ និងមនោគមវិជ្ជា គឺជាលទ្ធផលនៃការរំលាយព្រំដែនឬជញ្ជាំងសិប្បនិម្មិត ដែលអ្នកប្រវត្តិសាស្ត្របានសាងសង់ឡើងព័ទ្ធជុំវិញខ្លួនឯង។

ទំនាក់ទំនងរវាងសង្គមវិទ្យានិងប្រវត្តិវិទ្យា, ដែលបង្ហាញឱ្យឃើញច្បាស់បំផុតនៅ ក្នុងការវិវត្តនៃប្រវត្តិសាស្ត្រសង្គម, គឺមិនខុសពីទំនាក់ទំនងរវាងបងប្អូនបង្កើតដែលឈ្លោះប្រកែកគ្នាឡើយ។ ក្នុងនាមជាមុខវិជ្ជាដែលត្រូវបានគេទទួលស្គាល់ ពួកគេបានចាប់កំណើតឡើង និងរីកធំធាត់ ក្នុងពេលតែមួយ។ ហើយចំណាប់អារម្មណ៍របស់ពួកគេមានភាពដូចគ្នាខ្លាំង។ ការរៀបចំ និងសណ្តាប់ធ្នាប់សង្គមការិយាធិបតេយ្យ ការលំហែកាយ សាសនា សង្គ្រាម ទីក្រុង គ្រួសារ អាកប្បកិរិយាអ្នកបោះឆ្នោត គ្រាន់តែជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ បានទាក់ទាញការចាប់អារម្មណ៍យ៉ាងច្រើន ពីសង្គមវិទូ និងប្រវត្តិវិទូ។ ទោះយ៉ាងណាវិធីសាស្ត្រ ឬគោលការណ៍ របស់មុខវិជ្ជានីមួយៗ ចំពោះបញ្ហាទាំងនេះ បានក្លាយជាប្រភពនៃការបែងចែកដ៏ស្រួចស្រាល ក្នុងចំណោមមុខវិជ្ជាទាំងពីរ សង្គមវិទូចាប់អារម្មណ៍ក្នុងការកំណត់គំរូ ឬ ទំនោរទូទៅ ដោយផ្អែកលើមូលដ្ឋានដែលពួកគេអាចបង្កើតច្បាប់ជាសកលនៃអាកប្បកិរិយារបស់មនុស្ស។ ផ្ទុយទៅវិញ ប្រវត្តិវិទូ មានការចាប់អារម្មណ៍ទៅលើការពន្យល់ អំពីឯកលក្ខណៈភាពនិង លក្ខណៈពិសេសណាមួយ ទៅវិញ។ ជាឧទាហរណ៍ សាកល្បងពិនិត្យការធ្វើចំណាកស្រុករបស់មនុស្ស។ សង្គមវិទូ បានសិក្សាពីទម្រង់និងបទពិសោធន៍ផ្សេងៗគ្នា ដែលពួកគេបានដាក់ចេញនូវច្បាប់ ដែលអនុញ្ញាតឱ្យយើងកំណត់និងពន្យល់ពីភាពខុសគ្នារបស់ពួកគេ។ ក្នុងការធ្វើដូច្នេះ ពួកគេបានបែងចែកភាពខុសគ្នារវាងជនអន្តោប្រវេសន៍ដែលត្រូវបានគេបង្ខំ ដូចជា ចលនានៃអ្នកដែលរត់គេចពីការធ្វើទុក្ខបុកម្នេញ (ឧទាហរណ៍ ហ៊ូហ្គូណូត ទាសករអាហ្វ្រិក និងជនជាតិជ្វីហ្វ) និងជនចំណាកស្រុកដែលត្រូវបានជំរុញ ដោយការប៉ុនប៉ង ដើម្បីស្វែងរកជីវិតល្អប្រសើរ (ជនជាតិអាស៊ី និងជនជាតិអៀរឡង់ជាច្រើន) ។ ម៉្យាងវិញទៀត ប្រវត្តិវិទូទំនងយល់ពីលក្ខណៈពិសេសនិងសក្តានុពលនៃបទពិសោធន៍ឱផរ៉ង់ស្បៃលខុសៗគ្នាទាំងនេះ ហើយស្វែងរកការផ្តល់យោបល់អំពីភាពស្រដៀងគ្នាណាមួយ រវាងហ៊ូហ្គូណូតនិងទាសករដែលមិនមានប្រយោជន៍។

ទោះយ៉ាងណាក៏ដោយពេលខ្លះ អ្នកប្រវត្តិសាស្ត្របានមើលដោយការច្រណែននឹងសមត្ថភាពរបស់សង្គមវិទូអាចលេងជាមួយទ្រឹស្តីបាន។ ដូចដែលយើងបានឃើញការអភិវឌ្ឍន៍នៃមុខវិជ្ជាប្រវត្តិសាស្ត្រ មាននិន្នាការគេចចេញ ឬជៀសវាងការប្រើទ្រឹស្តី ព្រោះវាត្រូវបានគេជឿជាក់ថាការប្រើប្រាស់ទ្រឹស្តីនឹងធ្វើឱ្យខូចសមត្ថភាពរបស់ ប្រវត្តិវិទូក្នុងការបកស្រាយឬវិភាគ ភស្តុតាង អោយបានត្រឹមត្រូវ។ ជាមួយនឹងការទទួលស្គាល់ថា ប្រវត្តិសាស្ត្រមិនអាចចងក្រង ឬបកស្រាយអោយបានពេញលេញ និងសុក្រឹតមួយរយភាគរយ ពីព្រោះប្រវត្តិសាស្ត្រទាំងអស់ត្រូវបានជះឥទ្ធិពលដោយមនសិការផ្ទាល់ខ្លួន ឬ ដោយទស្សនៈទ្រឹស្តីនានាក្តី ប្រវត្តិវិទូបានពិនិត្យមើល យ៉ាងស៊ីជម្រៅនូវតួនាទីឬប្រយោជន៍ដែលផ្តល់អោយដោយទ្រឹស្តី ។ ហើយមានប្រវត្តិវិទូជាច្រើន នាពេលបច្ចុប្បន្ននេះ ដែលពិតជាចាប់អារម្មណ៍ក្នុងការធ្វើឱ្យប្លែកពីគេដើម្បីកំណត់អត្តសញ្ញាណលំនាំសកល ឬសូម្បីតែ អាកប្បកិរិយារបស់មនុស្ស ក្នុងតំបន់ណាមួយនាអតីតកាលដោយផ្អែកលើច្បាប់ ដែលអាចត្រូវបានបង្កើតឡើង។ មុខវិជ្ជាផ្ទាល់ខ្លួនរបស់ពួកគេមានទ្រឹស្តីតិចតួចណាស់ ដែលអាចចូលរួមចំណែក។ ដូច្នេះហើយ ពួកគេសម្លឹងរកទ្រឹស្តី នៅកន្លែងផ្សេង។ នរៈវិទូ សេដ្ឋកិច្ចវិទូ និងអ្នកវិទ្យាសាស្ត្រនយោបាយ មានទ្រឹស្តីរបស់ពួកគេផ្ទាល់ ប៉ុន្តែ អ្វីដែលល្អបំផុត ត្រូវបានរកឃើញ នៅក្នុងកម្មសិទ្ធិរបស់អ្នកសង្គមវិទ្យា។ ហេតុនេះហើយបានជា អ្នកប្រវត្តិសាស្ត្រ បានធ្វើការអនុវត្តដោយយកចិត្តទុកដាក់នូវគោលគំនិតទាំងនោះ (ដូចជាវណ្ណៈសង្គម ការិយាធិបតេយ្យ អត្តសញ្ញាណ និងការគ្រប់គ្រងសង្គម ដែលទាំងអស់នេះត្រូវបានអភិវឌ្ឍន៍ឡើងដោយសង្គមវិទូ) ដើម្បីកត់ត្រាប្រវត្តិសាស្ត្រ ។

លទ្ធផលនៃការអនុវត្តន៍ ចេញផ្លែផ្កាគួរជាទីពេញចិត្ត ក្នុងវិសាលភាពនៃការសិក្សាប្រវត្តិសាស្ត្រដែលបានពង្រីកទៅក្នុងវិស័យថ្មីៗ ដែលគួរឱ្យចាប់អារម្មណ៍។ បើគ្មានចំណាប់អារម្មណ៍លើសង្គមវិទ្យាទេ ការងារប្រវត្តិសាស្ត្រនៅក្នុងវិស័យនានា ដូចជា គ្រួសារ ឧក្រិដ្ឋកម្ម និងជំនឿនិងសាសនាប្រជាប្រិយ នឹងមិនកើតឡើងទេ។ ប៉ុន្តែប្រវត្តិវិទូត្រូវជានាថា ពួកគេមិនប្រកាន់យកទស្សនៈសង្គមវិទ្យាក្នុងលក្ខណៈមិនច្បាស់លាស់នោះទេ។ ភាពពាក់ព័ន្ធ អត្ថន័យ និងតម្លៃនៃទស្សនៈ អាចផ្លាស់ប្តូរពីសម័យប្រវត្តិសាស្ត្រមួយទៅសម័យមួយទៀត ហើយពិតជាមានគ្រោះថ្នាក់ពិតប្រាកដ ដែលប្រភេទទ្រឹស្តីសកល បិទបាំងភាពពិសេសឬភាពដោយឡែក ទាំងក្នុងអតីតកាល និងបច្ចុប្បន្នកាល ។ ហេតុនេះ យើងត្រូវតែបន្តការប្រុងប្រយ័ត្នដើម្បីកុំឱ្យងាយលង់នឹងទ្រឹស្តីរបស់បងប្អូនយើង[១១]។

## សំណួរជជែកវែកញែក

១. តើនរណាជាស្ថាបនិកទ្រឹស្តីប្រវត្តិសាស្ត្របែបសង្គម?

២. ចូរពន្យល់«ប្រវត្តិសាស្ត្រខាងលើ» និង«ប្រវត្តិសាស្ត្រខាងក្រោម»?

៣. ដូចម្តេចដែលហៅថា «ប្រវត្តិមនោគតិ»? ចូរពន្យល់ និង លើកឧទាហរណ៍បញ្ជាក់ ។

៤. តើអ្វីទៅជា«ប្រវត្តិសាស្ត្រទាំងមូល»?

៥. តើ«វស្សប្បវត្តិ»មានន័យយ៉ាងដូចម្តេច?

៦. តើប្រវត្តិវិទូសង្គមសាស្ត្រអាចប្រើប្រាស់ប្រភពព័ត៌មានអ្វីខ្លះ?

[១១] (Peter Claus, John Marriott, ២០១៧)

# មេរៀនទី ៧ ៖ ទ្រឹស្តីប្រវត្តិវិទ្យាក្រោយសម័យទំនើប

## ៧.១. សេចក្តីផ្តើម

ទ្រឹស្តីក្រោយសម័យទំនើប ឬ ទ្រឹស្តីក្រៅរចនាសម្ព័ន្ធ (Post-Structuralism) គឺជាវិធីសាស្ត្រថ្មីនៃការគិតពិចារណា ដែលត្រូវបានអភិវឌ្ឍន៍ឡើងក្រោយសម័យកាលរីករវ នៅអឺរ៉ុប នៅដើមសតវត្សរ៍ទី ២០ ។

សង្គ្រាមលោកលើកទី១ បានផ្ទុះឡើង ដោយសារតែយោធាជាតិនិយមនៅអឺរ៉ុប ។ សង្គ្រាមលោកលើកទី២ គឺជាការប្រយុទ្ធប្រឆាំងនឹងចលនាហ្វាស៊ីសនិយម ចំណែកសង្គ្រាមត្រជាក់ ប្រយុទ្ធប្រឆាំងនឹងកុម្មុយនិស្តនិយម ។ សង្គ្រាមនីមួយៗ បានរាលដាលខ្លាំង ដោយសារទ្រឹស្តីនយោបាយនិងប្រវត្តិសាស្ត្រ កើនឡើងឥទ្ធិពលខ្លាំងពេកពោលគឺ បណ្តាជនទាំងឡាយបានជឿលង់លើទ្រឹស្តីហ្វាស៊ីសនិយម កុម្មុយនិស្តនិយម និងអាណានិគមនិយម រហូតបណ្តាលអោយមានជម្លោះ ។ លើសពីនេះទៀត អ្នកសង្កេតការណ៍នៅប្រទេសដទៃ អាចមើលឃើញយ៉ាងច្បាស់ថា នៅពេលមានឱកាសអនុវត្តន៍ទ្រឹស្តីទាំងនោះ មេដឹកនាំមិនបានធ្វើអ្វីដែលពួកគេបានសន្យានោះទេ ។ ពួកមេដឹកនាំកុម្មុយនិស្ត នៅប្រទេសរុស្ស៊ី ចិន និងក្រោយមកកម្ពុជា បានឡើងកាន់អំណាច ដោយសារតែពួកគេអះអាងថា ពួកគេនឹងធ្វើអោយជីវិតរបស់ប្រជាជនសាមញ្ញកាន់តែប្រសើរឡើងនិងពង្រឹងសមភាពក្នុងសង្គម ។ ផ្ទុយទៅវិញ ពួកគេបានបង្កើតប្រព័ន្ធគាបសង្កត់យ៉ាងឃោរឃៅ ដែលបណ្តាលអោយប្រជាជនទាំងនាកាន់តែអស់អំណាចឬគ្មានឥទ្ធិពលសោះឡើយ ។

តាមធម្មតា ប្រវត្តិសាស្ត្រត្រូវបានសរសេរឡើង ដោយអាស្រ័យទៅតាម**រចនាសម្ព័ន្ធ**ឬទម្រង់ដ៏មានឥទ្ធិពលនៃទ្រឹស្តីណាមួយ ។ ជាឧទាហរណ៍ ប្រវត្តិសាស្ត្របែបម៉ាក្សីសនិយមផ្តោតអារម្មណ៍ខ្លាំងតែលើប្រវត្តិសាស្ត្រតស៊ូវណ្ណៈជាដើម ។ បណ្តាអ្នកប្រាជ្ញ និងប្រវត្តិវិទូផ្សេងទៀតបានសង្កេតមើលកិច្ចការទាំងនេះ ហើយកត់សម្គាល់ឃើញថា ទ្រឹស្តីទាំងអស់មិនគួរត្រូវគេជឿទាំងស្រុងនោះទេ ។ ជំនួសអោយប្រវត្តិសាស្ត្រដែលផ្អែកលើរចនាសម្ព័ន្ធសំណេរទាំងនេះ បណ្តាអ្នកប្រាជ្ញមួយចំនួន ដូចជាលោក **មីសែល ហ្វូយលត៍** (Michel Foucault) បានណែនាំនូវវិធីសាស្ត្រសិក្សាឬចងក្រងប្រវត្តិសាស្ត្រថ្មី ដោយមិនពឹងលើរចនាសម្ព័ន្ធរបស់ទ្រឹស្តីណាមួយឡើយ នោះគឺ **ប្រវត្តិសាស្ត្រក្រៅរចនាសម្ព័ន្ធ** (post-structural history)។

## ៧.២. ប្រវត្តិសាស្ត្រក្រោយសម័យទំនើបនិយមជាអ្វី?

ដោយមិនអនុវត្តតាមទ្រឹស្តីណាតែមួយ ហើយមិនជឿថាទ្រឹស្តីតែមួយអាចពន្យល់គ្រប់អ្វីទាំងអស់បាន, ទ្រឹស្តីក្រៅរចនាសម្ព័ន្ធ ឬហៅម្យ៉ាងទៀតថា **ទ្រឹស្តីក្រោយសម័យទំនើបនិយម**(Post-modernism) (ដោយសារវាបានកើតឡើងក្រោយ**ទ្រឹស្តីទំនើបនិយម**) បានណែនាំថា មានមិនទ្រឹស្តីណាមួយ អាចពន្យល់គ្រប់អ្វីៗទាំងអស់បាននោះទេ, វាបន្តអះអាងថា (ទ្រឹស្តី)មិនផ្សារភ្ជាប់ទៅនឹង(តថភាព)សង្គមឡើយ ។ ផ្ទុយទៅវិញ សង្គមរបស់មនុស្សអនុវត្តតាម**សំណុំនៃបទបញ្ញត្តិ**(set of rules) ដែលហាក់មានភាពសមហេតុសមផល ក្នុងសម័យកាលណាមួយ ។ អ្នកប្រាជ្ញទ្រឹស្តីក្រោយសម័យទំនើបនិយម លោក **មីសែល ហ្វូយលត៍** បានហៅ **សំណុំនៃបទបញ្ញត្តិ** ដែលត្រូវបានគេទទួលជឿ ថាជាសច្ចៈភាព ក្នុងពេលវេលាឬកាលៈទេសៈណាមួយនោះ ថាជា **ប្រធានវិបស្សនា**[១២] (dominant

[១២] វិបស្សនា ជាភាសាបាលី មានន័យថា ការពិចារណាឃើញច្បាស់តាមពិត ។

discourse) ។ ឧទាហរណ៍មួយនៃប្រធានវិបស្សនា នាសម័យយើងឥឡូវនេះ គឺ វិបស្សនា *វិទ្យាសាស្ត្រ* បាននិយថា ប្រសិនបើអ្វីមួយត្រូវបានពិសោធន៍ដោយវិទ្យាសាស្ត្រនោះ គេនឹងជឿជាក់ថាវាពិត ។ វិបស្សនានេះ មានឧត្តមភាពគ្របដណ្តប់លើបញ្ញត្តិផ្សេងទៀតដូចជា ទស្សនៈបែបអភិនិហា ឬ ទស្សនៈសាសនាចក្រ ដែលបានអះអាងថា សច្ចៈភាពមិនអាចទោរទន់តាមវិទ្យាសាស្ត្រឡើយ ។

ដោយចង្អុលបង្ហាញថា **មិនមានសច្ចៈភាពទេ ប៉ុន្តែ មានត្រឹមតែវិបស្សនាផ្សេងៗ** ទ្រឹស្តីក្រោយសម័យទំនើបនិយម គឺជារបៀបពិចារណាថ្មីហើយប្លែកខ្លាំង និងជះឥទ្ធិពលធំធេងលើសង្គម ។ វាដកចេញនូវមូលដ្ឋានសម្រាប់អ្វីដែលយើងធ្លាប់បានជឿថាជាការពិត និងទាមទារអោយ យើងចោទសួរអ្វីៗគ្រប់យ៉ាងដែលយើងទទួលយក ដោយស្វ័យប្រវត្តិ ។ នេះក៏ដោយសារតែអ្នកទ្រឹស្តីក្រោយសម័យទំនើបនិយមជឿថា បច្ចុប្បន្ននេះមានអត្ថិភាព ក៏ដោយសារតែរឿងជាក់ស្តែងមួយចំនួនបានកើតឡើង កាលពីអតីតកាល ។ អ្នកទ្រឹស្តីក្រោយសម័យទំនើបនិយម ស្រាវជ្រាវអតីតកាលដើម្បីស្វែងរក**សាវតារវិទ្យា**(genealogy)នៃព្រឹត្តិការណ៍ ឬ វត្ថុណាមួយ តើវាបានចាប់កំណើតឡើង និងវិវត្តន៍យ៉ាងដូចម្តេច ។ ដូច្នេះហើយ ពួកគេបានរកឃើញថា អ្វីដែលយើងជឿជាក់ ដោយងងឹតងងុលថាជាការពិតនាពេលបច្ចុប្បន្ននេះ គឺជាលទ្ធផលនៃការសម្រេចចិត្ត ឬ អំពើរបស់បុគ្គលដ៏មានឥទ្ធិពលកាលពីអតីតកាល ។

ជាឧទាហរណ៍ លោក ហ្វូយលត៍ បានស្រាវជ្រាវរុករកប្រវត្តិសាស្ត្របទដ្ឋានសីលធម៌ និងបញ្ហាផ្លូវភេទ ហើយបានរកឃើញថា អ្វីដែលមនុស្សគិតថាត្រឹមត្រូវតាមបទដ្ឋានសីលធម៌ បានផ្លាស់ប្តូរយ៉ាងខ្លាំង ដោយអាស្រ័យតាមពេលវេលា និងរវាងវប្បធម៌នីមួយៗ ។ តួយ៉ាង គាត់រកឃើញថាអ្វីដែលយើងគិតថាត្រឹមត្រូវនាពេលបច្ចុប្បន្ន មិនមែនជាអ្វីដែលជនជាតិក្រិកបុរាណគិតថា គឺជាការត្រឹមត្រូវនោះទេ ។ ក្នុងពេលដែលយើងចូលចិត្តអាពាហ៍ពិពាហ៍រវាងភេទផ្ទុយគ្នា មួយទល់នឹងមួយ, ជនជាតិក្រិកបុរាណបានគិតថា សេចក្តីស្រឡាញ់ពិតអាចកើតមាន នៅក្នុងទំនាក់ទំនងភេទដូចគ្នាតែប៉ុណ្ណោះ ។ ឥរិយាបថចំពោះបញ្ហាសីលធម៌ផ្សេងៗទៀត ដូចជាការប្រហារជីវិតដោយរដ្ឋអំណាច ការធ្វើអត្តឃាត ឬការរំលូតកូន ក៏មានភាពខុសប្លែកគ្នា ពីសម័យកាលមួយទៅសម័យកាលមួយទៀតផងដែរ ។

លោក ហ្វូយលត៍ ជឿជាក់ថា ប្រធានវិបស្សនា ដែលលេចធ្លោជាងគេ គឺជាវិបស្សនាទាំងឡាយណាដែលត្រូវបានគាំទ្រដោយអ្នកមានអំណាច ។ បុគ្គលមានអំណាចនាំអោយមានវិបស្សនាឬសុន្ទរកថាដ៏មានឥទ្ធិពល ហើយជាទូទៅ យើងសង្កេតឃើញថា ប្រធានវិបស្សនាដែលលេចធ្លោជាងគេនៅក្នុងសង្គមណាមួយ គឺត្រូវបានស្នើឡើង ឬពោលឡើង ដោយមេដឹកនាំក្នុងសង្គមនោះ មិនថាជាមេដឹកនាំនយោបាយ សាសនា ឬ វប្បធម៌ ។ នៅពេលមានចលាចលនយោបាយ ដូចជាបដិវត្តន៍ជាអាទិ៍ ប្រធានវិបស្សនានោះនឹងត្រូវបោះបង់ចោលតាមមេដឹកនាំនោះដែរ ហើយប្រធានវិបស្សនានិងជំនឿរបស់រដ្ឋាភិបាលថ្មីនឹងត្រូវចូលមកជំនួស ។

ដូច្នេះហើយ ទ្រឹស្តីក្រោយសម័យទំនើបនិយមទាមទារអោយយើងចេះចោទសួរពីអំណាច ។ វាតម្រូវអោយយើងសួរថា ហេតុអ្វីបានជាអ្នកកំពុងកាន់អំណាចអាចឈរជើងនៅទីនោះបាន ហើយតើពួកគេបានធ្វើអ្វីខ្លះដើម្បីសមនឹងទទួលបានអំណាចបែបនោះ ។ ដូចដែលលោក ហ្វូយលត៍ និងអ្នកប្រាជ្ញក្រោយសម័យទំនើបនិយមដទៃទៀតសង្កេតឃើញ អំណាចជាអ្វីមួយដែលមាននៅគ្រប់ទីកន្លែង ។ ជាអាទិ៍ វាមិនមែនសម្រាប់តែអ្នកមានស្តុកស្តម្ភ អ្នកនយោបាយ ព្រះរាជានិងព្រះមហាក្សត្រីយានីទេ ។ តាមពិតទៅ វាមានវត្តមាន នៅក្នុងគ្រប់ទំនាក់ទំនងរវាងមនុស្សពីរនាក់ឬច្រើនជាងនេះ, នៅក្នុងគ្រួសារ មិត្តភាព និងក្រុមផ្សេងទៀតផងដែរ ។ នរណាក៏ដោយ អោយតែអាចមានសមត្ថកិច្ច ឬអាជ្ញាសឹក(authority) លើនរណាម្នាក់ទៀត (ឧទាហរណ៍ តាមរយៈការយល់ ដឹង ឬចេះច្រើនជាង) ឬក៏អាចគ្រប់គ្រងពួកគេ តាមរយៈកម្លាំង(បាយ) អ្នកនោះមានអំណាច ។ ហេតុនេះទើបបណ្តាលអោយ

លោក ហ្វូយលត៍ អះអាងថា «ចំណេះដឹងគឺជាអំណាច» ។ ដូច្នេះ ប្រវត្តិវិទូក្រោយសម័យទំនើប បានសម្លឹងមើលទៅអតីតកាល ដើម្បីរកអោយឃើញនូវរចនាសម្ព័ន្ធអំណាច ដែលនាំអោយវិបស្សនាណាមួយក្លាយជាវិបស្សនាលេចធ្លោជាងគេ ។

ចុងក្រោយ ចំពោះការសរសេរប្រវត្តិសាស្ត្រ ទ្រឹស្តីក្រោយសម័យទំនើបនិយម អះអាងថា៖ ដោយសារតែយើងជឿលង់យ៉ាងជ្រៅលើវិបស្សនាឬទ្រឹស្តីក្នុងសម័យកាលរបស់យើងពេក យើងមិនអាចដកខ្លួន ចេញពីវាបានឡើយ ។ ទ្រឹស្តីដែលយើងជឿជាក់ គឺជាចំណែកមួយនៃខ្លួនយើង ។ យើងនឹងតែងតែយកភស្តុតាងបែបវិទ្យាសាស្ត្រជាតឹកតាងគួរអោយជឿជាក់ ជាងភស្តុតាងដទៃទៀត ដូចជា ភស្តុតាងរបស់សាក្សីដែលមានលក្ខណៈអភិនិហា ឬមានលក្ខណៈអាថ៌កំបាំង ។ បើទោះនេះជារឿងធម្មតា វាជះឥទ្ធិពលវិធីសាស្ត្រ ដែលយើងសម្លឹងមើលអតីតកាល ។ មនុស្សពីរនាក់ មិនដែលគិតលើអ្វីមួយ ដូចគ្នាបេះបិទនោះទេ, ដូច្នេះហើយ ការសម្លឹងមើលអតីតកាលរបស់អ្នកទាំងពីរនោះ ក៏មិនដូចគ្នាដែរ ។ ជារួម នេះមានន័យថា យើងនឹងមិនអាចសិក្សាស្វែងយល់អំពីអតីតកាលអោយបានពិតជាក់ស្តែង ដូចដែលគេប្រាថ្នាចង់បានតាំងពីសម័យលោក រ៉េងយ៉ រ ឡើយ ។

**សំណួរពិភាក្សា**

១. តើទ្រឹស្តីប្រវត្តិសាស្ត្រក្រោយសម័យទំនើបត្រូវបានបង្កើតឡើងនៅពេលណា?

២. តើជំនឿងប់ងល់ខ្លាំងលើទ្រឹស្តីណាមួយអាចបង្កអោយមានផលវិបាកអ្វីខ្លះ?

៣. តើលោកមីសែលហ្វូយលត៍យល់យ៉ាងណាចំពោះប្រវត្តិសាស្ត្រ?

៤. តើដូចម្តេចដែលហៅថា«ប្រធានវិបស្សនា»? ចូរលើកឧទាហរណ៍ ។

៥. តើកត្តាអ្វីខ្លះបណ្តាលអោយ វិបស្សនាឬទ្រឹស្តីណាមួយលេចធ្លោជាងគេ?

៦. តើហេតុអ្វីទ្រឹស្តីក្រោយសម័យទំនើបនិយមទាមទារអោយយើងចេះចោទសួរពីអំណាច?

៧. ចូរពន្យល់និងលើកឧទាហរណ៍នៃប្រយោគ៖ «ចំណេះដឹងគឺជាអំណាច» ។

**គំនូសបំព្រួញវិធីសាស្ត្រចាស់ សម្រាប់អង្កេតនិងស្វែងរកការពិតអតីតកាល**




**គំនូសបំព្រួញវិធីសាស្ត្រ ថ្មីសម្រាប់អង្កេតនិងស្វែងរកការពិតអតីតកាល**



**គំនូសបំព្រួញសង្ខេបទ្រឹស្តីប្រវត្តិសាស្ត្រក្រោយសម័យទំនើប**




**គំនូសបំព្រួញសង្ខេបទ្រឹស្តីប្រវត្តិសាស្ត្រទាំងអស់**



## ៧.៣. អំណានអត្ថបទប្រវត្តិសាស្ត្រ

ខាងក្រោមនេះ ជាការដកស្រង់ចេញពីស្នាដៃប្រវត្តិសាស្ត្រចំនួនបី ។ សម្រង់នីមួយៗត្រូវបានសរសេរឡើងដោយអាស្រ័យតាមទ្រឹស្តីប្រវត្តិសាស្ត្រ ដែលនិស្សិតបានសិក្សារួចមកហើយ ។ ចូរអានដោយយកចិត្តទុកដាក់ ហើយ៖

(ក) ចូរឆ្លើយសំណួរទាំងប្រាំ នៅក្រោមសម្រង់អត្ថបទនីមួយៗ ។

១. តើសម្រង់អត្ថបទនេះ ត្រូវបានចងក្រងឡើងតាមទ្រឹស្តីប្រវត្តិសាស្ត្រណាមួយ ?

២. តើទ្រឹស្តីប្រវត្តិសាស្ត្រនោះ ផ្តោតការយកចិត្តទុកដាក់ខ្លាំងលើ នយោបាយ, សេដ្ឋកិច្ច ឬវប្បធម៌ ឬក៏បានផ្តោតលើគ្រប់វិស័យទាំងអស់នេះ ?

៣. តើបញ្ហាអ្វីដែលជាប្រធានបទពេញនិយមសម្រាប់ទ្រឹស្តីនេះ ហើយត្រូវបានរកឃើញនៅក្នុងសម្រង់អត្ថបទនេះ?

៤. តើមានពាក្យគន្លឹះអ្វីខ្លះ ក្នុងទ្រឹស្តីនេះ ត្រូវបានរកឃើញនៅក្នុងសម្រង់ខាងលើ?

៥. ចូររៀបរាប់ឈ្មោះប្រភពដើម**មួយ**ដែលប្រវត្តិវិទូខាងលើ បានប្រើប្រាស់ដើម្បីធ្វើសេចក្តីសន្និដ្ឋានរបស់គាត់ ។

៦. ចូរដាក់ចំណងជើងដ៏សមស្របសម្រាប់អត្ថបទនីមួយ ។

(ខ) បន្ទាប់មក ចូរជ្រើសរើសយកសម្រង់អត្ថបទ**ពីរ**ក្នុងចំណោមបី ។ ចូរសរសេរអត្ថបទតែងសេចក្តីមួយអោយបាន**ពីរទំព័រ** ដោយឆ្លើយនឹងសំណួរនេះ «តើសម្រង់អត្ថបទទាំងពីរ ដែលអ្នកបានជ្រើសរើស មានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច បើគិតពីវិធីសាស្ត្រសរសេរប្រវត្តិសាស្ត្រ?

### ៧.៣.១. អត្ថបទទី ១

ចំណងជើង ៖ ____________________

១ ហេតុដល់ឆ្នាំ ១៨៤៨ សេដ្ឋកិច្ចតែមួយប៉ុណ្ណោះ ត្រូវបានធ្វើបដិវត្តន៍ឧស្សាហកម្ម ដោយប្រសិទ្ធភាព នោះគឺ (សេដ្ឋកិច្ច)ចក្រភពអង់គ្លេស ហើយជាលទ្ធផល វាបានគ្រប់គ្រងពិភពលោក... ដោយឡែក ការផ្លាស់ប្តូរយឺតយ៉ាវនៅក្នុងប្រទេសផ្សេងក្រៅពីចក្រភពអង់គ្លេស មានន័យថា ចលនាសេដ្ឋកិច្ចប្រទេសទាំងនោះ ត្រូវបន្តស្ថិតនៅក្រោមឥទ្ធិពលចង្វាក់ផលិតកម្មបែបប្រពៃណី ដែលឆ្នាំខ្លះបានទិន្នផលល្អ ឆ្នាំខ្លះទៀតមិនសូវបានផល ហេតុទីអវសាន្តនៃសម័យយើង ជាជាងក្រោមឥទ្ធិពលវដ្តនៃកំនើននិងការធ្លាក់ចុះនៃឧស្សាហកម្ម ។

២ វិបត្តិសេដ្ឋកិច្ច ដែលបានដុតបំផ្លាញសេដ្ឋកិច្ចអឺរ៉ុបអស់ជាច្រើន នៅក្នុងឆ្នាំ ១៨៤៦ ដល់ ១៨៤៨ ជាវិបត្តិដែលឡើងដោយប្រព័ន្ធកសិកម្មចាស់កំរិល ។ ម្យ៉ាង វាអាចជាបរាជ័យសេដ្ឋកិច្ចបុរាណចុងក្រោយ ហើយក៏ប្រហែលជាធ្ងន់ធ្ងរបំផុតដែរ ។ ករណីនេះខុសពីចក្រភពអង់គ្លេស ដែលបរាជ័យសេដ្ឋកិច្ចធ្ងន់ធ្ងរបំផុត ក្នុងសម័យបដិវត្តន៍ឧស្សាហកម្មដំបូង កើតឡើងក្នុងរវាងឆ្នាំ១៨៣៩ និង ១៨៤២ ដោយសារតែមូលហេតុ«ទំនើបកម្ម» ហើយស្របពេលតំលៃពោតធ្លាក់ចុះ ។ បន្ទុះបញ្ហាសង្គមនៅអង់គ្លេស បានឡើងដល់ចំណុចកំពូល នៅពេលមានមហាបាតុកម្ម

ធ្វើឡើងដោយចលនាកម្មករ Chartist នៅរដូវប្រាំងឆ្នាំ ១៨៤២ ដែលគេស្គាល់ជា កុបកម្មឆ្នុក (plug riots) ។ ទម្រាំវាពលដាល នៅទ្វីបអឺរ៉ុបដីគោក នាឆ្នាំ ១៨៤៨ ប្រទេសអង់គ្លេសគ្រាន់តែរងគ្រោះពីឥទ្ធិពលវដ្តនៃវិបត្តិសេដ្ឋកិច្ចក្នុងយុគសម័យវីកតូរីយ៉ា (Vitoria) ដ៏យូរ ។ ទន្ទឹមនឹងនោះ ប្រទេសបែលហ្សិកដែលជាប្រទេសមួយនៅទ្វីបអឺរ៉ុប មានសន្ទុះសេដ្ឋកិច្ចឧស្សាហកម្មប្រហាក់ប្រហែលគ្នា ក៏បានទទួលរងឥទ្ធិពលនេះដែរ ។ ចលនាបដិវត្តន៍ទូទាំងទ្វីប ដោយមិនបានកើតឡើងស្របពេលជាមួយនឹងចលនានៅអង់គ្លេស ដូចដែលលោក កាល ម៉ាក្ស បានទស្សទាយ មុខតែវិនាសជាមិនខាន ។ តែអ្វីដែលលោកមិនបានទស្សទាយនោះគឺ ការអភិវឌ្ឍមិនស៊ីចង្វាក់គ្នា នៅចក្រភពអង់គ្លេសនឹងទ្វីបអឺរ៉ុបដីគោកទាំងមូល បណ្តាលអោយទ្វីបនេះរីកចម្រើនតែឯង ដោយជៀសមិនផុត ។ ទោះជាយ៉ាងណា អ្វីដែលសំខាន់ក្នុងកំឡុងឆ្នាំ ១៧៨៩ ដល់ឆ្នាំ ១៨៤៨ មិនមែនទំហំប្រែប្រួលសេដ្ឋកិច្ចតិចតួចទេ (បើគិតតាមស្តង់ដាថ្មីៗ) ប៉ុន្តែ ការប្រែប្រួលជាមូលដ្ឋានកំពុងចាប់ផ្តើមឡើង...

៣ ស្រទាប់នៃពួកមូលធននិយម ក្នុងសេដ្ឋកិច្ចបារាំងប្រៀបបានដំបូលខាងលើ ដែលត្រូវបន្ទុបពីលើគ្រឹះ ដែលមិនអាចដកចេញទៅណាបាន រួមមានបណ្តាកសិករ និងពួកគហបតីតូចតាច ។ ពលករដែលជាអ្នកជានិងគ្មានដីធ្លីត្រូវបានអូសទាញអោយផ្លាស់ទីទៅកាន់ទីក្រុងនានា ជាទីផលិតទំនិញតម្លៃថោក មានស្តង់ដារដូចៗគ្នា ដែលជាប្រភពទ្រព្យសម្បត្តិរបស់ឧស្សាហករជឿនលឿននិយម នៅកន្លែងផ្សេងទៀតខ្វះទីផ្សារដែលកាន់តែរីកធំ...

៤ គ្មានអ្វីគួរអោយឆ្ងល់ទេ ជោគជ័យទាំងអស់នេះក៏មានផលវិបាកផងដែរ បើទោះជាវាមិនមានច្រើនគ្រប់គ្រាន់ សម្រាប់សង្ខេបដាក់ក្នុងតារាងស្ថិតិមួយក៏ដោយ ។ តើគេអាចរកសុច្ចករបែបណា ដើម្បីវាស់កម្រិតសច្ចៈភាព (មនុស្សមួយចំនួនសព្វថ្ងៃអាចនឹងបដិសេធន៍) ដែលថាបដិវត្តន៍ឧស្សាហកម្មបានបង្កើតពិភពលោកដ៏អាក្រក់បំផុតសម្រាប់មនុស្សរស់នៅ ដូចដែល សរបញ្ជាក់ ដោយក្លិនស្អុយ និងអ័ព្ទខ្មៅងងឹត នៅក្រោយផ្លូវ Manchester ? ឬក៏ត្រូវបញ្ជាក់ដោយការផ្លាស់ទីលំនៅបុរសនិងស្ត្រីក្នុងចំនួនច្រើនលើសលប់មិនធ្លាប់មានពីមុនដែលធ្វើអោយពួកគេលែងមានទីពំនាក់ច្បាស់លាស់ ក្នុងពិភពសោកសង្រេង? គ្មានអ្នកបដិសេធន៍ថា គ្មានភាពក្រីក្រគួរអោយរន្ធត់នោះ ។ ផ្ទុយទៅវិញ មនុស្សជាច្រើនយល់ថា ភាពក្រីក្រកាន់តែរីករាលដាលនិងចាក់ស្រេះយ៉ាងជ្រៅ ។ ដោយឡែក ដោយប្រើលក្ខណៈវិនិច្ឆ័យសម្រាប់វាស់ភាពរីកចម្រើនឧស្សាហកម្មនិងវិទ្យាសាស្ត្រ គ្រប់សម័យកាល តើអ្នកសង្កេតការណ៍ទុទិដ្ឋិនិយមខ្លាំងបំផុតអាច អះអាងបានទេថា ចំពោះផ្នែកសម្ភារៈ វាកាន់តែអន់ជាងសម័យមុន ឬអន់ជាប្រទេសដែលមិនទាន់មានឧស្សាហកម្មរីកចំរើន នាពេលបច្ចុប្បន្ននេះ ដែរឬទេ ? ច្បាស់ណាស់ គេពិតជាមិនអាចទេ ។ ម្ចាស់ជើងឯកនៃការរីកចម្រើនបានការពារវា ដោយអះអាងបែបដោះសារថាបរាជ័យខាងលើនេះ មិនមែនដោយសារប្រតិបត្តិការនៃសង្គមគហបតីថ្មីនោះទេ ប៉ុន្តែ ដោយសារតែឧបសគ្គដែលរបបសក្តិភូមិចាស់ ស្តេចនិងអភិជន កំពុងតែបន្ទុបង្កដល់លក្ខណៈប្រតិបត្តិការនៃសហគ្រាសសេរីដ៏ល្អឥតខ្ចោះរបស់ខ្លួន ។ ផ្ទុយទៅវិញ ពួកសង្គមនិយមថ្មី បានលើកមូលហេតុថាដោយសារតែ ប្រតិបត្តិការនៃប្រព័ន្ធនោះផ្ទាល់តែម្តង ។ ប៉ុន្តែទាំងពីរក្រុមយល់ស្របថា ទុក្ខវេទនា កំពុងកើនឡើង ក្នុងសង្គម ។ ភាគីម្ខាងជឿថាពួកគេនឹងអាចជំនះបាន ក្នុងក្របខ័ណ្ឌនៃមូលធននិយម ចំណែកម្ខាងទៀត គិតថាមិនអាចទេ ប៉ុន្តែ ទាំងពីរក្រុមជឿជាក់ថា ជីវិតមនុស្សត្រូវប្រឈមមុខនឹងការធ្វើអោយរីកចម្រើនខាងសម្ភារៈ ដើម្បីអោយមនុស្សមានភាពប្រសើរឡើង ក្នុងការគ្រប់គ្រងលើកម្លាំងធម្មជាតិ ។

៥ ជារួម ពិភពលោក នាទសវត្សឆ្នាំ ១៨៤០ គ្មានស្ថេរភាពនោះទេ ។ កម្លាំងនៃការប្រែប្រួល សេដ្ឋកិច្ចបច្ចេកទេស និងសង្គម ដែលបានចាប់ផ្តើមឡើង កាលពីកន្លះសតវត្សរ៍មុន គឺមិនធ្លាប់មានពីមុនឡើយ ហើយក៏មិនអាចបដិសេធន៍បានដែរ សូម្បីតែចំពោះអ្នកសង្កេតការណ៍រាក់ៗក៏ដោយ ។ ម្យ៉ាងទៀត ឥទ្ធិពលរបស់វាលើស្ថាប័ន

នានា មានទំហំតិចតួច ។ ជាឧទាហរណ៍ ជៀសមិនរួចទេ ដែលថា មុននឹងក្រោយ ប្រព័ន្ធទាសករនិងខ្ញុំកញ្ជះស្របច្បាប់ (លើកលែងតែនៅតំបន់ដាច់ស្រយាលដែលរបបសេដ្ឋកិច្ចថ្មីមិនទាន់ដល់) នឹងត្រូវលុបបំបាត់ ដូចដែលចក្រភពអង់គ្លេសមិនអាចរក្សាឋានៈជាប្រទេសមានឧស្សាហកម្មរីកចម្រើនតែមួយគត់ នៅលើលោក ។ មុខតែជៀសមិនរួចទេ ដែលថា ប្រព័ន្ធអភិជន(ម្ចាស់ដីធំៗ)និងរាជាធិបតេយ្យនិយមផ្តាច់ការ ត្រូវតែដួលរលំ នៅគ្រប់ប្រទេសទាំងអស់ ដែលប្រព័ន្ធគហិបតីនិយមរឹងមាំ កំពុងអភិវឌ្ឍឡើង ទោះបីជាមានការសម្រុះសម្រួលផ្នែកនយោបាយ ឬរបមន្តណាមួយ ដើម្បីរក្សាឋានៈ ឥទ្ធិពល និងអំណាចនយោបាយ(របស់ពួកគេ) ក៏ដោយ ។ លើសពីនេះទៅទៀត ជារឿងជៀសមិនរួចទេដែលការបញ្ចូលសតិសម្បជញ្ញៈ និងសកម្មភាពនយោបាយ ក្នុងចំណោមមហាជនទាំងឡាយ ដែលជាមរតកធំធេងនៃបដិវត្តន៍បារាំង, មុនឬក្រោយ ត្រូវបានគេទទួលស្គាល់ថា មហាជនទាំងនោះមានតួនាទីផ្លូវការក្នុងនយោបាយ ។ ហើយដោយសារមានការជំរុញល្បឿនបន្ថែម ដោយបម្លាស់ប្តូរសង្គមចាប់តាំងពីឆ្នាំ ១៨៣០ និង ដោយចលនាបដិវត្តន៍ពិភពលោក ច្បាស់ជាជៀសមិនរួចទេ ដែល ការប្រែប្រួលទាំងឡាយ (មិនសំខាន់ថាវាមានលក្ខណៈស្ថាប័ន ឬយ៉ាងណា) នឹងមិនអាចពន្យាពេលទៀតបានទេ ៕

### ៧.៣.២. អត្ថបទទី ២

ចំណងជើង ៖ ______________________________________________

១ តើមានបម្លាស់ប្តូរគួរអោយកត់សម្គាល់អ្វីខ្លះក្រោយបដិវត្តន៍បារាំង? សំនួរមួយនេះហាក់ដូចជាមិនសមនឹងសួរសោះសម្រាប់បច្ចុប្បន្ន ខណៈពេលពិភពលោកទាំងមូលកំពុងអបអរសារទរប្រទេសបារាំងក្នុងឱកាសខួប ២០០ ឆ្នាំ ទិវាបុណ្យជាតិបារាំង (Bastille) ដែលជាថ្ងៃរបបសក្តិភូមិត្រូវលុបបំបាត់ និងទិវាប្រកាសសិទ្ធិមនុស្ស និងពលរដ្ឋ (Declaration of the Rights of Man and the Citizen) ។ ប៉ុន្តែ នេះមិនមានអ្វីច្រើនទាក់ទងនឹងរឿងរ៉ាវ ដែលបានកើតឡើងជាក់ស្តែង កាលពី ២ សតវត្សរ៍មុនទេ...

២ ទោះបីជាស្មារតីនៃបដិវត្តន៍ ឆ្នាំ ១៧៨៩ មិនអាចរកពាក្យពេជន៍មកដាក់អោយត្រូវទាំងស្រុង វាអាចមានលក្ខណៈឆ្លុះបញ្ចាំងពីឥទ្ធិពលមួយប្រភេទ ដែលជាឆន្ទៈចង់កសាងពិភពលោកថ្មីមួយចេញពីភាពខ្ទេចខ្ទាំនៃរបបដែលបានដួលរលំ កាលពីរដូវប្រាំង ឆ្នាំ ១៧៨៩ ។ ឥទ្ធិពលនោះបានជ្រួតជ្រាបចូលក្នុងអ្វីៗទាំងអស់កំឡុងពេលបដិវត្តន៍បារាំង ។ វាបានបណ្តាលអោយជីវិតទាំងអស់មានការផ្លាស់ប្តូរ, មិនត្រឹមសម្រាប់តែជីវិតសកម្មជន ដែលព្យាយាមបំលែងវាអោយត្រូវតាមគន្លងមួយដែលពួកគេប្រាថ្នាចង់បានប៉ុណ្ណោះទេ តែថែមទាំងសំរាប់ជីវិតប្រជាជនសាមញ្ញទាំងអស់ ដែលប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃផងដែរ ។

៣ គំនិតនៃបម្លាស់ប្តូរជាមូលដ្ឋានក្នុងជីវភាពប្រចាំថ្ងៃ ហាក់ដូចជាងាយស្រួលក្នុងការទទួល យកបាន ទោះវាបង្កប់នូវលក្ខណៈអរូបីក្តី ។ ប៉ុន្តែ គ្នាយើងក្នុងចំនួនតិចតួចប៉ុណ្ណោះ ដែលពិតជាអាចស្វែងយល់គំនិតទាំងអស់នោះបាន ។ យើងសម្លឹងមើលពិភពលោកតាមលក្ខណៈធម្មជាតិរបស់វា ដោយមិនអាចស្រមើស្រមៃអ្វីខុសពីធម្មជាតិរបស់វាឡើយ លុះត្រាតែយើងជួបប្រទះនូវកាលៈទេសៈដែលអ្វីមួយប្រាសចាកខុសពីប្រក្រតី ឧទាហរណ៍ ប្រហែលជា មរណៈកាល ឬការលែងលះគ្នា ឬពេលអ្វីមួយរឹងមាំបែរជាត្រូវទទួលរងការបំផ្លិចបំផ្លាញភ្លាមៗ ដូចជាដំបូល (ផ្ទះ)លើក្បាលយើង ឬដីក្រោមជើងយើងត្រូវបាក់ស្រុតជាដើម...

៤ មុនឆ្នាំ ១៧៨៩ បារាំងជាប្រទេសមួយរួមផ្សំដោយស្ថាប័នមិនស៊ីគ្នាឬធ្វើការដាច់គ្នា ក្នុងវិស័យជាច្រើន វិស័យហិរញ្ញវត្ថុខ្លះ តុលាការខ្លះ រដ្ឋបាលខ្លះ សេដ្ឋកិច្ចខ្លះ និងសាសនាខ្លះទៅ ។ ក្រោយឆ្នាំ ១៧៨៩ វិស័យទាំងអស់នោះរលាយចូលគ្នាជាដុំមួយ៖ ជាតិបារាំង ។ ធ្វើដូច្នេះ ចលនាបដិវត្តន៍បានបញ្ចេញថាមពលថ្មី នោះគឺ (កម្លាំង) ជាតិនិយម ដែលអាចកៀងគរមនុស្សរាប់លាននាក់ ហើយផ្តល់រំលំរដ្ឋាភិបាល ក្នុងរយៈពេលពីរឆ្នាំបន្តទៀត ។

៥ ជាការពិតណាស់ ប្រជាជាតិសម័យទំនើប (nation-state) មិនបានលុបបំបាត់អ្វីៗទាំងអស់ដែលកើតមាន នៅក្នុងសម័យមុនទេ ។ វាបរាជ័យក្នុងការដាក់ភាសាបារាំងជាភាសាសំរាប់បណ្តាជនភាគច្រើន ដែលរស់នៅក្នុងប្រទេសបារាំង ហើយនៅតែបន្តនិយាយគ្រាមភាសា(ពិបាកយល់)ក្នុងតំបន់របស់គេដដែល បើទោះជាមានយុទ្ធនាការរៀបចំឡើង ដោយគណៈកម្មការបដិវត្តន៍ ណែនាំសាធារណជនក៏ដោយ ។ ប៉ុន្តែ ដើម្បីបោសសំអាតក្រុមដែលព្យាយាមបំបែកប្រជាជន ពីការគ្រប់គ្រងរបស់រដ្ឋ អង្គការបដិវត្តន៍បានផ្លាស់ប្តូរទិដ្ឋភាព ជាមូលដ្ឋាននៃជីវិតសាធារណៈ ។

៦ វាបានពង្រីកទិដ្ឋភាពសាធារណៈចូលទៅក្នុងជីវិតឯកជន ដោយបញ្ចូលខ្លួនវាផ្ទាល់ទៅក្នុងទំនាក់ទំនងស្និទ្ធស្នាលបំផុត ។ ភាពស្និទ្ធស្នាលក្នុងភាសាបារាំង ត្រូវបានបង្ហាញដោយសព្វនាម *tu* (ឯង ឬ ហ្អែង) ដែលខុសពីសព្វនាម *vous* (លោក ឬ អ្នក) ដែលប្រើសម្រាប់ភាសាផ្លូវការ ។ ទោះបីជាជនជាតិបារាំង ជួនកាល ប្រើ *tu* (ឯង ឬ ហ្អែង) ជាធម្មតា សព្វថ្ងៃនេះ, ក្នុងរបបចាស់កាលមុន ពាក្យនេះត្រូវប្រើសម្រាប់ក្នុងទំនាក់ទំនងជាមួយមនុស្សឋានៈតូចជាងខ្លួន ឬពេលជជែកគ្នាតឹងសរសៃកតែប៉ុណ្ណោះ ។ ឪពុកម្តាយប្រើពាក្យ *tu* (ឯង ឬ ហ្អែង) ទៅកាន់កូនចៅរបស់ខ្លួន ដែលត្រូវឆ្លើយតបមកវិញដោយប្រើពាក្យ *vous* (លោក ឬ អ្នក) ។ ពាក្យ *tu* (ឯង ឬ ហ្អែង) ត្រូវបានប្រើដោយមនុស្សចាស់ឬមានអំណាចធំជាង ទៅកាន់អ្នកមានអាយុតិចជាង ឬមនុស្សតូចតាចឬដោយមនុស្សសម្រាប់បញ្ជាសត្វ និងត្រូវប្រើដោយគូរស្នេហា ។

៧ បដិវត្តន៍បារាំងចង់ធ្វើអោយមនុស្សគ្រប់រូបក្លាយជា *tu* (ឯង ឬ ហ្អែង) ។ នេះគឺជាច្បាប់មួយដែលត្រូវបានអនុម័ត នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៧៩៣ នៅតំបន់ជួរភ្នំ ក្រីក្រ នៅភាគខាងត្បូងប្រទេសបារាំង៖ «ដោយយល់ឃើញថា គោលការណ៍ជានិរន្តន៍នៃភាពស្មើគ្នា រារាំងមិនអោយពលរដ្ឋនិយាយសព្វនាម *vous* (លោក ឬ អ្នក) ទៅជាពលរដ្ឋដទៃទៀត... ពាក្យ *vous* (លោក ឬ អ្នក) ចាប់ពីពេលនេះទៅ ត្រូវដកចេញពីភាសារបស់បារាំងសេរី ហើយនឹងត្រូវជំនួសដោយពាក្យ *tu* (ឯង ឬ ហ្អែង) ក្នុងគ្រប់កាលៈទេសៈ ។

៨ សម្លៀកបំពាក់ ជាញឹកញាប់ ដើរតួជាទេរម៉ូម៉ែត្រសម្រាប់វាស់សីតុណ្ហភាពនយោបាយ ។ ដើម្បីសម្គាល់ពួកអ៉ារីស្តូក្រាត់និងពួកសកម្មប្រយុទ្ធ ពួកអ្នកបដិវត្តបានអនុម័តប្រើពាក្យមួយសម្រាប់សំលៀកបំពាក់គ្រប់ប្រភេទ ៖ «*sans-culotte*» (ដោយគ្មានខោអាវ) សម្រាប់សម្គាល់អ្នកស្លៀកខោវែក ជាជាងខោរឹមត្រឹមក្រោមជង្គង់ តាមរបៀបរបបសង្គមចាស់ ។ ជនបដិវត្តន៍គំរូ ដែលលេចឡើងនៅលើខិត្តបណ្ណ ផ្ទាំងបដារ និងគ្រឿងពែងនិងចានតែ ចាប់ពីឆ្នាំ ១៧៩៣ រហូតមកដល់បច្ចុប្បន្នបានស្លៀកខោ ពាក់អាវបើកចំហ មានអាវខ្លីពីក្នុង ស្បែកជើងកវែង និងជាតិសេរីភាពមួយចម្រៀកពាក់លើសក់ «ធម្មជាតិ» មិនបានសិត ដែលបានប្រាសស្នា ។ សម្លៀកបំពាក់សម្រាប់ស្ត្រី មុនពេលបដិវត្តន៍ បានចំហររៀលក បង្ហាញដើមទ្រូង សំពត់ប៉ោងស្តើង និងស្ទីលសក់ស្អាតល្អឯក យ៉ាងហោចណាស់ ក្នុងចំណោមវណ្ណៈអភិជន ។ ម៉ូដសក់ប៉ះកន្ទ្រើង ខ្ពស់ត្រដែតពីលើក្បាល ហើយត្រូវបានតុបតែងលម្អយ៉ាងក្រាស់ ជាចានផ្លែឈើ ឬសួនសត្វ ។ ម៉ូដសក់មួយ ក្នុងរាជវាំង ត្រូវបានរៀបចំជាទិដ្ឋភាពស្រុកស្រែ៖ មានស្រះទឹក ព្រានបាញ់ទា

ហោត់ទឹកកំពុងវិលចុះវិលឡើង ហើយកសិរម្នាក់ជិះសត្វលាសំដៅទៅផ្សារ ខណៈពេលដែលអាចារ្យកាតូលិកកំពុងលួងលោមប្រពន្ធរបស់គាត់ ។

៩ ក្រោយឆ្នាំ ១៧៨៩ គេនិយមម៉ូដដែលចេញពីស្រទាប់មនុស្សខាងក្រោម ។ សក់ត្រូវសិតអោយរាបស្មើសំពត់ត្រង់ភ្លឹង កអាវលើកឡើងលើ ហើយកែងស្បែកជើងត្រូវបន្ទាបចុះ៕

### ៧.៣.៣. អត្ថបទទី ៣

ចំណងជើង ៖ ______________________________________________

១ ប្រវត្តិនៃការត្រួតពិនិត្យលើផ្នែកវេជ្ជសាស្ត្រ-នីតិសាស្ត្រ នៅតាមព្រំប្រទល់របស់អូស្ត្រាលី បង្កើតជាសាវតារ វិទ្យានៃការពិភាក្សាដ៏ចម្រូងចម្រះលើបញ្ហាឃុំឃាំងអ្នកសុំសិទ្ធិជ្រកកោន និងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីការពារទឹកដី និងវប្បធម៌ ប្រទេសអូស្ត្រាលី ...

២ ច្បាប់ស្តីពីសុខភាពអ្នកសុំទិដ្ឋការទេសចរណ៍ឬសុំចូលសញ្ជាតិ នៅក្នុងប្រទេសអូស្ត្រាលីមានការផ្លាស់ប្តូរលក្ខណ្ឌខ្លះ ហើយនៅក្នុងពេលណាមួយ វាមានលក្ខណៈខុសៗគ្នាសម្រាប់ក្រុមជនជាតិផ្សេងៗគ្នា ដោយអាស្រ័យទៅតាមប្រទេសកំណើតឬប្រទេសជាគោលដៅរបស់ពួកគេ ។ ជាឧទាហរណ៍ សំរាប់ទេសចរមកពីប្រទេសខ្លះត្រូវអនុញ្ញាតអោយចូលប្រទេសអូស្ត្រាលី យ៉ាងងាយដោយមិនចាំបាច់ធ្វើការត្រួតពិនិត្យសុខភាពឡើយ តែសម្រាប់អ្នកមកពីប្រទេសផ្សេងត្រូវតែមានលិខិតបញ្ជាក់សុខភាព និងស្ថានភាពជម្ងឺឆ្លង, អ្នកខ្លះទៀតដែលសុំទិដ្ឋាការប្រភេទផ្សេងៗដូចជាទិដ្ឋាការនិសិត្សជាដើម ត្រូវធ្វើតេស្តសុខភាព ថតកាំរស្មីអ៊ិចនៅទ្រូង និងតេស្តរកមេរោគអេដស៍ ។ តើនាពេលបច្ចុប្បន្ន មានការព្រួយបារម្ភផ្នែកនយោបាយ ជំងឺឆ្លងរីករាលដាល និងអតិសុខុមជីវសាស្ត្រ យ៉ាងដូចម្តេចបានជាចាត់ទុក «និស្សិតអន្តរជាតិ» ជាពិសេស ថាមានគ្រោះថ្នាក់និងត្រូវការការឃ្លាំមើល ឬក៏ដាក់អោយនៅដោយឡែក?

៣ ក្នុងការលើកសំណួរបែបនេះ ជាប្រវត្តិសាស្ត្រ ខ្ញុំគិតអំពីប្រសិទ្ធិភាពដ៏គួរអោយកត់សម្គាល់ក្នុងប្រវត្តិសាស្ត្រនៃការដាក់អ្នកឆ្លងជំងឺនៅដាច់ដោយឡែក និងច្បាប់សុំចូលក្នុងប្រទេសអូស្ត្រាលី ។ ជាក់ស្តែង នេះជាឧទាហរណ៍មួយដែលទ្វីបនេះមិនធ្លាប់មានជំងឺអាសន្នរោគ ។ ប៉ុន្តែ ជាញឹកញាប់បទប្បញ្ញត្តិ, ការវិវត្តន៍ និងការប្រែប្រួលនានា មិនអាចពន្យល់អោយបានសមហេតុផលស្តីពីជំងឺឆ្លងរីករាលដាល និងអតិសុខុមជីវសាស្ត្រ...

៤ រដ្ឋធម្មនុញ្ញអូស្ត្រាលី ឆ្នាំ ១៩០១ បានផ្តល់អំណាចតែមួយប្រភេទគត់ទៅដល់រដ្ឋាភិបាលសហព័ន្ធថ្មី ដើម្បីធានាសុខុមាលភាពសាធារណៈ នោះគឺ អំណាចដាក់អ្នកជំងឺឆ្លងអោយនៅដោយឡែក «the power of quarantine» ... ទាំងនៅក្នុងក្របខ័ណ្ឌរដ្ឋធម្មនុញ និងទាំងនៅក្នុងសាវតារនៃការិយាល័យធិបតេយ្យ, ស្ថាប័នរដ្ឋបាលសុខភាពសាធារណៈរបស់ជាតិនេះ មានប្រភពចេញពីការដាក់អ្នកជំងឺឆ្លងអោយនៅដោយឡែក...

៥ ច្បាប់ស្តីពីសុខភាពសាធារណៈ, អន្តោប្រវេសន៍ និងការសុំចូលសញ្ជាតិ គឺជាធាតុសំខាន់សំរាប់ការកសាងជាតិ និងការគ្រប់គ្រងប្រជាពលរដ្ឋ នៅក្នុងប្រវត្តិសាស្ត្រអូស្ត្រាលី ។ សម្រាប់ពង្រឹងបទបញ្ញត្តិក្នុងវិស័យទាំងអស់នេះ រដ្ឋបាននិងកំពុងចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងការត្រួតពិនិត្យព្រំដែនជាតិ និងក្នុងការគ្រប់គ្រងការចូលរួម ឬផាត់ប្រជាជនចេញពីជីវភាពនយោបាយ និងទឹកដីនៅអូស្ត្រាលី ។ ដំណើរការនៃការគ្រប់គ្រងជម្ងឺឆ្លង និង

ត្រួតពិនិត្យសុខភាព តែងតែបង្កើតបានជាបទបញ្ញត្តិជាផ្លូវការសម្រាប់អនុញ្ញាតទិដ្ឋការចូលលេងឬផាត់ចេញ និងតែងតែជាការលើកហេតុផលដ៏ចម្បង សម្រាប់យន្តការនានា និងគោលនយោបាយគ្រប់គ្រងសន្តិសុខ តាមព្រំដែនគ្រប់ប្រភេទ ៕

# មេរៀនទី ៨ ៖ ការប្រៀបធៀបទ្រឹស្តីប្រវត្តិសាស្ត្រនានា

កន្លងមក យើងបានរៀនទ្រឹស្តីមួយចំនួនរួចមកហើយ រួមមាន ទ្រឹស្តីប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ (មេរៀនទី ៤), ទ្រឹស្តីប្រវត្តិសាស្ត្របែបម៉ាក្សីសនិយម (មេរៀនទី ៥), ទ្រឹស្តីប្រវត្តិសាស្ត្របែបសង្គម (មេរៀនទី ៦) និងទ្រឹស្តីប្រវត្តិសាស្ត្រក្រោយសម័យទំនើប (មេរៀនទី ៧) ។ ចូរសាកល្បងធ្វើលំហាត់អនុវត្តន៍រម្លឹកទ្រឹស្តីដែលបានរៀនកន្លងមក ។

លំហាត់នេះមានបីផ្នែក៖ ទី ១ ជាសំណួរពហុជ្រើសរើស ចំនួន ១០ សំណួរ, ទី ២ ជាសំណួរផ្គូផ្គងចំនួន១០ សំណួរ និងផ្នែកទី ៣ ជាសំណួរបែងចែកប្រភពឯកសារយោង ។

**ផ្នែកទី ១៖ សំណួរពហុជ្រើសរើស ។ ចូរជ្រើសរើសចម្លើយត្រឹមត្រូវតែមួយគត់ ហើយសរសេរចម្លើយអ្នក (ក. ខ. គ. ឬ ឃ.) ក្នុងប្រអប់លើសន្លឹកចម្លើយនៅទំព័របន្ទាប់ ។**

១. តើលោក ហេរ៉ូដូទឹសមានហេតុផលអ្វីសម្រាប់សរសេរប្រវត្តិសាស្ត្ររបស់គាត់ ?

ក. ដើម្បីបង្ហាញពីភាពអស្ចារ្យរបស់ព្រះជាម្ចាស់

ខ. ដើម្បីឲ្យគេចង់ចាំនូវសមិទ្ធិផលរបស់មនុស្ស

គ. ដើម្បីបង្ហាញប្រវត្តិសាស្ត្រជាន់ជានដដែលៗ

ឃ. ដើម្បីបង្ហាញថាក្រិកបុរាណប្រសើរជាងរ៉ូម៉ាំង

២. តើលោក ស៊ូស៊ីឌីឌីសបានបន្ថែមវិធីសាស្ត្រអ្វីដល់ទ្រឹស្តីប្រវត្តិសាស្ត្រក្រិចបុរាណ ?

ក. ទាមទារឲ្យប្រវត្តិវិទូចេះវិភាគពីភាពទុកចិត្តនៃប្រភពព័ត៌មាន

ខ. សំណេរជាភាសាឡាតាំង

គ. បដិសេធន៍មិនយកទេវកថាជាប្រភពព័ត៌មានប្រវត្តិសាស្ត្រ

ឃ. ប្រវត្តិសាស្ត្រសម្ភាសន៍ផ្ទាល់មាត់

៣. តើក្រុមប្រវត្តិវិទូបែបសាសនានិយមមានហេតុផលអ្វីសម្រាប់សរសេរប្រវត្តិសាស្ត្ររបស់គេ ? ដើម្បី៖

ក. ដើម្បីបង្ហាញថាព្រះគ្រឹស្តជាអាទិទេពតែមួយគត់

ខ. ឲ្យគេចង់ចាំនូវសមិទ្ធិផលរបស់មនុស្ស

គ. បង្ហាញប្រវត្តិសាស្ត្រជាន់ជានដដែលៗ

ឃ. បង្ហាញពីភាពអស្ចារ្យរបស់ព្រះជាម្ចាស់

៤. ដោយយោងតាមទ្រឹស្តីប្រវត្តិសាស្ត្រចិនបុរាណ ប្រវត្តិសាស្ត្រមានសណ្ឋានឬទ្រង់ទ្រាយដូចម្តេច ?

ក. ជាបន្ទាត់ត្រង់ទៅមុខ

ខ. ជារង្វង់វិលចុះវិលឡើង

គ. ជាបំពង់ស៊ីឡាំង

ឃ. ជាការ៉េ

៥. តាមលោក លេអូផូល វុន រ៉ែងគី តើប្រវត្តិវិទូមានកាតព្វកិច្ចបង្ហាញពីអតីតកាលបែបណា ?

ក. លទ្ធផលនៃការបកស្រាយរបស់ខ្លួន

ខ. អ្វីដែលជះឥទ្ធិពលដល់សម័យបច្ចុប្បន្ន

គ. ប្រវត្តិនៃការតស៊ូវណ្ណៈ

ឃ. សច្ចៈភាពដែលបានកើតឡើងយ៉ាងពិតប្រាកដ

៦. បើយោងតាមប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ តើប្រវត្តិសាស្ត្រមានសណ្ឋានយ៉ាងដូចម្ដេច ?

ក. ជាបន្ទាត់ត្រង់ទៅមុខ

ខ. ជារង្វង់វិលចុះវិលឡើង

គ. ជាបំពង់ស៊ីឡាំង

ឃ. ជាការ៉េ

៧. តើប្រវត្តិវិទូបែបវិទ្យាសាស្ត្រមានទំនោរសិក្សាអំពីអ្វី?

ក.ទំនាក់ទំនងអំណាច

ខ. ការប្រែប្រួលសេដ្ឋកិច្ច

គ. ព្រឹត្តិការណ៍នយោបាយ

ឃ. វប្បធម៌

៨. តើទ្រឹស្ដីប្រវត្តិសាស្ត្រណាមួយដែលផ្ដោតអារម្មណ៍ខ្លាំងទិដ្ឋភាពសេដ្ឋកិច្ច ?

ក. បែបវិទ្យាសាស្ត្រ

ខ. បែបសង្គមសាស្ត្រ

គ. ម៉ាក្សស៊ីសនិយម

ឃ. ចិនបុរាណ

៩. តើទ្រឹស្ដីប្រវត្តិសាស្ត្រណាមួយដែលផ្ដោតអារម្មណ៍ខ្លាំងទិដ្ឋភាពវប្បធម៌ ?

ក. បែបវិទ្យាសាស្ត្រ

ខ. បែបសង្គមសាស្ត្រ

គ. ម៉ាក្សស៊ីសនិយម

ឃ. ចិនបុរាណ

១០. តើក្រុមប្រវត្តិវិទូដែលអភិវឌ្ឍទ្រឹស្តីប្រវត្តិសាស្រ្តបែបសង្គមជានរណា ?

ក. ក្រុមលោកវ៉ែងគី

ខ. ក្រុមថ្មី

គ. ក្រុមបុរាណ

ឃ. ក្រុមកាលប្បវត្តិ

**ប្រអប់ចម្លើយផ្នែកទី១**

| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

**ផ្នែកទី ២៖ ចូរផ្គូរផ្គងពាក្យគន្លឹះ ជាមួយនឹងខ្លឹមសារ ឬ អត្ថន័យនៃពាក្យនីមួយៗ ។**

| ពាក្យគន្លឹះឬស្ថាបនិក | ខ្លឹមសារ ឬ អត្ថន័យ ឬស្នាដៃ |
|---|---|
| ១. ទេវកថា | ក.ស្ថាបនិកទ្រឹស្តីប្រវត្តិសាស្រ្តបែបវិទ្យាសាស្រ្ត ។ |
| ២.អាណត្តិ នៃឋានសួគ៌ | ខ. វិធីសាស្រ្តស្រាវជ្រាវប្រវត្តិសាស្រ្ត ដែលចង់ក្រងពីអ្វីដែលកើតឡើងយ៉ាងពិតប្រាកដ ដោយគ្មានការបកស្រាយបន្ថែមឡើយ ។ |
| ៣. សម័យមជ្ឈឹម | គ. ស្ថាបនិកទ្រឹស្តីបែបសង្គមសាស្រ្ត ។ |
| ៤. គោលការណ៍យថាភូត | ឃ. ពពួកមនុស្សរស់នៅដោយសារបញ្ចេញកម្លាំងពលកម្ម ជាចំបង មានកម្មករ ឬ ពលករ ជាដើម ។ |
| ៥. មធ្យោបាយផលិតកម្ម | ង. ជំនឿថា ឋានសួគ៌ គឺជាអ្នកជ្រើសរើសនរណាម្នាក់គ្រប់គ្រងគនរ ដោយគ្មានរយៈពេលកំណត់ ដរាបណានគរមានសុខសន្តិភាពនិងរុងរឿង ។ |
| ៦. ពលជីព | ច. ស្ថាបនិកទ្រឹស្តីម៉ាក្សស៊ីសនិយម ។ |
| ៧. កាល់ម៉ាក្ស | ឆ. រឿងរ៉ាវបែបប្រពៃណីដែលលាយឡំនឹងព្រឹត្តិការណ៍ប្រវត្តិសាស្រ្ត ដើម្បីបើកកកាយអាថ៌កំបាំងពិភពលោក ។ |
| ៨. លេអូផូលវ៉ុន រ៉ែងឃ័រ | ជ. ឧបករណ៍ឬសម្ភារៈត្រូវការចាំបាច់សម្រាប់ផលិតទំនិញលក់លើទីផ្សារ ។ |
| ៩. លូសៀន ហ្វេបវ្រ៍ | ឈ. មហាប្រវត្តិវិទូរបស់ចិនសម័យបុរាណ ។ |
| ១០. ស៊ឺម៉ា ឈៀន | ញ. ប្រវត្តិសាស្រ្តអឺរ៉ុបរវាងឆ្នាំ ៥០០ គ.ស. ដល់ ១៥០០ គ.ស. ។ |

**ចូរសរសេរចំលើយសំណួរផ្គូផ្គងក្នុងប្រអប់ចំលើយខាងក្រោមនេះ៖**

| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

**ផ្នែកទី ៣៖ លំហាត់បែងចែកប្រភពឯកសារ ។**

ប្រវត្តិវិទូម្នាក់ កំពុងសិក្សាស្រាវជ្រាវ អំពីការអប់រំកម្រិតមធ្យមសិក្សា នៅកម្ពុជាសម័យអាណានិគមបារាំង ។ ចូរបែងចែកប្រភពឯកសារខាងក្រោម ដោយសរសេរ «**ដ**» សម្រាប់ «ប្រភពឯកសារដើម» និង «**ព**»សម្រាប់ «ប្រភពឯកសារទីពីរ» លើប្រអប់ចម្លើយនៅខាងចុងផ្នែកនេះ ។

១. សៀវភៅ ៖ លុច ប៊ុនសែន «ប្រព័ន្ធអប់រំនៅកម្ពុជា ១៨៥០-១៩៥០» គ្រឹះស្ថានបោះពុម្ពសៀលរ៉េម, ឆៀងម៉ៃ ១៩៨៨ ។

២. កម្មវិធីសិក្សា ៖ វិទ្យាល័យស៊ីសុវត្ថិ, ក្រុងភ្នំពេញ ១៩១០ - ១៩១៥ ។

៣. រូបថត ៖ «សិស្សសាលាវិទ្យាល័យ នាក្រុងភ្នំពេញ» ១៩៣៨ ។

៤. អត្ថបទ ៖ លោក ចន ធូន័រ, «អាណានិគមបារាំងនៅក្នុងថ្នាក់រៀន៖ បរិបទកម្ពុជា», ដោយព្រឹត្តិប័ត្រ Asian Study Reviews លេខ ១៩ ទី ៣ (មីនា ឆ្នាំ ១៩៩៧) ។

៥. សារណា ៖ យូ ធារី, «កាលខ្ញុំរៀននៅសាលា ក្នុងភ្នំពេញ នាសម័យអាណានិគម», ផ្សាយដោយ Oxford University Press, ក្រុងឡុងដ៍ ១៩៩៩ ។

៦. សៀវភៅ ៖ អាន រ. ហានសិន «ពុទ្ធសាសនានិងទំនើបនិយមនៅកម្ពុជាសម័យអាណានិគម ១៨៦០-១៩៣០» គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ, ហូណូលូលូ ២០០៧ ។

៧. សៀវភៅ ៖ ផេន្នី អេឌវឺឌ «កម្ពុជា៖ ការបណ្ដុះពន្លកជាតិ ១៨៤០-១៩៤៥» គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ, ហូណូលូលូ ២០០៧ ។

៨. ព្រះរាជប្រកាស ៖ ព្រះករុណាព្រះបាទស៊ីសុវត្ថិ ស្ដីពីការបង្កើតសាលារចនា ភ្នំពេញ ១៩១២ ។

**ចូរសរសេរចំលើយសំណួរបែងចែកប្រភពឯកសារ ក្នុងប្រអប់ចំលើយខាងក្រោមនេះ៖**

| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ |
|---|---|---|---|---|---|---|---|
| | | | | | | | |

## ៨.១. លំហាត់ប្រៀបធៀប

ចូរត្រលប់ទៅមើលមេរៀនទាំងបួនខាងលើត្រួសៗឡើងវិញ រួចហើយនាំគ្នាពិភាក្សា និងឆ្លើយសំណួរទាំងបួន ដោយសរសេរចម្លើយសំណួរទី ១ ក្នុងចន្លោះខាងក្រោម និងបំពេញចម្លើយសំណួរទី ២ និង ៣ ក្នុងតារាងប្រៀបធៀបខាងក្រោមនេះ, សម្រាប់សំណួរទី ៤ ចូរសរសេរក្នុងចន្លោះលេខ ៨.៣. ។

១. ចូរសង្ខេបខ្លឹមសារគោល «មួយប្រយោគ» សម្រាប់ទ្រឹស្ដីនីមួយៗ ។
ក. ទ្រឹស្ដីប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ ៖ ______________________

______________________________________

______________________________________

ខ. ទ្រឹស្ដីប្រវត្តិសាស្ត្របែបម៉ាក្សិសនិយម ៖ ______________________

______________________________________

______________________________________________

គ. ទ្រឹស្តីប្រវត្តិសាស្ត្របែបសង្គម ៖______________________

______________________________________________

______________________________________________

ឃ. ទ្រឹស្តីប្រវត្តិសាស្ត្រក្រោយសម័យទំនើប ៖______________________

______________________________________________

______________________________________________

២. ស្ថាបនិកឬបុគ្គលសំខាន់ៗក្នុងទ្រឹស្តីនីមួយៗ

៣. តើទ្រឹស្តីប្រវត្តិសាស្ត្រណាដែលផ្តោតលើវិស័យនីមួយៗ ខាងក្រោម៖
(១) សេដ្ឋកិច្ច (២) វប្បធម៌ (៣) នយោបាយ (៤) តួនាទីស្ត្រី (៥) សាសនា (៦) អំណាច

## ៨.២. តារាងប្រៀបធៀបទ្រឹស្តី

ចូរឆ្លើយសំណួរទី ២ និង ៣ ដោយបំពេញចន្លោះក្នុងតារាងខាងលើ ។

| ទ្រឹស្តី ប្រវត្តិសាស្ត្រ | វិទ្យាសាស្ត្រ | ម៉ាក្សីសនិយម | សង្គមសាស្ត្រ | ក្រោយ សម័យទំនើប |
|---|---|---|---|---|
| ស្ថាបនិក | | | | |
| វិស័យសេដ្ឋកិច្ច | | | | |
| វិស័យវប្បធម៌ | | | | |
| វិស័យនយោបាយ | | | | |
| តួនាទីស្ត្រី | | | | |
| វិស័យសាសនា | | | | |
| អំណាច | | | | |

៤. តើអ្នកពេញចិត្តយកទ្រឹស្តីណាមួយសម្រាប់គម្រោងការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្ររបស់អ្នក នាពេលអនាគត? ចូរពន្យល់មូលហេតុនៃជម្រើសរបស់អ្នក ។

## ៨.៣. មូលហេតុនៃជម្រើសទ្រឹស្តីរបស់អ្នក

ដើម្បីជួយដល់ការសម្រេចចិត្តរបស់អ្នក ចូរអានសំណួរទាំងអស់ខាងក្រោម ហើយសាកល្បងឆ្លើយតាមតែអាចធ្វើទៅបាន៖

១. ចូរបកស្រាយអត្ថន័យនៃពាក្យ «ប្រវត្តិសាស្ត្រ» តាមលក្ខណៈភាសាខ្មែរ, ភាសាអង់គ្លេសចាស់, ភាសាបារាំង, ភាសាឡាតាំង និងក្រិចបុរាណ។

២. ចូរពន្យល់អត្ថន័យនៃសម្រង់ពាក្យរបស់លោក ហ្វ្រីមែន (E.A. Freeman) ខាងក្រោមនេះ ៖ «ប្រវត្តិសាស្ត្រគឺជានយោបាយពីអតីតកាល ចំណែកនយោបាយគឺជាប្រវត្តិសាស្ត្របច្ចុប្បន្ន។»

៣. តើប្រភពចំណេះដឹងមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់ប្រភេទនីមួយៗ។

៤. តើហេតុអ្វីបានជាមនុស្សចេះតែចាប់អារម្មណ៍លើរឿងរ៉ាវពីអតីតកាល?

៥. តើទ្រឹស្តីប្រវត្តិសាស្ត្រក្រិចបុរាណ មានគោលការណ៍សំខាន់ៗយ៉ាងដូចម្តេចខ្លះ?

៦. ចូរប្រៀបធៀបរវាងទ្រឹស្តីប្រវត្តិសាស្ត្របែបសាសនានិងទ្រឹស្តីប្រវត្តិសាស្ត្រក្រិចបុរាណដោយលើកយកចំនុចសំខាន់៤៖ មូលហេតុ ប្រធានបទ ប្រភព និង អត្ថន័យនៃការសរសេរប្រវត្តិសាស្ត្រ

៧. ដូចម្តេចដែលហៅថា «អាណត្តិនៃឋានសួគ៌» ? ចូរពន្យល់អោយក្បោះក្បាយ។

៨. តើប្រភពឯកសារសម្រាប់ចង់ក្រងប្រវត្តិសាស្ត្រ មានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់។

៩. តើទ្រឹស្តីប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រត្រូវបានបង្កើតឡើងនៅពេលណា?

១០. យោងតាម ប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រ តើប្រវត្តិវិទូអាចស្វែងយល់អតីតកាលតាមរយៈមធ្យោបាយណាខ្លះ?

១១. តើស្ថាបនិកទ្រឹស្តីប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រជានរណា?

១២. តើលោក ឡេអូផូល វ៉ុន រ៉ែងគី កើតនិងស្លាប់នៅឆ្នាំណា?

១៣. លោក ឡេអូផូល វ៉ុន រ៉ែងគី ជាជនជាតិអ្វី?

១៤. តើលោក រ៉ែងគី ធ្លាប់អនុវត្តទ្រឹស្តីប្រវត្តិវិទ្យាបែបណាខ្លះ មុនក្លាយជាប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រ?

១៥. តាមគំនិតលោក រ៉ែងគី តើប្រវត្តិវិទូគួរតែយកប្រភពឯកសារបែបណាសម្រាប់មកសិក្សាស្រាវជ្រាវ?

១៦. តើទ្រឹស្តីប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រចែងយ៉ាងដូចម្តេច?

១៧. ដូចម្តេចដែលហៅថា «គោលការណ៍នៃវត្ថុវិស័យភាព»?

១៨. តើស្នាព្រហស្តរបស់ព្រះ អាចជាប្រធានបទសិក្សាសម្រាប់ទ្រឹស្តីប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រ ដែរឬទេ?

១៩. តាមទស្សនៈលោករ៉ែងគី តើប្រវត្តិសាស្ត្រអាច ឬគួរតែអាចត្រូវបានគេប្រើប្រាស់សម្រាប់អប់រំទូន្មានមនុស្សលើបញ្ហាណាមួយនាពេលបច្ចុប្បន្នឬអនាគតដែរឬទេ? ហេតុអ្វី ?

២០. តើទ្រឹស្តីប្រវត្តិវិទ្យាបែបវិទ្យាសាស្ត្រត្រូវបានគេរិះគន់យ៉ាងដូចម្តេចខ្លះ?

២១. តើលោករ៉ែងគីអនុញ្ញាតអោយប្រើពាក្យ «ខ្ញុំ» នៅក្នុងស្នាដៃសិក្សាស្រាវជ្រាវ ដែរឬទេ? តើហេតុអ្វី?

២២. ចូរបកស្រាយពំនោល «ប្រវត្តិវិទ្យាខុសពីវិទ្យាសាស្ត្រដទៃដោយសារវាជាសិល្បៈផងដែរ។» ចូរលើកឧទាហរណ៍បញ្ជាក់ ។

២៣. តើទស្សនៈទានជាបន្តបន្ទាប់នៃប្រវត្តិសាស្ត្រ (linear conception of history) មានន័យយ៉ាងដូចម្តេច?

២៤.តើនេះជាពំនោលក្នុងទ្រឹស្តីប្រវត្តិសាស្ត្រណាមួយ? «វិធីសាស្ត្រនៃការសរសេរប្រវត្តិសាស្ត្រគឺជាដំណើរការនៃការលុបបំបាត់ភាពលម្អៀង ។»

២៥.តើនរណាជាស្ថាបនិកទ្រឹស្តីម៉ាក្សស៊ីសនិយម?

២៦.តើលោកកាល់ម៉ាក្សកើតនិងស្លាប់វិញនៅឆ្នាំណា ?

២៧. តើទ្រឹស្តីម៉ាក្សស៊ីសនិយមយកអ្វីធ្វើជាមូលដ្ឋានគ្រឹះ ?

២៨.តើទ្រឹស្តីម៉ាក្សស៊ីសនិយមមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

២៩.តើលោក កាល់ម៉ាក្ស មានមុខងារជាអ្វីខ្លះ?

៣០.ចូររៀបរាប់ឈ្មោះស្នាដៃដ៏ល្បីល្បាញបំផុតរបស់លោក កាល់ម៉ាក្ស ។

៣១.លោក កាល់ម៉ាក្ស គិតថាសង្គមមនុស្សអាចត្រូវបែងចែកជាប៉ុន្មានវណ្ណៈ? អ្វីខ្លះ ? វណ្ណៈនីមួយៗមានក្រុមមនុស្សបែបណាខ្លះ?

៣២. ចូរពន្យល់បច្ចេកពាក្យទាំងនេះ «មធ្យោបាយផលិតកម្ម» ? ចូរលើកឧទាហរណ៍ ។

៣៣. តើវណ្ណៈណាខ្លះជាអ្នកគ្រប់គ្រងមធ្យោបាយផលិតកម្ម? ហើយផ្តល់ផលវិបាកអ្វីខ្លះ?

៣៤.ចូរពន្យល់បច្ចេកពាក្យទាំងនេះ «ពលជីព» «ប៉ារ៉ាស៊ីត» «មូលដ្ឋានគ្រឹះ» «ដំបូលឬទ្រង់ទ្រាយលើ» ។

៣៥.តើទ្រឹស្តីប្រវត្តិសាស្ត្របែបម៉ាក្សស៊ីសនិយមចែងយ៉ាងដូចម្តេច?

៣៦.តើអ្វីទៅជា«គោលដៅ»នៃការតស៊ូវណ្ណៈ?

៣៧. តើជំហានបន្ទាប់ក្រោយពេលបដិវត្តន៍ជោគជ័យ មានអ្វីខ្លះ?

៣៨.តើតាមទស្សនៈលោក កាល់ម៉ាក្ស ក្នុងចំណោមវិស័យទាំងនេះ (សេដ្ឋកិច្ច នយោបាយ សង្គម និងវប្បធម៌) វិស័យណាមួយសំខាន់ជាងគេ ? ហេតុអ្វី ?

៣៩.តាមទស្សនៈលោក កាល់ម៉ាក្ស ក្នុងការចង់ក្រងប្រវត្តិសាស្ត្រ តើប្រវត្តិវិទូត្រូវបង្ហាញអ្វីខ្លះ?

៤០.តើក្រោយពេលបដិវត្តន៍បានជោគជ័យ តើមានប្រវត្តិសាស្ត្រទៀតដែរឬទេ? ហេតុអ្វី?

៤១.តើវណ្ណៈសង្គមនានាតស៊ូប្រឆាំងនឹងគ្នាក្នុងរូបភាពបែបណាខ្លះ?

៤២.ចូរលើកឧទាហរណ៍នៃការប្រឈមមុខដាក់គ្នារវាងមនុស្សក្នុងសង្គម អោយបានបីខុសគ្នា ។

៤៣.ចូររៀបរាប់ពីដំណើរនៃការកើតឡើងនិងរីកធំធាត់នៃវណ្ណៈគហបតី ។

៤៤. ចូរលើកឧទាហរណ៍នៃសមាគមវិជ្ជាជីវៈដែលមានសណ្ឋានដូចនៅអឺរ៉ុបនាសម័យមជ្ឈឹម ។

៤៥. ចូរពន្យល់ពីរបៀបដែលខ្មែរក្រហមអនុវត្តទ្រឹស្តីម៉ាក្សស៊ីសនិយមនៅកម្ពុជា ។

៤៦. ចូរពន្យល់ពីរបៀបដែលខ្មែរក្រហមប្រើប្រាស់ប្រវត្តិសាស្ត្រក្នុងចលនាបដិវត្តន៍របស់ពួកគេ ។

៤៧.តើប្រវត្តិវិទូបែបសង្គមគិតថានរណាជាអ្នកដឹកនាំបដិវត្តន៍នយោបាយ? ហេតុអ្វី?

៤៨. ដូចម្តេចដែលហៅថា«ប្រវត្តិសាស្ត្រពីខាងលើ»?

៤៩.ដូចម្តេចដែលហៅថា«ប្រវត្តិសាស្រ្តពីខាងក្រោម»?

៥០.តើនរណាជាស្ថាបនិកទ្រឹស្តីប្រវត្តិសាស្រ្តបែបសង្គម ?

៥១.ដូចម្តេចដែលហៅថា«ប្រវត្តិសាស្រ្តទាំងមូល»? វាមានធាតុសំខាន់ៗប៉ុន្មាន? អ្វីខ្លះ?

៥២.ដូចម្តេចដែលហៅថា«ប្រវត្តិនៃគំនិតប្រាជ្ញាស្មារតី»? ចូរឧទាហរណ៍បញ្ជាក់ ។

៥៣.តើអ្វីខ្លះអាចចាត់ទុកជាប្រភពព័ត៌មានសម្រាប់ចងក្រងប្រវត្តិសាស្រ្តបែបសង្គម ?

៥៤.តើទ្រឹស្តីប្រវត្តិសាស្រ្តក្រោយសម័យទំនើបត្រូវបានបង្កើតឡើងនៅពេលណា?

៥៥.តើជំនឿប៉ងល់ខ្លាំងលើទ្រឹស្តីណាមួយអាចបង្កផលវិបាកអ្វីខ្លះ?

៥៦.តើនរណាជាស្ថាបនិកទ្រឹស្តីប្រវត្តិសាស្រ្តក្រោយសម័យទំនើប?

៥៧.តើទ្រឹស្តីប្រវត្តិសាស្រ្តក្រោយសម័យទំនើបចែងយ៉ាងដូចម្តេច?

៥៨.ដូចម្តេចដែលហៅថា «ប្រធានវិបស្សនា»? ចូរលើកឧទាហរណ៍បញ្ជាក់ ។

៥៩.ហេតុអ្វីបានជាទ្រឹស្តីក្រោយសម័យទំនើបនិយមណែនាំឲ្យយើងកុំចេះតែជឿថាអ្វីមួយជាការពិត ដោយត្រូវចេះសាកសួរឬឆ្ងល់លើអ្វីទាំងអស់ដែលយើងដឹងលឺ ?

៦០.ហេតុអ្វីបានជាប្រវត្តិវិទូក្រោយសម័យទំនើបនិយមខិតខំស្វែងរកប្រវត្តិខ្សែស្រលាយ ឬពង្សាវតារ?

៦១.តើប្រធានវិបស្សនានិយមជាងគេដោយសារកត្តាអ្វីខ្លះ? ចូរពន្យល់និងឧទាហរណ៍បញ្ជាក់ ។

៦២.ហេតុអ្វីបានជាទ្រឹស្តីប្រវត្តិសាស្រ្តក្រោយសម័យទំនើប តម្រូវឲ្យយើងចេះសាកសួរឬជជែកវែកញែកពីបញ្ហាអំណាច?

៦៣.ចូរបកស្រាយនិងឧទាហរណ៍បញ្ជាក់ឃ្លានេះ «អំណាច គឺជាអ្វីមួយដែលកើតមាននៅគ្រប់ទីកន្លែង ។»

៦៤.ចូរបកស្រាយនិងឧទាហរណ៍បញ្ជាក់ឃ្លានេះ «ចំណេះដឹង គឺជាអំណាច ។»

៦៥.តាមទ្រឹស្តីប្រវត្តិសាស្រ្តក្រោយសម័យទំនើប តើគេអាចស្វែងយល់ពីអតីតកាល ដែលបានកើតឡើងយ៉ាងពិតប្រាកដដែរឬទេ? ហេតុអ្វី?

ចូរសរសេរហេតុផលផ្ទាល់ខ្លួនរបស់អ្នកក្នុងចន្លោះខាងក្រោម ៖

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________៕

# មេរៀនទី ៩ ៖ ប្រវត្តិសាស្ត្រ និងពិភពក្រៅពីបស្ចិមលោក

ទ្រឹស្តីប្រវត្តិសាស្ត្រដែលបានសិក្សាកន្លងមក ភាគច្រើនផ្តោតលើជនជាតិអឺរ៉ុប ។ ក្នុងមេរៀននេះ នឹងងាកទៅមើលទស្សនៈទានរបស់ជនជាតិជ្វីហ្វនិងបណ្តាជនឥស្លាមចំពោះប្រវត្តិសាស្ត្រម្តង ។

ឥឡូវនេះ ប្តូរពីបរិយាកាសត្រជាក់នៅអឺរ៉ុប នាភាគខាងលិច ទៅទឹកដីក្តៅក្រហែងនៃអារ៉ាប់នៅភាគខាងកើតបច្ចុប្បន្នម្តុំប្រទេសអារ៉ាប៊ីសាអូឌីត ដោយរុករកក្នុងបណ្ណាល័យប្រវត្តិវិទូអ៊ីស្លាម អាល់វ៉ាគីឌីដែលយោងតាមប្រតិទិន ហ៊ីជ្រី (មូស្លីម) បានស្លាប់ នៅឆ្នាំ ២០៧ នៃហ៊ីជ្រី ឬ ឆ្នាំ ៨២៣ នៃគ្រឹស្តសករាជ។ អ្វីដែលយើងបានរកឃើញមិនមែនជាសៀវភៅចំនួន ៦០០ ក្បាល ដែលបង្កើតបានជាឃ្លាំងចំណេះដឹងរបស់ព្រះតេជគុណ បេដ៍ នោះទេ ប៉ុន្តែសៀវភៅចំនួន ៦០០ ក្បាលដែលត្រូវបានយកចេញ ក្រោយពេលអាល់វ៉ាគីឌីស្លាប់ដោយមានជំនួយពីបុរសខ្លាំងពីរនាក់លើកហឹបនីមួយៗ ។ រឿងរ៉ាវស្រដៀងគ្នាមួយទៀតកើតឡើងជាមួយអ្នកនិពន្ធអត្ថបទ អាល់-ហ្សាហ៊ីស (ស្លាប់នៅឆ្នាំ ៨៦៨) ដែលមានវ័យចំណាស់ ហើយត្រូវបាន ហឹបសៀវភៅ ធ្លាក់លើរហូតដល់ស្លាប់ ។ ពិតជាជោគវាសនាមួយ នៅពេលដែលពួកគេបូកសរុបឃើញមាន រហូតដល់ ចំនួន ៤០០ ចំណងជើង ។ នៅចុងសតវត្សទី ១០ បណ្ណាល័យមួយនៅទីក្រុងគែរបានប្រមូលនិងស្តុកសៀវភៅរាប់សែនក្បាលរាប់បញ្ចូលទាំងសៀវភៅប្រវត្តិសាស្ត្រជាច្រើនផងដែរ។ ចំនួននេះមានបរិមាណច្រើនលើសពីអ្វីដែលព្រះតេជគុណ បេដ៍ បានអះអាង ក្នុងកំឡុងពេលជាមួយគ្នានោះ និងច្រើនជាងអ្វីដែលត្រូវបានប្រមូលដោយមនុស្សសម័យមុនៗ។ មានតែប្រទេសចិនទេដែលតាមដានប្រពៃណីប្រវត្តិសាស្ត្រមុនៗ រហូតដល់សម័យ ឌុងជី (ស. ៤៧៩ មុនគ្រឹស្តសករាជ ) ដែលអាចប្រដែងជាមួយអក្សរសិល្ប៍ប្រវត្តិសាស្ត្រនៅក្នុងពិភពអ៊ីស្លាមនៅចុងសតវត្សទី ៨ និងដើមសតវត្សទី ៩ សម្រាប់យុគសម័យបេដ៍ និងសម័យអាបាសស៊ីដ នៃការរីកលូតលាស់អ៊ីស្លាម មានអាយុកាលប្រហាក់ប្រហែលនឹងរាជវង្សថាង (៦១៨-៩០៧) ដែលនៅពេលនោះជនជាតិចិនបានប្រមូលផ្តុំបណ្ណាល័យជាច្រើនសតវត្សមកហើយ។ លោកខាងលិចនឹងត្រូវរង់ចាំរហូតដល់មានការបង្កើតម៉ាស៊ីនបោះពុម្ពដើម្បីទទួលបានបទពិសោធន៍ឡើងវិញ។ អ្វីដែលគួរឱ្យកត់សម្គាល់បំផុតនោះគឺការជំរុញប្រវត្តិសាស្ត្រនៅក្នុងនវៈសម័យអឺរ៉ុប ដោយប៉ូលីហ្គោលនិងម៉ាស៊ីនបោះពុម្ពសៀវភៅវីលៀមកាកស្តុន (គ្រឹស្តសករាជ ១៤២២-៩២) ។

លោក អារណាល់ដូ ម៉ូមីគ្លីអាណូ (Arnaldo Momigliano) (១៩០៨-៨៧) ប្រហែលជាអ្នកអត្ថាធិប្បាយដ៏សំខាន់បំផុតលើប្រវត្តិសាស្ត្របុរាណ។ នៅក្នុងជីវិតការងារជំទូលាយដែលបានចាប់ផ្តើមនៅក្នុងប្រទេសអ៊ីតាលីហ្វាស៊ីសនិយមហើយបានបញ្ចប់នៅទីក្រុងឈីកាហ្គោតាមរយៈអុកហ្វដនិង ទីក្រុងឡុងដ៍ សម័យក្រោយសង្គ្រាមលោក ម៉ូមីគ្លីអាណូ កាន់តែមមាញឹកជាមួយជនជាតិពែក្ស ក្រិក (របៀបដែលវាជះឥទ្ធិពលលើរ៉ូម) និងការសរសេរប្រវត្តិសាស្ត្រជ្វីហ្វ។ គាត់បានជួយយ៉ាងច្រើនដើម្បីកំណត់ពីរបៀបដែលគោលការណ៍ប្រវត្តិសាស្ត្រទាំងនេះទាក់ទងគ្នា និងទាក់ទងទៅនឹងវប្បធម៌ប្រវត្តិសាស្ត្របុរាណ ដ៏ទូលំទូលាយនិងប្រភេទជីវប្រវត្តិនិង*ប្រវត្តិទំនាក់ទំនងគ្រួសារ*។ (*ប្រវត្តិទំនាក់ទំនងគ្រួសារ*ត្រូវបានប្រើដំបូងដោយ ប្រវត្តិវិទូទីក្រុងរ៉ូម និងជាការសិក្សាដែលជីវប្រវត្តិបុគ្គលអាចត្រូវបានភ្ជាប់តាមរយៈទំនាក់ទំនងគ្រួសារប្រវត្តិអាជីពនិងអ្វីៗផ្សេងទៀត។ ) នៅក្នុងស្នាដៃរបស់គាត់ «មូលដ្ឋានគ្រឹះបុរាណនៃប្រវត្តិសាស្ត្រសម័យទំនើប» (១៩៩០) លោក ម៉ូមីគ្លីអាណូ សួរសំណួរជាមូលដ្ឋានចំនួនបី៖

១. តើប្រវត្តិសាស្ត្រក្រិក និងព្រះគម្ពីរមានលក្ខណៈដូចគ្នា ត្រង់ណាខ្លះ?

២. តើអ្វីជាភាពខុសគ្នារវាងប្រវត្តិសាស្ត្រក្រិកនិងព្រះគម្ពីរ?

៣. តើហេតុអ្វីបានជាប្រវត្តិសាស្ត្រក្រិក បង្ហាញថាមានសារៈសំខាន់ខ្លាំងណាស់ ខណៈពេលដែលប្រវត្តិសាស្ត្រជ្វីហ្វត្រូវបានបញ្ឈប់ភ្លាមៗនៅសតវត្សរ៍ទី ១ គ្រិស្តសករាជ?

សំណួរពីរដំបូងត្រូវបានពន្យល់ក្នុងតារាង នៅក្នុងមេរៀនមុនៗ ដូច្នេះ សំណួរទីបីដែលនឹងត្រូវដោះស្រាយនៅក្នុងពេលនេះ។ នៅដើមឆ្នាំនៃយុគសម័យគ្រីស្ត ក៏ដូចសម័យមុនគ្រីស្តសករាជជនជាតិយូដាចូលចិត្តសរសេរជាភាសាក្រិក។ ការចង់បានការគោរពនិងការទទួលយកក្នុងចំណោមសហគមន៍ភាគច្រើន ពួកគេបានបាត់បង់សមត្ថភាព ក្នុងការប្រាស្រ័យទាក់ទងជាភាសាហេប្រឺ ឬអារ៉ាមិចដែលជាភាសាពាក់កណ្ដាលនៃមជ្ឈឹមបូព៌ា ដែលមានអាយុកាលប្រហែល ១១០០ មុនគ្រីស្តសករាជ ឬអាចមុនេះទៅទៀត ។ តាមពិត ជនជាតិយូដា សម័យហេលេននិយម យើងត្រូវបានប្រាប់ដោយ ម៉ូមីគ្លីអាណូថាពួកគេ មានភាពស៊ីសង្វាក់គ្នា ដោយសេរី ដោយលាយបញ្ចូលជាតុក្រុមមនុស្សព្រៃ Pagan និងជ្វីហ្វដោយសេរីហើយធ្វើការបញ្ចូលជាតុទាំងនេះទៅក្នុងវប្បធម៌និងប្រវត្តិសាស្ត្រផ្ទាល់ថខ្លួន។ ការអប់រំរបស់ជនជាតិយូដា ត្រូវបានផ្អែកលើភាសាក្រិក អំពីចំណេះដឹងខ្លួនឯង និងការអប់រំសម្រាប់ភាពជាពលរដ្ឋនៅក្នុងរដ្ឋបុរីនានា ហើយនេះបានបញ្ចូលដោយផ្ទាល់ទៅក្នុងវប្បធម៌ប្រវត្តិសាស្ត្រ ដ៏ទូលំទូលាយ។ ជនជាតិយូដាដែលជាអ្នកសង្កេតការណ៍មិនត្រូវបានរងផលប៉ះពាល់ដោយវប្បធម៌ប្រវត្តិសាស្ត្រដ៏ធំទូលាយនេះ ដែលនាំឱ្យមានការកើនឡើងនូវកម្រិតនៃការបញ្ចូលគ្នាជាមួយប្រជាជនសញ្ជាតិធំទូលាយដទៃទៀត។

ជាផ្នែកមួយនៃវប្បធម៌ ដែលមានការរួបរួមគ្នានេះ នៅក្នុងឆ្នាំដំបូងនៃសតវត្សរ៍ទី ១ នៃគ្រឹស្តសករាជ ប្រវត្តិសាស្ត្រជ្វីហ្វខ្វះចំណេះដឹងបុរាណជាច្រើន និងមិនសូវមានទស្សនៈគិតគូរដល់ «ថ្ងៃអវសាន្ត»ឡើយ ។ ហ្វ្លេវៀស យ៉ូសែហ្វឹស (Flavius Josephus) (ឆ្នាំ ៣៧ ដល់ ឆ្នាំ ១០១ គ្រឹស្តសករាជ) ដែលជាប្រវត្តិវិទូជនជាតិជ្វីហ្វ និងយូដានិយមយ៉ាងពិតប្រាកដ បានចាប់ផ្តើមប្រើប្រាស់ ភាសាបាប៊ីឡូននិងប្រវត្តិសាស្ត្រអេហ្ស៊ីប ដោយប្រវត្តិវិទូ Hecataeus នៃ Miletus និង Manetho (ជនជាតិអេហ្ស៊ីបពីរាជវង្សទី ៣០ ដែលយើងស្គាល់តិចតួចបំផុត) សម្រាប់ការចងក្រងឡើងវិញនូវប្រវត្តិសាស្ត្រ«សង្គ្រាមជ្វីហ្វ» ប្រឆាំងនឹងរ៉ូម ។ ស្នាដៃដំបូងរបស់គាត់ត្រូវបានសរសេរជាភាសាអារ៉ាម (Aramaic) ហើយស្នាដៃជាបន្តបន្ទាប់របស់គាត់ស្របតាមការបញ្ចូលគ្នារបស់ជនជាតិយូដា នៅក្នុងពិភពហេលេននិយម នាពេលបច្ចុប្បន្ននេះ ត្រូវបានផ្សាំឡើងជាភាសាក្រិក។ ដោយមានឥទ្ធិពលយ៉ាងខ្លាំង ប្រវត្តិសាស្ត្ររបស់គាត់មានប្រជាប្រិយខ្លាំងរហូតដល់បច្ចុប្បន្ន៖ ត្រូវបានដាក់តាំង នៅគ្រប់ទីកន្លែង នៅក្នុងបណ្ណាល័យជាច្រើន សម័យវីកតូរី ។ ដោយបង្កើតដើមកំណើតនិងវង្សត្រកូលរបស់គាត់ គាត់បានដាក់ជនជាតិយូដាជាចំណុចកណ្តាលនៃកិច្ចការនយោបាយនិងសង្គម។ ដោយចង់បង្កើត ប្រវត្តិសាស្ត្រនិងទីកន្លែងរបស់ជនជាតិយូដានៅក្នុងនោះ គាត់ក៏បានធ្វើការសន្ទត់អំពីការផ្តល់ភាពទេវភាពរបស់ព្រះ និងការព្យាករណ៍នានា។ ដូច្នោះហើយ សៀវភៅចំនួនម្ភៃក្បាលរបស់គាត់ឈ្មោះ Antiquitates Judaicae ឬវត្ថុបុរាណរបស់ជនជាតិយូដាបានចាប់ផ្តើមនៅសួន*អេដែន* ពី*អាដាម* ហើយបានបញ្ចប់ការនិទានកថារបស់ខ្លួន នៅមុនពេលការបះបោររបស់ជនជាតិយូដាប្រឆាំងនឹងរ៉ូមនៅឆ្នាំ ៦៦ ។ ក្នុងនាមជាសាសន៍យូដាដែលបានអប់រំនៅសាលាសាសនាយូដា ដែលពេលខ្លះ មេដឹកនាំនៃក្រុមជនជាតិយូដានៅស្រុកកាលីឡេ ដែលបានបះបោរប្រឆាំងនឹងរ៉ូម ឥឡូវនេះគាត់ត្រូវបានរ៉ូមវាយតម្លៃថាជាអ្នកមើលធុត។ កាលៈទេសៈ ដែលផ្លាស់ប្តូររបស់គាត់បានធ្វើឱ្យគាត់ទទួលបានប្រាក់សោធននិវត្តន៍ ដើម្បីគាត់អាចលះបង់ពេលវេលាទាំងអស់របស់គាត់ ដើម្បីតែសរសេរប្រវត្តិសាស្ត្រ។

ហ្វ្លេវៀស យ៉ូសែហ្វឹស បានប្រើកស្តុតាងតាមរបៀបដែលខុសពីការសរសេរប្រវត្តិសាស្ត្រនានា នៅសម័យមុនគាត់ ។ ចំណេះដឹងផ្ទាល់ខ្លួន និងការទទួលបានការអត្ថាធិប្បាយពិសេសពី តាស៊ីតឹស (ជាពិសេសកំណត់ត្រាប្រតិបត្តិការយោធារបស់គាត់) បានជួយឱ្យសំរួលកិច្ចការសរសេររបស់គាត់ ។ ច្បាស់ណាស់ថាការទទួលបាន

កំណត់ត្រាទាំងនេះ ដោយសារចំពោះស្ថានភាពរជនរបស់គាត់ ហើយសម្រាប់ហេតុផលស្រដៀងគ្នានេះ គាត់បានសរសេរតាមវិធីរ៉ូម៉ាំង ក្នុងការបង្កើតកំណត់ហេតុ ឬកំណត់ត្រាប្រចាំឆ្នាំ។ ប៉ុន្តែគាត់ក៏បានសរសេរតាមខ្លឹមសារ ដោយសង្កត់ធ្ងន់លើទំព័រទាំងអស់ ដោយគ្មានលេខយោង ឬឧបសម្ព័ន្ធដោយប្រើសុន្ទរកថាវែងឆ្ងាយនិងសម្រង់ដោយផ្ទាល់ពីការសន្ទនាដែលគាត់មិនបានពាក់ព័ន្ធផ្ទាល់ ហើយថែមទាំងបាន និយាយបំផ្លើសយ៉ាងខ្លាំង ដូចនៅក្នុងប្រពៃណីរបស់ជនជាតិក្រិកដែរ។ នៅទីនេះគាត់កំពុងពិពណ៌នាអំពីស្ថានភាពនៅក្រុងយេរូសាឡឹម មុនពេលការបំផ្លាញព្រះវិហារជ្វីហ្វទី ២ នៅក្រុងយេរូសាឡឹម៖

> ក្នុងនាមជាព្រះរាជអាជ្ញានៃយូឌា ទីបេរាសីស បានបញ្ជូន ពីឡាត ដែលនៅពេលយប់ដោយសម្ងាត់និងដោយលាក់កំបាំង បានបញ្ជូនរូបភាពរបស់ស៊ីហ្សែរ ទៅទីក្រុងយេរូសាឡឹម ដែលត្រូវបានគេស្គាល់ថាជាទងព្រះមហាក្សត្រ។ នៅពេលថ្ងៃរះ ហេតុការណ៍នេះបានធ្វើអោយជនជាតិយូដាតក់ស្លុតយ៉ាងខ្លាំង។ សម្រាប់អ្នកដែលនៅជិតមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះទិដ្ឋភាព ដែលមានន័យថា ច្បាប់របស់ពួកគេត្រូវបានគេជាន់ឈ្លី, ពួកគេមិនអនុញ្ញាតឱ្យមានរូបចម្លាក់ណាមួយត្រូវបានតំឡើងនៅក្នុងទីក្រុងទេ ហើយហ្វូងមនុស្សទីក្រុង ដែលកំពុងមានកំហឹង ត្រូវបានចូលរួមដោយ ការហូរចូលដ៏ច្រើនពីប្រជាជន ពីជនបទពួកគេបានប្រញាប់ទៅជួបលោក ពីឡាត់ នៅសេសារាហើយសុំអង្វរ អោយគាត់ដកទងព្រះមហាក្សត្រចេញពីទីក្រុងយេរូសាឡិម និងគោរពទំនៀមទម្លាប់បុរាណរបស់ពួកគេ។ នៅពេលដែល ពីឡាត់ បដិសេធ, ពួកគេបានក្រោកឈររហោ ពាសពេញផ្ទះ របស់គាត់ហើយនៅស្ងៀមអស់រយៈពេលប្រាំថ្ងៃនិងយប់។
>
> នៅថ្ងៃបន្ទាប់ លោក ពីឡាត់ បានអង្គុយលើសាលាក្តីនៅក្នុងពហុកីឡាដ្ឋានដ៏ធំហើយបានកោះហៅហ្វូងមនុស្សដោយសំអាងថា គាត់បានត្រៀមខ្លួន ដើម្បីផ្តល់ចម្លើយដល់ពួកគេ។ ផ្ទុយទៅវិញ គាត់បានផ្តល់សញ្ញា ដែលបានរៀបចំទុកមុន ដល់ទាហានដើម្បីឡោមព័ទ្ធជនជាតិយូដា ដោយមានគ្រឿងសឹកពេញទំហឹង ហើយកងទ័ពបានបង្កើតជារង្វង់ព័ទ្ធបីជាន់។ ជនជាតិយូដាមានការងឿងឆ្ងល់យ៉ាងខ្លាំង ចំពោះអ្វីដែលនឹកស្មានមិនដល់ ប៉ុន្តែ ពីឡាត់ បានប្រកាសថា គាត់នឹងកាត់ជាបំណែក ៗ លុះត្រាតែពួកគេមិនព្រមទទួលយករូបចម្លាក់របស់ ស៊ីហ្សែរ ហើយងក់ក្បាលអោយសញ្ញាដល់ពួកទាហានអោយ ដកដាវត្រៀម។ នៅចំណុចនេះ ជនជាតិយូដាហាក់បីដូចជាបន្ទន់ខ្លួនប្រាណដល់ដី ដាក់ ក របស់ពួកគេ ដោយស្រែកថា ពួកគេត្រៀមខ្លួនរួចជាស្រេច សុខចិត្តដាច់ក ក៏មិន បំពានច្បាប់ដែរ។ ដោយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះភាពក្លៀវក្លាខាងសាសនារបស់ពួកគេ លោក *ពីឡាត់* បានបញ្ជាឱ្យដកទងព្រះមហាក្សត្រចេញពីទីក្រុងយេរូសាឡិមភ្លាម១។
>
> (យ៉ូសែហ្វីស ១៩៨១ ទំព័រ ១៣៨)

ថ្វីបើលោក យ៉ូសែហ្វីស បានប្រើសុន្ទរកថា ទាំងស្រុងនិងវែង១ ពីតួអង្គប្រវត្តិសាស្ត្រឈានមុខគេក៏ដោយ ប្រវត្តិរបស់គាត់ គឺស្របតាមវិធីសាស្ត្ររបស់ជនជាតិរ៉ូម ដែលខ្វល់ខ្វាយនឹងសីលធម៌ក្នុងនយោបាយជាពិសេសឥទ្ធិពលនៃសង្គ្រាមក្នុងការផ្លាស់ប្តូរប្រវត្តិសាស្ត្រ និងប្រើកំណត់ហេតុដើម្បីបង្កើតជាកាលប្បវត្តិ។ ទោះយ៉ាងណាក៏ដោយ មានធាតុផ្សំសំខាន់ៗមួយចំនួន ដែលញែកសំណេរ ប្រវត្តិសាស្ត្រជ្វីហ្វខុសពីសមភាគីក្រិកនិងរ៉ូម៉ាំង៖ ទំនោរក្នុងចំណោមប្រវត្តិវិទូជ្វីហ្វដែលចូលចិត្ត រៀបរាប់ព្រឹត្តិការណ៍តាំងពីការចាប់ផ្តើមដំបូងនៃពិភពលោក មិនមែនគ្រាន់តែជាការចាប់ផ្តើមពេលដែលមានកំណើតមនុស្សនោះទេ។ ក៏មានការព្រួយបារម្ភចំពោះសច្ចៈភាពផងដែរ មិនមែនគ្រាន់តែជាការពិតដែលផ្តោតលើភាពត្រឹមត្រូវ ដូចដែលយើងបានឃើញជាមួយអ្នកកត់ត្រា នៅមជ្ឈិមសម័យដែល

បានពិភាក្សានៅក្នុងផ្នែកមុននោះទេប៉ុន្តែបារម្ភលើការពិតដែលបានប្រាប់ដោយព្រះជាម្ចាស់ផ្ទាល់ ដែលមានឯកភាព និងមានអំណាចបំផុត ។ ជាការពិត ការរម្លឹកឡើងវិញឬការចងចាំពីព្រះអាទិទេព និងអព្ភូតហេតុដែលបានអះអាងថា ជាផ្នែកមួយនៃមរតកហេព្រើរ ៖ ការរត់គេចពីរបបទាសភាពនៅអេហ្ស៊ីបដែលលេចធ្លោជាងគេ, ត្រូវបានតាក់តែងឡើងវិញ តាមប្រពៃណីដោយគ្រួសារជ្វីហ្វនៅជុំវិញតុញ៉ាំបាយ ក្នុងពិធីបុណ្យរៀងរាល់ឆ្នាំ ។ នេះគ្រាន់តែជាឧទាហរណ៍មួយនៃការរម្លឹកឡើងវិញដ៏ល្បីល្បាញបំផុតមួយប៉ុណ្ណោះ ។ ការរាប់ឆ្នាំតាមសាសនាជ្វីហ្វ តាំងពីមុននិងឥឡូវនេះ រំលឹកឡើងវិញ និងធ្វើគ្រាប់ព្រឹត្តិការណ៍អតីតកាលអោយមានភាពរស់រវើកគួរឱ្យភ្ញាក់ផ្អើលនិងមានភាពទៀងទាត់។

ជនជាតិយូដា ប្រហែលជាខ្វះវិធីសាស្ត្រប្រវត្តិសាស្ត្រ បើប្រៀបធៀបជាមួយជនជាតិក្រិក (ឬសូម្បីតែរ៉ូម) ប៉ុន្តែពួកគេមិនខ្វះមធ្យោបាយដើម្បីបង្កើតនិងរក្សាកំណត់ត្រាសាធារណៈនោះទេ។ អ្នកខ្លះថែមទាំងបានពិពណ៌នាអំពីប័ណ្ណសារជ្វីហ្វ នៅសម័យបុរាណថាប្រសើរជាងរបស់ក្រិក។ ប៉ុន្តែ ក្នុងពេលដែលក្រិក បានរក្សា នូវការចាប់អារម្មណ៍លើប្រវត្តិសាស្ត្រ ទោះបីក្នុងពេលជាតិរបស់ខ្លួនត្រូវធ្លាក់ចុះ និងការកើនឡើងនៃវិសាលភាពចក្រភពរ៉ូម ដោយបន្តចំណាប់អារម្មណ៍នេះទៅក្នុងវប្បធម៌របស់ពួកគេ,ជនជាតិយូដាគឺឈប់ងក់ ពោលគឺឈប់សរសេរ តែម្តង។

វាហាក់ដូចជាមិនមែនដោយសារខ្វះការយកចិត្តទុកដាក់ចំពោះបណ្ណសារ ឬសម្រាប់គំនិតជជីកសួរនោះទេ, តាល់មូដ(Talmud) (ដែលរួមបញ្ចូលគ្នារវាងមីសណា(Mishnah) និង ហ្គេម៉ារ៉ា (Gemara)) គឺ ជាការបង្កើតច្បាប់ផ្ទាល់មាត់ របស់ជ្វីហ្វ ដែលត្រូវបានសរសេរ នៅចន្លោះសតវត្សទី ២ និងទី ៥ និង គឺជាពាក្យ សម្រាប់យុត្តាធិការ និងវិវាទ។ ទោះបីជាគ្មានតាល់មូដក៏ដោយសៀវភៅជ្វីហ្វ ហាក់ដូចជាមានការពិពណ៌នាគ្រប់គ្រាន់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងព្រឹត្តិការណ៍ «សហសម័យ» ឬ ស្រដៀងៗនេះ ។ គម្ពីរ *អែសរ៉ានេហេមា*និង គម្ពីរ *ម៉ាកាប៊ីដំបូង*ដែលបានប្រាប់ពីរឿងរ៉ាវនៃការតស៊ូរបស់វីរបុរសប្រឆាំងនឹងជនជាតិពែរ្សនិងក្រិក, ហើយយោងតាម ម៉ូមីគ្លីអាណូ, ស្ថិតនៅចន្លោះ«ផ្លូវបំបែករវាងគំនិតជ្វីហ្វនិងក្រិក» ត្រូវបានស្គាល់ថា មានលក្ខណៈបង្ហាញការឈ្លោះប្រកែកគ្នា យ៉ាងឃោរឃៅ។ សំខាន់ជាងនេះទៅទៀត ការលំលោយរបស់រដ្ឋជ្វីហ្វ នៅឆ្នាំ ៦៦ គ្រឹស្តសករាជ (ទើបមានវត្តមានឡើងវិញនៅឆ្នាំ ១៩៤៨) បានន័យថាជនជាតិជ្វីហ្វត្រូវបាននិរទេសពីដែនដីរបស់ខ្លួន «ដែលព្រះបានសន្យាអោយ» ដោយគ្មានប្រាសាទដើម្បីតម្កល់រូបសំណាក់និងលើកតម្កើងច្បាប់។ នេះជានាថា ពួកគេរក្សាបាននូវសាមគ្គីភាពក្រុម និងការចាប់អារម្មណ៍ជាប្រវត្តិសាស្ត្រដែលផ្តោតសំខាន់លើគ្នាទៅវិញទៅមក។ ហើយក្នុងករណីណាក៏ដោយ ជនជាតិយូដាមានសៀវភៅប្រវត្តិសាស្ត្រឬគម្ពីរកំពូល ៖ តូរ៉ា ។ គ្មានប្រវត្តិសាស្ត្រផ្សេងទៀតសំខាន់នោះទេ បើយោងតាមលោក ម៉ូមីគ្លីអាណូ ដែលនាំឱ្យមានការព្រងើយកន្តើយចំពោះវិស័យស្រាវជ្រាវប្រវត្តិសាស្ត្រដទៃទៀត។

នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថ *ជនជាតិយូដានិងប្រវត្តិរបស់គាត់* (១៩៧៧), លោក លីអូណែល កូឆាន (១៩២២-២០០៥) បានបញ្ជាក់ថា ប្រវត្តិសាស្ត្រជ្វីហ្វ ពិតជា មិនមានទេតាំងពីសម័យបុរាណរហូតដល់ពេល R. Joseph Ha 'Cohen (១៤៩៦-១៥៧៨) បានសរសេរកំណត់ហេតុពីបណ្តា ស្តេច បារាំង និងតួកគី សម័យអូតូម៉ង់ ។ គាត់បានច្រានចោលសញ្ញាណដែលថា ជនជាតិយូដាត្រូវញ៉ាំញីឬបានស្រូបយកដោយនិទានកថាក្នុងព្រះគម្ពីរ ឬថាក្នុងនាមជាមនុស្សដែលគ្មានរដ្ឋ, ពួកគេទំនងជាមិនសូវមានវប្បធម៌ប្រវត្តិសាស្ត្ររួមដូចប្រជាជាតិទូទៅនោះទេ ហើយនេះបានផ្តល់នូវការពន្យល់រួម សម្រាប់ភាពស្ងៀមស្ងាត់ ដោយគ្មានកំណត់ត្រា អស់រយៈពេលរាប់សតវត្សរ៍ ។ ដូចគ្នាដែរ គាត់បានបដិសេធថាជនជាតិយូដាត្រូវបានរងឥទ្ធិពល ខ្លាំងក្លា ពីគំនិតរបស់គ្រឹស្តសាសនា ដែលថា ជនជាតិយូដាក្នុងនាមជាប្រជាជន គឺជាភាគីមួយនៃកិច្ចព្រមព្រៀងឥតបានប្រយោជន៍ ដែលបានបំផ្លាញបន្ទាប់ពីការយាងមករបស់ព្រះយេស៊ូវ ហើយឥឡូវនេះវាលែងពាក់ព័ន្ធទៀតហើយ - ប្រទេសដែលគ្មាន

អនាគតមិនចាំបាច់ត្រូវការអតីតកាល។ ផ្ទុយទៅវិញ កូធាន់ បានលើកឡើងថា ជនជាតិយូដាបានចងក្រងប្រវត្តិសាស្ត្រដោយការអនុវត្តផ្ទាល់៖ «ដោយពន្យល់លំអិតពីមធ្យោបាយ ដែលផ្ទុយពីភាពប្រណីត នៅទីបញ្ចប់» ដែលគាត់បានវិនិច្ឆ័យថាជា «ការធ្វើបញ្ញាសពីការគិតបែបល្អត្រចះត្រចង់ ដែលកើតមានក្នុងចំណោម ពិភពលោកសាសន៍ដទៃ (កូធាន់ ១៩៧៧, ទំព័រ ១១៧) ។ ខណៈពេលដែល គម្ពីរ តាល់មូដ បានទទួលយកជំនឿលើដំណើរការមកដល់របស់ព្រះជាលើកទីពីរ «មេស្ស៊ី»[១៣] នៅក្នុងប្រវត្តិសាស្ត្រ ហើយថែមទាំងប៉ាន់ស្មានថា ពិភពលោកនឹងនៅមានអត្ថិភាព ក្នុងរយៈពេលប្រាំមួយពាន់ឆ្នាំ បន្ទាប់ពី «ថ្ងៃអវសាន្ត» នៅក្នុងយុគសម័យជាបន្តបន្ទាប់, វាផ្ទុយពីទស្សនៈជំនឿគ្រីស្តសាសនា ដោយបដិសេធការព្យាករណ៍ថាតើព្រះនឹងយាងមកម្តងទៀតនៅពេលណា និងដោយរបៀបណា ឬតាមរបៀបណា ។

ភាពមន្ទិលសង្ស័យអំពីភាពស័ក្តិសិទ្ធិ ឬប្រសិទ្ធភាពនៃការទស្សទាយនគរវេតខ្មោះ អាចពន្យល់ពីមូលហេតុដែលអ្នកប្រាជ្ញមានឥទ្ធិពលបំផុត នៅក្នុងសម័យក្រោយព្រះគម្ពីរ គឺ រ៉ាប៊ី ម៉ូហ្សេ បេន ម៉ៃម៉ុន ឬ ម៉ៃម៉ូនីដ (១១៣៨-១២០៤) បានចាប់យកទិដ្ឋភាព នៃជីវិតបញ្ញាអារ៉ាម ផ្សេងទៀត ដូចជា គណិតវិទ្យាទស្សនវិជ្ជា ឱសថ និងកំណាព្យ ប៉ុន្តែបានប្រកាសសៀវភៅប្រវត្តិសាស្ត្រថា ជាការខ្ជះខ្ជាយពេលវេលា។ ទោះយ៉ាងណាក៏ដោយ ដូចដែលត្រូវបានណែនាំដោយប្រវត្តិវិទូ ខេនណេត សេសស្ទីន ថ្មីៗនេះ គាត់មានអារម្មណ៍គិតដល់អតីតកាលដែរ ប៉ុន្តែ ជាអតីតកាលដែលសមស្របនឹងយុគសម័យមជ្ឈិមដែលគាត់រស់នៅ។ សំខាន់ជាងនេះទៅទៀត ជនជាតិយូដា គឺជាសាក្សីនៃប្រវត្តិសាស្ត្រមនុស្សជាតិទាំងមូលហើយកាតព្វកិច្ចដ៏ឧឡារិករបស់ពួកគេ គឺត្រូវបន្តរស់នៅ (សេសស្ទីន, ២០០៤) ។ មិនមែន ម៉ៃម៉ូនីដ បានធ្វើការនៅក្នុងចន្លោះវប្បធម៌ ឬប្រពៃណីនោះទេ ។ ជាការពិត នេះគឺជា«យុគសម័យមាស» ដែលមានការអត់ឱនក្នុងចំណោមប្រពៃណីទាំងបី ដែលត្រូវបានជម្រុញ ដោយការសញ្ជ័យរបស់ជនជាតិម៉ូរីស នៅអេស្ប៉ាញ ក្នុងឆ្នាំ ៧១១ ហើយមិនបានបញ្ចប់ទេ រហូតដល់ជនជាតិយូដា ត្រូវបានបណ្តេញចេញ ដោយគ្រីស្តសាសនិកជននៅឆ្នាំ ១៤៩២ ។ ក្នុងរយៈពេលនេះ កិច្ចសហប្រតិបត្តិការវប្បធម៌និងបញ្ញា ជាមួយសាសនាឥស្លាមគឺជារឿងធម្មតាទោះបីជា ដូចដែលយើងនឹងឃើញនៅពេលនេះមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅក្នុងវិធីសាស្ត្ររបស់ពួកគេចំពោះប្រវត្តិសាស្ត្រ។

សាសនាអ៊ីស្លាមបានលេចចេញជាកម្លាំងយោធា នៅឆ្នាំ ៧០០ ប៉ុន្តែ សំណេរប្រវត្តិសាស្ត្រអ៊ីស្លាមមិនបានលេចចេញជារូបរាងឡើយរហូតដល់ ២០០ ឆ្នាំក្រោយមក ។ ប្រវត្តិសាស្ត្ររបស់គេសង្កត់ធ្ងន់ ទៅលើប្រវត្តិសាស្ត្រនៃរាជវង្សនិងប្រជាជាតិ ដែលជះឥទ្ធិពលដល់ពង្សាវតារនិងវង្សត្រកូលរបស់ព្យាការីនិងប្រវត្តិនៃអនាគត ពោល គឺការព្យាករណ៍អំពីការបញ្ចប់នៃពិភពលោក ឬថ្ងៃជំនុំជម្រះ ។ ដូចសាសនាគ្រីស្តដែរជីវប្រវត្តិ របស់ម៉ូហាម៉ាត់ និងសំណេរប្រវត្តិសាស្ត្រអ៊ីស្លាមត្រូវបានកំណត់ នៅចុងបញ្ចប់នៃពិភពលោក ហើយនេះត្រូវបានគេរំពឹងទុកជាមុនថាពិតជាបានកើតឡើងរួចហើយ ។ ផ្ទុយទៅវិញ ការសរសេរចងក្រងនៃព្រឹត្តិការណ៍នានា ដូចជាការបង្កើតពិភពលោកស្ថិតនៅក្នុងផ្នែកមួយនៃប្រវត្តិសាស្ត្រទូទៅ ប៉ុន្តែនៅតែមានលក្ខណៈចៃដន្យ។

ដោយបានចាប់ផ្តើម យ៉ាងហ្មត់ចត់ នៅប្រហែលឆ្នាំ ៦០០ ឬ ៧០០ ទ្រឹស្តីប្រវត្តិសាស្ត្រអ៊ីស្លាមត្រូវបានគោរពតាមច្បាប់និងសាសនាអ៊ីស្លាម ដែលត្រូវបានលាយបញ្ចូលគ្នាជាមួយឥទ្ធិពល ប៊ីហ្សង់ទីននិងអ៊ីរ៉ង់។ ប្រវត្តិវិទូដែលមាននិន្នាការបែបនេះនៅក្នុងសាសនាអ៊ីស្លាម បានដោះស្រាយបញ្ហានៅពេលដែលទម្រង់សរសេរបែបអ៊ីស្លាមបានរីកចម្រើនពិតប្រាកដហើយបានព្យាយាមវាយតម្លៃពីឥទ្ធិពលនិងផលប៉ះពាល់របស់វា។ ឧទាហរណ៍ លោក

[១៣] ដូចក្នុងព្រះពុទ្ធសាសនា ទស្សទាយអំពីការមកដល់នៃព្រះសិរអារ្យមេត្រីយ៍

ឆេស រ៉ូប៊ីនសុន (២០០៣) បានគូសបញ្ជាក់ពីកំឡុងពេលបង្កើតប្រវត្តិសាស្ត្រអ៊ីស្លាម ដែលលាតសន្ធឹងពីឆ្នាំ ៦០០ ទៅ ៩០០ និងសម័យបុរាណ ដែលមានចេញលទ្ធផលពីឆ្នាំ ៩៥០ ទៅ ១៥០០ ។ យ៉ាងណាមិញ លោក ហ្វ្រង់ហ្វ្រ័ូសិនថល (១៩៩០) បានចុះកាលបរិច្ឆេទសំណេរប្រវត្តិសាស្ត្រអ៊ីស្លាម ដោយអះអាងថាវាបានក្លាយជាកម្លាំងឯករាជ្យជាច់ដោយឡែកមួយចាប់ពីឆ្នាំ ៧០០ ។ វាជាប្រពៃណីមួយដែលឆ្លុះបញ្ចាំងពីគំនិតរបស់មូស្លីមនិងវប្បធម៌ដែលបានរៀនសូត្រពីអរិយធម៌មួយដែលបានលេចចេញក្នុងរយៈពេលដ៏ខ្លីបំផុត ដែលបានលេចធ្លោ នៅចុងសតវត្សទី ៨ និងដើមសតវត្សទី ៩ ។ វាបានផ្តល់នូវលំហសុវត្ថិភាពមួយ សម្រាប់ការបញ្ចេញមតិផ្ទាល់ខ្លួន ហើយទើបនៅក្រោយ សតវត្សទី១៤ និង១៥ ទើបវាបានទាក់ទាញអ្នករិះគន់ពី «វិទ្យាសាស្ត្រពិត» ដូចជា ទស្សនវិជ្ជា ឬ វេជ្ជសាស្ត្រ។

ទោះជាការពិត អំពីកាលប្បវត្តិនិងការទទួលយកប្រវត្តិសាស្ត្រថា ជាប្រភពចំណេះវិទ្យាដែលអាចជឿទុកចិត្តបាន (ជាមូលដ្ឋាននៃចំណេះដឹង) នៅក្នុងពិភពអ៊ីស្លាម យ៉ាងណាក៏ដោយ ពិតជាគួរអោយស្ងើចសរសេរអំពី ទំហំនៃការផលិត និងស្ថានភាពជឿនលឿនរបស់ពួកគេឡើយ។ នេះជាការពិតជាពិសេសនៅពេលដែលយើងពិចារណាថាជនជាតិចិនបានចំណាយពេល ៥០០ ឆ្នាំ ដើម្បីឈានដល់កំរិតនិងភាពប៉ិនប្រសប់ដែលអ្នកប្រាជ្ញអ៊ីស្លាមសម្រេចបានក្នុងរយៈពេល៥ជំនាន់តែប៉ុណ្ណោះ។ ប្រសិនបើកម្លាំងច្នៃប្រឌិតនេះហាក់ដូចជាឆាប់ឆេះអស់លឿនជាងឋាមពលគ្រីស្ត ដែលត្រូវបានបំភ្លឺ ឬយ៉ាងហោចណាស់ត្រូវបានបង្កើតឡើងវិញដោយ ប្រវត្តិវិទូព្រះសង្ឃ បេដ៍ នោះក៏យ៉ាងហោចណាស់ដោយសារតែរយៈពេលនៃការចងក្រងប្រវត្តិសាស្ត្រនៅក្នុងពិភពអ៊ីស្លាម គឺមិនអាចទាញយកបាន។ ក្នុងដំណាលពេលដែលអ្នកប្រាជ្ញមជ្ឈិមសម័យនៅអឺរ៉ុប ប្រើក្រដាសនិងស្បែកសត្វ ដើម្បីកត់ត្រាប្រវត្តិរបស់ពួកគេ ប្រវត្តិវិទូអ៊ីស្លាម ក្នុងសម័យជាមួយគ្នានោះបានប្រើសម្ភារៈក្រដាស ដែលសោត់និងបាត់បង់ តាមពេលវេលា, ឬត្រូវបានបំផ្លាញ ដោយបរទេសឈ្លានពានឬ ជម្លោះផ្ទៃក្នុងសាសនាអ៊ីស្លាម។ ជាលទ្ធផល មានបញ្ហាពិតប្រាកដ ដែលអ្នកប្រាជ្ញអ៊ីស្លាមបច្ចុប្បន្នជួបប្រទះ៖ ភាពប្រាកដអំពី«រយៈពេលបង្កើត» នៃសាសនាអ៊ីស្លាមគឺពិបាកបង្កើតឡើងខណៈដែលអ្នកដែលចង់ស្តារប្រវត្តិសាស្ត្រនៃសង្គមមុនសាសនាអ៊ីស្លាម ប្រឈមមុខនឹងកិច្ចការដែលមិនអាចធ្វើទៅបាន ព្រោះមិនមានកំណត់ត្រាជាលាយលក្ខណ៍អក្សរដើម្បីពិគ្រោះយោបល់។

ទោះយ៉ាងណា បន្ទាប់ពីឆ្នាំ ៩៥០ យើងអាចពិនិត្យពិច័យសំណេរប្រវត្តិសាស្ត្រអ៊ីស្លាមអំពី អ្វីដែលគេហៅថា «សម័យបុរាណ» ។ តើអ្វីទៅជាការសន្មតនិងវិធីសាស្ត្រ ហើយតើយើងគួរធ្វើការវិនិច្ឆ័យអំពីភាពត្រឹមត្រូវនិងប្រសិទ្ធភាពរបស់វាយ៉ាងដូចម្តេច? ចំណេះដឹងបច្ចុប្បន្ន ត្រូវបានរៀបចំឡើងតាមប្រធានបទធំ ៗ ចំនួនបី គឺ កាលប្បវត្តិ ជីវប្រវត្តិ និងប្រវត្តិខ្សែស្រលាយ។ វិធីសាស្ត្រប្លែកៗទាំងនេះបានបង្កើតឡើងដើម្បី បង្កើតទម្រង់និងលក្ខណៈពិសេសនៃសំណេរប្រវត្តិសាស្ត្រអ៊ីស្លាម នៅក្នុងបរិបទកាន់តែទូលំទូលាយកក្នុងការធ្វើអាវ៉ាប់នីយកម្មលើ សាសនាអ៊ីស្លាម, ដើម្បីផ្តល់នូវកំណត់ត្រាពេញលេញនៃខ្សែជីវិតរបស់ព្យាការីនិងដើម្បីរក្សាប្រវត្តិសាស្ត្រ មុនអ៊ីស្លាម មុនពេលមានការកត់ត្រា ឬការចងចាំ កុំអោយបាត់បង់។

ការរម្លឹកការចងចាំបានដើរតួយ៉ាងសំខាន់ នៅក្នុងទំនៀមទំលាប់អ៊ីស្លាម ប៉ុន្តែមានលក្ខណៈ ខុសពីសាសនាយូដា ឬ សាសនាគ្រីស្ត។ អ្នកប្រវត្តិសាស្ត្រអ៊ីស្លាម បានប្រើកាលប្បវត្តិ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃជីវប្រវត្តិព្យាការី និង ដើម្បីយល់និង«បញ្ជាក់» *ហៃឌិត* ឬ *ហាដវ៉េត* ដែលជាប្រពៃណីផ្ទាល់មាត់នៅក្នុងសាសនាអ៊ីស្លាមដែលបានរំលឹកឡើងវិញនូវការបង្រៀននិងជីវិតរបស់ព្យាការីខណៈ*ស៊ុនណា* ព្យាយាមស្វែងយល់បន្ថែមអំពីរបៀបរស់នៅព្យាការី ។ «វិទ្យាសាស្ត្រ» នៃការរិះគន់ *ហៃឌិត* បានផ្តល់វិធីសាស្ត្រដល់ សំណេរប្រវត្តិសាស្ត្រអ៊ីស្លាម។ វិធីសាស្ត្រនេះមានភាពស្មុគស្មាញយ៉ាងខ្លាំង ប៉ុន្តែ យ៉ាងហោចណាស់ ចំណាត់ថ្នាក់ ៧ ប្រភេទ ត្រូវបានកត់សម្គាល់ ។ ការចាត់ថ្នាក់

ទាំងនេះត្រូវបានរចនាឡើងដើម្បីតេស្តភាពជឿទុកចិត្តនៃទំនៀមទំលាប់និងការប្រៀនប្រដៅ ដែលត្រូវបានសន្មត ដោយព្យាការី ប៉ុន្តែ កន្លែងដែលអាចមានភាពគួរឱ្យសង្ស័យ ឬកន្លែងដែលមានបញ្ហា យុត្តិសាស្ត្រថ្មី ត្រូវបាន គេបោះបង់ចោលដោយកាលៈទេសៈទំនើប, ការរិះគន់ *ហៃឌិត*ស្វែងរកប្រភពនៃភស្តុតាងបង្ហាប់បញ្ជាជាបន្តបន្ទាប់។ នេះត្រូវបានគេហៅថា *អ៊ីសាណាដ* ។ *អ៊ីសាណាដ* បានសួរសំណួរអំពី ភាពអាចជឿជាក់បានរបស់សាក្សី ទំនាក់ ទំនងរវាងសាក្សី ភាពត្រឹមត្រូវនៃកាលបរិច្ឆេទនិងភស្តុតាងដែលបានផ្តល់ ឬលំដាប់នៃភស្តុតាងដែលបានផ្តល់។

វាគួរឱ្យសង្ស័យថា *ហៃឌិត* ក្នុងនាមជាច្បាប់ប្រពៃណី អាចត្រូវបានស្រាវជ្រាវទំនាក់ទំនងដោយផ្ទាល់ ទៅនឹងសម័យរបស់ព្យាការី ប្រហែលជា មិនលើសពី ២០០ ឆ្នាំ ឬបន្ទាប់ពីមរណភាពរបស់គាត់។ ខណៈពេលដែល ទស្សនៈនេះ ភាគច្រើនឆ្លុះបញ្ចាំងពី ទស្សនៈរបស់អ្នកប្រាជ្ញលោកខាងលិច, អ្នកប្រាជ្ញអ៊ីស្លាមភាគច្រើនបានជំទាស់ នឹងទស្សនៈនេះ។ ក្នុងករណីណាក៏ដោយ អ្វីដែលយើងរកឃើញ (និង អ្វីដែលសំខាន់សម្រាប់ប្រវត្តិវិទូអ៊ីស្លាម នៅយុគសម័យមជ្ឈិមសម័យ) គឺថាលក្ខណៈវិនិច្ឆ័យនៃភស្តុតាងនិងភាពជឿជាក់នៃភស្តុតាងមានភាពខុសគ្នា យ៉ាងខ្លាំង រវាងសំណេរប្រវត្តិសាស្ត្របូព៌ាប្រទេស និងបស្ចឹមប្រទេស។ បទដ្ឋាននៃការវិនិច្ឆ័យអោយចំគោលដៅ និង សញ្ញាណនៃប្រធានវិស័យភាព មានភាពខុសគ្នាយ៉ាងខ្លាំង យ៉ាងហោចណាស់ នៅក្នុងរយៈពេលបន្ទាប់ពីអ្វីដែល លោកខាងលិចហៅថា យុគមជ្ឈឹមសម័យ ។

អាទិភាពចម្បងនៃប្រវត្តិសាស្ត្រអ៊ីស្លាមក្នុងអតីតកាល គឺការអភិរក្សបំណែករប៉ាត់រប៉ាយនៃអតីតកាលប៉ុន្តែ វាមិនដែលអាចរំដោះខ្លួនពីភាពរំជើបរំជួលបានទេ ហើយក៏មិនបានដាក់សម្ពាធឱ្យបានត្រឹមត្រូវក្នុងការបម្រើបច្ចុប្បន្ន ដែរ។ នៅចំណុចកំពូលនៃភាពទំនើប ក្នុងយុគសម័យមាស នៅក្នុងប្រទេសអេស្ប៉ាញ នៅពេលដែលសាសនា អ៊ីស្លាមនាំមុខគេ នៅពិភពលោកខាងវិទ្យាសាស្ត្រទស្សនវិជ្ជានិងវេជ្ជសាស្ត្រ តែក្រោយមកវាមានភាពយឺតយ៉ាវក្នុងការ ទទួលយកការផ្លាស់ប្តូរ។ ជាការពិត ការបញ្ចប់នៃយុគសម័យមាសនៅក្នុងទសវត្សរ៍ឆ្នាំ ១៤០០ បានកើតឡើង ស្របពេលជាមួយនឹងការបំបិទការរិះគន់ទៅលើគម្ពីរកូរ៉ាន ខណៈពេលជាមួយគ្នានេះដែរ វិទ្យាសាស្ត្រ និងការរិះគន់ លើព្រះគម្ពីរនៅបស្ចឹមលោក នឹងជម្រុញឱ្យសង្គមមានការបើកចំហនិងមាននិរន្តរភាព។

ទោះជាយ៉ាងណា ប្រវត្តិសាស្ត្រនៅក្នុងពិភពអារ៉ាប់ ត្រូវបានចងក្រងឡើងនៅក្នុងក្របខ័ណ្ឌវប្បធម៌ធំ ទូលាយជាងការពាក្យទូន្មានប្រៀនប្រដៅរបស់ព្យាការីហើយបានផ្ទុះកកើតឡើងពី វិធីសាស្ត្រ *ហៃឌិត* ។ លោក Ya'qubi (ស្លាប់ ឆ្នាំ ៨៩៧) បានព្យាយាម សរសេរប្រវត្តិសាស្ត្រពិភពលោក (រួមទាំងមានការដកស្រង់ពីជនជាតិ ក្រិច) ជាលើកដំបូង ជាភាសាអារ៉ាប់ ហើយក្រោយមក អ្នកផ្សេងទៀត បានព្យាយាមចងក្រងប្រវត្តិសាស្ត្រធម្មជាតិ ប្រវត្តិសាស្ត្រក្នុងស្រុក ប្រវត្តិសាស្ត្ររាជវង្ស ជីវប្រវត្តិនៃតួអង្គប្រវត្តិសាស្ត្រ ជាដើម។ ប្រវត្តិសាស្ត្រទាំងនោះ ត្រូវបាន ចងក្រងឡើង (ជាញឹកញាប់ជាភាសាពែក្ស) ក្រោយការឈ្លានពានម៉ុងហ្គោលទៅលើពិភពមូស្លីមនៅឆ្នាំ ១២១៩ ហើយនៅសតវត្សរ៍ទី១៤ ប្រវត្តិសាស្ត្រត្រូវបានសរសេរនៅអាហ្វ្រិកខាងជើង ដោយមានលក្ខណៈជាសកល និង មានភាពស្មុគស្មាញខាងទ្រឹស្តី ខ្លះដែរ។ ទោះយ៉ាងណាប្រវត្តិសាស្ត្រអ៊ីស្លាម មិនមានឥទ្ធិពលសំខាន់ ដូចសមភាគី របស់ពួកគេនៅខាងលោកខាងលិចដែលមានលក្ខណៈអាណាចក្រច្រើនជាង តែប្រវត្តិសាស្ត្រ អ៊ីស្លាមភាគច្រើនមាន នៅក្នុងសង្គមមូស្លីមដែលនៅមានភាព អនថយ និងគាបសង្កត់។

## ៩.១. លទ្ធផលនៃការសិក្សាទ្រឹស្តីប្រវត្តិសាស្ត្រអឺរ៉ុប

លទ្ធផលនៃប្រពៃណីសិក្សាប្រវត្តិសាស្ត្រអឺរ៉ុប ៖

១. ទ្រឹស្តីប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ (Scientific History)

២. ទ្រឹស្តីប្រវត្តិសាស្ត្របែបម៉ាក្សីសនិយម (Marxist History)

៣. ទ្រឹស្តីប្រវត្តិសាស្ត្របែបសង្គម (Social History)

៤. ទ្រឹស្តីប្រវត្តិសាស្ត្រក្រោយសម័យទំនើប (Post-Structuralism) ឬ (Post-Modernism)

## ៩.២. ការអនុវត្តន៍ទ្រឹស្តី

រាល់ទ្រឹស្តីគោលថ្មីៗ ដែលយើងបានរៀនហើយ ទាំងទ្រឹស្តីប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ, ទ្រឹស្តីប្រវត្តិសាស្ត្រម៉ាក្សីសនិយម, និងទ្រឹស្តីប្រវត្តិសាស្ត្រក្រោយសម័យទំនើប, សុទ្ធសឹងតែត្រូវបានចង់ក្រងឡើងដោយយោងតាមប្រពៃណីប្រវត្តិសាស្ត្រអឺរ៉ុប ។ ទ្រឹស្តីនីមួយៗបានកើតចេញពីបរិបទប្រវត្តិសាស្ត្រណាមួយជាក់លាក់ ពិសេសគឺអឺរ៉ុប ។ តួយ៉ាង ទ្រឹស្តីម៉ាក្សីសនិយមត្រូវបានអភិវឌ្ឍឡើង ដោយចេញពីលទ្ធផលនៃការបែងចែកវណ្ណៈសង្គមនិងសេដ្ឋកិច្ចអឺរ៉ុប ឯទ្រឹស្តីក្រោយសម័យទំនើបនិយម ដោយសារនិន្នាការនយោបាយ និងប្រព័ន្ធអប់រំអឺរ៉ុប ក្នុងពាក់កណ្តាលទីពីរនៃសតវត្សរ៍ទី ២០ ។

ប៉ុន្តែ តើទ្រឹស្តីទាំងអស់នោះអាចត្រូវអនុវត្តនៅប្រជាជាតិឬវប្បធម៌ផ្សេងពីអឺរ៉ុប ដែរឬទេ ? ជាឧទាហរណ៍ តើមានអ្វីកើតឡើងនៅពេល ទ្រឹស្តីម៉ាក្សីសរបស់អឺរ៉ុប (ត្រូវគេហៅថា ទ្រឹស្តីសកល) ត្រូវបានគេអនុវត្តនៅកម្ពុជា ? មែនទែនទៅ ប្រទេសកម្ពុជា មិនមែនជាប្រទេសឧស្សាហកម្មទេ, គ្មានវណ្ណៈកម្មករទេ, គ្មានបដិវត្តន៍របស់វណ្ណៈគហបតី ដើម្បីជាគ្រឹះក្នុងការធ្វើបដិវត្តម៉ាក្សីសនោះទេ ។ ជាលទ្ធផល សម័យប៉ុលពតបានចាប់កំណើតឡើង ។ នេះជាឧទាហរណ៍នៃការជឿងុបងល់ខ្លាំងពេកលើទ្រឹស្តីណាមួយ, ដែលបង្កជាគ្រោះមហន្តរាយគួរសង្វេគពេកក្រៃ ។

បណ្តាទ្រឹស្តីបស្ចឹមប្រទេស ដោយរួមទាំងទ្រឹស្តីវិទ្យាសាស្ត្រ បានបណ្តាលអោយមានការដាក់អាណានិគមលើប្រទេសផ្សេងៗ ដូចជា ប្រទេសកម្ពុជា ។ នេះក៏ដោយសារគំនិតពូជសាសន៍ វិទ្យាសាស្ត្រ ការស្រាវជ្រាវ មូលធននិយម បន្ទុះគ្រួសារតូចៗ ត្រូវបានគេយល់ថាជាគំនិតល្អបំផុត ស្ថិតនៅលើកំពូលជណ្តើរនៃការវិវត្តន៍(របស់មនុស្សលោក) ។ នេះជាឧទាហរណ៍មួយបញ្ជាក់ពីឥទ្ធិពលនៃការគិតគូរឬទស្សនៈរបស់បស្ចឹមប្រទេសទៅលើផ្នែកផ្សេងៗលើពិភពលោក, ជាឧទាហរណ៍មួយដែលបញ្ជាក់ពីកង្វល់នានាដែលទ្រឹស្តីទាំងឡាយត្រូវបានបង្កើតឡើងនៅបស្ចឹមប្រទេស ហើយមិនមែននៅបូព៌ាប្រទេស ។

បច្ចុប្បន្នឥទ្ធិពលរបស់បស្ចឹមប្រទេសទៅលើការសរសេរប្រវត្តិសាស្ត្រនៅមានវិសាលភាពធំធេងនៅឡើយ ។ ជាក់ស្តែង ប្រវត្តិសាស្ត្រប្រទេសកម្ពុជាសឹងតែត្រូវបានសរសេរដោយជនជាតិបរទេសទាំងអស់ ដែលបាននាំយកទស្សនៈនិងផ្នត់គំនិតបរទេសមកជាមួយផងដែរ ។

## ៩.៣. ការពិភាក្សា និងជជែកវែកញែក

ចូរបែកចែកជាក្រុម ហើយនាំគ្នាពិភាក្សាលើសំណួរខាងក្រោម ។

១. តើមានអ្វីខ្លះដែលជាភាពខុសគ្នារវាងបស្ចឹមប្រទេស និងជនជាតិកម្ពុជា ?

២. តើអ្វីខ្លះដែលអ្នកដទៃមិនអាចយល់ច្បាស់ពីកម្ពុជា?

៣. តើ«យើង»អាចតំណាងអោយ«អ្នកដទៃ»បានដែរឬទេ ? ហេតុអ្វី?

៤. តើអ្នកនិពន្ធបរទេសពិតជាអាចស្វែងយល់ច្បាស់ពីអតីតកាលស្តីពីកម្ពុជាដែរឬទេ?
**«ក» បាទឬចាស អាច** ឬ **«ខ» ទេ មិនអាច៖** ហេតុអ្វី? មានអ្វីជាភស្តុតាង ឬទឡ្ហីករណ៍?

ចូរបែងចែកជាពីរក្រុម មួយគាំទ្រគោលគំនិត «ក» និងមួយទៀតគាំទ្រគោលគំនិត «ខ»

## ៩.៤. ដំណើរការនៃការជជែកវែកញែក

ដំណើរការនៃការជជែកវែកញែកមានបួនដំណាក់កាល ៖

១. បើកវេទិកាជជែក (Opening Statements) ៖ ក្រុមនីមួយៗមានពេលរហូតដល់ ៥ នាទី ដើម្បីលើកឡើងនូវសំណើ និងអំណះអំណាងរបស់ក្រុមខ្លួន ។

២. ការវាយបក (Counter-Attacks) ក្រុមនីមួយៗមានពេលរហូតដល់ ៣-៥ នាទី ដើម្បីលើកសំណួរវាយបកលើអំណះអំណាងរបស់គូរបដិបក្ស ។ បន្ទាប់ទទួលបានសំណួរហើយ ក្រុមនីមួយៗមានពេល ៥ នាទីដើម្បីរៀបចំអំណះអំណាងដើម្បីបកស្រាយ ។

៣. វគ្គបកស្រាយ (Explaining)៖ ក្រុមនីមួយៗមានពេលរហូតដល់ ៥-១០ នាទី ដើម្បីបកស្រាយរាល់សំណួរពីគូរបដិបក្ស ។

៤. បិទវេទិកាជជែក (Closing Statements) ៖ ក្រុមនីមួយៗមានពេលរហូតដល់ ៥ នាទី ដើម្បីសំយោគនូវចំណុចខ្លាំងរបស់ខ្លួន និងចង្អុលពីចំណុចខ្សោយរបស់គូរបដិបក្ស ។

ចំណាំ៖ នេះជាឱកាសចុងក្រោយដើម្បីបញ្ចុះបញ្ចូលចៅក្រមអោយជឿក្រុមអ្នក ។ បើមានអ្វីចង់ពន្យល់បន្ថែមលើកឡើងអោយហើយ ព្រោះគ្មានការតវ៉ាទៀតឡើយ ក្រោយវគ្គនេះចប់ ។

## ៩.៥. ការវាយតម្លៃរួម

ក្រុមនីមួយៗនឹងត្រូវទទួលការវាយតម្លៃរួមតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ។ ដូច្នេះហើយសមាជិកក្រុមទាំងអស់ត្រូវចូលរួមដោយយកចិត្តទុកដាក់និងយ៉ាងសកម្ម ៖

A – ស្រាវជ្រាវបានទូលំទូលាយ, រៀបចំឃ្លាឃ្លោងល្អ, ចេះវាយបកចំៗ

(Well researched, paraphrases, acknowledges or refutes a topic.)

B – បង្ហាញថាយល់ច្បាស់ពីប្រធានបទ និងទាញទឡ្ហីករណ៍ល្អ

(Showed comprehension of topic, makes a good argument)

C – ចូលរួមយ៉ាងសកម្មនិងបានកត់ត្រាចំណុចគោលៗ (Participates and takes notes)

D-E – មិនបានចូលរួមពិភាក្សា និងបង្ហាញចំណាប់អារម្មណ៍តិចបំផុត

(Does not participate in discussion, and shows minimum attentiveness)

F - គ្មានឆន្ទះចូលរួមជជែក (Shows unwillingness to participate in class debate)

## ជំពូកទី ២ ចំណេះដឹង និងបំណិនសិក្សាវគ្គទ្រឹស្តីប្រវត្តិសាស្ត្រ

## មេរៀនទី ១០ ៖ វិធីសាស្ត្ររៀនប្រវត្តិសាស្ត្រអោយមានប្រសិទ្ធិភាពខ្ពស់

### ១០.១. តើប្រវត្តិវិទូកំពុងព្យាយាមធ្វើអ្វីខ្លះ?

ចាប់តាំងពីពេលមនុស្សជាតិ ចេះបង្កើតអក្សរសម្រាប់សរសេរ ពួកគេបានបន្សល់ទុកនូវកំណត់ត្រាអំពីចំណេះដឹងរបស់ពួកគេជុំវិញពិភពលោក អំពីព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងជំនាន់ពួកគេនិងអារម្មណ៍ផ្ទាល់ខ្លួនចំពោះព្រឹត្តិការណ៍ទាំងនោះ ។ តាមរយៈការសិក្សាលើកំណត់ហេតុបន្សល់ទុកដោយមនុស្សជំនាន់មុន យើងអាចរកឃើញនឹងយល់ដឹងពីជីវភាពរស់នៅរបស់ពួកគេ និងបញ្ហាដែលពួកគេបានជួបប្រទះ ។ យើងអាចប្រើប្រាស់បទពិសោធន៍មនុស្សជំនាន់មុន សម្រាប់ដោះស្រាយបញ្ហាដែលយើងកំពុងជួបប្រទះ ពេលសព្វថ្ងៃ ។ ទោះបីជាពិភពលោកដ៏ទំនើបបច្ចុប្បន្នខុសប្លែកច្រើនពីសង្គម ដែលដូនតាយើងបានរស់នៅ បទពិសោធន៍ជោគជ័យនិងបរាជ័យរបស់ពួកគេ គឺជាវិធានការណ៍តែមួយគត់ ដែលយើងអាចប្រើប្រាស់ដើម្បីថ្លឹងថ្លែងពីគុណភាពជីវិតយើង និងភាពជោគជ័យក្នុងការរៀបចំសង្គមរបស់យើងនាពេលបច្ចុប្បន្ននេះ ។

មនុស្សលោកយើង គ្រប់រូប ក្រលេកមើលអតីតកាលម្តងហើយម្តងទៀត ។ យើងអានប្រលោមលោកបែបប្រវត្តិសាស្ត្រ ឬសៀវភៅដែលនិយាយពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ យើងសម្លឹងមើលរូបថតចាស់ៗ ដោយមិនដាក់ភ្នែក ឬស្តាប់រឿងរ៉ាវដែលជីដូនជីតាយើងនិទានប្រាប់ យ៉ាងជក់ចិត្តបំផុត ។ យ៉ាងណាមិញ ប្រវត្តិវិទូ គឺជាអ្នកដែលខិតខំធ្វើការសិក្សាពីព្រឹត្តិការណ៍អតីតកាល ដោយយកចិត្តទុកដាក់ ដោយមានក្បួនខ្នាតនិងប្រព័ន្ធត្រឹមត្រូវ និងព្យាយាមប្រើប្រាស់ចំណេះដឹង ដែលខ្លួនមាន ដើម្បីជួយពន្យល់ពីបុគ្គលិកលក្ខណៈរបស់មនុស្ស និងកិច្ចការរបស់ពួកគេ ។ ប្រវត្តិវិទូវិជ្ជាជីវៈចំណាយពេលមួយជីវិត ដើម្បីស្វែងរកអត្ថន័យអតីតកាលសម្រាប់បច្ចុប្បន្នកាល ។ ចំពោះអ្នកប្រវត្តិសាស្ត្របែបកំសាន្ត (amateurs) ការស្រាវជ្រាវប្រវត្តិសាស្ត្រ គ្រាន់តែជាចំណង់ចំណូលចិត្តសម្រាប់ពួកគេប៉ុណ្ណោះ ប៉ុន្តែ ការដែលពួកគេស្វែងរកអត្ថន័យពីអតីតកាលក៏អាចចូលរួមចំណែកស្តារឡើងវិញនូវចំណេះដឹងអំពីមនុស្សជាតិ និងអាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវិតរបស់ពួកគេ ។ ការសិក្សានិងស្រាវជ្រាវរបស់អ្នកក្នុងនាមជានិស្សិត អាចធ្វើអោយអ្នកអាចក្លាយជាអ្នកប្រវត្តិសាស្ត្របែបកំសាន្តផងដែរ ។ កិច្ចការប្រលងប្រវត្តិសាស្ត្ររបស់អ្នក គឺជាផ្នែកមួយនៃការស្វះស្វែង រកចំណេះដឹង ដែលត្រូវផ្ទេរពីមួយជំនាន់ទៅមួយជំនាន់ ។

### តើប្រវត្តិសាស្ត្រអាចអប់រំយើងយ៉ាងដូចម្តេចខ្លះ ?

អ្វីៗដែលមានវត្តមានក្នុងពេលបច្ចុប្បន្ន បានវិវត្តន៍កើតចេញពីពេលអតីតកាល មិនថាអ្វីៗទាំងអស់នោះមានលក្ខណៈ រូបរាង ទ្រង់ទ្រាយថ្មី ឬចម្លែកយ៉ាងណា ទាំងនោះពិតជាត្រូវបានរក្សាទុក ឬនៅសល់លក្ខណៈពីអតីតកាល ។ ឧទាហរណ៍មួយដ៏ល្អ គឺការវិវត្តន៍នៃស្នាដៃសិល្បៈខ្មែរ ។ រចនាបថថ្មីត្រូវបានកែច្នៃចេញពីរចនាបថចាស់ៗ ។ ដូចគ្នានេះដែរ តន្ត្រីញាក់ថ្មីបំផុតរបស់ក្រុមចម្រៀងសម័យថ្មី គឺជាលទ្ធផលនៃការវិវត្តន៍ចេញពីស្ទីលតន្ត្រីក្រុមមុនៗ ដោយសារឥទ្ធិពល ក៏ដូចជាអោយស្របទៅតាមទំនោរ និងបរិយាកាសសង្គម ។ ប្រហែលជាស្ទីលរបស់ពួកគេវិវត្តន៍ចេញពីស្ទីលតន្ត្រីរ៉ក (Rock Music) ជាមួយនឹងក្រុមចម្រៀង Beatle ឬវិវត្តន៍ចេញពីស្ទីលរបស់ Bob Dylan ។

ដោយឡែក សិល្បៈករ Dylan ក៏យកស្ទីលចេញពី Woody Guthie ដែលបានតែងចម្រៀងគាត់ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ហើយដែលខ្លួនគាត់ផ្ទាល់ ក៏យកស្ទីលឬទទួលមរតកពីតន្ត្រីប្រពៃណីអាមេរិក កាលពីសតវត្សរ៍ទី ១៩ ដែលបាននាំចូលពីប្រទេសអង់គ្លេស និងស្កុតឡែន ហើយដែលមានប្រភពមកពី មជ្ឈឹមសម័យ ។ តន្ត្រីហ្សាស់សម័យថ្មី (Modern Jass) ដូចជាតន្ត្រីរបស់ Duke Ellington និង Billie Holiday ឬតន្ត្រីនាពេលថ្មីៗនេះ ដូចជា Miles Davis, Chick Corea និង Pat Metheny សុទ្ធតែបានវិវត្តន៍ចេញពីតន្ត្រីរបស់សហគមន៍ស្បែកខ្មៅនៅអាមេរិក និងតំបន់ការីប៊ីន ។ ពួកទេសករស្បែកខ្មៅបាននាំតន្ត្រីទាំងនោះមកពីទ្វីបអាហ្វ្រិកតាំងពីសតវត្សរ៍ទី ១៨ និង ១៩ ។ ដូច្នេះ អ្នកអាចប្រៀបធៀបថា ផ្ទះបច្ចុប្បន្នកាល ត្រូវបានបំពេញដោយបង្អួចអតីតកាល ។

ឡានដែលអ្នកជិះ ទោះបីជាវាត្រូវបានគេរចនាឡើងនៅប៉ុន្មានឆ្នាំមុននេះក៏ដោយ ក៏វានៅប្រើប្រាស់គ្រឿង ឬឧបករណ៍នៃរទេះគ្មានសេះ កាលពីដើមសតវត្សរ៍ ២០ ។ ឡានរបស់អ្នកមានដំណើរការដោយសារមនុស្សចេះពីវិធីធ្វើរទេះ កង់ និងម៉ាស៊ីន ហើយមានគំនិតយកគ្រឿងទាំងអស់នេះ ផ្គុំគ្នាបង្កើតបានជាទោចក្រយានយន្តជាលើកដំបូង ។ ចំណេះដឹងដែលចាំបាច់សម្រាប់បង្កើតរទេះ និងកង់ តាមពិតទៅបានមកពី ការច្នៃប្រឌិតបង្កើតឡើងកាលពីសម័យមុននោះដែរ ។ អ្វីៗផ្សេងទៀត ក៏ដូចជាកង់ដែរ មានប្រភពកំណើតតាំងពីបុរាណកាល របស់មនុស្សជំនាន់មុន ។

អ្វីទាំងអស់តែងមានសាវតារ ឬប្រវត្តិរបស់វាផ្ទាល់ ។ យ៉ាងហោចណាស់ ចម្លើយសម្រាប់សំណួរនិងចម្ងល់ស្តីពីពិភពលោកសព្វថ្ងៃ អាចនឹងលេចឡើង ក្រោយពេលយើងសិក្សាពីដំណើរដើមទង ស្ថានការណ៍ពីអតីត ភ្ជាប់រហូតមកដល់ពេលបច្ចុប្បន្ន ។ បញ្ហាដែលត្រូវស្វែងរក គឺ ព្រឹត្តិការណ៍អតីតកាល មូលហេតុ ការរៀបចំ(សង្គម) ទស្សនៈផ្សេង ឬការពិតដែលជះឥទ្ធិពលលើស្ថានការណ៍បច្ចុប្បន្ន ដែលអ្នកតែងតែមានចម្ងល់ ។ បើអ្នកយល់ដឹងពីឥទ្ធិពលពីអតីតកាលកាន់តែច្រើននោះអ្នកកាន់តែចេះដឹងស្ថានការណ៍បច្ចុប្បន្នដែលអ្នកចង់ដឹង ។

## ប្រវត្តិសាស្ត្រនិងពិភពលោកបច្ចុប្បន្ន

មនុស្សយើងម្នាក់ៗតែងមានចម្ងល់មិនចេះអស់មិនចេះហើយ ។ កាលយើងនៅក្មេង យើងតែងតែសួរឪពុកម្តាយយើង សំណួរជាច្រើន ក្នុងនោះសំណួរពេញនិយមជាងគេ គឺ «ហេតុអ្វី?» ។ លុះដល់ពេលយើងធំឡើង យើងនៅតែបន្តសួរសំណួរប្រហាក់ប្រហែលនេះទៀត ព្រោះថាយើងទាំងអស់គ្នាចង់ដឹងចង់យល់អំពីអ្វីៗ នៅជុំវិញខ្លួនយើង ក៏ដូចជាឆ្ងល់ពីអាថ៌កំបាំងលើពិភពលោកទាំងមូល ។ ដោយសារតែអ្វីគ្រប់យ៉ាងមានប្រវត្តិកំណើតរបស់វាផ្ទាល់ ប្រវត្តិវិទូអាចមានចម្លើយសម្រាប់ភាគច្រើននៃចម្ងល់ឬសំណួរទាំងនោះ តាមរយៈការសិក្សាស្រាវជ្រាវរឿងរ៉ាវអតីតកាល ។

## តើប្រវត្តិវិទូបំពេញកិច្ចការរបស់ខ្លួនយ៉ាងដូចម្តេច?

កិច្ចការប្រវត្តិវិទូត្រូវធ្វើ មិនមែនជាការងាយស្រួលប៉ុន្មាននោះទេ ។ តាមពិតទៅ ពួកគេព្យាយាមប្រើប្រាស់ជំនាញស្រាវជ្រាវ និងអង្កេតលើហេតុការណ៍ប្រវត្តិសាស្ត្រដើម្បីដោះស្រាយបញ្ហាទាំងឡាយក្នុងពេលបច្ចុប្បន្ន ឬអនាគត ។ ដូចបានបញ្ជាក់ខាងលើ ប្រវត្តិវិទូព្យាយាមរកចម្លើយតបនឹងចម្ងល់នានា ។ តើជាកិច្ចការរបស់ពួកគេ ឬក៏មិនមែន ក្នុងការឆ្លើយនឹងសំណួរ ដូចជា «តើខ្ញុំជាមនុស្សគួរអោយស្រលាញ់ដែរឬទេ?» «តើនរណាជាមនុស្សឆ្លាតជាងគេលើក្នុងពិភពលោក?» ចម្លើយគឺ ទេ ទាំងនេះមិនមែនជាកិច្ចការប្រវត្តិវិទូទេ ព្រោះវាជាសំណួរឡប់ៗ ឥតប្រយោជន៍ឡើយ ។

ដូចនេះ ប្រវត្តិវិទូមិនត្រឹមតែខិតខំរកដំណោះស្រាយសម្រាប់បញ្ហានានាប៉ុណ្ណោះទេ តែថែមទាំងត្រូវគិតថាតើបញ្ហាណាដែលសំខាន់និងផ្តល់អាទិភាពមុនគេ ។ ការកំណត់អាទិភាពសម្រាប់បញ្ហាទាំងអស់នេះ គឺអាស្រ័យលើ

គុណតម្លៃផ្ទាល់ខ្លួន ការយកចិត្តទុកដាក់ពីមនុស្សគាំទ្រកិច្ចការរបស់ពួកគេ កាលៈទេសៈដែលប្រវត្តិវិទូនោះកំពុងជួប ប្រទះឬ ឬក៏ការរួមផ្សំនៃកត្តាទាំងនេះ ។ ប្រវត្តិវិទូក៏ត្រូវពិចារណាផងដែរ ទៅលើភស្តុតាងឬសាក្សីដែលខ្លួនជ្រើស យកមកសិក្សាស្រាវជ្រាវ ។ ឧទាហរណ៍ថាតើភស្តុតាងទាំងនោះ គួរអោយជឿជាក់បានដែរឬទេ? តើវាមានភាព ត្រឹមត្រូវកម្រិតណា ហើយលម្អៀងកម្រិតណាដែរ ? ក្នុងករណីមានឯកសារដែលនិយាយខុសគ្នាលើបញ្ហាតែមួយ គេ ត្រូវគិតថា តើមួយណាត្រឹមត្រូវ (ឬត្រឹមត្រូវជាង)?

## ១០.២. វិធីសាស្ត្រអានកិច្ចការប្រវត្តិសាស្ត្រ

ការអានរឿងរ៉ាវប្រវត្តិសាស្ត្រ អាចនាំមកនូវភាពរីករាយ និងផ្តល់ដល់អ្នកអាន នូវបទពិសោធន៍គួរជាទីពេញ ចិត្ត ប៉ុន្តែ ចូរសាកល្បងប្រៀបធៀបថា យើងកំពុងទស្សនាទីកន្លែងណាមួយ ដែលមានទេសភាពស្រស់ត្រកាល ។ ដើម្បីបានរីករាយត្រេកត្រអាលនឹងទេសភាពនោះ ក៏ដូចជាធ្វើអោយយើងងាយស្រួលចងចាំបទពិសោធន៍ល្អៗសំរាប់ កែវភ្នែកយើង ជាដំបូងយើងគួរសួរខ្លួនយើងថា តើយើងកំពុងនៅទីណា? ដូចគ្នានេះដែរ ដើម្បីងាយស្រួលយល់ពី ប្រវត្តិសាស្ត្រពិតណាមួយ យើងត្រូវការការយល់ដឹងពី ប្រធានបទ ដែលគេកំពុងនិយាយ រួមទាំងវិធីសាស្ត្រ ដែលគេ ប្រើសម្រាប់បរិយាយពីហេតុការណ៍ទាំងនោះ ។ ប្រសិនបើអ្នកចាប់ផ្តើមអាន មុនពេលអ្នកយល់ពីលក្ខណៈរបស់ អត្ថបទ អ្នកអាចនឹងយល់ខុសលើព្រឹត្តិការណ៍ពិតមួយចំនួន ហើយនាំអោយទាញសេចក្តីសន្និដ្ឋានខុសដែរ ។ ឧទាហរណ៍ ពេលខ្លះអ្នកនិពន្ធប្រើវិធីសាស្ត្រចំអកក្នុងការបង្ហាញហេតុការណ៍ពិតណាមួយ ឬជួកកាល គាត់លើក យកព្រឹត្តិការណ៍ផ្សេងមកប្រៀបធៀប ។ ក្នុងករណីនេះ ប្រសិនបើយើងមិនពិនិត្យអោយបានច្បាស់ជាមុននោះទេ យើងប្រហែលជាយល់ច្រលំថាអ្នកនិពន្ធកំពុងរៀបរាប់អ្វីដែលចាកឆ្ងាយពីប្រធានបទ ។ ដំបូង យកល្អយើងគួរតែ ស្វែងយល់អំពីអ្នកនិពន្ធ និងគោលបំណងរបស់គាត់ក្នុងការសរសេរសៀវភៅនោះ ។ បន្ទាប់មក ចូរអានមាតិការ អត្ថបទ ដើម្បីស្វែងយល់នូវគោលគំនិតទូទៅរបស់អ្នកនិពន្ធ និងវិធីសាស្ត្រ ឬបែបបទក្នុងការតាក់តែងសៀវភៅរបស់ គាត់ ។ បន្ទាប់មក ចូរពិនិត្យមើលជំពូកនីមួយៗត្រួសៗ រួចអានចំណងជើងរង និងក្រលេកមើលការចង្អុលបង្ហាញ នានា និងរូបភាព ក្រាហ្វិកផ្សេងៗ ។ បើអ្នកមានពេល ចូរអានជាមុននូវផ្នែកសេចក្តីផ្តើម និងសេចក្តីបញ្ចប់អោយបាន រហ័សមុននឹងចូលអានអត្ថបទពិស្តារ ។

ក្រោយពេលអ្នកចាប់បាននូវគោលគំនិតសំខាន់ៗខ្លះហើយ នោះអ្នកនឹងត្រៀមលក្ខណៈរួចជាស្រេចក្នុងការ អានសៀវភៅនោះ ។ រហូតមកដល់ពេលនេះ អ្នកមានការយល់ដឹងខ្លះពី៖

- ប្រធានបទនៃសៀវភៅ៖ អ្វីទៅជាខ្លឹមសារទូទៅរបស់វា?
- ជីវប្រវត្តិរបស់អ្នកនិពន្ធ៖ តើគាត់ជាអ្នកនយោបាយ ឬអ្នកសារព័ត៌មាន ឬអ្នកប្រវត្តិសាស្ត្រ ឬជាសាក្សី ប្រវត្តិសាស្ត្រ ឬជាអ្នកនិពន្ធប្រលោមលោក? ។ល។
- ពេលវេលាបោះពុម្ព៖ តើវាត្រូវបានបោះពុម្ពប៉ុន្មានឆ្នាំហើយ? ១០០ ឆ្នាំ? ឬក៏ជាសៀវភៅថ្មីបំផុតដែល និយាយពីប្រធានបទនេះ?
- របៀបតាក់តែង ឬនិពន្ធ៖ តើវាត្រូវបានរៀបចំឡើងតាមលំដាប់ពេលវេលា ឬតាមប្រធានបទ? ហើយអ្វី ដែលសំខាន់បំផុត គឺ
- ខ្លឹមសារសំខាន់ និងសេចក្តីសន្និដ្ឋានរបស់វា ៖ ខ្លឹមសារគោលរបស់សៀវភៅ គឺជាផ្នែកឬចំណុចសំខាន់ៗ ដែលអ្នកនិពន្ធចង់លើកយកមកបង្ហាញដល់អ្នកអាន ។ ជាឧទាហរណ៍ គេលើកថា បញ្ហាភូមិសាស្ត្រនៃ

ប្រទេសអេស្ប៉ាញ គឺជាឧបសគ្គធំ ដែលរារាំងប្រទេសនេះ មិនអោយទទួលជោគជ័យក្នុងការធ្វើឧស្សាហូបនីយកម្ម នៅក្នុងសតវត្សរ៍ទី ១៨ និង ១៩ ។

អ្នកនិពន្ធភាគច្រើនបង្ហាញខ្លឹមសារគោលនៅក្នុងផ្នែកអារម្ភកថា ឬនៅក្នុងសេចក្តីផ្តើម ។ ប្រសិនបើអ្នកយល់ពីចំណុចសំខាន់ដែលអ្នកនិពន្ធចង់បង្ហាញនោះ អ្នកនឹងយល់យ៉ាងច្បាស់អំពីការរៀបចំកិច្ចតែងនិពន្ធ និងសេចក្តីសន្និដ្ឋានរបស់សៀវភៅនោះ ។ អ្នកនិពន្ធនោះនឹងរៀបចំបង្ហាញភស្តុតាង និងទាញសេចក្តីសន្និដ្ឋាន ដើម្បីគាំទ្រគំនិតសំខាន់ ។ យ៉ាងណាមិញ ប្រសិនបើខ្លឹមសារសំខាន់មិនត្រូវបានបង្ហាញឡើងអោយច្បាស់លាស់ ឬក៏ថាភស្តុតាងមិនមានលក្ខណៈគាំទ្រវាទេ សៀវភៅនោះមិនមែនជាសៀវភៅប្រវត្តិសាស្ត្រដ៏ល្អនោះទេ ទោះបីវាមានព្រឹត្តិការណ៍ពិតយ៉ាងណាក៏ដោយ ។ សមត្ថភាពក្នុងការស្វែងរកអោយឃើញនូវចំណុចខ្សោយ និងបរិយាយពីវាអាចទទួលបានតាមរយៈការសិក្សាប្រវត្តិសាស្ត្រ ។

ការសិក្សាវិធីសាស្ត្រ ឬល្បិចទាំងអស់នេះ ជារឿងឥតប្រយោជន៍បើអ្នកមិនយកវាទៅអនុវត្ត ។ សំណាងល្អអ្នកនឹងមានឱកាសសាកល្បងប្រើប្រាស់វិធីសាស្ត្រនេះ សម្រាប់ការងារក្រុម របស់អ្នក ។ សម្រាប់ជំហានជាក់ច្បាស់ក្នុងការអាននិងសង្ខេបមេរៀនឬសៀវភៅ ចូរពិគ្រោះជាមួយនឹងផ្នែកបន្ទាប់ និងវិធីសាស្ត្រក្នុងការសង្ខេបមេរៀន នៅមេរៀនទី ១២ ។

## ១០.៣. វិធីសាស្ត្រអានសៀវភៅពុម្ពគោល

កិច្ចការទូទៅសម្រាប់ការសិក្សាប្រវត្តិសាស្ត្រ គឺត្រូវអានសៀវភៅប្រវត្តិសាស្ត្រអោយបានច្រើនតាមតែអាចធ្វើបាន ។ កន្លងមក និស្សិតជាច្រើនរំពឹងនឹងទទួលចំណេះដឹងតែតាមរយៈមេរៀនដែលគ្រូបង្រៀននៅក្នុងថ្នាក់ ហើយព្រងើយកន្តើយមិនស្វះស្វែងរកសៀវភៅអាន ដោយខ្លួនឯងឡើយ ដោយចាំដល់ថ្ងៃប្រលងបញ្ចប់ជិតមកដល់ ទើបពួកគេតតេះតតះរកសៀវភៅអាន ។ ការអានសៀវភៅជារៀងថ្ងៃ រាល់សប្តាហ៍ នឹងជួយអោយអ្នកមានចំណេះដឹងជាមូលដ្ឋានសម្រាប់ស្វែងយល់មេរៀន ដែលគ្រូនឹងបង្រៀន ។ ទម្លាប់ដ៏ល្អនេះក៏អាចផ្តល់ដល់អ្នកនូវចំណេះដឹងបន្ថែមផងដែរ ។ នៅក្នុងវគ្គសិក្សាភាគច្រើន មេរៀនត្រូវបានគេបញ្ចូលបន្ថែមនូវអត្ថបទផ្សេងៗ ហើយគ្រូរបស់អ្នក រំពឹងថាអ្នកមានចំណេះពីវាខ្លះៗដែរ ។ ឧបមាថា អ្នកអង្គុយរៀនពីមេរៀនស្តីពី ទិដ្ឋភាពសេដ្ឋកិច្ចនៃសម័យបដិវត្តន៍អាមេរិក អ្នកអាចនឹងមានការលំបាកឬច្រលំ បើអ្នកមិនបានអានសៀវភៅបន្ថែមស្តីពីទ្រឹស្តីជំនួញ ដែលពួកអាណានិគមន៍តែងតែប្រើនាពេលនោះទេ ។

ដូច្នេះ ចូរអានអត្ថបទដែលទាក់ទងនឹងមេរៀនដែលត្រូវរៀនផង ។ បើអ្នកយល់មិនច្បាស់ចូរអានវាម្តងហើយម្តងទៀត ។ ចូរគូសបន្ទាប់ពីក្រោម ឬគូសពណ៌ចំណាំព័ត៌មានពិតជាក់ច្បាស់បំផុត ។ ចូរគូសបន្ទាត់ពីក្រោមនូវការទាញសន្និដ្ឋានរួម ការបកស្រាយ និងសេចក្តីសន្និដ្ឋាន ។ ជាការពិតណាស់ យើងមិនអាចឬមិនគួរគូសបន្ទាត់ពីក្រោមឃ្លាទាំងអស់នោះទេ ។ បើដូច្នេះ មានន័យថា អ្នកមិនអាចបែងចែកអោយដាច់រវាង គំនិតសំខាន់ដែលអ្នកនិពន្ធចង់បង្ហាញ និងគំនិតឬឃ្លាបន្ទាប់បន្សំ ដែលគាត់ប្រើសម្រាប់តែបញ្ជាក់ឬពន្យល់ ឬគាំទ្រគំនិតសំខាន់ទាំងនោះឡើយ ។ ក្រៅពីគូសបន្ទាត់ពីក្រោម ចូរស្វែងរកផ្នែកឬល្បះដែលអ្នកនិពន្ធនិយាយឬសង្កត់ន័យ ដើម្បីរកអោយឃើញនូវទស្សនៈផ្ទាល់របស់គាត់ ឬចំណុចដែលអ្នកមិនយល់ស្របតាមគំនិតគាត់ ។ សូមសរសេរិះគន់ ឬមតិផ្សេងៗរបស់អ្នក និងសរសេរសេចក្តីសង្ខេបនៃអត្ថបទនៅលើរឹមទំព័រ ។ លំហាត់បែបនេះនឹងជួយអ្នកពេលរម្លឹកមេរៀន មុនពេល

ប្រលងឆមាស ពោលគឺ អ្នកមិនចាំបាច់រម្លឹកអត្ថបទទាំងមូលឡើងវិញឡើយ ដោយគ្រាន់តែអានសេចក្តីសង្ខេបនេះក៏អាចជួយអ្នកចូលប្រលងប្រកបដោយក្តីសង្ឃឹម និងជឿជាក់ផងដែរ ។ ម្យ៉ាងទៀត អ្នកនឹងមានលទ្ធភាពអានសារឡើងវិញនូវឃ្លាសំខាន់ៗ ដែលអ្នកបានគូសបន្ទាប់ពីក្រោម និងការបកស្រាយផ្សេងៗ យ៉ាងរហ័សនិងមានប្រសិទ្ធិភាព ។ និយាយរួម អ្នកអាចយល់ដឹងនិងចងចាំនូវខ្លឹមសាររបស់មេរៀនទាំងមូល ។ ដោយឡែក បើអ្នកនៅតែមិនទាន់យល់ពីខ្លឹមសារមេរៀនទេ សូមចំណាយពេលអានវាឡើងវិញ ប្រសិនបើអ្នកចង់បានពិន្ទុខ្ពស់ជាងគេ ងាយស្រួលដាក់អាហារូបករណ៍សិក្សាបន្តនៅបរទេស ។

## ១០.៤. វិធីសាស្ត្រកត់ចំណាំមេរៀន នៅក្នុងថ្នាក់

ការសិក្សាទទួលបានជោគជ័យត្រូវអាស្រ័យលើកត្តាជាច្រើនផ្សំគ្នា ក្នុងនោះការកត់ត្រាក្នុងថ្នាក់រៀនក៏សំខាន់ណាស់ដែរ ។ ខាងក្រោមនេះ គឺជាគោលការណ៍គម្រូសម្រាប់កត់ចំណាំមេរៀន៖

១. ចូររៀបចំមេរៀនដែលត្រូវរៀនជាមុន តាមរយៈការអានឯកសារពាក់ព័ន្ធទាំងអស់ ។
២. សរសេរព័ត៌មាននៃវគ្គសិក្សា ចំណងជើងមេរៀន កាលបរិច្ឆេទ នៅខាងលើនៃទំព័រ។
៣. ចូរចេះជ្រើសរើស៖ កុំព្យាយាមចម្លងអ្វីៗទាំងអស់ដែលគ្រូនិយាយ ដោយកត់តែចំណុចសំខាន់ៗ ។
៤. ចូរប្រាកដក្នុងចិត្តថា អ្នកចំលងអ្វីៗដែលគ្រូ សរសេរលើក្តារខៀន និយាយថាវាសំខាន់ និងសង្កត់ន័យដោយពន្យល់វាម្តងហើយម្តងទៀត ។
៥. ចូរទុកចន្លោះទំនេររវាងបន្ទាត់នីមួយៗ ក្នុងសៀវភៅកំណត់ត្រារបស់អ្នក ក្នុងករណីចាំបាច់ សរសេរបន្ថែមពេលក្រោយ ។
៦. ចូរអានកំណត់ត្រារបស់អ្នកឡើងវិញ ក្រោយពេលចប់មេរៀននីមួយៗ ។
៧. ចូរគូសពណ៌ចំណាំ ឬគូសបន្ទាត់ពីក្រោមចំណុចសំខាន់ៗ ។
៨. ពិនិត្យមើលអត្ថន័យពាក្យដែលអ្នកមិនដឹងច្បាស់ ។
៩. ក្នុងករណី កំណត់ត្រារបស់អ្នកមានភាពរញ៉េរញ៉ៃ ឬគ្មានសណ្តាប់ធ្នាប់ ចូរសរសេរវាឡើងវិញអោយមានរបៀបរៀបរយ ។
១០. ប្រសិនបើចំណុចសំខាន់ណាមួយក្នុងសៀវភៅកត់ត្រារបស់អ្នក មានភាពស្រពិចស្រពិល ចូរសួរគ្រូរបស់អ្នកអោយគាត់ពន្យល់ឡើងវិញ ។

# មេរៀនទី ១១ ៖ ការចង់ដឹងនៃមនុស្ស និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ[១៤]

មនុស្សគ្រប់រូប ខិតខំប្រឹងប្រែងនិងព្យាករណ៍ពីតថភាព ឬ ស្វែងរកសច្ចៈភាព ក្នុងសង្គមខ្លួនរស់នៅនិងនៅក្នុង ពិភពលោកទាំងមូល មិនថា អតីតកាល បច្ចុប្បន្នកាល ឬអនាគតឡើង។ ការស៊ើបអង្កេតបែបវិទ្យាសាស្ត្រ និងការស្រាវជ្រាវសង្គម ត្រូវបានធ្វើឡើង ជាពិសេស ដើម្បីចៀសផុតពីគ្រោះថ្នាក់នៃការស៊ើបអង្កេតមិនគ្រប់ជ្រុងជ្រោយរបស់សាធារណជនទូទៅ។

ជាចំបង មេរៀននេះ ពិភាក្សាអំពីការដឹងអ្វីៗគ្រប់យ៉ាង ពោលគឺ តើយើងដឹងរឿងទាំងនោះ ដោយរបៀបណា ។ យើងនឹងចាប់ផ្តើមដោយពិនិត្យមើលរឿងមួយចំនួន ដែលអ្នកប្រហែលជាដឹងរួចមកហើយ។

អ្នកដឹងថាហើយថា ពិភពលោកមានសណ្ឋានរាងមូល ។ អ្នកប្រហែលជាដឹងដែរថា ព្រះច័ន្ទចាប់ផ្តើមត្រជាក់នៅផ្នែកងងឹត (ផ្នែកដែលមិនត្រូវពន្លឺព្រះអាទិត្យ) ហើយអ្នកដឹងថាមនុស្សនិយាយភាសាជប៉ុននៅក្នុងប្រទេសជប៉ុន។ អ្នកក៏ដឹងដែរថា វីតាមីនសេអាចជួយការពារជំងឺផ្តាសាយ ហើយការរួមភេទដែលមិនបានប្រើស្រោមអនាម័យ អាចបណ្តាលឱ្យកើតជំងឺអេដស៍។

តើអ្នកដឹង*ដោយរបៀបណា*? ប្រសិនបើអ្នកគិតមួយនាទីអ្នកនឹងឃើញអ្នកដឹងពីរឿងទាំងនេះ ព្រោះមាននរណាម្នាក់ប្រាប់អ្នក ហើយអ្នកជឿតាមពួកគេ។ អ្នកប្រហែលជាបានអានខ្លឹមសារ នៅក្នុងទស្សនាវដ្តី National Geographic ដែលមនុស្សនិយាយភាសាជប៉ុន នៅប្រទេសជប៉ុន ហើយស្តាប់ទៅវាសមហេតុសមផលសម្រាប់អ្នក ដូច្នេះអ្នកក៏មិនបានសាកសួរជជីកបន្តទៀត ។ ប្រហែលជាគ្រូរូបវិទ្យា ឬ តារាសាស្ត្ររបស់អ្នកបានប្រាប់អ្នកថា ផ្នែកម្ខាងទៀតនៃព្រះច័ន្ទ ដែលមិនត្រូវពន្លឺថ្ងៃ មានសីតុណ្ហភាពត្រជាក់ខ្លាំង ឬបើមិនអញ្ចឹងទេ ប្រហែលជាអ្នកបានលឺវាពីកម្មវិធីព័ត៌មានលើកញ្ចក់ទូរទស្សន៍។

រឿងដែលអ្នកដឹងមួយចំនួន មើលច្បាស់ក្រឡែត សម្រាប់អ្នក។ ប្រសិនបើខ្ញុំសួរអ្នកថាតើអ្នកដឹងថាពិភពលោក មានរាងមូល ដោយរបៀបណា អ្នកប្រាកដជានិយាយថា «នរណាក៏ដឹងថាវាមូលដែរ» ។ មានរឿងជាច្រើន ដែលមនុស្សគ្រប់គ្នាដឹង។ ជាការពិត នៅពេលណាមួយ ក្នុងសម័យបុរាណ អ្នករាល់គ្នា «ដឹង» ថាពិភពលោកមានសណ្ឋានរាបស្មើ ។

អ្វីដែលអ្នកដឹង ភាគច្រើន គឺជាបញ្ហានៃការ ព្រមព្រៀង និងជំនឿ។ ភាគតិចណាស់ ដែលអ្នកបានដឹងដោយសារឆ្លងកាត់បទពិសោធន៍ និងដោយសារ របកគំឃើញផ្ទាល់ខ្លួន ។ ការពិតទៅ នៅពេលអ្នកធំពេញវ័យនៅក្នុងសង្គមណាមួយ បន្តិចម្តងៗ អ្នករៀនទទួលយក អ្វីដែលមនុស្សគ្រប់គ្នានៅជុំវិញអ្នក «ដឹង» និងបើកចិត្តទទួលថាវាពិតជាដូច្នេះមែន ។ ប្រសិនបើអ្នកមិនដឹងរឿងទាំងនោះ អ្នកពិតជាមិនអាចក្លាយជាសមាជិកក្នុងសង្គមអ្នកបានទេ។ ប្រសិនបើអ្នកត្រូវចោទសួរ មែនទែនថា ពិភពលោកនេះពិតជាមូលមែននោះអ្នកនឹងក្លាយជាមនុស្សខុសគេក្នុងសង្គម របៀបថា មួយស្រុកមានតែមួយ។ អ្នកអាចត្រូវបានគេបញ្ជូនឱ្យទៅរស់នៅក្នុងមន្ទីរពេទ្យជាមួយអ្នកផ្សេងទៀតដែលសួរសំណួរដូចនេះ។

---

[១៤] (Babbie, ២០២០)

ដូច្នេះ អ្វីដែលអ្នកដឹងភាគច្រើន គឺជាបញ្ហានៃការជឿលើអ្វីដែលគេបានប្រាប់មកអ្នក។ ត្រូវយល់ថាមិនមានអ្វីខុសទាស់ក្នុងរឿងនេះទេ ។ នោះគឺជារបៀបដែលរចនាសម្ព័ន្ធនៃសង្គមមនុស្សត្រូវបានរៀបចំឡើង។ មូលដ្ឋានគ្រឹះនៃចំណេះដឹង គឺកិច្ចព្រមព្រៀងមួយ។ ដោយសារតែអ្នកមិនអាចរៀនអ្វីទាំងអស់ ដែលអ្នកត្រូវដឹងតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន និងរបកគំហើញដោយខ្លួនឯង អ្វីៗត្រូវបានបង្កើតឡើងស្រាប់ មានស្រាប់ ដូច្នេះអ្នកអាចនឹងព្រមជឿលើអ្វីដែលអ្នកដទៃប្រាប់អ្នក។ អ្នកដឹងពីរឿងខ្លះតាមរយៈប្រពៃណីនិងអ្វីៗផ្សេងទៀតពី«អ្នកជំនាញ»។ មិនមែនថា អ្នកមិនគួរសាកសួរអំពី ចំណេះដឹងដែលអ្នកបានទទួលបែបនេះទេ ប៉ុន្តែគ្រាន់តែចង់អោយអ្នកចាប់អារម្មណ៍ចំពោះរបៀប ដែលអ្នកនិងសង្គម តាមធម្មតា មានភាពចុះសម្រុងនឹងគ្នា ក្នុងការទទួលបាននូវអ្វីដែលជាចំណេះដឹងបែបណាមួយ ។

ទោះយ៉ាងណាក៏ដោយ មានវិធីជាច្រើនផ្សេងទៀត ដើម្បីដឹងរឿងអ្វីមួយ។ ផ្ទុយពីការដឹងរឿងតាមរយៈការព្រមព្រៀង អ្នកអាចស្គាល់វាតាមរយៈបទពិសោធន៍ផ្ទាល់៖ តាមរយៈការសង្កេត ។ ប្រសិនបើអ្នកជ្រមុជចូលទៅក្នុងផ្ទាំងទឹកកកនៅតំបន់ប៉ូល អ្នកមិនត្រូវការនរណាម្នាក់ប្រាប់អ្នកថា វាត្រជាក់នោះទេ។

ទោះបីជាបទពិសោធន៍របស់អ្នកផ្ទុយពីអ្វី ដែលអ្នកផ្សេងដឹងក៏ដោយ អាចមានឱកាស ឬភាគរយខ្ពស់ដែលអ្នកនឹងបោះបង់ចោលបទពិសោធន៍ផ្ទាល់ខ្លួន ហើយយល់ព្រមឬសុខចិត្ត ជឿអ្វីដែលអ្នកផ្សេងដឹង ។ ជាឧទាហរណ៍ស្រមៃថា អ្នកមកចូលរួមពិធីជប់លៀងនៅផ្ទះខ្ញុំ។ វាជាពិធីដ៏ឱឡារិកហើយភេសជ្ជៈនិងអាហារ ពិតជាមានឱជារសឈ្ងុយឆ្ងាញ់ ជាទីគាប់ចិត្ត ។ ជាពិសេសអ្នក បានចាប់ជក់ចិត្តជាមួយនឹងអាហារសម្រន់មួយមុខដែលខ្ញុំយកមកដាក់លើថាស ដើរបម្រើភ្ញៀវផ្ទាល់ដៃ ៖ ដុំនំបំពង ដ៏មានឱជារស ឈ្ងុយឆ្ងាញ់ ។ អ្នកបានញ៉ាំពីរបីដុំ ហើយលាន់មាត់ថាឆ្ងាញ់ខ្លាំងណាស់ ហើយអ្នកក៏ញ៉ាំថែមទៀត។ មិនយូរប៉ុន្មាន អ្នកដើរចុះដើរឡើង ក្រវល់តាមថាសនំដែលខ្ញុំកាន់ចុះឡើង ជុំវិញបន្ទប់។

ទីបំផុត អ្នកអាចទប់ចិត្តលែងជាប់ ហើយក៏សួរថា «ហើយអាហ្នឹងនំអីគេ?» ខ្ញុំក៏ទម្លាយអាថ៌កំបាំង៖ «អ្វីដែលអ្នកបានញ៉ាំនោះ គឺ នំដង្កូវបំពង »។ អ្នកនៅស្ងៀមទ្រឹង ក្រពះកូរគ្រូកៗ ប្រាលឡើង ហើយ ភ្លាមនោះ អ្នកក៏ក្អួតពេញកំរាលព្រំ ក្នុងបន្ទប់ទទួលភ្ញៀវ។ អាហារជប់លៀងស្អីគេ ក៏គួរឱ្យខ្ពើមម្លេះ

ចំនុចសំខាន់នៃសាច់រឿងនេះ គឺថា អារម្មណ៍របស់អ្នក ចំពោះអាហារសម្រន់ ទាំងពីរលើកគឺជាអារម្មណ៍ពិតរបស់អ្នក ។ ដំបូង អ្នកពិតជាបានចូលចិត្តវាមែន ប៉ុន្តែក៏ជាអារម្មណ៍ពិតផងដែរនៅពេលអ្នកដឹងថាអ្នកកំពុងញ៉ាំអ្វី។ ទោះយ៉ាងណាក៏ដោយច្បាស់ ដែលថា អារម្មណ៍ស្អប់ខ្ពើមរបស់អ្នកគឺជា ផលិតផលនៃកិច្ចព្រមព្រៀងដែលអ្នកបានព្រមព្រៀងជាមួយអ្នកនៅជុំវិញអ្នក ៖ មិនសមនឹងស៊ីដង្កូវទេ ។ នោះគឺជាកិច្ចព្រមព្រៀងមួយដែលអ្នកបានចាប់ផ្តើមជាលើកដំបូងដែល ឪពុកម្តាយរបស់អ្នក ឃើញអ្នកកំពុងអង្គុយនៅក្នុងពំនូកដីខ្វក់ ហើយមានដង្កូវរើបម្រាស់ចេញពីបបូរមាត់របស់អ្នក។ នៅពេលដែលពួកគេចាប់ទាញដង្កូវចេញពីមាត់អ្នក អ្នកបានចាប់ផ្តើមដឹងថាដង្កូវមិនមែនជាអាហារញ៉ាំ នៅក្នុងសង្គមយើងទេ។

ក្រៅពីកិច្ចព្រមព្រៀងទាំងនេះ តើញ៉ាំដង្កូវមានអីខុស? តាមពិត ដង្កូវមានប្រូតេអ៊ីនខ្ពស់និងកាឡូរីទាប។ ទំហំតូចល្មមខាំញ៉ាំ និងងាយស្រួលវេចខ្ចប់ សម្រាប់អ្នកវេចខ្ចប់យកទៅចែកចាយ។ ពួកគេក៏ជាអាហារឆ្ងាញ់សម្រាប់មនុស្សមួយចំនួន ដែលរស់នៅក្នុងសង្គមផ្សេង ដែល ខ្វះការព្រមព្រៀងដូចសង្គមយើង ដែលថា ដង្កូវគួរខ្ពើមរអើម។ មនុស្សខ្លះអាចចូលចិត្តដង្កូវ ប៉ុន្តែត្រូវបានបិទដោយម្សៅនំប៉ុង ហើយយកវាទៅបំពងសិន។

នេះគឺជាសំណួរដែលត្រូវពិចារណា៖ «តើដង្កូវពិតជាងអាហារល្អ ឬអាក្រក់?» ហើយនេះគឺជាសំណួរដែលគួរឱ្យចាប់អារម្មណ៍ជាង៖ «តើអ្នកដឹងថាវាពិតជាដូច្នេះយ៉ាងដូចម្តេច?» មេរៀននេះព្យាយាមពិភាក្សា សំណួរទីពីរ។

គោលបំណងនៃមេរៀននេះដើម្បីជួយអ្នកអានអោយ ចេះកំណត់វិធីសាស្ត្រនានាដែលមនុស្សលោកសម្រេចចិត្តជឿថាអ្វីជាការពិត, អាចពន្យល់ពីលក្ខណៈជាមូលដ្ឋាននៃវិទ្យាសាស្ត្រសង្គមនិងស្វែងយល់ពីជម្រើសជាមូលដ្ឋានសម្រាប់ស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ។

## ១១.១. ប្រភពចំណេះដឹង

ការពិត គឺជាប្រស្នា ដែលលាក់កំនួចជាច្រើន។ អ្នកប្រហែលជាសង្ស័យជាយូរមកហើយថារឿងខ្លះដែលអ្នក«ដឹង» អាចមិនពិត ប៉ុន្តែតើអ្នកអាចដឹងថាអ្វីជាការពិតដោយរបៀបណា? ចំពោះ ប្រស្នានេះ មនុស្សជាច្រើនបានឈ្លោះប្រកែកគ្នា អស់រាប់ពាន់ឆ្នាំមកហើយ។

រាល់ការស្រាវជ្រាវទាំងអស់ ជាប់ពាក់ព័ន្ធនឹងដំណើរការប្រមូលព័ត៌មាន។ ដើម្បីអោយព័ត៌មានទាំងនោះក្លាយជាចំណេះដឹងយើងត្រូវតែធ្វើតេស្តសាកល្បងវា ដើម្បីដឹងថាវាពិតឬ មិនពិត។ ប៉ុន្តែ សច្ចៈភាពច្រើនត្រូវបានគេព្រមទទួលជឿ ដោយមិនបានធ្វើតេស្តថាវាពិតឬមិនពិតឡើយ។

### ក. ចំណេះដឹងបានពីប្រពៃណី

យើងគ្រប់គ្នាទទួលមរតកវប្បធម៌ ដែលបានកកើតឡើងនិងព្រមទទួលយកយ៉ាងរឹងមាំនូវចំណេះដឹងអំពីពិភពលោក និងគុណតម្លៃដែលទាក់ទាញការចូលរួមរបស់យើងនៅក្នុងវប្បធម៌នោះ ។ យើងប្រហែលជាដឹងពីអ្នកដទៃថា ការញ៉ាំស្ករគ្រាប់ច្រើនពេកនឹងធ្វើឱ្យធ្មេញយើងពុកផុយ...ឬក៏ការសម្រេចកាមដោយខ្លួនឯងនឹងធ្វើឱ្យអ្នកខ្វាក់ភ្នែក។ គំនិតអំពីយេនឌ័រ ពូជសាសន៍ សាសនានិងប្រទេសផ្សេងៗគ្នាដែលអ្នកបានដឹងបន្តិចម្តងៗនៅពេលអ្នកធំឡើង គឺចូលក្នុងចំណេះដឹងប្រភេទនេះ ។ យើងអាចធ្វើតេស្តដើម្បីបញ្ជាក់ពី«ការពិត»ទាំងនេះ ដោយខ្លួនឯងប៉ុន្តែ តាមធម្មតា យើង ទទួលយកភាគច្រើននៃការពិត ដែល «មនុស្សគ្រប់គ្នាដឹង» ។

ប្រពៃណី នៅក្នុងន័យនេះ ផ្តល់នូវគុណសម្បត្តិមួយចំនួន ចំពោះការស៊ើបអង្កេតរបស់មនុស្ស។ តាមរយៈការទទួលយកអ្វីដែលមនុស្សគ្រប់គ្នាដឹង យើងមិនចាំបាច់ធ្វើកិច្ចការដ៏លើសលប់ ក្នុងការចាប់ផ្តើមពីដៃទទេ ក្នុងការស្វែងរកភាពទៀងទាត់ និងបំពេញការយល់ដឹងរបស់យើង។ ចំណេះដឹងគឺជាការប្រមូលផ្តុំ ផ្សំបន្តិចម្តងៗ ហើយឃ្លាំងមរតកនៃចំណេះដឹង គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ បន្ថែមទៀត។ ជារឿយៗយើងនិយាយអំពី «ឈរនៅលើស្មារបស់យក្ស» ពោលគឺចាប់ផ្តើមពីមូលដ្ឋានចំណេះដឹងរបស់មនុស្សជំនាន់មុនៗ។

ក្នុងពេលជាមួយគ្នានេះ ទំនៀមទម្លាប់ឬប្រពៃណី អាចមានផលប៉ះពាល់ដល់ការស៊ើបអង្កេតស្វែងរកការពិត របស់មនុស្ស។ ប្រសិនបើយើងស្វែងរកអ្វីដែលថ្មីដែលមនុស្សគ្រប់គ្នាយល់ហើយតែងតែយល់ ជាយូរណាស់មកហើយ យើងអាចត្រូវគេសម្គាល់ថាជាមនុស្សល្ងីល្ងើ ចំពោះការខិតខំរបស់យើង។ ទោះយ៉ាងណាក៏ដោយ អ្វីដែលសំខាន់យើងភាគច្រើនកម្រគិតអំពីការស្វែងរកការយល់ដឹងផ្សេងអំពីអ្វីដែលយើងទាំងអស់គ្នា«ដឹង»ថា ជាការពិតរួចស្រេចទៅហើយ។

ជារួម ចំណេះដឹងប្រភេទនេះផ្អែកទៅលើ ប្រពៃណី ទំនៀមទម្លាប់ ដែលមាននៅក្នុងជំនឿលើគតិបណ្ឌិតពីសម័យមុន ឬជឿតាមគំនិតជីដូនជីតាមុនៗ ។ នេះបានន័យថានរណាៗក៏ដឹងពីវាដែរ មិនចាំបាច់មន្ទិលសង្ស័យថាវាមិនពិតនោះទេ ។ តើអ្នកនឹងស្វែងរករូបភាពផ្សេងទៀតនៃសច្ចៈភាព ដែលត្រូវបានគេទទួលជឿជាយូរមកហើយនោះ ។ ឧទាហរណ៍ កាលដើមឡើយគេជឿថាផែនដីរាបស្មើ នរណាៗក៏យល់ស្របដែរថា វាពិតជាមានរាងសំប៉ែតដូចដែលដូនតារបស់ពួកគេធ្លាប់ជឿពីមុនមក ។ ប្រសិនបើជាអ្នកស្ថិតនៅសម័យកាលនោះ តើអ្នកអាចជឿថាផែនដីមានរាងមូលដូចដែលអ្នកប្រាជ្ញផ្សេងបានអះអាងដែរឬទេ ?

## ខ. អាជ្ញាព្រឹត្តិ

ថ្វីបើចំណេះដឹងបែបប្រពៃណីមានឥទ្ធិពលយ៉ាងណាក៏ដោយ មានចំណេះដឹងថ្មីៗ លេចឡើងជារៀងរាល់ថ្ងៃ។ ក្រៅពីការស្វែងរកចំណេះដឹងដោយអង្កេតផ្ទាល់ខ្លួន ក្នុងមួយជីវិតយើងទទួលបានអត្ថប្រយោជន៍ពីការរកឃើញថ្មីនិងចំណេះដឹងដែលបង្កើតដោយអ្នកដទៃ។ ជារឿយៗការទទួលយកចំណេះដឹងថ្មីទាំងនេះ អាស្រ័យលើស្ថានភាពរបស់អ្នករកឃើញ។ អ្នកទំនងជាជឿលើអ្នកជំនាញខាងពេគរាគត្បាតដែលប្រកាសថាជំងឺផ្តាសាយធម្មតាអាចឆ្លងតាមរយៈការថើប ជាជាងជឿពូ សំ របស់អ្នកនិយាយរឿងដូចគ្នា។

ដូចប្រពៃណីដែរ អាជ្ញាធរអាចជួយជម្រុញ ក៏ដូចជារារាំងការអង្កេតរកចំណេះដឹងរបស់មនុស្ស។ ជារឿងល្អដែលយើង ជឿជាក់លើការវិនិច្ឆ័យរបស់បុគ្គលដែលមានការបណ្តុះបណ្តាលពិសេស, ជំនាញនិងកេរ្តិ៍ឈ្មោះល្អ នៅក្នុងបញ្ហាណាមួយ ជាពិសេសនៅក្នុងករណីប្រឈមមុខនឹងភាពចម្រូងចម្រាស។ ទន្ទឹមនឹងនេះការស៊ើបអង្កេតអាចត្រូវបានរារាំងយ៉ាងខ្លាំង ដោយអាជ្ញាធរស្របច្បាប់ ដែលធ្វើខុស នៅក្នុងដែនដីពិសេស ឬតំបន់របស់ខ្លួន។ យ៉ាងណាមិញ ជីវវិទូក៏អាចនឹងប្រព្រឹត្តខុសឆ្គង ក្នុងផ្នែកជីវវិទ្យាផងដែរ។

ការស៊ើបអង្កេតរកការពិតឬចំណេះដឹង ក៏អាចត្រូវបានរាំងផងដែរ នៅពេលដែលយើងពឹងផ្អែកលើអាជ្ញាធរឬអ្នកជំនាញណាមួយ ដែលនិយាយនៅខាងក្រៅវិស័យជំនាញរបស់ពួកគេ។ ជាឧទាហរណ៍ចូរពិចារណាមេដឹកនាំនយោបាយ ឬសាសនា ដោយគ្មានជំនាញជីវគីមី ដែលប្រកាសថា កញ្ឆាបង្កថ្នាំគ្រោះថ្នាក់។ ឧស្សាហកម្មផ្សាយពាណិជ្ជកម្ម ដើរតួយ៉ាងសំខាន់លើការប្រើសិទ្ធិអំណាចមិនត្រឹមត្រូវ តួយ៉ាងមានអត្តពលិកល្បីល្បាញ ពិភាក្សាអំពីគុណតម្លៃអាហារូបត្ថម្ភនៃអាហារពេលព្រឹក ឬ តួសម្តែងភាពយន្តវាយតម្លៃពីប្រសិទ្ធភាពថេយន្តជាដើម។

សរុបមកវិញ ចំណេះដឹងប្រភេទនេះ មានប្រភពចេញពីមនុស្សណាម្នាក់គួរជាទីគោរពនៃមនុស្សទាំងពួង ឬកើតចេញពីប្រភពដែលមានអំណាច ។ ថាតើយើងទទួលជឿ ឬទទួលយកចំណេះដែលបានរកឃើញដោយនរណាម្នាក់ វាដោយអាស្រ័យលើតួនាទី ឋានៈ និងអំណាចរបស់ពួកគេ ។ វាហាក់ដូចជាថា ការអះអាង របស់អ្នកមានតួនាទីធំឬអំណាចខ្ពស់ឬមានបទពិសោធន៍ច្រើនត្រូវបានគេទទួលយកភាគច្រើនបំផុត ។

ដូច្នេះ ប្រពៃណីនិងសិទ្ធិអំណាចអាជ្ញាព្រឹត្ត គឺជាអាវុធមុខពីរក្នុងដំណើរការស្វែងរកចំណេះដឹងអំពីពិភពលោក។ និយាយដោយសាមញ្ញពួកគេផ្តល់ឱ្យយើងនូវចំណុចចាប់ផ្តើមសម្រាប់ការស៊ើបអង្កេតផ្ទាល់របស់យើង ប៉ុន្តែពួកគេអាចនាំយើងឱ្យចាប់ផ្តើមនៅចំណុចខុស ហើយអាចរុញយើងចេញក្នុងទិសដៅខុស។

### គ. ចំណេះដឹងបានពីបទពិសោធន៍

ចំណេះដឹងប្រភេទនេះមានប្រភពចេញពីការឃើញផ្ទាល់ភ្នែកឬមានពិសោធន៍ផ្ទាល់ខ្លួន ។ អ្នកត្រូវប្រយ័ត្ន ចំណេះដឹងប្រភេទនេះ អាចត្រូវតែក្នុងករណីណាពិសេសមួយប៉ុណ្ណោះ ។ អ្នកពិបាកទាញសេចក្តីសន្និដ្ឋានរួមណាស់ ។

### ឃ. អព្ភន្តរញ្ញាណ

ចំណេះដឹងប្រភេទនេះ មានប្រភពចេញពីការយល់ឃើញ ឬ យល់ដឹងលើអ្វីមួយភ្លាមៗ ដោយមិនមានការត្រិះរិះពិចារណារកហេតុផលឡើយ ។

### ង. សនិទាននិយម-តក្កវិទ្យា

ចំណេះដឹងប្រភេទនេះ មានប្រភពចេញពីការត្រិះរិះពិចារណាតែម្យ៉ាងគត់ ដើម្បីបំលែងអោយអ្វីមួយក្លាយជាចំណេះដឹង ។ ប្រសិនបើការសន្មត់ឬការសំអាងណាមួយ ហាក់ដូចជាទំនង ហើយក្រោយពេលត្រិះរិះរកហេតុផលយ៉ាងត្រឹមត្រូវ តាមច្បាប់តក្កវិទ្យា នោះគេនឹងមានការសន្និដ្ឋានពីសច្ចៈភាពតែម្តង ។

### ច. វិទ្យាសាស្ត្រ

ប្រភពមួយដែលកើតចេញពីការជជែកជីកឬសជីកគល់ គឺវិទ្យាសាស្ត្រដែលផ្តល់គោលការណ៍សម្រាប់ ការពិតចេញពីកិច្ចព្រមព្រៀង និងការពិតចេញពីការពិសោធន៍។ អ្នកវិទ្យាសាស្ត្រកំណត់លក្ខណៈវិនិច្ឆ័យជាក់លាក់ដែលត្រូវតែឆ្លើយតប មុននឹងពួកគេព្រមទទួលយកការពិត អំពីអ្វីមួយដែលពួកគេមិនធ្លាប់បានជួបប្រទះដោយផ្ទាល់។ ជាទូទៅ ការអះអាងមួយត្រូវតែមានការគាំទ្រដោយ ទាំងឡូហ្សិក (logical) និងទាំងភស្តុតាងជាក់ស្តែង (empirical) ៖ វាត្រូវតែសមហេតុផល ហើយវាមិនត្រូវផ្ទុយពីការសង្កេតជាក់ស្តែងឡើយ។ តើហេតុអ្វីបានជាអ្នកវិទ្យាសាស្ត្រនៅលើភពផែនដី ទទួលយកការអះអាងថា នៅលើភពព្រះច័ន្ទ អាកាសធាតុ ត្រជាក់ នៅផ្នែកងងឹត (ឆ្ងាយពីព្រះអាទិត្យ)? ទីមួយ វាសមហេតុផលពីព្រោះកំដៅបរិយាកាសព្រះច័ន្ទកើតចេញពីកាំរស្មីព្រះអាទិត្យ។ ទីពីរការវាស់វែងសីតុណ្ហភាពបែបវិទ្យាសាស្ត្រ ដែលធ្វើឡើងនៅផ្នែកងងឹតនៃព្រះច័ន្ទពិតជាបានបញ្ជាក់ពីការរំពឹងទុកខាងលើមែន។ ដូច្នេះ អ្នកវិទ្យាសាស្ត្រទទួលយកការពិតនៃរឿងអ្វីមួយ ដែលពួកគេមិនជួបផ្ទាល់៖ ពួកគេទទួលយកការពិតតាមបែបកិច្ចព្រមព្រៀងប៉ុន្តែពួកគេមានស្តង់ដារពិសេសដើម្បីបញ្ជាក់ការពិតនោះ។

ទោះយ៉ាងណាក៏ដោយអ្វីដែលសំខាន់នៅក្នុងមេរៀននេះ វិទ្យាសាស្ត្រផ្តល់នូវវិធីសាស្ត្រពិសេសមួយសម្រាប់រកសច្ចៈភាព តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន ពោល គឺ ជាធ្វើការស៊ើបអង្កេត។ ពុទ្ធិវិទ្យា (Epistemology) គឺជាវិទ្យាសាស្ត្រនៃការដឹង, វិធីសាស្ត្រ (សាខាមួយ នៃ ពុទ្ធិវិទ្យា) អាចត្រូវបានគេហៅថាវិទ្យាសាស្ត្រនៃការស្វែងរក។ មេរៀននេះ ពិនិត្យនិងបង្ហាញអំពីវិធីសាស្ត្ររបស់វិទ្យាសាស្ត្រសង្គមឬរបៀបដែលអ្នកវិទ្យាសាស្ត្រសង្គមស្វែងយល់អំពីជីវិតសង្គមរបស់មនុស្ស។ អ្នកនឹងឃើញថាវិធីសាស្ត្រមួយចំនួនត្រូវគ្នានឹងគោលការណ៍វិទ្យាសាស្ត្រប្រពៃណី ប៉ុន្តែវិធីខ្លះទៀតត្រូវបានផ្តោតជាពិសេសទៅលើចំណាប់អារម្មណ៍អំពីសង្គមវិទ្យា។

ចំណេះដឹងប្រភេទនេះ មានប្រភពចេញពីការសង្កេតដោយចងជាប្រព័ន្ធឬជាក្បួនត្រឹមត្រូវ ហើយមានលក្ខណៈពិសេសដូចតទៅ ៖

ក. សំអាងលើបទពិសោធន៍ពិត ( Empirical )

ខ. ជាប្រព័ន្ធដោយឥតលំអៀង ( Systematic )

គ. អាចបង្កើតបានជាសកល ( Replication )

ឃ. ស្វែងរកនូវមូលហេតុ ( Search for causes )

ង. ជាបណ្តោះអាសន្ន ( provisional )

ច. មិនលំអៀង ( Objective )

## ១១.២. កំហុសឆ្គងក្នុងដំណើរការចង់ដឹងរបស់មនុស្ស

ក្រៅពីគ្រោះថ្នាក់ដែលអាចកើតមាន ដោយសារប្រពៃណីនិងសិទ្ធិអំណាច យើងតែងតែជំពប់ដើងហើយដួលនៅពេលយើងចាប់ផ្តើមបេសកកម្មចេញរៀនដោយខ្លួនឯង។ សាកក្រឡេកមើលកំហុសឆ្គងទូទៅមួយចំនួនដែលយើងអាចនឹងបង្កឡើង នៅក្នុងការស៊ើបអង្កេតធម្មតារបស់យើងនិងវិធីដែលវិទ្យាសាស្ត្រការពារកុំអោយមានកំហុសទាំងនោះ។

នៅក្នុងដំណើរការស្វែងរកអ្វីមួយ យើងតែងតែបង្កើតមានកំហុស ដូចខាងក្រោម ៖

ក. ការសង្កេតខុស ( Inaccurate Observation )

ជាញឹកញាប់ យើងអាចប្រព្រឹត្តិខុសក្នុងការសង្កេតរបស់យើង។ ឧទាហរណ៍តើគ្រូបង្រៀនទ្រឹស្តីប្រវត្តិសាស្ត្ររបស់អ្នកស្លៀកពាក់អ្វីមកថ្នាក់រៀន នៅថ្ងៃដំបូង? ប្រសិនបើអ្នកត្រូវទាយនោះ គឺដោយសារតែការសង្កេតប្រចាំថ្ងៃរបស់យើង ភាគច្រើន ប្រព្រឹត្តទៅធម្មតាៗ និងមិនមានអ្វីពិសេសកើតឡើង។ នោះហើយជាមូលហេតុដែលយើងជារឿយៗមិនយល់ស្របអំពី «អ្វីដែលបានកើតឡើងពិតប្រាកដ» ។

ផ្ទុយពីការស៊ើបអង្កេតធម្មតាៗរបស់មនុស្សទូទៅ ការសង្កេតវិទ្យាសាស្ត្រ គឺជាសកម្មភាពដឹងខ្លួន ប្រុងប្រៀបជាមុន ។ គ្រាន់តែធ្វើឱ្យការសង្កេតមើល ដោយចេតនា ហ្មតចត អាចកាត់បន្ថយកំហុស។ ប្រសិនបើអ្នកត្រូវទាយថាគ្រូបង្រៀនរបស់អ្នកស្លៀកពាក់អ្វីមកថ្នាក់រៀន នៅថ្ងៃដំបូង អ្នកប្រហែលជាមានកំហុស។ ប្រសិនបើអ្នកបានទៅចូលរៀនថ្នាក់ដំបូង ដោយមានផែនការដឹងមុនត្រៀមសង្កេតនិងកត់ត្រានូវអ្វីដែលគ្រូបង្រៀនរបស់អ្នកពាក់នោះអ្នកទំនងជាមានភាពត្រឹមត្រូវជាង។ (អ្នកក៏ប្រហែលជាត្រូវការផងដែរនោះគឺចំណង់ចំណូលចិត្ត។ )

ក្នុងករណីជាច្រើន ទាំងឧបករណ៍វាស់ស្ទង់សាមញ្ញៗនិងពិសេស ជួយការពារកុំអោយមានការសង្កេតមិនត្រឹមត្រូវ។ លើសពីនេះទៅទៀតពួកគេបន្ថែមកម្រិតជាក់លាក់មួយបានយ៉ាងល្អលើសពីសមត្ថភាពរបស់មនុស្សដែលគ្មានជំនួយ។ ឧបមាថា អ្នកបានថតរូបពណ៌របស់គ្រូរបស់អ្នកនៅថ្ងៃដំបូងនោះ។ (សូមមើលឃ្លាខាងលើអំពីការត្រូវការចំណង់ចំណូលចិត្ត។ )

ខ. ការទាញសន្និដ្ឋានហួស ( Overgeneralization )

នៅពេលយើងរកមើលទម្រង់ ឬគំរូក្នុងចំណោមវត្ថុអ្វីមួយ ដែលយើងសង្កេតឃើញ នៅជុំវិញខ្លួនយើង យើងតែងតែសន្មត់ថា ព្រឹត្តិការណ៍ស្រដៀងគ្នាពីរបី គឺជាភស្តុតាងនៃគំរូទូទៅ។ នោះគឺយើងមានទំនោរចង់ធ្វើឱ្យមានលក្ខណៈទូទៅ ឬទូទៅនីយកម្មហួសពេក ដោយផ្អែកលើការសង្កេតមានកំណត់របស់យើង។ នេះអាចនាំផ្លូវខុស ឬរារាំងការស៊ើបអង្កេតរកសច្ចៈភាពពិតប្រាកដ។

សាកស្រមៃថា អ្នកជាអ្នកយកព័ត៌មានរាយការណ៍អំពីការធ្វើបាតុកម្មការពារសិទ្ធិរបស់សត្វ។ អ្នកមានពេលតែពីរម៉ោង ដើម្បីសរសេររឿងដើម្បីរាយការណ៍។ ដោយប្រញាប់ទៅកន្លែងកើតហេតុផ្តល់អ្នកចាប់ផ្តើមសម្ភាសន៍មនុស្ស ដោយសួរពួកគេថា ហេតុអ្វីបានជាពួកគេធ្វើបាតុកម្ម។ ប្រសិនបើបាតុករពីរនាក់ដំបូងដែលអ្នកសម្ភាស ផ្តល់ឱ្យអ្នកនូវហេតុផលដូចគ្នា, អ្នកអាចសន្មត់ថា ៣០០០ នាក់ផ្សេងទៀត ក៏មានហេតុផលដូច្នោះដែរ ។ ជាអកុសលនៅពេលដែលរឿងរបស់អ្នកលេចចេញមក និពន្ធនាយកនៃអង្គភាពអ្នកបានទទួលបានសំបុត្រជាច្រើន ពីអ្នកតវ៉ាដែលនៅទីនោះ ដោយសារហេតុផលខុសគ្នា ទាំងស្រុង។

ជាការពិត ត្រូវដឹងថា ពេលខ្លះ យើងត្រូវទូទៅនីយកម្មខ្លះ ដើម្បីរស់រានមានជីវិតបន្ត។ វាប្រហែលជាមិនមែនជាគំនិតល្អទេ ក្នុងការបន្តសួរថា តើសត្វពស់វែកនេះ មានពិសពុល ឬយ៉ាងណា? ត្រូវសន្មតថាពស់វែកទាំងអស់មានពិស។ ក្នុងពេលជាមួយគ្នានេះ យើងមានទំនោរចង់ធ្វើទូទៅនីយកម្មហួសផងដែរ ។

អ្នកវិទ្យាសាស្ត្រការពារមិនអោយមានការធ្វើទូទៅនីយកម្មហួសពេក ឬទាញសេចក្តីសន្និដ្ឋានហួសដោយស្វែងរកសំណាកច្រើនគ្រប់គ្រាន់សម្រាប់ធ្វើការសង្កេត។ ការចម្លងការស៊ើបអង្កេតផ្តល់នូវការការពារមួយកម្រិតទៀត។ ជាទូទៅនេះមានន័យថាធ្វើការសិក្សាម្តងហើយម្តងទៀតដើម្បីពិនិត្យមើលថា តើលទ្ធផលដូចគ្នាកើតឡើងរាល់ពេលដែរឬទេ។ បន្ទាប់មកជាការធ្វើតេស្តបន្ថែមការសិក្សាអាចត្រូវបានធ្វើម្តងទៀត ក្រោមលក្ខខណ្ឌប្រែប្រួលបន្តិចបន្តួច។

គ. ការសង្កេតមិនគ្រប់ជ្រុងជ្រោយ ( Selective Observation )

គ្រោះថ្នាក់មួយនៃការធ្វើទូទៅនីយកម្មហួស អាចនាំឱ្យមានការសង្កេតដោយមិនគ្រប់ជ្រុងជ្រោយ ។ នៅពេលដែលអ្នកបានសន្និដ្ឋានថា លំនាំជាក់លាក់ ឬគម្រូរមួយមានវត្តមានហើយបានបង្កើតការយល់ដឹងជាទូទៅអំពីមូលហេតុដែលវាកើតឡើង អ្នកនឹងផ្តោតលើព្រឹត្តិការណ៍និងស្ថានភាព នាពេលអនាគតដែលត្រូវនឹងលំនាំនោះ ហើយអ្នកនឹងមិនអើពើនឹងអ្វីដែលមិនត្រូវនឹងលំនាំនោះផងដែរ ។ ការរើសអើងជាតិសាសន៍និងជនជាតិភាគតិចមួយភាគធំបណ្តាលមកពីការសង្កេតមិនគ្រប់ជ្រុងជ្រោយលើការតស៊ូរបស់ពួកគេ។

នៅក្នុងឧទាហរណ៍មួយទៀតនេះគឺជារបៀបដែលលោក Lewis Hill រំលឹក ពីការធំដឹងក្តី នៅតំបន់ ជនបទក្នុងរដ្ឋ វើម៉ុត ៖

> ហាលសម្ងួតស្មៅ( ទុកធ្វើចំបើង )បានចាប់ផ្តើមភ្លាមៗ ក្រោយថ្ងៃទី ៤ ខែកក្កដា ។ ប្រជាកសិករនៅក្នុងសង្កាត់របស់យើងជឿថា អ្នកដែលចាប់ផ្តើមមុននេះ ប្រាកដជាទទួលរងនូវព្យុះ នៅចុងខែមិថុនាបន្ថែមពីលើព្យុះក្រោយថ្ងៃឈប់សម្រាក(៤កក្កដា) ដែល ចាស់ៗនិយាយថា បណ្តាលមកពីសំលេង និងផ្សែងនៃការផុតផាវ កាំជ្រួច។ ម្តាយខ្ញុំបានប្រាប់ខ្ញុំថាជីតារបស់ខ្ញុំនិងអតីតយុទ្ធជនសង្គ្រាមស៊ីវិលផ្សេងទៀត បានអះអាងថា មេឃតែងតែភ្លៀងធ្លាក់ខ្លាំង បន្ទាប់ពីមានការប្រយុទ្ធគ្នាដ៏ធំមួយ។ ជាការពិត អ្វីៗមិនតែងតែកើតឡើងដូចអ្វីដែល ចាស់ៗបានចំណាំនោះទេប៉ុន្តែមនុស្សគ្រប់គ្នាចងចាំតែពេលវេលាដែលវាបានកើតឡើងតាមការចំណាំរបស់ពួកគេតែប៉ុណ្ណោះ។
>
> (Hill, ២០០០)

ពេលខ្លះ ការរៀបគម្រោងស្រាវជ្រាវនឹងបញ្ជាក់ជាមុនអំពីចំនួននិងប្រភេទនៃការសង្កេត ដែលត្រូវធ្វើជាមូលដ្ឋានដើម្បីឈានដល់ការសន្និដ្ឋាន។ ប្រសិនបើអ្នកនិងខ្ញុំចង់ដឹងថា តើស្ត្រីទំនងជាគាំទ្រការរំលូតកូនដោយស្របច្បាប់ ក្នុងភាគរយច្រើនជាងបុរស ដែរឬទេ, យើងនឹងប្តេជ្ញាចិត្តធ្វើការកំណត់ចំនួនជាក់លាក់ចំពោះសំណួរនោះនៅក្នុងគម្រោងស្រាវជ្រាវមួយ។ យើងអាចជ្រើសរើសមនុស្សមួយពាន់នាក់ដែលត្រូវសម្ភាសអំពីបញ្ហានេះ។ ម៉្យាងទៀតនៅពេលធ្វើការសង្កេត ដោយផ្ទាល់នូវព្រឹត្តិការណ៍មួយ ដូចជាការធ្វើបាតុកម្មការពារសិទ្ធិសត្វអ្នកវិទ្យាសាស្ត្រសង្គមខិតខំប្រឹងប្រែងពិសេសដើម្បីស្វែងរក «ករណីល្មៀង» អ្នកដែលត្រូវនឹងគំរូទូទៅ។

ឃ. ព័ត៌មានប្រឌិត ( Make-up Information )

ង. ការលើកហេតុផលខុសវិធីតក្កវិទ្យា ( Illogical Reasoning )

មានវិធីផ្សេងទៀត ដែលយើងតែងតែដោះស្រាយជាមួយនឹងការសង្កេតដែលផ្ទុយពីការយល់ដឹងរបស់យើងអំពីរបៀបរស់នៅប្រចាំថ្ងៃ។ ច្បាស់ណាស់ ការបង្កើតដ៏អស្ចារ្យបំផុតមួយនៃចិត្តមនុស្សគឺ «ករណីលើកលែងផ្សេងៗគ្នាដែលបញ្ជាក់ពីសុពលភាពនៃក្បួនតម្រា» ។ គំនិតនោះគ្មានន័យអ្វីទាំងអស់។ ករណីលើកលែងមួយ អាចទាក់ទាញការយកចិត្តទុកដាក់ចំពោះក្បួនតម្រា ឬច្បាប់ណាមួយ ឬច្បាប់ដែលគេសន្មត់ (ក្នុងន័យដើមរបស់វា «បញ្ជាក់» មានន័យថា «តេស្ត») ប៉ុន្តែ គ្មានប្រព័ន្ធតក្កវិជ្ជាណាមួយ អាចបញ្ជាក់សុពលភាពច្បាប់ដែលផ្ទុយពីនេះបានទេ។ ទោះជាយ៉ាងនេះក៏ដោយយើងតែងតែប្រើពាក្យនិយាយនេះ ដើម្បីលុបចោលភាពផ្ទុយគ្នា ដោយលើកយកភាពមិនសមហេតុផលមកអះអាង។ នេះជារឿងធម្មតាជាពិសេសទាក់ទងទៅនឹងទស្សនៈក្រុម។ នៅពេលជនជាតិស្បែកខ្មៅ ស្ត្រី ឬខ្ទើយ ធ្វើអ្វីមួយ មិនតាមគោលគំនិតបុរេវិនិច្ឆ័យរបស់ក្រុមមនុស្សណាមួយនោះ នោះវា«បញ្ជាក់» ថាក្រៅពីករណីលើកលែងមួយនេះ បុរេវិនិច្ឆ័យនៅតែមានសុពលភាពសម្រាប់អ្វីដែលនៅសល់។ឧទាហរណ៍អ្នកគ្រប់គ្រងអាជីវកម្មស្ត្រីម្នាក់ ដែលមានចិត្តល្អនិងជាសុភាពនារីត្រូវបានគេចាត់ទុកថាជា«ភស្តុតាងបញ្ជាក់» ថានាយកប្រតិបត្តិជាស្ត្រីដទៃទៀត សុទ្ធតែមានចរិតកំណាញ់និងចរិកដូចប្រុស។

អ្វីដែលអ្នកស្ថិតិបានហៅ ការយល់ច្រឡំរបស់អ្នកលេងល្បែង គឺជាឧទាហរណ៍មួយទៀតនៃភាពមិនសមហេតុផលក្នុងការវែកញែកឬថ្លឹងថ្លែងហេតុផល ពីមួយថ្ងៃទៅមួយថ្ងៃ។ ការមានសំណាងល្អឬអាក្រក់ជាប់ៗគ្នា ត្រូវបានសន្មតថា បង្ហាញពីភាពផ្ទុយគ្នារបស់វា។ លេងបៀរចាញ់មួយល្ងាចហើយអាចបង្កឱ្យមានជំនឿថា អាចនឹងឈ្នះនៅក្តារបន្ទាប់។ អ្នកលេងបៀរជាច្រើនបានជក់លេងយូរពេក ដោយសារតែជំនឿខុស។ (ការសន្និដ្ឋានដែលសមហេតុផលជាងនេះ គឺថាពួកគេមិនសូវពូកែលេងបៀរទេ) ។

ថ្វីត្បិតតែយើងទាំងអស់គ្នា ពេលខ្លះ ធ្លាក់ចូលទៅក្នុងហេតុផលមិនសមហេតុផល ដែលគួរឱ្យខ្មាស់អៀនក្នុងជីវិតប្រចាំថ្ងៃ, អ្នកវិទ្យាសាស្ត្រចៀសផុតពីបញ្ហានេះ ដោយប្រើប្រព័ន្ធតក្កវិជ្ជាដោយមនសិការនិងច្បាស់លាស់។ យើងអាចនឹងពិនិត្យមើលតក្កវិជ្ជាក្នុងផ្នែកវិទ្យាសាស្ត្រឱ្យកាន់តែស៊ីជម្រៅនៅពេលក្រោយ។ សម្រាប់ពេលនេះ វាគ្រប់គ្រាន់ហើយក្នុងការកត់សម្គាល់ថា ការវែកញែកតក្កវិជ្ជាគឺជាសកម្មភាពដឹងខ្លួនរបស់អ្នកវិទ្យាសាស្ត្រ ដែលមានសហការីនៅត្រួតពិនិត្យ នៅជុំវិញខ្លួន ដើម្បីរក្សាភាពស្មោះត្រង់។

ដូច្នេះ វិទ្យាសាស្ត្រព្យាយាមការពារយើងពីចំនុចគ្រោះថ្នាក់នៃការស៊ើបអង្កេតធម្មតាៗ។ ការសង្កេតនិងស្វែងយល់ឱ្យបានច្បាស់អំពីការពិត មិនមែនជាបញ្ហាតូចតាចទេ។

មុននឹងបន្តទៅមុខទៀត ត្រូវដឹងថា ការយល់ដឹងបែបវិទ្យាសាស្ត្រអំពីអ្វីមួយក៏ផ្លាស់ប្តូរឥតឈប់ឈរដែរ។ ការពិនិត្យឡើងវិញលើប្រវត្តិវិទ្យាសាស្ត្រ នឹងផ្តល់ឧទាហរណ៍ជាច្រើននៃ«ចំណេះដឹង» ចាស់ដែលត្រូវបានជំនួសដោយ«ចំណេះដឹង»ថ្មី។ ពេលខ្លះ អ្នកជំនាន់ក្រោយហាក់អារម្មណ៍ថាខ្លួនអស្ចារ្យជាងអ្នកវិទ្យាសាស្ត្រកាលពី១០០ ឬ ១០០០ ឆ្នាំមុន ប៉ុន្តែ មាននិន្នាការគិតថា ការផ្លាស់ប្តូរទាំងនោះ នៅពីក្រោយយើងហើយ។ ឥឡូវនេះ យើងដឹងពីរបៀបដែលអ្វីៗមាន។

នៅក្នុងស្នាដៃ ពាក់កណ្តាលជីវិតនៃការពិត (*The Half-Life of Facts*) (២០១២) លោក សាមូអែល អាបេសម៉ាន ដោះស្រាយចម្ងល់ថា តើ«ការពិត»បែបវិទ្យាសាស្ត្រ សព្វថ្ងៃនេះ អាចរស់រានមានជីវិត រហូតដល់ពេលណា ? តើវានៅតែជាការពិតរហូតដល់ពេលណា ទម្រាំវាត្រូវបានគេ ពិចារណាឡើងវិញ ធ្វើតេស្តឡើងវិញ និងការរកឃើញថ្មី។ ឧទាហរណ៍ពាក់កណ្តាលនៃអ្វីដែលវិទ្យាសាស្ត្រវេជ្ជសាស្ត្រដឹងអំពីជំងឺរលាកថ្លើមនិងជំងឺក្រិនថ្លើម ត្រូវបានជំនួសក្នុងរយៈពេល ៤៥ ឆ្នាំ។

ការពិតដែលថាចំណេះដឹងវិទ្យាសាស្ត្រ កំពុងផ្លាស់ប្តូរឥតឈប់ឈរ ពិតជាបង្ហាញពីភាពខ្លាំងនៃឃ្លាំងចំណេះដឹងវិទ្យាសាស្ត្រ។ ក្នុងពេលដែលជំនឿវប្បធម៌និងអបិយជំនឿអាចរស់រានមានជីវិតដោយគ្មានឧបសគ្គអស់ជាច្រើនសតវត្សរ៍ អ្នកវិទ្យាសាស្ត្រប្តេជ្ញាថានឹងសម្រេចបាននូវការយល់ដឹងកាន់តែច្បាស់អំពីពិភពលោក។

ច. ការជាប់ជំពាក់ផ្ទាល់ខ្លួនក្នុងការស្វែងយល់ ( Ego-involvement in understanding )

ឆ. អាថ៌កំបាំង ( Mystification )

## ១១.៣. ក្រមសីលធម៌ក្នុងដំណើរការស្រាវជ្រាវ

ក. មានការចូលរួមដោយស្ម័គ្រចិត្តពីអ្នកផ្តល់ព័ត៌មាន (Voluntary Participation )

ខ. មិនបង្កគ្រោះថ្នាក់ដល់អ្នកចូលរួម ( No harmful to Participation )

គ. មិនមានការបំភាន់-បំភាន់អ្នកចូលរួម ( Deception- Deceiving Subjects )

ឃ. ឯកជនភាព: អនាមិក និង ការលាក់បាំង ( Privacy- Anonymity and Confidentiality )

# មេរៀនទី ១២ ៖ វិធីសាស្ត្រសង្ខេបមេរៀន

## ១២.១. សេចក្តីផ្តើម

មេរៀននេះមានគោលដៅផ្តល់ ចំណេះ ជំនាញ និងសេចក្តីណែនាំពាក់ព័ន្ធផ្សេងៗ ដើម្បីជួយអោយនិស្សិតអាចបំពេញកិច្ចការសង្ខេបមេរៀននិងធ្វើកិច្ចការក្រុមអោយកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល។

ការធ្វើសេចក្តីសង្ខេបបានយ៉ាងល្អ បញ្ជាក់ថាអ្នកពិតជាយល់អត្ថបទ ឬមេរៀនយ៉ាងច្បាស់ និងបញ្ជាក់ថាអ្នកអាចផ្ទេរការយល់ដឹងឬចំណេះដឹងដល់អ្នកអានផ្សេងបាន ។ ជាការផ្តើមដំបូង អ្នកអាចមានការពិបាកក្នុងការសរសេរដោយសារអ្នកមិនដឹងច្បិចយកចំណុចណាខ្លះ ជួនកាលអ្នកបញ្ចូលព័ត៌មានច្រើនពេក ឬជួលកាល តិចពេក ។ ប៉ុន្តែបើអ្នកអនុវត្តតាមវិធីសាស្ត្រទាំងប្រាំបួនដំណាក់កាលនេះ អ្នកនឹងអាចសង្ខេបអត្ថបទបានយ៉ាងល្អ និងរហ័សទៀតផង មិនថាអត្ថបទ ឬមុខវិជ្ជាណាឡើយ ។

## ១២.២. ដំណាក់កាលទាំង ៩

### ១. មាតិកា និងសំណួរ

មុនដំបូង ត្រូវស្រង់ចំណងជើងមេរៀន ចំណងជើងរងកម្រិតទី ១ និងទី ២ ដើម្បីបង្កើតជាមាតិកាមេរៀន ។ បន្ទាប់មកត្រូវបង្កើតជាកម្រងសំណួរ ដោយប្រើចំណងជើងនីមួយៗ ។ ត្រូវសួរខ្លួនឯងថា តើយើងរំពឹងនឹងដឹងអ្វីខ្លះក្នុងចំណុចនីមួយៗ ។ ជាឧទាហរណ៍ បើចំណងជើងរងកម្រិតទី ១ ដាក់ថា «និយមន័យ ប្រវត្តិសាស្ត្រ» អ្នកគួរសួរខ្លួនឯងថា តើប្រវត្តិសាស្ត្រត្រូវគេកំណត់និយមន័យយ៉ាងដូចម្តេចខ្លះ ? ពេលអ្នកចាប់ផ្តើមអាន ចូរផ្ទៀងរកចម្លើយសម្រាប់សំណួររបស់អ្នក ។

### ២. បំបែក(បំបាក់) ដើម្បីគ្រប់គ្រង

ដំបូង អ្នកត្រូវបើកមើលត្រួសៗនូវអត្ថបទដែលអ្នកត្រូវសង្ខេប ហើយបែងចែកវាជាផ្នែកៗ ។ ផ្តោតលើចំណងជើងឬចំណងជើងរងនានា ។ ចូរសង្កេតមើលពាក្យគន្លឹះដិតៗ ហើយត្រូវពិនិត្យមើលនិយមន័យ ឬខ្លឹមសាររបស់វា មុនពេលអាន ។

### ៣. អានលឿន

មកដល់ត្រឹមនេះ អ្នកប្រាកដជាបានត្រៀមរួចរាល់ហើយ ដូច្នេះត្រូវបន្តអានផ្នែកដែលជាទំនួលខុសត្រូវរបស់អ្នក ។ ចូរអានពីដើមដល់ចប់ ដោយមិនចាំបាច់ផ្អាកដើម្បីកត់ត្រាឬស្វែងរកនិយមន័យអ្វីផ្សេងឡើយ ។ ការធ្វើដូចនេះ អ្នកអាចស្វែងយល់ពីស្ទីល ឬបច្ចេក-ទេសនៃការសរសេរ ពិសេសគោលគំនិតសំខាន់របស់អ្នកនិពន្ធ ។

### ៤. អានសកម្មឡើងវិញ

ការអានឡើងវិញ ត្រូវតែសកម្ម ។ គូសបន្ទាត់ពីក្រោមប្រយោគគោល និងតួលេខឬទិន្នន័យគន្លឹះ ។ ដាក់សញ្ញាសំគាល់ ឬ លាបពណ៌ត្រង់ចំណុចណាដែលអ្នកចង់រម្លឹកដល់ពេលអ្នកធ្វើការសង្ខេប ។ លាបពណ៌ផ្សេងត្រង់

ចំណុចដែលអ្នកចង់ផាត់ចេញ ព្រោះវាលម្អិតពេក បើទោះវាគួរអោយចាប់អារម្មណ៍ក៏ដោយ ។ អ្នកក៏អាចសម្គាល់ត្រង់ចំណុចណាដែលអ្នកមិនយល់ ដើម្បីបកមកអានស្វែងយល់ឡើងវិញ ។

### ៥. មួយប្រយោគម្តងៗ

អ្នកគួរតែយល់អត្ថបទត្រូវសង្ខេបអោយបានច្បាស់ ។ ក្នុងជំហានទី ១ ដល់ ៤ អ្នកបានបែងចែកអត្ថបទជាផ្នែកតូចៗ និងស្វែងរកគំនិតសំខាន់របស់អ្នកនិពន្ធ ។ ឥឡូវ ចូរសរសេរគំនិតសំខាន់ក្នុងផ្នែកនីមួយៗ ត្រឹមមួយប្រយោគគន្លឹះ ។ ចូរបញ្ចូលតែចំណុចសំខាន់ក្នុងប្រយោគនេះ ដោយមិនចេះតែដាក់ចំណុចតូចៗចូលឡើយ ។

### ៦. សរសេរ «ប្រយោគគោល»

នេះជាគន្លឹះសម្រាប់ការសរសេរកិច្ចការសង្ខេបដ៏ល្អ ។ ត្រួតពិនិត្យប្រយោគគន្លឹះនានា ដែលអ្នកបានសរសេរក្នុងជំហានទី ៥ ។ ដោយប្រើប្រយោគនោះ អ្នកអាចសរសេរ «ប្រយោគគោល» ដើម្បីប្រាប់អោយអ្នកអានដឹងថាអត្ថបទទាំងមូលនឹងពិភាក្សាឬនិយាយពីអ្វី ។ ក្នុងករណីអ្នកមិនអាចសរសេរប្រយោគគោលបានទេ ចូរបកទៅកែតម្រូវប្រយោគគន្លឹះឡើងវិញ ដោយធានាអោយបានថា ប្រយោគគន្លឹះនីមួយៗ ពិតជាឈ្លេចយកចំណុចសំខាន់ៗក្នុងផ្នែកនីមួយៗ ។

### ៧. រៀបចំសរសេរ

មកដល់ជំហាននេះ អ្នកប្រហែលបានព្រាងសេចក្តីសង្ខេបរួចហើយ ។ អ្នកអាចប្រើប្រយោគគោលសម្រាប់ជាប្រយោគផ្តើមក្នុងសេចក្តីផ្តើម ហើយប្រើប្រយោគផ្សេងៗក្នុងតួសេចក្តី ។ ត្រូវធានាថា ប្រយោគទាំងនោះ ត្រឹមត្រូវតាមលំដាប់ ដូចក្នុងមេរៀន ។ ចូរប្រើឃ្លាភ្ជាប់សេចក្តី (បន្ទាប់មក, ផងដែរ, យ៉ាងណាមិញ, លើសពីនេះទៅទៀត)ដើម្បីធានាលំហូរដ៏ល្អដែលនឹងជួយអ្នកអានកាន់តែច្បាស់ ។ ពេលចាប់ផ្តើមកាន់ប៊ិចសរសេរ ចូរចាំថា ៖

- សរសេរប្រយោគនានា ជាទំរង់បច្ចុប្បន្នកាល ។
- ធានាថាអ្នកបានបញ្ចូលឈ្មោះអ្នកនិពន្ធ និងចំណងជើងសៀវភៅ ។
- ខ្លីតែខ្លឹម៖ សេចក្តីសង្ខេបមិនត្រូវស្មើឬវែងជាងអត្ថបទដើមឡើយ ។ ម្លោះហើយ ក្រុមនីមួយៗ មិនត្រូវសរសេរលើសពី ៥ ទៅ ៧ ទំព័រឡើយ ។
- បើអ្នកប្រើពាក្យដើមរបស់អ្នកនិពន្ធផ្ទាល់ ត្រូវដាក់ឬចុះលេខយោងផង ។
- សូមកុំបញ្ចេញគំនិត យោបល់ ឬការបកស្រាយផ្ទាល់ខ្លួនរបស់អ្នក នៅក្នុងសេចក្តីសង្ខេបនោះ ។ គោលដៅនៃការសង្ខេប គឺព្យាយាមស្វែងយល់នឹងសរសេរឡើងវិញនូវគំនិតគោលដែលអ្នកនិពន្ធចង់បង្ហាញ មិនមែនធ្វើការរិះគន់ឬវែកញែកទេ ។ យ៉ាងណាមុំញ អ្នកអាចបញ្ចូលចំណាប់អារម្មណ៍របស់អ្នកក្នុងផ្នែកចុងក្រោយនៃសេចក្តីសន្និដ្ឋាន ។ ឧទាហរណ៍ តើអ្នកមានចំណាប់អារម្មណ៍យ៉ាងណា ក្រោយបានអាន ឬសង្ខេបមេរៀនស្តីពីអរិយធម៌សម័យអង្គរ ?

### ៨. ត្រួតពិនិត្យខ្លឹមសារ

ចូរអានសេចក្តីសង្ខេបរបស់អ្នកឡើងវិញ ដើម្បីធានាថាអ្នកពិតជាបានច្បិចយកគំនិតគោល និងចំណុចសំខាន់ៗ ដែលអ្នកនិពន្ធចង់បង្ហាញ ។ ត្រូវធានាថាអ្នកបានដាក់ឬចុះលេខយោងលើចំណុចដែលអ្នកដកស្រង់ពី

អត្ថបទដើមទាំងស្រុងឬប្រើពាក្យពេចន៍ឃ្លាឃ្លោងដូចបេះបិទ ។ អ្នកក៏ត្រូវជានាថា សេចក្ដីសង្ខេបនេះមិនបានបញ្ចូលទស្សនៈផ្ទាល់ខ្លួនរបស់អ្នកឡើយ ។

### ៩. កែតម្រូវឡើងវិញ

ក្រោយពេលអ្នកប្រាកដក្នុងចិត្តថា សេចក្ដីសង្ខេបនោះពិតជាត្រឹមត្រូវហើយ អ្នកគួរត្រួតពិនិត្យមើលអក្ខរាវិរុទ្ធ វេយ្យាករណ៍ ឬសញ្ញាផ្សេងៗ អោយបានត្រឹមត្រូវ ។ បើមានពេល សាកហុចសេចក្ដីសង្ខេបរបស់អ្នកអោយអ្នកដទៃអាន ។ ប្រសិនបើគេយល់ច្បាស់មេរៀនឬអត្ថបទទាំងមូល ដោយគ្រាន់តែអានសេចក្ដីសង្ខេបរបស់អ្នក នោះមានន័យថាអ្នកសង្ខេបបានល្អនិងត្រឹមត្រូវ ។ តែបើគេមិនយល់ទេ ប្រហែលជា អ្នកផ្ដោតខ្លាំងលើផ្នែកណាមួយខ្លាំងពេក ដោយមិនច្បិចយកគំនិតគោលរបស់អ្នកនិពន្ធ ។

សំគាល់ ៖ តើអ្វីទៅជាការសង្ខេបសៀវភៅ ? សេចក្ដីសង្ខេប ជាធម្មតា គឺត្រូវតែខ្លឹម តែខ្លី ។ ដូច្នេះ សង្ខេបសៀវភៅ ត្រូវបញ្ចូលធាតុសំខាន់ៗនៃមេរៀន ។ វារៀបរាប់ចំណុចផ្ដើម តួសេចក្ដី ចំណុចសំខាន់ៗ ឬអំណះអំណាងនានា និងសេចក្ដីសន្និដ្ឋាន (ជាដើម) ឡើងវិញ (យ៉ាងខ្លី) ។

ពេលអ្នកអានសេចក្ដីសង្ខេបដែលល្អត្រឹមត្រូវ អ្នកគួរតែអាចបរិយាយថាតើសៀវនៅនោះនិយាយពីអ្វី ដោយប្រើពាក្យរបស់អ្នកផ្ទាល់ ។ ចូរស្រម៉ៃថាអ្នកចូលបណ្ណាល័យ ឬបណ្ណាគារ អ្នកអាចនឹងភ្លេចចំណងជើងសៀវភៅអ្នកចង់អាន ឬទិញតែអ្នកអាចចាំព័ត៌មានគោលៗល្មមអាចអោយបណ្ណារក្សឬអ្នកលក់រកសៀវភៅអោយអ្នកបាន ។

តើអ្វីទៅជាសេចក្ដីសង្ខេបមេរៀន? ការសង្ខេបមេរៀន គឺជាការច្បិចយកអត្ថន័យខ្លីតែខ្លឹមចេញពីសៀវភៅ ។ ការសង្ខេបមេរៀននឹងផ្ដល់ចំណុចគោលៗភស្ដុតាងឬទឡ្ហីករណ៍សំខាន់ៗដល់អ្នកសិក្សានានា ។ ដើម្បីស្វែងយល់ពីដំណាក់កាលនីមួយៗ ចូរមើលសិក្សាសៀវភៅ «ប្រវត្តិកម្ពុជានិងតំបន់» មេរៀនទី៤ ស្ដីអំពី **ឥទ្ធិពលឥណ្ឌា និងចិនមកលើអាស៊ីអាគ្នេយ៍** នៅទំព័របន្ទាប់៖

# ឥទ្ធិពលឥណ្ឌា និងចិនមកលើអាស៊ីអាគ្នេយ៍[១៥]

## មាតិកា

I. សេចក្តីផ្តើម

II. ឥទ្ធិពលឥណ្ឌាលើអាស៊ីអាគ្នេយ៍

*សំណួរ៖ តើឥទ្ធិពលឥណ្ឌានៅអាស៊ីអាគ្នេយ៍មានអ្វីខ្លះ?*

*សំណួរ៖ តើឥទ្ធិពលទាំងនោះ អាចហូរចូលដោយរបៀបណា?*

III. ឥទ្ធិពលចិនលើអាស៊ីអាគ្នេយ៍

*សំណួរ៖ តើឥទ្ធិពលចិននៅអាស៊ីអាគ្នេយ៍មានអ្វីខ្លះ?*

*សំណួរ៖ តើទំនាក់ទំនងជាមួយ ចាប់ផ្តើមពីពេលណាមក? ដោយនរណា? នៅកន្លែងណាខ្លះ...?*

*សំណួរ៖ តើឥទ្ធិពលចិននៅអាស៊ីអាគ្នេយ៍មានអ្វីខ្លះ?*

IV. សេចក្តីសន្និដ្ឋាន

## សំណេរសង្ខេបមេរៀន

I. សេចក្តីផ្តើម

តំបន់អាស៊ីអាគ្នេយ៍ គឺជាផ្នែកមួយនៃទ្វីបអាស៊ី ស្ថិតនៅភាគខាងកើតប្រទេសឥណ្ឌា និងខាងត្បូងប្រទេសចិន ។ ភូមិវិទូដាណឺម៉ាក ឈ្មោះ ម៉ាល់ប្រុន បានហៅតំបន់នេះថា «ឥណ្ឌូចិន» ដោយសារតែវាទទួលឥទ្ធិពលឥណ្ឌា និងចិនយ៉ាងជោគជាំ ។ ទោះឥទ្ធិពលទាំងនោះបានហូរចូលតាំងពីសម័យបុរាណមក មានភស្តុតាងបញ្ជាក់យ៉ាងច្រើន ហើយច្បាស់លាស់ណាស់ ។ ប៉ុន្តែ អ្វីដែលមិនទាន់ច្បាស់លាស់គឺ៖ ទីមួយ តើឥទ្ធិពលឥណ្ឌាបានហូរចូលមកក្នុងតំបន់ដោយរបៀបណា? ទីពីរ ងាកមកភាគខាងកើតវិញ តើប្រទេសចិនមានឥទ្ធិពលបែបណាដែរ មកលើតំបន់នេះ? សេចក្តីសង្ខេបនេះនឹងព្យាយាមបកស្រាយលើសំណួរទាំងពីរខាងលើនេះ ។

II. ឥទ្ធិពលឥណ្ឌាលើអាស៊ីអាគ្នេយ៍

ឥណ្ឌាគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានអរិយធម៌ និងវប្បធម៌ចំណាស់ជាងគេ នៅក្នុងពិភពលោក។ ទន្ទឹមនឹងនេះផងដែរ អរិយធម៌ និងវប្បធម៌ទាំងនោះក៏បានសាយភាយទៅកាន់បណ្តាប្រទេសជាច្រើនដែលក្នុងនោះក៏មានតំបន់អាស៊ីអាគ្នេយ៍ផងដែរ។ ឥណ្ឌាបានបន្សល់ទុកនូវឥទ្ធិពលរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ មានដូចជា ភាសាបាលី និងភាសាសំស្ក្រឹត និងវប្បធម៌ឥណ្ឌាតាមរយៈសង្គមចំរុះ ដែលបានរីកចំរើនលូតលាស់ឡើង។ គេឃើញមានប្រជាជននៅអាស៊ីអាគ្នេយ៍ធ្វើពិធីបុណ្យតាមសាសនាឥណ្ឌា ចំណែកឯខាងស្ថាបត្យកម្មវិញក៏មានលក្ខណៈស្រដៀងនឹងឥណ្ឌាផងដែរ។ មានការបកស្រាយបែបបុរាណ បានបង្ហាញថានៅអាស៊ីអាគ្នេយ៍ មានស្តេច

---

[១៥] (វង់, ២០០៣)

អសោក ដែលបានសោយរាជ្យ នៅ សតវត្សរ៍ទីបី មុនគ.ស និងបានបញ្ជូនសាសនាទូតខាងពុទ្ធសាសនាទៅកាន់ភាគខាងកើតប្រទេសឥណ្ឌា «សុវណ្ណភូមិ» ។ ជនជាតិឥណ្ឌាដែលត្រូវបានដឹកនាំដោយព្រះអង្គម្ចាស់មួយអង្គ បានធ្វើអាណានិគមមកលើតំបន់អាស៊ីអាគ្នេយ៍ ហើយបង្កើតបាននូវសង្គមសម័យឥណ្ឌា ប៉ុន្តែ មិនបានបន្សល់ទុកស្លាកស្នាមអ្វីនោះទេ។

ផ្អែកទៅលើការសិក្សាស្រាវជ្រាវមួយចំនួន ឥទ្ធិពលឥណ្ឌាដែលមានមកលើអាស៊ីអាគ្នេយ៍កើតឡើងតាមរយៈកត្តាមួយចំនួន ដូចជា សាសនា ពាណិជ្ជកម្ម ស្ថាបត្យកម្ម...។ យោងទៅតាមទស្សនៈលោកវ៉ាន់ល័រ (Van Leur) បានលើកឡើងថាពួកព្រាហ្មណ៍មកអាស៊ីអាគ្នេយ៍ តាមរយៈការអញ្ជើញរបស់ស្តេចឬអ្នកដឹកនាំមកកាន់តំបន់អាស៊ីអាគ្នេយ៍ ដោយសារពួកនោះមានមន្តអាគម និងមានកម្លាំងសក្តិសិទ្ធិម្យ៉ាង។ លើសពីនេះទៅទៀត ក៏មានស្តេចមួយអង្គនៅឥណ្ឌា បានបញ្ជូនសាសនទូតខាងពុទ្ធសាសនាមកកាន់ទឹកដីអាស៊ីអាគ្នេយ៍ដើម្បីផ្សព្វផ្សាយសាសនា។ ចំពោះផ្នែកស្ថាបត្យកម្មវិញយើងឃើញថា ក្រោយពេលដែលពួកព្រាហ្មណ៍បានមកដល់ទឹកដីសុវណ្ណភូមិមួយនេះហើយ ក៏ចាប់ផ្តើមមានការតុបតែងរាជធានីបែបឥណ្ឌា ហើយក៏មានបង្រៀនភាសាសំស្ក្រឹត និងសិប្បករក្នុងស្រុកតាមស្ថាបត្យកម្មនិងបដិមាករឥណ្ឌា។

លើសពីនេះទៅទៀត អ្នកប្រាជ្ញពីតំបន់អាស៊ីអាគ្នេយ៍ ដែលបានទៅរៀននៅឥណ្ឌា ពេលដែលត្រលប់មកវិញក៏ចេះមានគំនិតសាងសង់សំណង់ ដែលយកតាមគំរូប្រទេសឥណ្ឌាហើយច្របាច់បញ្ចូលជាមួយនឹងគំនិតរបស់ពួកគេថែមទៀតផង។ ម្យ៉ាងវិញទៀត យោងទៅតាមទស្សនៈលោក ហ្សក សឺដែស (George Coedès) ឥណ្ឌាចូលមកកាន់អាស៊ីអាគ្នេយ៍តំបូងគេតាមរយៈពាណិជ្ជករ ដែលមកធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីក្នុងស្រុកតែម្តងទៅ (រដ្ឋឥណ្ឌានីយកម្មនៅអាស៊ីអាគ្នេយ៍)។

III. ឥទ្ធិពលចិនលើអាស៊ីអាគ្នេយ៍

បណ្តាញពាណិជ្ជកម្មតាមផ្លូវសមុទ្រ តាមតម្រូវការ ឬជាមួយចិន បានកំណត់នូវការរីកចំរើន និងការចុះខ្សោយរបស់បណ្តារដ្ឋជាច្រើននៅអាស៊ីអាគ្នេយ៍។ ស្របពេលមានទំនាក់ទំនងទាំងនោះ ជនជាតិចិនបានកត់ត្រារឿងរ៉ាវនានា ដែលជាប្រភពមួយដ៏សំខាន់សម្រាប់ប្រវត្តិសាស្ត្រដំបូងៗ នៅអាស៊ីអាគ្នេយ៍ ។

### ៣.១ ទំនាក់ទំនងចិនជាមួយហ្វូណាន និង តាមឆ្នេរសមុទ្រឥណ្ឌូចិន

ទំនាក់ទំនងចិនជាមួយហ្វូណាន និង តាមឆ្នេរសមុទ្រឥណ្ឌូចិន ក៏ដូចជាទំនាក់ទំនងចិនជាមួយឥណ្ឌូនេស៊ីបានចង្អុលបង្ហាញពីឥទ្ធិពលចិនខ្លាំងក្លាមកលើតំបន់អាស៊ីអាគ្នេយ៍ទាំងមូល តាមរយៈពាណិជ្ជកម្ម តាមកប៉ាល់ឬសំពៅនៅតាមផ្លូវទឹកសំខាន់ៗនានាដែលមានក្នុងតំបន់។

បើក្រលេកមើលទីតាំងភូមិសាស្ត្រ ប្រទេសចិនស្ថិតនៅភាគខាងជើង នៅតំបន់ដីគោកហួសទន្លេយ៉ង់សេ ដែលវប្បធម៌ និងសេដ្ឋកិច្ចគឺពឹងផ្អែកទៅលើ ការធ្វើកសិកម្ម។ ម្យ៉ាងទៀត ចិនក៏មានឯកសារជាច្រើនដែលបានចងក្រង ជាលាយលក្ខណ៍អក្សរ ស្តីពីរបាយការណ៍បញ្ហានានា ក្នុងនោះក៏បានរួមបញ្ចូលពីដើមកំណើតហ្វូណានផងដែរ។

មនុស្សអាស៊ីអាគ្នេយ៍ ជាពិសេសចំពោះអ្នកដែលនិយាយភាសាអូស្ត្រូនេស៊ីមានទំនាក់ទំនងជាមួយរដ្ឋទាំងអស់នៅអាស៊ីអាគ្នេយ៍។ នៅភាគខាងត្បូងទន្លេយ៉ង់សេ ប្រជាជននៅទីនោះជាប្រជាជនអាស៊ីអាគ្នេយ៍ ដូចជាថៃជាដើមដែលចិនបានហៅអ្នកទាំងអស់នោះថា **យេហ(វៀត)** ដែលជាប្រជាជនពូកែធ្វើពាណិជ្ជកម្ម និងនាវាចរណ៍តាមសមុទ្រ។

ជាងនេះទៅទៀត នៅសតវត្សទី២-៣ នៃគ.ស ចិនក៏មានទំនាក់ទំនងជាមួយហ្វូណាន ព្រោះចង់បានគ្រឿងប្រណិត ដែលមានដូចជាភ្លុកដំរី កុយរមាស គុជ ឈើមានតម្លៃ ជ័រឈើ និងវត្ថុមានតម្លៃដទៃទៀត។ ចិនមានទំនាក់ទំនងជាលើកដំបូងរបស់ខ្លួននៅក្នុងអាណាចក្រខាងត្បូង ឬអាគ្នេយ៍ដែលមានរដ្ឋ អ៊ូ (Wu) ធ្វើពាណិជ្ជកម្មតាមរយៈផ្លូវសមុទ្រ ព្រោះផ្លូវគោកត្រូវបានគេកាត់ផ្តាច់ទៅហើយ។

ដំបូងឡើយ ផ្លូវទឹកដែលសំខាន់ គឺនៅតាមបណ្តោយឆ្នេរសមុទ្រពីកង់តុងឆ្ពោះទៅ **ចាវ-ជី, លីន-យី, ចាម្ប,** និង **ហ្វូណាន** បន្ទាប់មកឆ្លងកាត់ឈូងសមុទ្រសៀមទៅឧបទ្វីប (**ទុន-ស៊ុន**)។ ដោយឡែកក្រោយមក ក្នុងកំឡុងសតវត្សរ៍ទី៥-៦ ផ្លូវពីចិនត្រង់ឆ្ពោះទៅឥណ្ឌូនេស៊ីចាប់ផ្តើមប្រើប្រាស់ ហើយនៅសតវត្សទី៧ ផ្លូវទឹកមួយខ្សែនេះក៏ក្លាយជាផ្លូវពាណិជ្ជកម្មចិន ដ៏ចំបង ។ សូម្បីបញ្ជាក់ផងដែរថា បើទោះបីចិនមានទំនាក់ទំនងពាណិជ្ជកម្មជាមួយរដ្ឋនានាក្នុងតំបន់ក៏ពិតមែន មានតែ **ចាវ-ជី** តែមួយគត់ដែលទទួលយកចិននីយកម្ម ។

តាមលោក គុងវូ (Gungwu) បាននិយាយក្នុងសៀវភៅត្រង់ទំព័រទី៦៥ ថាប្រជាជនខុនលុន មកពីភាគខាងត្បូងបានគេធ្វើជា អ្នកបកប្រែ និងនៅត្រង់ទំព័រ ១១៤ ដល់ ១១៥ ស្តីពីឥទ្ធិពលដ៏តិចតួចបំផុតរបស់ចិនលើអាស៊ីអាគ្នេយ៍ ដោយសារតែអាស៊ីអាគ្នេយ៍មានទំនាក់ទំនងជាមួយឥណ្ឌា មុនពេលដែលចិនធ្វើដំណើរ ឆ្លងកាត់ទន្លេយ៉ង់សេ។

### ៣.២ ទំនាក់ទំនងរបស់ចិនជាមួយឥណ្ឌូនេស៊ី

ដូចបញ្ជាក់ខាងលើហើយ ចាប់ពីស.វទី៧ ប្រទេសចិនបានចាប់ផ្លូវពាណិជ្ជកម្មត្រង់ពីឥណ្ឌូនេស៊ី ជំនួសឲ្យផ្លូវចាស់ពីចិនទៅហ្វូណាន ហើយឥណ្ឌូនេស៊ីដំបូងបានចាប់ផ្តើមដឹកជញ្ជូនផលិតផលនានាទៅកាន់ប្រទេសចិន នៅក្នុងចំណោមនោះគេរកឃើញថាមានរបស់ខ្លះអាចធ្វើពាណិជ្ជកម្មរវាងចិននឹងឥណ្ឌូនេស៊ីបាន ដូចជា **ប៉ស្ស៊ី (ពែរ្ស)**។

នៅសតវត្សទី៥-៦ ទឹកដីជាច្រើនកន្លែងនៅឥណ្ឌូនេស៊ី ត្រូវបានដាក់ឈ្មោះដោយជនជាតិចិនដែលទឹកដីទាំងនោះមានដូចជា **ហូឡូតាន, កូយីង, កានតូលី, តានតាន, ឡាងយ៉ាស៊ុ, ជីទូមូឡូយូ** ជាដើម។ លើសពីនេះទៅទៀត ព្រះសង្ឃចិនមុននឹងធ្វើដំណើរទៅប្រទេសឥណ្ឌា គេសង្កេតឃើញនៅសម័យថ្មីនេះឃើញថា ព្រះសង្ឃទាំងអស់តែងតែចូលកោះមួយចំនួនរបស់ឥណ្ឌូនេស៊ីដូចជា ស៊ូម៉ាត្រា ម៉ូឡូយូ ដើម្បីទេសនា តាមបែបសាសនាព្រះពុទ្ធសាសនា។

ប្រទេសចិន ក្រោមរាជវង្ស**សុង** ដែលគ្រប់គ្រងត្រឹមតែភាគខាងត្បូង បានផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្មចាស់ ។ គេបានសម្រេចបោះបង់កំពង់ផែកណ្តាល នៅអាស៊ីអាគ្នេយ៍ ដោយអនុញ្ញាតអោយជនជាតិខ្លួនចេញទៅទិញទំនិញតាមចិត្ត ដើម្បីស្វែងរកលទ្ធភាពទទួលបានទំនិញល្អប្រសើរជាងមុន ក្នុងតំលៃសមរម្យ ។ ក្នុងឆ្នាំ ១២៧៩ នៅពេលដែលពួកម៉ុងហ្គោលបានដណ្តើមកាន់កាប់នគរសុងភាគខាងត្បូង គេបានបន្តនយោបាយរហូតដល់ពួកគេត្រូវបានដួលរលំ។ កាលសម័យនោះ ក្រុងសៀនដែលមានកំពង់ផែជាច្រើននៅឆ្នេរសមុទ្រថ្លា ក៏បានក្លាយជាកំពង់ផែពាណិជ្ជកម្ម ស្របពេលដែលកំពង់ផែស៊ូម៉ាត្រាកំពុងចុះខ្សោយ។

សន្តតិវង្សរបស់ចិនថ្មីគឺ **មិង** (Ming) បានមកជំនួសពួកម៉ុងហ្គោលនៅឆ្នាំ១៣៦៨ ដោយបំណងរបស់ពួកគេគឺធ្វើឲរស់ឡើងវិញនូវប្រពន្ធសេដ្ឋកិច្ចចាស់ ដោយរាល់ពាណិជ្ជកម្មទាំងអស់ ត្រូវធ្វើឡើងដោយជនបរទេសលើកកប៉ាល់បរទេស។ ប្រទេសចិនបានចាប់អារម្មណ៍លើការរីកចម្រើនយ៉ាយឆាប់រហ័សលើវិស័យកំពង់ផែក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាកត្តាជំរុញឲ្យមានការប្រកួតប្រជែងយ៉ាងខ្លាំង ដើម្បីទាក់ទាញចំណាប់អារម្មណ៏របស់ចិន។ កន្លែងប្រកួតប្រជែងសំខាន់ៗមាន **សៀន** នៅតាមឈូងសមុទ្រថៃ ម៉ាឡាកា នៅម៉ាឡេ រួមទាំងកំពង់ផែ មួយ

ចំនួនទៀតនៅឡើយ។ ទោះបីជាមានការប្រកួតប្រជែងយ៉ាងណាក៏ដោយ ក៏ម៉ាឡាកានៅតែទទួលបានជ័យជំនះ ហើយម៉ាឡាកាត្រូវបានទទួលស្គាល់ជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់ប្រទេសចិន។

IV. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកយើងឃើញថា អត្ថបទខាងលើបានឆ្លុះបញ្ចាំងអំពីឥទ្ធិពលដែលតំបន់អាស៊ីអាគ្នេយ៍ទទួលបានពីចិន និងឥណ្ឌាជាច្រើន។ ឥទ្ធិពលសំខាន់ៗដែលឥណ្ឌាមានមកលើអាស៊ីអាគ្នេយ៍រួមមាន អក្សរ ភាសា សាសនា និង ស្ថាបត្យកម្មជាដើម។ បើយោងទៅតាមការសិក្សាមួយចំនួនបានបង្ហាញថា ឥទ្ធិពលរបស់ឥណ្ឌាមកដល់អាស៊ីអាគ្នេយ៍តាមរយៈពាណិជ្ជករឥណ្ឌា និង អ្នកដឹកនាំនៅអាស៊ីអាគ្នេយ៍ ដែលបានទៅសិក្សានៅប្រទេសឥណ្ឌា។ យ៉ាងណាមិញ ក៏នៅតែមានកង្វះខាត និង ភាពស្រពេចស្រពិលទៅលើទ្រឹស្តីដែលបានលើកឡើងនេះដែរ ដោយសារតែទស្សនៈខុសៗគ្នារបស់អ្នកប្រាជ្ញផ្សេងៗផងដែរ។ ដោយឡែក ចំពោះឥទ្ធិពលដែលចិនមានមកលើអាស៊ីអាគ្នេយ៍វិញ គឺត្រូវបានគេសន្និដ្ឋានថាមានតិចតួច ដោយសារតែឥទ្ធិពលរបស់ឥណ្ឌាមកដល់អាស៊ីអាគ្នេយ៍មុនទៅហើយ។ យ៉ាងណាក៏ដោយ ក៏នៅតែមានទំនាក់ទំនងសំខាន់ៗ ដូចជា ការធ្វើពាណិជ្ជកម្មរវាងចិន និង ហ្វូណននៅក្នុងសតវត្សទី៣ និង ទំនាក់ទំនងផ្លូវទឹកមួយចំនួនទៀត។ ចំណែកឯទំនាក់ទំនងរវាងចិន និង ឥណ្ឌូនេស៊ីវិញគឺផ្តើមឡើងពីការធ្វើពាណិជ្ជកម្មជាមួយគ្នាតាំងពីសម័យបុរេប្រវត្តិ ហើយតំបន់មួយចំនួននៃឥណ្ឌូនេស៊ីត្រូវបានដាក់ឈ្មោះដោយជនជាតិចិនផងដែរ។

ផ្អែកតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា អត្ថបទខាងលើពិតជាបានផ្តល់នូវពុទ្ធិ ដល់អ្នកអាន អ្នកសិក្សាទាំងឡាយឲ្យស្គាល់ និងស្វែងយល់ឲ្យកាន់តែស៊ីជម្រៅពីឥទ្ធិពល និងទំនាក់ទំនងដែលឥណ្ឌា និង ចិន មានមកលើអាស៊ីអាគ្នេយ៍តាំងពីយូរលង់ណាស់មកហើយ។ មិនត្រឹមតែប៉ុណ្ណោះ វាក៏ចូលរួមចំណែកក្នុងការបកស្រាយពីប្រវត្តិដើមរបស់តំបន់អាស៊ីអាគ្នេយ៍ ៕

## ១២.៣. លំហាត់អនុវត្តន៍

### កថាខ័ណ្ឌគំរូ៖

ចូរសង្ខេបមេរៀនទី ៤ ខាងដើមដោយច្បិចយកខ្លឹមសារគោល ហើយសរសេរសង្ខេបជាកថាខ័ណ្ឌមួយ។ ដោយឡែក តើអ្វីទៅជាកថាខ័ណ្ឌ? ចូរសិក្សាអំពីនិយមន័យ ធាតុផ្សំ និងគំរូក្នុងការសរសេរកថាខ័ណ្ឌអោយបានល្អ។

**កថាខ័ណ្ឌ**[១៦] គឺជាក្រុមនៃប្រយោគពាក់ព័ន្ធគ្នា ចំនួនពីរឬច្រើន ដើម្បីពិភាក្សាអំពី **«គំនិតសំខាន់មួយ»** អោយបានពេញលេញ មានន័យគ្រប់គ្រាន់ អាចស្តាប់បាន។ ក្នុងកថាខ័ណ្ឌមួយ អាចមានប្រយោគបីប្រភេទ៖ ប្រយោគគោល (Topic Sentence) ដែលមានគំនិតគោល ឬគំនិតសំខាន់, ប្រយោគគាំទ្រគំនិតគោល(Supporting Sentences) និង ប្រយោគសរុបមតិ (Concluding Sentence)។ ជាធម្មតា **គំនិតគោល**ត្រូវលេចក្នុងប្រយោគដំបូងគេ ហើយប្រយោគបន្តបន្ទាប់ទៀតជា *ប្រយោគគាំទ្រគំនិតគោល* ដោយរួមបញ្ចូលនូវតួលេខ ទិន្នន័យការពិត ឬ ឧទាហរណ៍ជាក់ស្តែង ដើម្បីគាំទ្រគំនិតសំខាន់នោះ ។ ជួលកាល ប្រយោគសរុបមតិ ត្រូវបន្ថែមនៅខាងចុងដើម្បីសរុបសេចក្តី ក្នុងករណីកថាខ័ណ្ឌវែង។

[១៦]

ធាតុនៃប្រយោគគោល (Topic Sentence Elements) រួមមាន **ប្រធានបទ** (Topic) និង ព្រំដែនកំណត់ប្រធានបទ (Controlling Ideas)។

**ឧទាហរណ៍៖ មាស** ដែលជារតនៈសម្បត្តិ មានលក្ខណៈពិសេសពីរយ៉ាង។

ចូរមើលគំរូគម្រោងសរសេរ និងកថាខ័ណ្ឌស្តីពីមាសខាងក្រោម៖

**១. គម្រោងសំណេរ ជាចំណុចៗ គ្រោះ**

+គំនិតសំខាន់(Main Idea)៖ **លក្ខណៈពិសេសរបស់មាស**

- ចំណុច១គាំទ្រគំនិតសំខាន់៖ **សំរស់**
    - ភ្លឺ ចែងចាំង ស្រស់ស្អាត
    - ឧទាហរណ៍៖ កាក់
- ចំណុច២គាំទ្រគំនិតសំខាន់៖ **ប្រយោជន៍**
    - ឧស្សាហកម្ម
        - ទន្តសាស្ត្រ
        - រូបថត
    - វិទ្យាសាស្ត្រ
        - អាវអវកាសយានិក

**២. សំណេរកថាខ័ណ្ឌ ដោយប្រើចំណុចៗខាងលើ**

①**មាស**ដែលជារតនៈសម្បត្តិ មានលក្ខណៈពិសេសពីរយ៉ាង។ ②លក្ខណៈពិសេសទីមួយ មាស មានសម្រស់ស្រស់ស្អាត ភ្លឺចែងចាំង ដែលធន់នឹងភាពសឹករេចរិល។ ③ម្លោះហើយ វាសាកសមបំផុតសំរាប់ធ្វើគ្រឿងអលង្ការ កាក់ និងគ្រឿងលំអផ្សេងៗទៀត។ ④មាសនៅតែភ្លឺស្អាតជារៀងរហូត ដោយមិនចាំបាច់ដុសខាត់ឡើយ។ ⑤ជាក់ស្តែង កាក់របស់ម៉ាសេដូនី នៅតែស្អាត មិនច្រេះចាប់ រហូតដល់សព្វថ្ងៃ បើទោះជាវាត្រូវធ្វើឡើង តាំងពី ២៥០០ ឆ្នាំកន្លងមកហើយ។ ⑥លក្ខណៈពិសេសមួយទៀតរបស់មាស គឺប្រយោជន៍របស់វាក្នុង វិស័យឧស្សាហកម្ម និងវិទ្យាសាស្ត្រ។ ⑦កន្លងមក វាត្រូវបានប្រើប្រាស់ក្នុងកម្មវិធីឧស្សាហកម្មជាច្រើន រាប់រយពាន់ ដូចជាផ្នែកទន្តសាស្ត្រ និងរូបថត ជារៀងរាល់ឆ្នាំ ។ ⑧មាសត្រូវបានគេប្រើក្នុងការផលិតអាវក្រៅរបស់អវកាសយានិក។ ⑨អវកាសយានិក ពាក់អាវស្រោបមាស ការពារកំដៅ ពេលពួកគេចេញពីយាន ទៅលំហអាកាស។ ⑩ជារួម មាសត្រូវគេចាត់ទុកជាកំណប់មហាសាល មិនត្រឹមដោយសារតែ**សម្រស់**របស់វាប៉ុណ្ណោះទេ តែថែមទាំងដោយសារតែ**ប្រយោជន៍**លើសលប់របស់វាទៀតផង។

ចូរមើលគំរូកថាខ័ណ្ឌមួយទៀតដូចខាងក្រោម ហើយឆ្លើយនឹងសំណួរទាំងអស់ខាងក្រោម៖

១. តើអ្វីជាគំនិតគោលនៅក្នុងកថាខ័ណ្ឌនេះ?
២. តើគំនិតគាំទ្រគំនិតគោល មានប៉ុន្មាន? អ្វីខ្លះ?
៣. ចូរស្វែងរកចំណងជើងសមស្របមួយសម្រាប់កថាខ័ណ្ឌខាងក្រោម។

សណ្ឋានដីប្រទេសកម្ពុជាត្រូវបានបែងចែកជាបួនតំបន់សំខាន់ៗ ។ តំបន់សំខាន់បំផុតស្ថិតនៅចំផ្ទៃកណ្ដាលប្រទេស លាតសន្ធឹងពីពាយព្យមកអាគ្នេយ៍ មានផ្ទៃក្រលាប្រហែលមួយភាគបីនៃប្រទេស ហើយត្រូវបែងចែកជាពីរភូមិភាគបន្តទៀត មានទំនាបបឹងនិងទំនាបចតុមុខ ។ តំបន់នេះសំខាន់ជាងគេ ព្រោះវាជាទីតាំងនៃស្ថាប័នរដ្ឋកំពូលៗ និងជាបេះដូងនៃសេដ្ឋកិច្ចជាតិ ។ រីឯតំបន់ឆ្នេរស្ថិតនៅប៉ែកនិរតីនៃប្រទេស រួមមានខេត្តកែបកំពត កោះកុង និងកំពង់សោម ។ វិស័យទេសចរណ៍និងនេសាទគឺជាសកម្មភាពសេដ្ឋកិច្ចស្នូល ។ ចំពោះតំបន់ខ្ពង់រាប ស្ថិតនៅប៉ែកឦសានប្រទេស គ្រប់ដណ្ដប់ដោយដីក្រហម ដែលអនុគ្រោះដល់ការធ្វើដំណាំកសិឧស្សាហកម្ម ពិសេសកៅស៊ូនិងម្រេច ។ ចុងក្រោយ តំបន់ភ្នំស្ថិតភាគពាយព្យនិងនិរតី ហើយត្រូវបែងចែកជាពីរភូមិភាគគឺ តំបន់ជួរភ្នំក្រវាញ និងភ្នំដងរែក ។ ប្រជាជនក្នុងតំបន់ទាំងនោះរស់នៅអាស្រ័យលើអនុផលព្រៃឈើ មានបោចវល្លិ៍ ជៀរជ័រ រកអុស ៕

### តែងសេចក្ដីគំរូ

បន្ទាប់ពីបានយល់ច្បាស់ និងចេះសរសេរកថាខ័ណ្ឌហើយ ចូរសាកល្បងសរសេរអត្ថបទសង្ខេបសៀវភៅប្រវត្តិសាស្ត្រ ដែលអ្នកបានជ្រើសរើស សម្រាប់ធ្វើកិច្ចការក្រុម។ តាមធម្មតា អត្ថបទតែងសេចក្ដីមួយ មានបីផ្នែកសំខាន់ៗ៖ (១)សេចក្ដីផ្ដើម (កថាខណ្ឌដំបូង), (២)តួសេចក្ដី (យ៉ាងហោចណាស់ មានមួយកថាខ័ណ្ឌ ប៉ុន្តែជាធម្មតា វាមានចាប់ពី ពីរកថាខ័ណ្ឌឡើងទៅ), និង (៣)សេចក្ដីសន្និដ្ឋាន (កថាខ័ណ្ឌបញ្ចប់ចុងក្រោយបង្អស់) ។ អត្ថបទខាងក្រោមនេះ គឺជាឧទាហរណ៍នៃតែងសេចក្ដី ដែលមានការរៀបចំបានយ៉ាងល្អ ។ ចូរពិនិត្យមើលគម្រូខាងក្រោម៖

## ឥទ្ធិពលជនជាតិដើមអាមេរិកទៅលើជនជាតិអាមេរិកទំនើប[១៧]

### សេចក្ដីផ្ដើម

១ នៅពេលជនជាតិអឺរ៉ុបដំបូងៗ បានចាប់ផ្ដើមតាំងទីលំនៅ នៅទ្វីបអាមេរិកខាងជើង ពួកគេបានពើបប្រទះនូវវប្បធម៌ថ្មីទាំងស្រុង នោះគឺ កុលសម្ព័ន្ធដើមអាមេរិក នៅទ្វីបអាមេរិកខាងជើង ។ ជនជាតិដើមអាមេរិក ដែលមានវប្បធម៌ ខ្ពង់ខ្ពស់គួរសម ច្បាស់ជាចង់ដឹងអំពីអាកប្បកិរិយា និងទំនៀមទម្លាប់របស់ជនអឺរ៉ុបដ៏ចម្លែក ដូចដែលជនជាតិអឺរ៉ុបចង់ដឹងអំពីជនជាតិដើមអាមេរិកដែរ ។ ជាធម្មតា នៅពេលដែលវប្បធម៌ពីរទាក់ទងគ្នា តែងតែមានការផ្លាស់ប្ដូរវប្បធម៌គ្នាទៅវិញទៅមក ។ ជនជាតិដើមអាមេរិក បានទទួលយកជាតុនៃវប្បធម៌ខ្លះរបស់ជនជាតិអឺរ៉ុប ហើយជនជាតិអឺរ៉ុបក៏បានប្រកាន់យកនូវទំនៀមទម្លាប់ប្រពៃណីខ្លះរបស់ជនជាតិដើមវិញដែរ ។ ជាលទ្ធផល ជនជាតិដើមអាមេរិក បានរួមចំណែកដ៏មានតម្លៃ ជាច្រើន ដល់វប្បធម៌អាមេរិកសម័យទំនើប ជាពិសេសផ្នែកភាសា សិល្បៈ ម្ហូបអាហារ និងរដ្ឋាភិបាល ។

### តួសេចក្ដី

២ <u>ជាបឋម</u> ជនជាតិដើមអាមេរិក បានបន្សល់ទុកនូវមរតកអចិន្ត្រៃយ៍ លើ**ភាសា**អង់គ្លេស។ អ្នកតាំងលំនៅដំបូងបានខ្ចីពាក្យពីភាសាដើមអាមេរិក ពីកុលសម្ព័ន្ធផ្សេងៗគ្នា ដើម្បីដាក់ឈ្មោះទីកន្លែងថ្មី និងវត្ថុថ្មីដែលពួកគេបានរកឃើញ នៅក្នុងទឹកដីថ្មីរបស់ពួកគេ ។ នៅក្នុងប្រទេសទាំងមូល គេអាចរកឃើញទីក្រុង

[១៧] (Oshima & Hogue, ២០០៦)

ធំៗ ទីប្រជុំជន ទន្លេ និងរដ្ឋនានា ដែលមានឈ្មោះតាមជនជាតិដើមអាមេរិក ។ ជាឧទាហរណ៍ រដ្ឋដេឡាវែរ (Delaware), អាយអូវ៉ា (Iowa), រដ្ឋអ៊ីលីណយ (Illinois) និង រដ្ឋអាល់ឡាបាម៉ា (Alabama) ត្រូវបានដាក់ឈ្មោះតាមកុលសម្ព័ន្ធអាមេរិកដើម និងទីក្រុងមួយចំនួន ដូចជាក្រុង*ឈីកាហ្គោ* (Chicago) *ម៉ៃអាមី* (Miami) និង *ស្ពូកាន* (Spokane) ។ បន្ថែមពីលើឈ្មោះទីកន្លែងនានា ភាសាអង់គ្លេសបានខ្ចីពាក្យប្រចាំថ្ងៃ ជាច្រើនពីភាសាអាមេរិកដើម ផ្សេងទៀតផងដែរ ។ ពាក្យថា សត្វកំប្រុក*ឈីបម៉ុន* (Chipmunk), សត្វក្តាន់ធំៗ*ម៉ូស* (Moose), សត្វសំពោច*រ៉ាក់ឃូន* (Raccoon), សត្វស្កុងឬ*ស្គែន* (Skunk), ថ្នាំជក់ (tobacco) និងត្រសក់(squash) គ្រាន់តែជាឧទាហរណ៍មួយចំនួន តែប៉ុណ្ណោះ។

៣ ថ្វីបើវាក្យសព្ទភាសាអង់គ្លេស បង្ហាញពីឥទ្ធិពលដ៏ខ្លាំងក្លានៃជនជាតិដើមអាមេរិកក៏ដោយ វាមិនមែនជាឥទ្ធិពលតែមួយគត់នៃវប្បធម៌អាមេរិក ដែលត្រូវបានផ្លាស់ប្តូរ ដោយការប្រាស្រ័យទាក់ទងជាមួយនឹងជនជាតិដើមអាមេរិកនោះទេ ។ **សិល្បៈ** គឺជាឥទ្ធិពលមួយទៀត ដែលបង្ហាញពីសញ្ញាណនៃទំនាក់ទំនងជនជាតិដើមអាមេរិក ។ កម្រាលពោមសត្វចៀម ដែលត្បាញដោយស្រ្តីនៃកុលសម្ព័ន្ធ*ណាវ៉ាហូ* នៅរដ្ឋ*អារីហ្សូណា* និងរដ្ឋ*ម៉ិកស៊ិកថ្មី* គឺជាស្នាដៃសិល្បៈដែលមានតម្លៃខ្ពស់នៅសហរដ្ឋអាមេរិក។ គួរបញ្ជាក់ផងដែរថា គ្រឿងអលង្ការជនជាតិដើមអាមេរិក ដែលធ្វើពីប្រាក់ និងត្បូងមរកត មានប្រជាប្រិយភាពនិងមានតម្លៃថ្លៃខ្លាំងណាស់។ ជាពិសេស នៅតំបន់ភាគខាងលិចនិងនិរតីនៃសហរដ្ឋអាមេរិក សិប្បកម្មរបស់ជនជាតិដើមអាមេរិក ដូចជា សិប្បកម្ម គ្រឿងស្មូន ផលិតផលស្បែក(សត្វ) និងសិប្បកម្មអង្កាំ អាចរកបាននៅក្នុងផ្ទះសម្បែង ជាច្រើន ។ ជាការពិត សិល្បៈនិងសិប្បកម្មជនជាតិដើម បានក្លាយជាចំណែកដ៏មានតម្លៃនៃវប្បធម៌អាមេរិក។

៤ ក្រៅពីភាសានិងសិល្បៈ **កសិកម្ម**គឺ ជាវិស័យមួយទៀត ដែលជនជាតិដើមអាមេរិក មានឥទ្ធិពលដ៏អស្ចារ្យនិងយូរអង្វែង។ ជាកសិករដ៏ជំនាញ ជនជាតិដើមអាមេរិកទាំងនោះបានបង្រៀនអ្នកចំណូលថ្មីនូវបច្ចេកទេសកសិកម្មនិងប្រភេទដំណាំ ជាច្រើន ។ សិស្សសាលាអាមេរិចគ្រប់រូប បានដឹង បានលឺ រឿងរ៉ាវអំពីរបៀប ដែលជនជាតិដើមអាមេរិក បានបង្រៀនអ្នកតាំងលំនៅដំបូង ឱ្យដាក់ត្រីស្អុយ នៅក្នុងរណ្តៅ ដើម្បីផ្តល់ជីដល់ដំណាំដែលដែលត្រូវដាំ ។ លើសពីនេះ ពួកគេបានបង្រៀនអ្នកតាំងលំនៅថ្មី ពីវិធីសាស្រ្តស្រោចស្រពនិងដាំដំណាំ វិលជុំ ។ លើសពីនេះ អាហារជាច្រើនដែលជនជាតិអាមេរិកញ៉ាំសព្វថ្ងៃនេះ ត្រូវបានជនជាតិដើមអាមេរិកជាអ្នកណែនាំដល់ជនជាតិអឺរ៉ុប ។ ជាឧទាហរណ៍ ដំឡូង ពោត សូកូឡា និងសណ្តែកដី មិនត្រូវបានគេស្គាល់នៅអឺរ៉ុប ពីមុនមកទេ ។ ឥឡូវនេះ ពួកវាបានក្លាយជាអាហារសំខាន់នៅក្នុងរបបអាហាររបស់អាមេរិក។

៥ ជាចុងក្រោយ មនុស្សមួយចំនួនអាចនឹងមានការភ្ញាក់ផ្អើលដែលដឹងថា ជនជាតិអាមេរិកក៏ជំពាក់បំណុលកុលសម្ព័ន្ធមួយ សម្រាប់ទម្រង់**រដ្ឋាភិបាល**របស់យើងដែរ ។ អ៊ីរ៉ូខួយ (Iroquois)ដែលជាកុលសម្ព័ន្ធដ៏ធំសម្បើមមួយ ដែលបែងចែកជាសាខា និងអនុសាខាតូចៗជាច្រើន (ហៅថា «ប្រជាជាតិ») បានបង្កើតប្រព័ន្ធរដ្ឋាភិបាល ដែលមានភាពស្មុគស្មាញខ្លាំង ដើម្បីការពារកុំអោយសាខានានារបស់កុលសម្ព័ន្ធនេះប្រយុទ្ធគ្នាស្លាប់រស់ ។ ក្នុងនោះ ប្រជាជាតិចំនួនប្រាំបានចូលរួមជាមួយគ្នា នៅក្នុងសហព័ន្ធមួយ ដែលមានឈ្មោះថា «សម្ព័ន្ធអ៊ីរ៉ូខួយ» ។ នៅក្រោមសម្ព័ន្ធមួយនេះ ប្រជាជាតិនីមួយៗ មានស្វ័យភាពក្នុងការដំណើរការកិច្ចការផ្ទៃក្នុងរបស់ខ្លួន ប៉ុន្តែប្រជាជាតិទាំងអស់ បានរួមគ្នាជាអង្គភាពមួយ នៅពេលដោះស្រាយជាមួយ

អ្នកខាងក្រៅ ។ ជាលទ្ធផល សម្ព័ន្ធនេះបានការពារអ៊ីរ៉ូខូស ពីការប្រយុទ្ធគ្នា រវាងគ្នាឯង និងមានឥទ្ធិពលក្នុងទំនាក់ទំនងការទូតជាមួយកុលសម្ព័ន្ធដទៃទៀត ។ នៅពេលដែលដែនដីអាណានិគមអាមេរិកទាំង ១៣ កំពុងពិចារណាថាតើត្រូវបង្កើតរដ្ឋាភិបាលប្រភេទណា ក្រោយទទួលបានឯករាជ្យពីចក្រភពអង់គ្លេស មានគេណែនាំថាពួកគេគួរប្រើប្រព័ន្ធមួយ ដែលស្រដៀងនឹងសម្ព័ន្ធអ៊ីរ៉ូខូយ ។ នៅក្រោមប្រព័ន្ធនេះ ដែនដីអាណានិគម ឬរដ្ឋនីមួយៗ នាពេលអនាគត នឹងមានស្វ័យភាពក្នុងការគ្រប់គ្រងកិច្ចការផ្ទាល់ខ្លួន ប៉ុន្តែនឹងរួមកម្លាំងជាមួយរដ្ឋផ្សេងទៀត ដើម្បីដោះស្រាយបញ្ហារួម ដែលទាក់ទងនឹងពួកគេទាំងអស់។ នេះពិតជាអ្វីដែលបានកើតឡើងមែន ។ ជាលទ្ធផល ទម្រង់បែបបទរដ្ឋាភិបាលបច្ចុប្បន្នរបស់សហរដ្ឋអាមេរិក អាចត្រូវបានឆ្លុះបញ្ចាំងដោយផ្ទាល់ទៅនឹងគំរូជនជាតិដើមអាមេរិក ។

**សេចក្តីសន្និដ្ឋាន**

៦ សរុបរួមមក យើងអាចមើលឃើញឧទាហរណ៍ខ្លះៗ នៃវិសាលភាពនៃឥទ្ធិពលជនជាតិដើមអាមេរិកយ៉ាងងាយស្រួលជាពិសេស ឥទ្ធិពលលើ**ភាសា** ទម្រង់**សិល្បៈ** ទម្លាប់នៃ**ការញ៉ាំ** និង**រដ្ឋាភិបាល**របស់យើង ។ ជនជាតិអាមេរិកសម័យទំនើបពិតជាជំពាក់គុណអាមេរិកដើម សម្រាប់ការចូលរួមចំណែកដល់វប្បធម៌របស់ពួកគេ។ សង្ឃឹមថា នៅថ្ងៃណាមួយ ការផ្លាស់ប្តូរវប្បធម៌ នឹងផ្តល់ភាពវិជ្ជមាន សម្រាប់ពួកគេ ដូចគ្នាៗ ៕

**សេចក្តីណែនាំសម្រាប់សរសេរកិច្ចការសង្ខេបមេរៀនជាក្រុម**

- ☐ ប្រើ**ក្រដាសទំហំ** A4
- ☐ សម្រាប់**គំរបកិច្ចការ** ត្រូវប្រើគំរូគំរប * ដែលភ្ជាប់មកជាមួយ ឬបង្ហោះក្នុងក្រុមហ្វេសប៊ុកសម្រាប់មុខវិជ្ជាទ្រឹស្តីប្រវត្តិសាស្ត្រ ។
- ☐ ចូររៀបចំដាក់ **មាតិកា** បន្ទាប់ពី ក្របសៀវភៅ ។
- ☐ ត្រូវប្រើ**ពុម្ពអក្សរខ្មែរយូនីកូដ** (Khmer Unicode)
  - ✓ សម្រាប់ជំពូកមេរៀន
    ចូរប្រើពុម្ពអក្សរ Khmer OS Muol Light ទំហំ **១៦** តំរឹម កណ្តាល
  - ✓ សម្រាប់ចំណងជើងកម្រិតទី១

ចូរប្រើពុម្ពអក្សរ Khmer OS Muol ទំហំ **១៤**តំរឹមឆ្វេង

  - ✓ សម្រាប់ចំណងជើងកម្រិតទី២
    ចូរប្រើពុម្ពអក្សរ Khmer OS Muol Pali ទំហំ**១២** តំរឹមឆ្វេង (ចូលបន្ទាត់ One Tab)
  - ✓ សម្រាប់ខ្លឹមសារអត្ថបទជាភាសាខ្មែរ
    ប្រើ Khmer OS Metal Chrieng ទំហំ **១២**តំរឹមសង្ខាង
  - ✓ សម្រាប់ខ្លឹមសារអត្ថបទ ឬ ពាក្យក្នុងវង្ងង់ក្រចក ជាពាក្យអង់គ្លេស
    ចូរប្រើពុម្ពអក្សរ (Times New Roman) ទំហំ **១១**

- ☐ ចូរសរសេរសង្ខេបត្រឹម **៥ ទៅ ៧ ទំព័រ** ដោយដាក់លេខទំព័រនៅខាងលើផ្នែកខាងស្តាំ ហើយមិនចាំបាច់ដាក់ Header ឬ Footer ទេ ។ (មិនលើសពី ១០ ទំព័រឡើយ)
- ☐ ចន្លោះបន្ទាត់នីមួយៗត្រូវប្រើ **១.៥** (Line and Paragraph Spacing)
- ☐ ចូររៀបចំសរសេរ**សេចក្តីផ្តើម** និង**សេចក្តីសន្និដ្ឋាន**ផង ។

គួរកត់សម្គាល់ថា សេចក្តីផ្តើមត្រូវមានធាតុពីរ៖ ទាក់ទាញចំណាប់អារម្មណ៍អ្នកអាន និងប្រាប់គំពោងសំណោរដល់អ្នកអានថាសេចក្តីសង្ខេបនេះនឹងផ្តោតលើចំនុចអ្វីខ្លះ។ រីឯសេចក្តីសន្និដ្ឋានត្រូវសរុបឡើងវិញនូវចំនុចសំខាន់ៗ ដែលត្រូវបានលើកមកពិភាក្សាក្នុងតួសេចក្តី ហើយចុងបញ្ចប់ត្រូវបង្ហាញចំណាប់អារម្មណ៍របស់ក្រុមលើសៀវភៅត្រូវសង្ខេប ពិសេសឆ្លុះបញ្ចាំងទ្រឹស្តីប្រវត្តិសាស្ត្រដែលបានរៀន ។

- ☐ ចូរអនុវត្តតាមសេចក្តីណែនាំនេះឲ្យបានខ្ជាប់ខ្ជួន បើមិនដូច្នោះ ការងារអ្នកអាចត្រូវបដិសេធន៍មិនទទួល និងតម្រូវអោយធ្វើឡើងវិញ។

## ទម្រង់វាយតម្លៃកិច្ចការសង្ខេប និងបទបង្ហាញក្រុម

និស្សិតក៏ត្រូវរៀបចំកិច្ចការក្រុម ទាំងសំណោរតែងសេចក្តី និងបទបង្ហាញអោយបានល្អ ។ ដូច្នេះ ចូរសិក្សាទម្រង់វាយតម្លៃកិច្ចការសង្ខេប និងទម្រង់វាយតម្លៃបទបង្ហាញខាងក្រោម៖

### ទម្រង់វាយតម្លៃកិច្ចការសង្ខេប

| ផ្នែកទី ១ ៖ ការផ្តោតចំចំណុចសំខាន់ៗ | | ពិន្ទុ (៣០%) |
|---|---|---|
| ១ | តើមានសេចក្តីផ្តើមគួរឲ្យចាប់អារម្មណ៍ដែរឬទេ? | .../០៥ |
| ២ | តើនៅក្នុងសេចក្តីផ្តើម មានឃ្លាឬប្រយោគប្រាប់ថាកិច្ចការសង្ខេបនេះនឹងពិភាក្សាពីអ្វីខ្លះដែរឬទេ? | .../០៥ |
| ៣ | តើកិច្ចការនេះផ្តោតចំៗលើខ្លឹមសារគោលដែរឬទេ? | .../១០ |
| ៤ | តើចុងបញ្ចប់មានសេចក្តីសន្និដ្ឋានឬសរុបខ្លឹមសាររួមឡើងវិញដែរឬទេ? | .../១០ |
| **ផ្នែកទី ២ ៖ ការពន្យល់ព័ត៌មានពិស្តារ និងការឆ្លុះបញ្ចាំងទ្រឹស្តី** | | **ពិន្ទុ (៤០%)** |
| ៥ | តើកិច្ចការសង្ខេបនេះបានពន្យល់យ៉ាងត្រឹមត្រូវ នូវអ្វីដែលអ្នកនិពន្ធចង់បង្ហាញដែរឬទេ? | .../១០ |
| ៦ | តើវាបញ្ចូលគម្រោងមេរៀនពេញលេញ ដោយមិនសល់ផ្នែកណាមួយ ដែរឬទេ? | .../០៥ |
| ៧ | តើនៅក្នុងកថាខ័ណ្ឌនីមួយៗ មានគំនិតសំខាន់នឹងប្រយោគគាំទ្រចំណុចសំខាន់នោះដែរឬទេ? | .../១០ |
| ៨ | តើសេចក្តីសង្ខេបនេះមានការឆ្លុះបញ្ចាំងទ្រឹស្តីប្រវត្តិសាស្ត្រដែលបានរៀនកន្លងមក ដែរឬទេ? | .../០៥ |

| | | |
|---|---|---|
| ៩ | តើវាធ្លុះបញ្ចាំងទ្រឹស្តីប្រវត្តិសាស្ត្រណា? (ចូរសរសេរនៅទីនេះ៖ ..................................) ហើយមានការពន្យល់និងផ្តល់ហេតុផលបានល្អកម្រិតណា? | .../១០ |
| **ផ្នែកទី ៣ ៖ យន្តការ និងរបៀបរបបការងារ** | | **ពិន្ទុ (៣០%)** |
| ១០ | តើសេចក្តីសង្ខេបមានបញ្ចូលព័ត៌មានគ្រួសៗពីសៀវភៅ (អ្នកនិពន្ធ ឆ្នាំបោះពុម្ព...) និងមាតិកាដែរឬទេ? | .../១០ |
| ១១ | តើមានសញ្ញាណបញ្ជាក់ពីជំនាញសរសេរ និង ការសហការល្អ ក្នុងក្រុម ដែរឬទេ?<br>(សមាជិកបានពិភាក្សាគ្នា សំណេរមានលំហូរល្អ ពីផ្នែកមួយទៅមួយទៀត អក្ខរាវិរុទ្ធត្រឹមត្រូវ សំណង់ឃ្លាច្បាស់...) | .../១០ |
| ១២ | តើវាមានរបៀបរបបត្រឹមត្រូវល្អដែរឬទេ៖ (ក្របសៀវភៅ ពុម្ពនិងទំហំអក្សរ ចំណងជើង(រង) លេខទំព័រ...)? | .../១០ |
| **ពិន្ទុសរុប ៖** | | **/១០០%** |

**ទម្រង់វាយតម្លៃបទបង្ហាញក្រុម**

| | | |
|---|---|---|
| **ផ្នែកទី ១ ៖ រចនាសម្ព័ន្ធ និងការរៀបចំ** | | **ពិន្ទុ (៣០%)** |
| ១ | តើបទបង្ហាញនេះ មានសេចក្តីផ្តើមល្អ គួរឲ្យចាប់អារម្មណ៍? | .../០៥ |
| ២ | តើមានការប្រាប់ព័ត៌មានគ្រួសៗពីសៀវភៅ (អ្នកនិពន្ធ ឆ្នាំបោះពុម្ព ចំនួនផ្នែក...)ដល់ទស្សនិកជនដែរឬទេ? | .../០៥ |
| ៣ | តើវាគ្មិនទាំងអស់មានជំនាញធ្វើបទបង្ហាញបានល្អកម្រិតណា? (ភ្នែកសម្លឹងមើលទស្សនិកជន កាយវិការ ជំនឿជាក់លើខ្លួនឯង ប្រើឃ្លាឬប្រយោគណែនាំសម្រាប់ផ្នែកនីមួយៗ) | .../០៥ |
| ៤ | តើវាគ្មិនប្រើប្រាស់ស្លាយឬក្តារខៀនប្រកបដោយប្រសិទ្ធិភាពខ្ពស់ដែរឬទេ? (ទំហំអក្សរងាយមើលបាន ពុម្ពអក្សរស៊ីគ្នា អក្ខរាវិរុទ្ធត្រឹមត្រូវ មិនមានព័ត៌មានស្មុកស្មាញពេកក្នុងស្លាយនីមួយៗ ...) | .../០៥ |
| ៥ | តើមានរូបភាព ផែនទី និមិត្តសញ្ញា ឬតារាងផ្សេងៗ ដើម្បីជួយអ្នកស្តាប់ឲ្យឆាប់យល់ដែរឬទេ? | .../០៥ |
| ៦ | តើបទបង្ហាញនេះ មានសេចក្តីសន្និដ្ឋាន ឬការសរុបសេចក្តីរួម ច្បាស់លាស់និងត្រឹមត្រូវដែរឬទេ? | .../០៥ |
| **ផ្នែកទី ២ ៖ ការពន្យល់ព័ត៌មានពិស្តារ និងការឆ្លុះបញ្ចាំងទ្រឹស្តី** | | **ពិន្ទុ (៥០%)** |
| ៧ | តើបទបង្ហាញក្តោបគ្រប់ជំពូកឬចំណុចសំខាន់ៗនៃសៀវភៅដែរឬទេ? | .../០៥ |
| ៨ | តើវាគ្មិននីមួយបានពន្យល់ពីខ្លឹមសារឬចំណុចរបស់ខ្លួន ដោយក្បោះក្បាយ ងាយយល់ដែរឬទេ? | .../៣៥ |
| | វាគ្មិនទី១ (...) + វាគ្មិនទី ២ (...) + វាគ្មិនទី ៣ (...) + វាគ្មិនទី ៤ (...) + វាគ្មិនទី៥= | .../៣៥ |

| | | |
|---|---|---|
| ៩ | តើមានការឆ្លុះបញ្ចាំងទ្រឹស្ដីប្រវត្តិសាស្ត្រច្បាស់លាស់ដែរឬទេ? ទ្រឹស្ដីណា? ហេតុអ្វី? | .../១០ |
| | (ពាក្យគន្លឹះរបស់ទ្រឹស្ដី ប្រភពឯកសារត្រូវបានប្រើប្រាស់ ចំនុចពិសេសដែលវាគ្មិនចូលចិត្ត ឬចង់បន្ថែម? ...) | |
| **ផ្នែកទី ៣ ៖ យន្តការ និងរបៀបរបបការងារ** | | **ពិន្ទុ (៣០%)** |
| ១០ | តើបទបង្ហាញប្រព្រឹត្តទៅតាមរយៈពេលកំណត់ ( ២០-៣០* នាទី) ដែរឬទេ? | .../០៥ |
| ១១ | តើក្រុមនេះឆ្លើយសំណួរបានត្រឹមត្រូវ និងក្បោះក្បាយដែរឬទេ? | .../១០ |
| ១២ | តើមានសញ្ញាណបញ្ជាក់ការសហការល្អក្នុងក្រុមដែរឬទេ? | |
| | សមាជិកក្រុមបានពិភាក្សានិងសំយោគកិច្ចការជាមុន និងយល់ដឹងពីចំនុចរបស់គ្នា មានការបែងចែកគ្នាឆ្លើយ...?សំណួរ) | .../០៥ |
| **ពិន្ទុសរុប ៖** | | **/១០០%** |

## វិធីសាស្ត្រធ្វើបទបង្ហាញ និងដំណាក់កាលត្រួតពិនិត្យនិងវាយតម្លៃកិច្ចការក្រុម

ហេតុមកដល់ត្រឹមនេះ និស្សិតបានរៀនចេះសង្ខេបមេរៀនឬសៀវភៅ ដោយសរសេរជាកថាខ័ណ្ឌ និងអត្ថបទសង្ខេប ដូចតែងសេចក្ដីជាដើម។ ជំហានបន្ទាប់និស្សិតត្រូវធ្វើបទបង្ហាញលទ្ធផលកិច្ចការក្រុមរបស់ខ្លួន។ ខាងក្រោមនេះ គឺជាសេចក្ដីណែនាំលម្អិត មួយជំហានម្ដងៗ សម្រាប់ធ្វើជាគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកិច្ចការក្រុម ។

### ១. បើក



**ក. វគ្គរៀបចំសណ្ដាប់ធ្នាប់ក្នុងថ្នាក់** (ប្រាប់មិត្តរួមថ្នាក់ឲ្យផ្ទៀងស្ដាប់ និងត្រៀមសំណួរ និងហាមឡូឡារំខាន ចុចម្វូត បិទសម្លេង...)

**ខ. វគ្គសំណេះសំណាល៖**

- សួរប្រធានក្រុមវាគ្មិនថាតើសមាជិកមក**ជុំគ្នា**ហើយឬនៅ ជាដើម?
- សំណេះសំណាលនិង**សំរួលអារម្មណ៍**វាគ្មិនដោយនិយាយសួរសុខទុក្ខ...និងប្រាប់លក្ខ័ណ្ឌនានា*
- បទបង្ហាញគួរធ្វើឡើងក្នុងចន្លោះ **៣០ - ៣៥ នាទី** ។ គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃ(គ.ត.វ.) អាចអនុញ្ញាតថែមឬថយ ៥ នាទី តាមការចាំបាច់។
- បញ្ជាក់តួនាទីគ.ត.វ.នីមួយៗផង៖ គ.ត.វ.ណាទទួលខុសត្រូវខាងថតវីដេអូ, ផ្ទៀងផ្ទាត់ម៉ោង, សម្របសម្រួលវគ្គសំណួរចម្លើយ ឬ វាយតម្លៃរួម។

**គ. ប្រកាសបើក** (ចាប់ផ្ដើមចុចថតវីដេអូ- Start recording)

បញ្ជាក់៖ **ប្រការគួរ និងពុំគួរ សម្រាប់ក្រុមវាគ្មិន**

**គួរ៖**

១ និយាយលឺៗ ក្នុងល្បឿនល្មមអាចស្ដាប់បាន

២ ប្រើកាតកត់ចំណាំ

៣ និយាយពន្យល់

៤ ពន្យល់ខ្លឹមសារក្នុងសៀវភៅត្រូវសង្ខេប

៥ ហាត់ឡើងនិយាយ ដើម្បីជានាថាខ្លួនយល់និងអាចធ្វើបានល្អ និងទាន់ពេល

៦ ធ្វើចលនាចុះឡើង

៧ ដើរចូលមកនិយាយកណ្ដាលថ្នាក់

៨ សម្លឹងមើលទស្សនិកជនជារឿយៗ

៩ លើកយកតែចំណុចសំខាន់មកនិយាយ ចាប់អារម្មណ៍លើអ្វី? និយាយតាមហ្នឹងមក

១០ នៅលើស្លាយ ឬក្ដារខៀន សរសេរច្បិចតែខ្លឹមសារគោល

១១ សរសេរសេចក្ដីផ្ដើមដោយឡែកសម្រាប់សេចក្ដីសង្ខេប

១២ ពិភាក្សាគ្នាលើ៖ស្ទីលនៃការសរសេរសៀវភៅ, ប្រភពព័ត៌មាន

១៣ ការឆ្លុះបញ្ចាំងទ្រឹស្ដី ៖ យល់យ៉ាងម៉េចដែរចំពោះខ្លឹមសារនៃសៀវភៅ? យល់ស្របឬមិនយល់ស្រប? ហេតុអ្វី?

**ពុំគួរ៖**

១ កាន់ឬអានសៀវភៅឬកិច្ចការសង្ខេបទាំងមូល

២ និយាយបន្ថែមលើចំណុច

៣ និយាយតិចៗ ស្ដាប់មិនបាន

៤ ចម្លងអត្ថបទឬឃ្លាទាំងស្រុង យកទៅដាក់ លើស្លាយឬ សរសេរនៅលើក្ដារខៀន

៥ យកសេចក្តីផ្តើមក្នុងសៀវភៅមកធ្វើជាសេចក្តីផ្តើមរបស់សេចក្តីសង្ខេបនៃក្រុមខ្លួនផ្ទាល់




## ២. ដំណើរការបទបង្ហាញ

**ក. វគ្គវាយតម្លៃវាគ្មិន៖** ក្រោយបទបង្ហាញចប់ ចាប់ផ្តើម**វាយតម្លៃ ១ ទល់ ១**
(«គ.ត.វ.» ម្នាក់ វាយតម្លៃវាគ្មិនម្នាក់ ដោយផ្តើមពីចំណុចវិជ្ជមាន
បន្ទាប់មកចង្អុលបង្ហាញពីចំណុចអវិជ្ជមានដល់វាគ្មិន)

**ខ. វគ្គសំណួរនឹងចម្លើយ៖** «គ.ត.វ.» ចាប់ផ្តើមបើកវគ្គសំណួរនិងចម្លើយ
ដោយបើកឱកាសអោយមិត្តរួមថ្នាក់សួរសំណួរទៅកាន់វាគ្មិន។ ក្រោយបានបីសំណួរ, «គ.ត.វ.»
អោយវាគ្មិនចេញទៅក្រៅ ៥ នាទី ដើម្បីពិភាក្សាគ្នា រកចម្លើយ ។ ក្រោយចប់វគ្គ «គ.» ៥នាទីកន្លងផុត
«គ.រ.វ.»អញ្ជើញ**វាគ្មិនមកឆ្លើយសំណួរ** ហើយសួរម្ចាស់សំណួរថាតើពួកគេទទួលបានចម្លើយដែរឬទេ។

**គ. វគ្គវាយតម្លៃគ.ត.វ.៖** កំឡុងពេល៥នាទីនេះ «គ.ត.វ.»នឹងត្រូវទទួល**មតិលើកទឹកចិត្តនិងកែលំអរ**ពីមិត្តរួមថ្នាក់ ។ គ្រូចូលមកសម្របសម្រួល។

បញ្ជាក់៖ **ប្រការគួរ និងពុំគួរ សម្រាប់ក្រុមគណៈកម្មការ**
**គួរ៖**

១ ត្រួតពិនិត្យមើលទទួលបានឯកសារគ្រប់គ្រាន់ពីក្រុមវាគ្មិន (សេចក្តីសង្ខេប និងទម្រង់វាយតម្លៃ)

២ អានអត្ថបទសង្ខេប និងបំពេញទម្រង់វាយតម្លៃជាមុន មុនពេលមកថ្នាក់

៣ បែងចែកកិច្ចការគ្នា គណៈកម្មការរូបណាជាប្រធានក្រុម អ្នកណាត្រួតពិនិត្យមើលវាគ្មិនរូបណា

៤ កំណត់និងផ្ទៀងម៉ោងសម្រាប់បទបង្ហាញ

៥ អោយយោបល់លើសេចក្តីសង្ខេបផង (ពិសេសពិនិត្យមើលតាមទម្រង់វាយតម្លៃ)

**ពុំគួរ៖**

១ ហាមកាន់សៀវភៅឬកិច្ចការសង្ខេបទាំងមូលមកអាន

២ ហាមអានតាមស្លាយខ្លាំងពេក ញឹកញាប់ពេក

៣ និយាយបន្ថែមលើចំណុច

៤ និយាយតិចៗ ស្តាប់មិនបាន

### ៣. បិទ




**ក. វគ្គវាយតម្លៃរួម៖** បន្ទាប់មក «គ.ត.វ.» ពិភាក្សាគ្នានិងវាយតម្លៃរួមទៅលើបទបង្ហាញទាំងមូល៖

- **និទ្ទេស៖** ប្រសើរណាស់, ល្អណាស់, ល្អ, ល្អបង្គួរ, មធ្យម, ខ្សោយ, ខ្សោយណាស់...
- **មូលហេតុសំខាន់ៗសំរាប់និទ្ទេសនីមួយៗ ៖**

ខ. ចុងក្រោយ **ប្រកាសបិទ** (និងចុច Stop recording)

**រំលឹក៖ គណៈកម្មការត្រួតពិនិត្យនិងវាយតំលៃត្រូវ**

- ចូរចូលទៅ«**តារាងបែងចែកកិច្ចការក្រុម**» ដើម្បីដាក់ពិន្ទុកិច្ចការក្រុម (តាមតំណភ្ជាប់ដែលចែកជូន)
- គួរថតវីដេអូ(Record)បទបង្ហាញទាំងមូល ជាពីរដំណាក់កាល៖
  ភាគ ១ សំរាប់បទបង្ហាញក្រុមទាំងមូល និង ភាគ ២ សំរាប់មតិយោបល់និងសំណួរ&ចំលើយ ។
- ចូរដោនឡូដវីដេអូទាំងពីរភាគយកទៅបង្ហោះក្នុងក្រុមហ្វេសប៊ុកសំរាប់មុខវិជ្ជា ។

# មេរៀនទី ១៣ ៖ វិធីបែងចែកប្រភពឯកសារ

ប្រភពឯកសារផ្សេងៗ អាចជួយយើងសម្រាប់តាក់តែងប្រវត្តិសាស្ត្របម្ញើកិច្ចការសាលាបាន ប៉ុន្តែ មិនមែនប្រភពឯកសារទាំងអស់សុទ្ធតែមានសារៈសំខាន់ និងតម្លៃដូចគ្នានោះទេ ។ ដូចនេះ ដើម្បីមានភាពងាយស្រួលក្នុងការសិក្សា និងស្រាវជ្រាវ ប្រវត្តិវិទូបានបែងចែកភស្តុតាងប្រវត្តិសាស្ត្រជាពីរប្រភេទ៖ ប្រភពឯកសារដើម (Primary Sources) និងប្រភពឯកសារទីពីរ(Secondary Sources)។

## ១៣.១. ប្រភពឯកសារដើម

ជាប្រភេទឯកសារកើតចេញពីសម័យកាលដែលប្រវត្តិវិទូកំពុងសិក្សា ក្នុងនោះមានដូចជា កំណត់ហេតុផ្ទាល់ខ្លួន ឯកសាររដ្ឋាភិបាល ឯកសារកាលប្បវត្តិ ប្រវត្តិសាស្ត្រផ្ទាល់មាត់ និងប្រពៃណី ភស្តុតាងបុរាណវិទ្យានិងជីវសាស្ត្រ ផ្ទាំងគំនូរ និងរូបថត ។ លោក លេអូផូល វ៉ុន រ៉ែងឃ័រ បិតាប្រវត្តិសាស្ត្រមុខវិជ្ជាប្រវត្តិសាស្ត្រសម័យថ្មីគិតថា ឯកសាររដ្ឋាភិបាលមានស្តង់ដារល្អជាងគេ ប៉ុន្តែ វាអាចបង្ហាញតែព្រឹត្តិការណ៍ខ្លះ ហើយបិទបាំងព្រឹត្តិការណ៍ឬហេតុការណ៍ផ្សេងទៀត ។

## ១៣.២. ប្រភពឯកសារទីពីរ

ឯកសារប្រភេទនេះមានដូចជា សៀវភៅពុម្ព អត្ថបទនានាទូទៅ អត្ថបទទស្សនាវដ្ដីសិក្សា សព្វវចនាធិប្បាយ(encyclopedia) ដែលត្រូវបានអ្នកនិពន្ធសរសេរឡើង ដោយផ្អែកលើប្រភពឯកសារដើម ។ គុណភាពរបស់វាអាស្រ័យលើវិធីសាស្ត្រ ដែលអ្នកនិពន្ធចេះប្រើប្រាស់ និងបកស្រាយការពិតនៃហេតុការណ៍ណាមួយ ។ ជួនកាល ប្រភពឯកសារទីពីរ អាចក្លាយជាប្រភពឯកសារដើមដ៏ល្អសម្រាប់មនុស្សជំនាន់ក្រោយ ។

ប្រភពឯកសារទាំងពីរមានតម្លៃនិងសារៈប្រយោជន៍ផ្សេងគ្នា ដោយអាស្រ័យទៅតាមកាលៈទេសៈ។

### គំនូសបំព្រួញភាពខុសគ្នារវាងប្រភពឯកសារដើម និងប្រភពឯកសារទីពីរ

| ប្រភព | ឯកសារដើម | ឯកសារទីពីរ |
|---|---|---|
| ១ | ត្រូវបានបង្កើតឡើង ដោយអ្នកពាក់ព័ន្ធផ្ទាល់ | ដោយអ្នកមិនបានពាក់ព័ន្ធផ្ទាល់ |
| ២ | ...ក្នុងកំឡុងពេលចង់សិក្សា | ...ក្រោយកំឡុងពេលចង់សិក្សា |
| ៣ | ជាភស្តុតាងផ្ទាល់ | ភស្តុតាងមិនផ្ទាល់ (យោងពីឯកសារដើម) |
| ៤ | កាសែត(កំឡុងពេលព្រឹត្តិការណ៍)  | កាសែត(ក្រោយព្រឹត្តិការណ៍យូរ)  |
| ៥ | កំណត់ហេតុប្រចាំថ្ងៃ  | សៀវភៅពុម្ព  |
| ៦ | ចម្រៀង  | សព្វវចនានុក្រម  |
| ៧ | រូបគំនូរ  | ជីវប្រវត្តិ  |

| | | |
|---|---|---|
| ៨ | រូបថត | អត្ថបទស្រាវជ្រាវ |
| ៩ | សំបុត្រ | វីដេអូឯកសារ |
| ១០ | សុន្ទរកថា | |

## ១៣.៣. លំហាត់បែងចែកប្រភពឯកសារ

ខាងក្រោមនេះជាលំហាត់បែងចែកប្រភពឯកសារយោង ។ និស្សិតចូលរួមជាក្រុម ពិនិត្យមើលប្រភពឯកសារនីមួយៗ ហើយពិភាក្សាគ្នាសម្រេចថា ឯកសារណាជាឯកសារដើម ឬទីពីរ? និស្សិតគួរស្វែងយល់ពីគន្លឹះក្នុងការធ្វើលំហាត់ទាំងនេះ ៖ លក្ខណៈវិនិច្ឆ័យនៃប្រភេទប្រភពឯកសារនីមួយៗ មានអ្វីខ្លះ ។

### ១៣.៣.១. លំហាត់ទី ១

ប្រធានបទ ៖ ប្រវត្តិវិទូម្នាក់កំពុងតែសិក្សាស្រាវជ្រាវ អំពីរាជវង្សានុវង្ស ក្នុងចក្រភពអង់គ្លេស នៅ ទសវត្សឆ្នាំ ១៩៨០ ។ គាត់បានប្រមូលប្រភពឯកសារជាច្រើន ដូចមានក្នុងបញ្ជីខាងក្រោម ។ ក្នុងករណីនេះ តើឯកសារណាខ្លះជាប្រភពឯកសារដើម ? ហើយណាខ្លះទៀត ជាប្រភពឯកសារទីពីរ ? ចូរគូសរង្វង់លើចម្លើយត្រឹមត្រូវ (ចូរមើលឧទាហរណ៍លំហាត់ទី ១.១)

| ល.រ. | ប្រភពឯកសារ | ឯកសារ | |
|---|---|---|---|
| ១.១ | កំណត់ហេតុប្រចាំថ្ងៃ, ដោយម្ចាស់ក្សត្រី Diana ក្នុងឆ្នាំ ១៩៨៥ ។ | ដើម | ទីពីរ |
| ១.២ | សៀវភៅ៖ ប្រាយអិន អេ. ប៊ូរែល, ខ្ញុំគឺជាអ្នកបម្រើផ្ទាល់របស់ព្រះមហាក្សត្រិយ៍៖ ចម្លើយសារភាពរបស់លោក Brian Burrell, បោះពុម្ពដោយរោងពុម្ព Penguin Press, នៅក្រុងឡុងដ៍, ២០០៤ ។ | ដើម | ទីពីរ |
| ១.៣ | រូបថត៖ ពិធីខួបកំណើតឆ្នាំទីបួនរបស់ព្រះអង្គម្ចាស់វីលៀម, នៅរាជដំណាក់ Windsor, ៤ មករា ១៩៨៧ ។ | ដើម | ទីពីរ |
| ១.៤ | អត្ថបទកាសែត៖ William Black, នៅខាងក្នុងព្រះរាជវាំង, The Times, London, ៤ មេសា ១៩៨២ | ដើម | ទីពីរ |
| ១.៥ | អត្ថបទកាសែត៖ William Black, 'អាថ៌កំបាំងនៃរាជវង្សានុវង្ស ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០, "Daily Telegraph, ១៩ កញ្ញា ២០០០។ | ដើម | ទីពីរ |
| ១.៦ | សៀវភៅ៖ Faith A. Kimbal, ប្រវត្តិនៃចក្រភពអង់គ្លេស, ១៩៦៥ -១៩៩០, Cambridge University Press, Cambridge, ឆ្នាំ ១៩៩៣ ។ | ដើម | ទីពីរ |
| ១.៧ | កំណត់ហេតុផ្ទាល់ខ្លួនប្រចាំថ្ងៃ៖ របស់ព្រះមហាក្សត្រិយ៍ អេលីហ្សាប៊ែតទី២ ឆ្នាំ ១៩៩៨ ។ | ដើម | ទីពីរ |

| | | | |
|---|---|---|---|
| ១.៨ | បទសំភាសន៍ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ ជាមួយ Lucy Grawell (លេខាផ្ទាល់របស់ព្រះមហាក្សត្រិយ៍), ធ្វើដោយ Percy Price សម្រាប់ការតម្កល់ក្នុង បណ្ណាល័យអង់គ្លេស, ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៥ ។ | ដើម | ទីពីរ |
| ១.៩ | សៀវភៅ៖ ក្ដីស្រលាញ់របស់យើងចំពោះទ្រង់, រូបថតមហាក្សត្រិយ៍អេលីហ្សាប៊ែតទី២ នាពេលកន្លងមក, Puffin ទីក្រុងឡុងដ៍, ឆ្នាំ ១៩៩៨ ។ | ដើម | ទីពីរ |
| ១.១០ | អត្ថបទទស្សនាវដ្ដី៖ «ពិធីខួបកំណើតឆ្នាំទីបួននៃព្រះអង្គម្ចាស់ វីល្លៀម៖ រយៈពេលម្ភៃឆ្នាំកន្លងមក» ទស្សនាវដ្ដីWHO, ៧ មករា ២០០៧ | ដើម | ទីពីរ |
| ១.១១ | សៀវភៅ៖ Roger Fieldman, ប្រវត្តិសាស្ត្រនៃប្រទេសអង់គ្លេស, ១៦៦៦ - ២០០០, សាកលវិទ្យាល័យ Oxford, ក្រុង Oxford, ២០០៤ ។ | ដើម | ទីពីរ |

### ១៣.៣.២. លំហាត់ទី ២

ប្រធានបទ ៖ ប្រវត្តិវិទូម្នាក់កំពុងសិក្សាពីបទពិសោធន៍របស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម ។ លោកស្រីមានប្រភពឯកសារដូចខាងក្រោម ។ តើឯកសារណាខ្លះជាប្រភពឯកសារដើម ? ហើយណាខ្លះទៀតជាប្រភពឯកសារទីពីរ ? ចូរគូសរង្វង់លើចម្លើយត្រឹមត្រូវ ។

| ល.រ. | ប្រភពឯកសារ | ឯកសារ | |
|---|---|---|---|
| ២.១ | សម្ភាសប្រវត្តិសាស្ត្រផ្ទាល់មាត់៖ ជាមួយ សមមិត្ត សុង សុខា ដែលជាកម្មាភិបាលនៅខេត្តកំពង់ធំ ក្នុងកំឡុងឆ្នាំខ្មែរក្រហម, ឆ្នាំ ១៩៩៥ | ដើម | ទីពីរ |
| ២.២ | សៀវភៅពុម្ព៖ Adrian Vickers, ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ នៅសតវត្សរ៍ទី ២០ ដែលចេញផ្សាយក្នុងឆ្នាំ ២០០៥ ។ | ដើម | ទីពីរ |
| ២.៣ | រូបថតឆ្នាំ ១៩៧៥៖ «ខ្មែរក្រហមចូលរាជធានីភ្នំពេញ» | ដើម | ទីពីរ |
| ២.៤ | បញ្ជីអត្រានុកូលដ្ឋាន៖ ភូមិកោះធំ ខេត្តកណ្ដាល, ១៩៥៥ - ១៩៨៥ | ដើម | ទីពីរ |
| ២.៥ | អត្ថបទទស្សនាវដ្ដី៖ រម្លឹករឿងខ្មែរក្រហម, ទស្សនាវដ្ដី Time, USA: ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៩ ។ | ដើម | ទីពីរ |
| ២.៦ | សៀវភៅ៖ DC-CAM, រូបថតនៃប្រទេសកម្ពុជា សម័យខ្មែរក្រហម,ចេញផ្សាយក្នុងឆ្នាំ ២០០២ ។ | ដើម | ទីពីរ |
| ២.៧ | របាយការណ៍សារព័ត៌មាន៖ «ជនភៀសខ្លួនប្រាប់ពីអំពើឃោរឃៅក្នុងរបបខ្មែរក្រហមនៅកម្ពុជា» បាងកកប៉ុស្ដិ៍, ថ្ងៃខែឆ្នាំ ១៤ កក្កដា ១៩៧៥ | ដើម | ទីពីរ |
| ២.៨ | សៀវភៅ៖ ការរស់នៅក្រោមរបបខ្មែរក្រហម៖ ការចងចាំ ដោយលោក គីម វុទ្ធី, បោះពុម្ពផ្សាយ ២០០៦ ។ | ដើម | ទីពីរ |

| | | |
|---|---|---|
| ២.៩ | សៀវភៅ៖ ប៉ុលពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ ដោយ ហ្វីលីព សត់, ឆ្នាំ ២០០៥ ។ | ដើម ទីពីរ |
| ២.១០ | អត្ថបទកាសែត៖ តើអ្វីកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជា? កាសែតញូវយ៉កថៃម, ៨ ឧសភា ១៩៧៧ ។ | ដើម ទីពីរ |

### ១៣.៣.៣. លំហាត់ទី ៣

ប្រធានបទ៖ ប្រវត្តិវិទូម្នាក់កំពុងសិក្សាអំពីរបៀបដែលកាសែតបរទេសរាយការណ៍ នៅសម័យខ្មែរក្រហម ។ គាត់ប្រមូលបានប្រភពឯកសារមួយចំនួនដូចខាងក្រោម ។ តើឯកសារណាខ្លះជាប្រភពឯកសារដើម ? ហើយណាខ្លះទៀតជាប្រភពឯកសារទីពីរ ? ចូរគូសរង្វង់លើចម្លើយត្រឹមត្រូវ ។

| ល.រ. | ប្រភពឯកសារ | ឯកសារ |
|---|---|---|
| ៣.១ | អត្ថបទកាសែត៖ របៀបដែលលោកខាងលិចបានរាយការណ៍នៅសម័យខ្មែរក្រហម, ក្រុងស៊ីដនីយ៍, ថ្ងៃអង្គារទី ៨ ខែមីនា ឆ្នាំ ១៩៩៥ | ដើម ទីពីរ |
| ៣.២ | សៀវភៅ៖ លោក Roger White, សារព័ត៌មាននៅកម្ពុជា, ១៩០០ - ២០០០, បោះពុម្ពផ្សាយឆ្នាំ ២០០១ | ដើម ទីពីរ |
| ៣.៣ | អត្ថបទកាសែត៖ ខ្មែរក្រហមនៅភ្នំពេញ, សារព័ត៌មាន Daily Telegraph (ប្រទេសអង់គ្លេស), ១៨ មេសា ១៩៧៥ ។ | ដើម ទីពីរ |
| ៣.៤ | សន្ទស្សន៍នៃអត្ថបទកាសែតទាក់ទងនឹងកម្ពុជា នៅក្នុងសារព័ត៌មានអាមេរិកឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ | ដើម ទីពីរ |
| ៣.៥ | អត្ថបទរបស់ទស្សនាវដ្តី: ការចងចាំអំពីរបបខ្មែរក្រហម, ទស្សនាវដ្តី Time, USA: ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៩ ។ | ដើម ទីពីរ |
| ៣.៦ | សៀវភៅ៖ ប្រវត្តិនៃអ្នកយកព័ត៌មាន៖របៀបដែលខ្ញុំបានរាយការណ៍នៅសម័យខ្មែរក្រហម, បោះពុម្ពផ្សាយឆ្នាំ ២០០២ ។ | ដើម ទីពីរ |
| ៣.៧ | របាយការណ៍សារព័ត៌មាន៖ «ជនភៀសខ្លួននិយាយពីអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហម» បាងកកប៉ុស្ដិ៍, ថ្ងៃទី ១៤ ខែកក្កដាឆ្នាំ១៩៧៥ | ដើម ទីពីរ |
| ៣.៨ | សៀវភៅ៖ តើសារព័ត៌មានធ្វើការដោយរបៀបណា?, ដោយ Ronald Snidely, បោះពុម្ពផ្សាយ ២០០៦ | ដើម ទីពីរ |
| ៣.៩ | រូបថតឆ្នាំ ១៩៧៥៖ «ខ្មែរក្រហមចូលភ្នំពេញ»,ថតដោយ ប្រ៊ូសហាត់សុន សម្រាប់កាសែត New York Times ។ | ដើម ទីពីរ |
| ៣.១០ | អត្ថបទកាសែត៖ តើអ្វីកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជា? ញូវយ៉កថៃម, ៨ ឧសភា ១៩៧៧ ។ | ដើម ទីពីរ |

# មេរៀនទី ១៤ ៖ វិធីសាស្ត្រចុះឯកសារយោង

## ១៤.១. តើខ្ញុំគួរប្រើប្រភេទឯកសារបែបណា នៅកម្រិតសាកលវិទ្យាល័យ?

និស្សិតប្រវត្តិសាស្ត្រ ភាគច្រើន នឹងត្រូវប្រើប្រភពឯកសារទីពីរ ដើម្បីសរសេរអត្ថបទនិងកិច្ចការសាលារបស់ខ្លួន ។ នៅកម្រិតសាកលវិទ្យាល័យ និស្សិតគួរប្រើប្រភពឯកសារសិក្សារឹងមាំដូចជា៖

- សៀវភៅដែលស្រាវជ្រាវ និងសរសេរដោយអ្នកប្រាជ្ញកម្រិតសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវផ្សេងៗទៀត ដូចជា សារមន្ទីរជាដើម ។
- អត្ថបទទិនានុប្បវត្តិដោយអ្នកសិក្សាស្រាវជ្រាវពីសាកលវិទ្យាល័យ ឬស្ថាប័នស្រាវជ្រាវល្បីៗដទៃទៀត និងត្រូវបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីសិក្សា ។ គម្រូនៃទិនានុប្បវត្តិសិក្សា រួមមាន ទស្សនាវដ្ដីនយោបាយនិងប្រវត្តិសាស្ត្រអូស្ត្រាលី (*Australian Journal of Politics and History*), ទស្សនាវដ្ដីប្រវត្តិសាស្ត្រអាមេរិច (*American Historical Review*), ប្រវត្តិសាស្ត្រសង្គម (*Social History*) និងប្រវត្តិសាស្ត្រនិងទ្រឹស្ដី(*History and Theory*) ។ ទិនានុប្បវត្តិទាំងនេះ អាចត្រូវបានរកឃើញលើបណ្ដាញអ៊ីនធើណែត ក៏ដូចជា នៅក្នុងច្បាប់ដើមរបស់ពួកគេ ។

និស្សិតមិនគួរប្រើប្រភពឯកសារដូចជា សព្វវចនាធិប្បាយ(រួមទាំងវិគីភីឌា wikipedia) ឬ អ៊ីនធើណេត (លុះត្រាតែជាគេហទំព័របានមកពីប្រភពគួរអោយទុកចិត្ត ដូចជាសាកលវិទ្យាល័យល្បីៗ ទស្សនាវដ្ដីសិក្សាស្រាវជ្រាវជាន់ខ្ពស់ ឬសារមន្ទីរធំៗ ) ។

## ១៤.២. តើខ្ញុំអាចអោយអ្នកអានដឹងពីប្រភពឯកសារខ្ញុំប្រើដោយរបៀបណាខ្លះ?

ប្រវត្តិវិទូបង្ហាញអោយអ្នកអានដឹងពីប្រភពព័ត៌មាន ដែលពួកគេទទួលបាន ដោយការចុះប្រភពព័ត៌មាន ។ ពួកគេចុះប្រភពឯកសារទាំងអស់របស់ពួកគេ ដោយ (១) ដាក់លេខយោងនៅខាងក្រោមទំព័រ(footnotes) ឬ (២)ដាក់លេខយោងនៅខាងចុងមេរៀននីមួយៗ (endnotes) ឬ (៣) ដាក់លេខយោងឬសេចក្ដីយោងក្នុងអត្ថបទ(in-text references)តែម្ដង ។ ចុងបញ្ចប់ ពួកគេរៀបចំនិងដាក់ គន្ថនិទ្ទេស (bibliography) នៅចុងបញ្ចប់នៃសៀវភៅ ។

### ១៤.២.១. លេខយោងខាងក្រោម

លេខយោងចង្អុលបង្ហាញអ្នកអាននូវប្រភពឯកសារ ឬព័ត៌មាន ឬ ភស្ដុតាង និងគំនិត ដែលអ្នកនិពន្ធកំពុងបង្ហាញ ។ លេខយោងត្រឹមត្រូវ អនុញ្ញាតអោយអ្នកអានរកឃើញភស្ដុតាងពិតប្រាកដដែលប្រវត្តិវិទូបានពិគ្រោះហើយ ដូច្នេះអ្នកអ្នកអាចតាមរកប្រភពដើម្បីបញ្ជាក់ថែម ។ អ្នកអាចចុះលេខយោង នៅកន្លែងណាមួយក្នុងអត្ថបទទាំងមូលបើគិតថាចាំបាច់ ។ ប្រវត្តិវិទូបញ្ចូលលេខយោង នៅខាងចុងបញ្ចប់នៃប្រយោគនីមួយៗដែលត្រូវការបញ្ជាក់ប្រភព ។ លេខយោងមានលក្ខណៈដូចនេះ[១៩]។ បន្ទាប់មកនៅផ្នែកខាងក្រោមនៃទំព័រ ប្រវត្តិវិទូបញ្ចូលព័ត៌មានស្ដីពីប្រភព ពីក្រោយលេខដែលត្រូវគ្នា ។

[១៩] លេខយោងមានលក្ខណៈដូចនេះ ។

ជាឧទាហរណ៍៖ «មនុស្សភាគច្រើននៅទសវត្សឆ្នាំ ១៩៦០ និង ១៩៧០ ចាត់ទុកថាការអភិវឌ្ឍ វប្បធម៌យុវជន ត្រូវបានផ្សារភ្ជាប់ទៅនឹងចលនា«វប្បធម៌តវ៉ា»។»[១៩]

### ១៤.២.២. លេខយោងខាងចុង

លេខយោងនៅខាងចុង ត្រូវដាក់រួមគ្នា នៅខាងចុងបង្អស់នៃជំពូកណាមួយ ឬសៀវភៅទាំងមូល ។ នេះមានន័យថា សេចក្តីយោងមិនបង្ហាញនៅលើទំព័រតែមួយដូចនឹងប្រយោគដែលត្រូវបានយោងឡើយ ។

### ១៤.២.៣. លេខយោងខាងក្នុងអត្ថបទ

លេខយោងឬ សេចក្តីយោងក្នុងអត្ថបទ បង្ហាញប្រភពព័ត៌មាន ដែលត្រូវយោង ក្នុងអត្ថបទ ផ្ទាល់តែម្តង ។ វាដាក់តែព័ត៌មានខ្លះៗ តែប៉ុណ្ណោះ មិនពេញដូចលេខយោងខាងក្រោមទំព័រ និងលេខយោងខាងចុងជំពូកឡើយ ។

ឧទាហរណ៍៖ «មនុស្សភាគច្រើន នៅទសវត្សឆ្នាំ ១៩៦០ និង ១៩៧០ ចាត់ទុកថាការអភិវឌ្ឍវប្បធម៌យុវជនត្រូវបានផ្សារភ្ជាប់ទៅនឹងចលនា«វប្បធម៌តវ៉ា» (Burgmann, ១៩៩៣៖៤៧) ។

### ១៤.២.៤. ឯកសារគន្ថនិទ្ទេស

ឯកសារគន្ថនិទ្ទេស ឬ បញ្ជីឯកសារពិគ្រោះ គឺជាព័ត៌មានដ៏សំខាន់ ដែលរួមមានបញ្ជីនៃប្រភពព័ត៌មានទាំងអស់ ដែលប្រវត្តិវិទូបានប្រើ ដើម្បីសរសេរប្រវត្តិសាស្ត្ររបស់គាត់ ។

ប្រវត្តិវិទូភាគច្រើនប្រើ លេខយោងខាងក្រោម (FOOTNOTES) មិនមែនជាលេខយោងខាងចុង ឬជាលេខយោងក្នុងអត្ថបទឡើយ ។ ដូច្នេះ សម្រាប់កិច្ចការសាលាប្រវត្តិរបស់អ្នក ចូរប្រើលេខយោងខាងក្រោម ។

## ១៤.៣. តើខ្ញុំត្រូវចុះលេខយោងក្នុងកាលៈទេសៈណាខ្លះ?

ជាទូទៅ អ្នកប្រវត្តិសាស្ត្រគួរដាក់លេខយោងក្នុងករណីដូចខាងក្រោម៖

### ១៤.៣.១. សម្រង់ផ្ទាល់

ជាឧទាហរណ៍៖ «នៅឆ្នាំ ១៩១៧ លោក Larry Smith បាននិយាយថា

«ក្មេងៗទាំងអស់សុទ្ធតែចូលចិត្តបង្អែម» ។

### ១៤.៣.២. ស្ថិតិ

ជាឧទាហរណ៍៖ «៩០%នៃកុមារអាយុក្រោម ៥ ឆ្នាំ ចូលចិត្តផ្អែម ។»

[១៩] (អ្នកស្រី) Verity Burgmann, អំណាចនិងបាតុកម្ម៖ ចលនាសម្រាប់ការផ្លាស់ប្តូរនៅក្នុងសង្គមអូស្ត្រាលី, (បោះពុម្ពដោយរោងពុម្ព) Allen & Unwin, ក្រុងស៊ីដនី, ឆ្នាំ ១៩៩៣, ទំ. ៤៧ ។

#### ១៤.៣.៣. ការពិតដែលអ្នកអានមិនដឹង

ជាឧទាហរណ៍៖ «កុមារ Jane Bellwether បានញ៉ាំស្ករគ្រាប់ អស់ចំនួន ៥៤ គ្រាប់ ក្នុងពេលដាក់គូថអង្គុយម្ដង(ៗ) នៅឆ្នាំ ១៩៨៣ ។»

#### ១៤.៣.៤. គំនិតឬបដិមតិរបស់អ្នកដទៃ

ជាឧទាហរណ៍៖ «កុមារញ៉ាំផ្អែមព្រោះវារំលឹកដល់កំឡុងពេលគេស្ថិតនៅក្នុងស្បូន ។»

### ១៤.៤. តើខ្ញុំត្រូវដាក់ព័ត៌មានអ្វីខ្លះក្នុងលេខយោង?

លេខយោងទាំងអស់ត្រូវការព័ត៌មាននានាអំពីប្រភពដែលត្រូវបានយោង៖

- ឈ្មោះអ្នកនិពន្ធ
- ចំណងជើង
- ព័ត៌មានរបស់អ្នកបោះពុម្ពផ្សាយ (ឈ្មោះគ្រឹះស្ថាន និង ឈ្មោះទីក្រុងដែលបានបោះពុម្ពផ្សាយ)
- កាលបរិច្ឆេទនៃការបោះពុម្ព

ព័ត៌មានទាំងនេះត្រូវរៀបចំផ្សេងគ្នា សម្រាប់រចនាបថផ្សេងៗគ្នា ។

#### ១៤.៤.១. ការចុះសៀវភៅជាឯកសារយោង

នៅពេលអ្នកចុះសៀវភៅណាមួយជាឯកសារយោង អ្នកត្រូវរៀបព័ត៌មានដាក់តាមលំដាប់ដូចខាងក្រោម៖

ឈ្មោះអ្នកនិពន្ធ; ចំណងជើងសៀវភៅ (*ដាក់ទ្រេត* ឬ គូសបន្ទាត់ក្រោម); ទីកន្លែងបោះពុម្ពផ្សាយ; គ្រឹះស្ថានបោះពុម្ព, ឆ្នាំបោះពុម្ព, លេខទំព័រដែលអ្នកបានស្រង់យកព័ត៌មាន (សរសេរក្នុងវង្វង់ក្រចក); ហើយដាក់សញ្ញាចុចពីរ ៖ ចន្លោះ ទីកន្លែងបោះពុម្ពផ្សាយ និង អ្នកបោះពុម្ពផ្សាយ ។

ឧទាហរណ៍៖ Dympha Cusack, *ស្ត្រីជនជាតិចិន(ហ៊ាន)និយាយ,* (ក្រុងស៊ីដនី៖ Angus & Robertson, ១៩៥៨), ទំ. ១២ ។

#### ១៤.៤.២. ការចុះសៀវភៅមានអ្នកនិពន្ធច្រើនជាឯកសារយោង

ចូរដាក់ព័ត៌មានតាមលំដាប់ដូចខាងក្រោម៖

ឈ្មោះរបស់អ្នកនិពន្ធទាំងពីរ, ចំណងជើងសៀវភៅ (*ដាក់ទ្រេត* ឬ គូសបន្ទាត់ក្រោម); គ្រឹះស្ថានបោះពុម្ពផ្សាយ; ទីកន្លែងបោះពុម្ព; ឆ្នាំបោះពុម្ព;លេខទំព័រដែលអ្នកបានស្រង់យកព័ត៌មាន ។

ឧទាហរណ៍៖ Colin Mackerras និង Neale Hunter, សង្កេតមើលប្រទេសចិន, ១៩៦៤-១៩៦៧, (ស៊ីដនី៖ គ្រឹះស្ថានបោះពុម្ពផ្សាយ ថូម៉ាស នេលសុន, ១៩៦៧), ទំ. ៥៥ ។

#### ១៤.៤.៣. ការចុះជំពូកណាមួយនៃសៀវភៅក្រុមអត្ថបទជាឯកសារយោង

ចូរដាក់ព័ត៌មានតាមលំដាប់ដូចខាងក្រោម៖

ឈ្មោះអ្នកនិពន្ធ, ចំណងជើងជំពូក «ដាក់ក្នុងអព្ភន្តរសញ្ញា» (មិនមែនដាក់ទ្រេត), ឈ្មោះចាងហ្វាងកែសម្រួល (eds.), ចំណងជើងសៀវភៅ (*ដាក់ទ្រេត* ឬ គូសបន្ទាត់ក្រោម); ទីកន្លែងបោះពុម្ពផ្សាយ; អ្នកបោះពុម្ព; ឆ្នាំបោះពុម្ព; លេខទំព័រដែលអ្នកបានស្រង់យកព័ត៌មាន ។

ឧទាហរណ៍៖ Meredith Burgmann, «ក្តៅ&ត្រជាក់៖ វេជ្ជបណ្ឌិត Evatt និងជនជាតិរុស្ស៊ីឆ្នាំ ១៩៤៦ - ១៩៤៩» នៅក្នុងសៀវភៅAnn CurtisនិងJohn Merritt (eds.), *សង្គ្រាមត្រជាក់ដំបូងបង្អស់នៅអូស្ត្រាលី ឆ្នាំ ១៩៤៥ - ១៩៥៣,* (ស៊ីដនី៖ គ្រឹះស្ថានបោះពុម្ពផ្សាយ Allen & Unwin, ១៩៨៤) ទំព័រ ៤ - ៦ ។

## ១៤.៤.៤. ការចុះអត្ថបទកាសែតឬទស្សនាវដ្តីស្រាវជ្រាវជាឯកសារយោង

ចូរដាក់ព័ត៌មានតាមលំដាប់ដូចខាងក្រោម៖ ឈ្មោះអ្នកនិពន្ធ, ចំណងជើងអត្ថបទ,
ឈ្មោះទិនានុប្បវត្តិ(*ដាក់អក្សរទ្រេត*), លេខវ៉ុល; លេខ Issue; ខែនិងឆ្នាំ (ដាក់ក្នុងរង្វង់ក្រចក),

លេខទំព័រដែលអ្នកបានស្រង់យកព័ត៌មាន ។

ឧទាហរណ៍៖ Richard White, «ទាហានជាអ្នកទេសចរ៖ បទពិសោធន៍របស់ជនអូស្ត្រាលីក្នុងសង្គ្រាមលោក» *សង្គ្រាមនិងសង្គម*, វ៉ុល ៥, លេខ ១, (កញ្ញា ១៩៨៧), ទំ. ១១៤ ។

## ១៤.៤.៥. ការចុះឯកសារអ៊ីនធឺណែតជាឯកសារយោង

ឈ្មោះពេញរបស់អ្នកនិពន្ធ (អាចជាបុគ្គលឬស្ថាប័ន), ចំណងជើងពេញរបស់ប្រភព (*ដាក់ទ្រេត*); ព័ត៌មានលំអិតនៃការបង្កើត និង/ឬ ការកែសម្រួលលើគេហទំព័រ, <url (អាសយដ្ឋាន ឬគេហទំព័រ)> (ត្រូវតែដូចបេះបិត), កាលបរិច្ឆេទដែលអ្នកបានមើលប្រភពនោះ ។

ឧទាហរណ៍៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា, បានធ្វើបច្ចុប្បន្នភាព ឆ្នាំ ២០១៦ <http://www.rupp.edu.kh/fssh/history/> បានបើកមើល នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៨ ។

## ១៤.៤.៦. ការចុះប្រភពឯកសារនៅក្នុងប្រភពឯកសារផ្សេងជាឯកសារយោង

ប្រសិនបើអ្នកចង់ចុះឯកសារយោងដែលអ្នកបានប្រះឃើញ នៅក្នុងឯកសារយោងនៅក្នុងសៀវភៅផ្សេងៗទៀត ជាឯកសារយោង (ពោលគឺ អ្នកចង់យោងដល់គំនិតរបស់នរណាម្នាក់ ប៉ុន្តែអ្នកមិនបានអានសៀវភៅគេទេ គ្រាន់តែបានអានអំពីគំនិតរបស់បុគ្គលនោះ នៅក្នុងសៀវភៅរបស់អ្នកដទៃ) ។ ក្នុងករណីនេះ អ្នកត្រូវបង្ហាញកន្លែងដែលអ្នកអានចំតែម្តង ។

ត្រូវដាក់ឈ្មោះអ្នកនិពន្ធដើម (បុគ្គលដែលអ្នកកំពុងតែយោង តែមិនបានអានដោយផ្ទាល់), ឈ្មោះអ្នកនិពន្ធសៀវភៅដែលអ្នកបានអាន, ចំណងជើងសៀវភៅដែលអ្នកបានអាន; ទីកន្លែងបោះពុម្ពផ្សាយរបស់សៀវភៅដែលអ្នកបានអាន; គ្រឹះស្ថានបោះពុម្ពសៀវភៅដែលអ្នកបានអាន; ឆ្នាំបោះពុម្ពផ្សាយ; និងលេខទំព័រដែលអ្នកបានស្រង់យកព័ត៌មាន ។

ឧទាហរណ៍៖ រ៉ូបឺតដែម ដែលត្រូវបានដកស្រង់ក្នុងសៀវភៅ លោក Susan Sontag, ស្តីពីរូបថត (ក្រុង Harmondsworth: Penguin Books, ១៩៨៤), ទំ. ៥៦ ។

## ១៤.៥. លំហាត់ចុះឯកសារយោង

ចូរអានអត្ថបទខាងក្រោម បន្ទាប់មក ចង្អុលបង្ហាញកន្លែងណាខ្លះ ដែលអ្នកអាច ឬគួរតែដាក់លេខយោង៖

១ ប្រវត្តិវិទូអាចស្វែងយល់ពីអតីតកាលតាមរយៈការស៊ើបអង្កេតលើ «ភស្តុតាងដែលមនុស្សជំនាន់មុនបានបន្សល់ទុកចេញពីសកម្មភាពពីអតីតកាលរបស់ពួកគេ» ។ ភស្តុតាងនេះអាចមានក្នុងទិដ្ឋភាពជាច្រើន ដូចជាពាក្យពេចន៍សរសេរ របាំ សម្ភារៈប្រើប្រាស់ និងវត្ថុសិល្បៈ ។ ប្រភពព័ត៌មានទាំងនេះ ដែលនៅសេសសល់ពីសម័យកាលដ៏យូរមកហើយនឹងត្រូវបានស៊ើបអង្កេតដោយប្រវត្តិវិទូ គឺជាប្រភពឯកសារដើម ។

២ តាមធម្មតា ប្រវត្តិវិទូធ្វើការអង្កេតយ៉ាងស៊ីជម្រៅ លើប្រភពឯកសារដើម សល់ពីសម័យកាល ឬព្រឹត្តិការណ៍ប្រវត្តិសាស្ត្រណាមួយ ដើម្បីចងក្រងការអធិប្បាយ ដោយឆ្លុះបញ្ចាំងតាមភស្តុតាងជាក់ស្តែងនីមួយៗ ។ ទស្សនៈទាននៃប្រវត្តិសាស្ត្របែបនេះ បាននាំអោយមានការប្រកាសថា«ប្រវត្តិវិទ្យាជាវិទ្យាសាស្ត្រចំតែម្តង មិនលើសមិនខ្វះ ។» តាមពិតគេមិនខ្វល់នឹងការពិតដែលថា តាមន័យសម័យទំនើប វិទ្យាសាស្ត្រ មិនអនុញ្ញាតអោយមានការបកស្រាយផ្ទាល់ខ្លួន ហើយដែល(ការបកស្រាយផ្ទាល់ខ្លួន) ស្ថិតនៅក្នុងបេះដូងនៃវិធីសាស្ត្រប្រវត្តិសាស្ត្រ ។ ជាការពិត លោក ជី. អ. អេលតុន បាននិយាយថា ចម្ងល់ថាតើ «ប្រវត្តិសាស្ត្រជាសិល្បៈ ឬវិទ្យាសាស្ត្រ មិនមានទៀតទេ ។ ចម្លើយគឺទាំងពីរ» ។ ទស្សនៈនេះអនុញ្ញាតអោយមានលក្ខណៈពីធម្មជាតិ នៃកិច្ចការប្រវត្តិសាស្ត្រ ដែលជាការឆ្លុះបញ្ចាំងពីការយល់ដឹងរបស់ប្រវត្តិវិទូណាម្នាក់អំពីអតីតកាល។

៣ ប្រការដែលថា មិនមែនគ្រប់ភស្តុតាងទាំងអស់ អាចនៅដល់សព្វថ្ងៃនេះ គឺជារឿងសំខាន់ណាស់ជាពិសេសនៅក្នុងផ្នែកប្រវត្តិស្ត្រី និងប្រវត្តិសង្គម ដែលជាមុខវិជ្ជាដែលតំណាងអោយអតីតកាល ដែលត្រូវបានគេចាត់ទុកថា «មិនសំខាន់ក្នុងសង្គម» ហើយមិនសមនឹងទទួលបានការយកចិត្តទុកដាក់និងអភិរក្ស ។ ដោយសារតែ «ការសិក្សាប្រវត្តិសាស្ត្រ មិនមែនជាការសិក្សាអំពីអតីតកាលទេ ប៉ុន្តែការសិក្សាពីដានបច្ចុប្បន្ននៃអតីតកាល» ការខ្វះភស្តុតាងប្រវត្តិសាស្ត្រ ដែលពាក់ព័ន្ធនឹងស្ត្រី អាចនាំអោយមានការសន្និដ្ឋានមិនត្រឹមត្រូវទាក់ទងនឹងកង្វះភ្នាក់ងារតំណាងអោយស្ត្រី ។

៤ ប្រវត្តិសាស្ត្រស្ត្រី ឆ្លុះបញ្ជាក់ពីចំណុចខ្វះខាតនៃវិធីសាស្ត្រប្រវត្តិសាស្ត្រ ។ ក្នុងករណីខ្វះខាតប្រភពឯកសារដើម ប្រវត្តិវិទូ ត្រូវបង្ខំចិត្តពិគ្រោះជាមួយប្រភពឯកសារទីពីរ ជាចាំបាច់ ។ ទាំងនេះ គឺជាកំណត់ត្រាប្រវត្តិសាស្ត្រដែលបានសរសេរដោយនរណាម្នាក់ ហើយដែលបកស្រាយពីអតីតកាល ដែលត្រូវបានបំភ្លឺ(ដោយភស្តុតាងនៅសេសសល់) ។ ដូចនេះ ប្រភពទាំងនេះ ទំនងជាមិនអាចបញ្ជាក់ច្បាស់លាស់ពីការពិត ដែលផ្តល់នូវមូលដ្ឋានមិនរឹងមាំ សម្រាប់ប្រវត្តិវិទូចងក្រងកំណត់ត្រារបស់នាង។»

## ១៤.៦. តើគន្ថនិទ្ទេសគឺជាអ្វី?

គន្ថនិទ្ទេស គឺជាបញ្ជីប្រភពឯកសារទាំងអស់ ដែលអ្នកបានពិគ្រោះ និងប្រើក្នុងការងាររបស់អ្នក។ វាបង្ហាញខ្លួន នៅចុងបញ្ចប់នៃអត្ថបទរបស់អ្នក។

នៅក្នុងគន្ថនិទ្ទេស រាយបញ្ជីគ្រប់ប្រភពឯកសារតាមលំដាប់អក្ខរក្រមនៃនាមត្រកូលរបស់អ្នកនិពន្ធ។

អ្នកនឹងត្រូវសរសេរព័ត៌មានដូចគ្នាក្នុងគន្ថនិទ្ទេស ដូចពេលអ្នកចុះលេខ ឬ សេចក្តីយោងផ្សេងៗ ។ អ្នកមិនចាំបាច់ដាក់លេខទំព័រទេ លុះត្រាតែអ្នកកំពុងយោងអត្ថបទកាសែត ។ ក្នុងករណីនោះសូមដាក់លេខទំព័រនៃអត្ថបទទាំងមូល មិនមែនគ្រាន់តែទំព័រដែលអ្នកប្រើនោះទេ។

ប្រសិនបើមានអ្នកនិពន្ធច្រើន អ្នកនិពន្ធដំបូងត្រូវសរសេរនាមត្រកូលមុន ចំណែកអ្នកនិពន្ធផ្សេងទៀត ត្រូវសរសេរនាមខ្លួន មុននាមត្រកូល។

ចូរមើលគម្រូខាងក្រោម ៖

Babbie, E. R. (១៩៩២). *The Practice of Social Research.* Belmont, California : Wadsworth Pub. Co.

Baker, T. L. (១៩៩៤). *Doing Social Research.* Singapore: McGraw-Hill.

Benjamin, J. R. (២០០១). *A Student's Guide to History .* New York: Bedford.

Bertens, H. (១៩៩៥). *THE IDEA OF THE POSTMODERN.* New York: Routledge.

Carr, E. H. (១៩៨៧). *What Is History.* London: Penquin Books Ltd.

Cheng, E. K.-M. (២០១២). *Historiography: An Introductory Guide.* New York: Continuum International Publishing Group.

# សេចក្តីសន្និដ្ឋានសៀវភៅ

ជាការពិត ប្រវត្តិសាស្ត្រ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ទោះក្នុងន័យណាក៏ដោយ ។ ក្នុងន័យធម្មតា វាជារឿងរ៉ាវដែលកើតមានឡើងក្នុងអតីតកាល ឬ ក្នុងន័យស៊ីជម្រៅ វាជាការសិក្សាបែបវិទ្យាសាស្ត្រស្តីពីព្រឹត្តិការណ៍អតីតកាលទាំងនោះឡើយដោយផ្អែកលើភស្តុតាង និងប្រភពឯកសាររឹងមាំ ។ ចំពោះបុគ្គលម្នាក់ៗ ប្រវត្តិសាស្ត្រផ្តល់នូវមធ្យោបាយស្វែងយល់ពី ប្រភពកំណើតថា យើងកើតមកពីណា ហើយយើងបានវិវត្តន៍ដល់ណាហើយ ក្នុងពិភពលោក សម័យទំនើបនេះ ។ ប្រការនេះ យើងទាំងអស់គ្នា ក្លាយជាអ្នកប្រវត្តិសាស្ត្រ ដោយសភាវគតិ ។

កំណើនប្រជាប្រិយភាពខ្លាំងនៃកម្មវិធីប្រវត្តិសាស្ត្រនានា ជាពិសេសការជ្រើសរើសមុខវិជ្ជាប្រវត្តិវិទ្យាក្នុងការប្រលងសញ្ញាបត្រទុតិយភូមិ ក្នុងប៉ុន្មានឆ្នាំកន្លងមក ការផលិតភាពយន្តបែបប្រវត្តិសាស្ត្រ ឬរឿងភាគបែបបុរាណ វីដេអូឯកសារប្រវត្តិសាស្ត្រ ប្រលោមលោកប្រវត្តិសាស្ត្រ និងការចូលទស្សនាទីតាំង បេតិកភណ្ឌប្រវត្តិសាស្ត្រយ៉ាងគគ្រឹកគគ្រេង (គ្រាន់តែប្រាសាទអង្គរវត្តតែមួយ មានភ្ញៀវទេសចរចូល ទស្សនា ២,៥ លាន នាក់ ក្នុងឆ្នាំ ២០១៧ (Spiess, ២០១៨)) គឺជាសក្ខីកម្មយ៉ាងច្បាស់បញ្ជាក់ពី សារៈសំខាន់របស់ប្រវត្តិសាស្ត្រ ក្នុងជីវិតរបស់យើង ។ ខណៈពេលក្រុមអ្នកអក្សរសិល្ប៍ និង ប្រព័ន្ធ សារព័ត៌មាន ហាក់មាននិន្នាការបង្កើតទស្សនៈស្របគ្នាតែមួយ ចំពោះអតីតកាល គេត្រូវកត់សម្គាល់ផងដែរថា ក្នុងការអនុវត្តជាក់ស្តែង ការបកស្រាយអំពីរឿងរ៉ាវអតីតកាលតែងមានការខ្វែងគំនិតគ្នា ។

ជាញឹកញាប់ ពេលខ្លះ ក្រោយជជែកគ្នាហើយ អាចចេញជាសេចក្តីសន្និដ្ឋានផ្សេងខុសមុនទាំងស្រុងក៏មានដែរ ។ ការបកស្រាយខុសៗគ្នាពីអតីតកាល ជួនកាលបានបណ្តាលឱ្យមានការខឹង និងកំពុងបន្តបង្កឱ្យមានជម្លោះរវាងប្រជាជន មិនថាជនជាតិខ្មែរយើង ឬជាតិសាសន៍ដទៃឡើយ ។ នៅពេលដែលរឿងនេះកាន់តែរីករាលដាលខ្លាំងហើយផ្ទុះឡើងជាសង្គ្រាម ភាគីជម្លោះនីមួយៗ នឹងប្រឹងបង្ហាញតែរឿងរ៉ាវអតីតកាលណាដែលគាំទ្រអំណះអំណាងរបស់ខ្លួន ប៉ុណ្ណោះ ។ ហើយការចង់កំហឹងអតីតកាល (ទោះពិតក្តីឬស្រមើស្រមៃក្តី) ដែលត្រូវបានបញ្ចេះបន្ថែមដោយការបកស្រាយព្រឹត្តិការណ៍អតីតកាលខ្លះ (លាក់បាំងខ្លះទៀត) ជារឿយៗ បានក្លាយជាកត្តាលីករជម្រុញចេញជាសកម្មភាពជាក់ស្តែង ក្នុងរូបភាពជាជម្លោះឬសង្គ្រាមជាតិពន្ធុ ។

ប៉ុន្តែ តើប្រវត្តិសាស្ត្រអាចក្លាយជាកម្លាំងចលករ ដ៏មុតស្រួចសម្រាប់ដុសខាត់ការគិតរបស់យើងស្តីអំពីបច្ចុប្បន្ននិងអនាគតដែរឬទេ ? ជារឿងគួរឱ្យសោកស្តាយ ដែលមេដឹកនាំនានាក្នុងសហសម័យមួយចំនួន មិនបានរៀនសូត្រពីកំហុសឆ្គងអតីតកាល ឬ មិនបានដកស្រង់យកបទពិសោធន៍អតីតកាលល្អៗ ។ ជាការពិតណាស់ សោកនាដ្យកម្មជាច្រើនដែលកំពុងបន្តកើតឡើងក្នុងជម្លោះប្រដាប់អាវុធនៅជុំវិញពិភពលោក មានលក្ខណៈដូចគ្នា ហើយកើតឡើងដដែលៗ ។ ទោះយ៉ាងណា ការលេចឡើងសារជាថ្មីនូវលទ្ធិហ្វាស៊ីសនិយម ក្នុងចំណោមអ្នកកាន់អំណាច នៅអឺរ៉ុប ឬ ការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរលើជនស៊ីវិល ឬ ការវិលត្រលប់មកវិញនៃរបបប្រល័យពូជសាសន៍ ហាក់ដូចជាមិនអាចកើតមានឡើយ ឬយ៉ាងហោចណាស់ នឹងមិនកើតឡើងក្នុងពេលឆាប់ៗខាងមុខនេះឡើយ ។ ចំពោះអនាគត ប្រវត្តិវិទូមិនមែនជាគ្រូទាយទេ ។ ប្រវត្តិវិទូភាគច្រើនអាចនឹងអះអាងថា ការប្រែប្រួលអតីតកាលតែងជះឥទ្ធិពល ឬផ្តល់ផលវិបាក ដែលមិនអាចទាយទុកមុនបានឡើយ ម្លោះហើយ អាចជាការរហ័សពេក ដែលគេព្យាយាមទស្សន៍ទាយថា មានអ្វីនឹងកើតឡើង នាពេលអនាគត ។

តាមពិតទៅ សៀវភៅគោលនេះត្រូវបានរៀបរៀងឡើង មិនមែនដើម្បីបញ្ចុះបញ្ចូលអ្នកណាម្នាក់ឲ្យយល់ស្របអំពីសារៈសំខាន់នៃប្រវត្តិសាស្ត្រទេ ។ អ្វីដែលជាការរំពឹងទុកនៅទីនេះគឺថា ក្រោយពេលដែលអ្នកបានអាន

ដោយហ្មត់ចត់ ឬក្រោយបញ្ចប់វគ្គសិក្សានេះ អ្នកនឹងមានការសម្រេចចិត្តមួយផ្ទាល់ខ្លួន ។ យ៉ាងណាមិញ សៀវភៅគោលក្នុងវគ្គសិក្សា«ទ្រឹស្តីប្រវត្តិសាស្ត្រ»នេះមានគោលដៅផ្តល់នូវការណែនាំជាទូទៅអំពីទ្រឹស្តី ឬ បញ្ហានានា ដែលប្រវត្តិវិទូបាននិងកំពុងជជែកគ្នាជាយូរមកហើយ ។ ទ្រឹស្តីប្រវត្តិសាស្ត្រជួយនាំផ្លូវយើងក្នុងការស្វែងយល់ពីអតីតកាលកាន់តែច្បាស់ ។ ប៉ុន្តែ តើប្រវត្តិវិទូត្រូវធ្វើការគាស់កកាយរកការពិតក្នុងអតីតកាលបានយ៉ាងដូចម្តេច ? កិច្ចការនេះស្តាប់ទៅដូចជាងាយស្រួលទេ តែជាក់ស្តែង ពិតជាមិនដូច្នោះឡើយ ។ តាំងពី ជំនាន់ លោក ហេរ៉ូដូទឹស និងលោកស៊ូស៊ីឌីឌីស ក្នុងពិភពលោកសម័យបុរាណ តួនាទីរបស់ប្រវត្តិវិទូនិងលក្ខណៈផ្ទាល់នៃប្រវត្តិសាស្ត្រ ត្រូវជជែកវែកញែកគ្នា យ៉ាងក្តៅគគុក ។ ដូច្នោះហើយ ក្នុងរយៈពេលពីរពាន់ឆ្នាំកន្លងមកហើយ ព្រំដែននៃការចងក្រង ក៏ដូចជាការសិក្សាប្រវត្តិសាស្ត្រមានមានការប្រែប្រួលរហូត ។ សូម្បីមកដល់សម័យនេះហើយក្តី (ពីរបីរយឆ្នាំបន្ទាប់ពីប្រវត្តិសាស្ត្របានក្លាយជាមុខវិជ្ជាសិក្សាជាន់ខ្ពស់) យើងនៅមិនដឹងច្បាស់ថា ប្រវត្តិសាស្ត្រ«ត្រឹមត្រូវ» ជាអ្វីនោះទេ ហើយក៏កាន់តែមិនដឹងថាត្រូវអាចគូសបន្ទាត់បែងចែកព្រំដែននៃមុខវិជ្ជា ប្រវត្តិវិទ្យា សង្គមវិទ្យា ឬភូមិវិទ្យា ត្រង់ណាឲ្យប្រាកដដែរ ។

ភាពលំបាកស្មុគស្មាញកាន់តែកើនឡើងថែមទៀត នៅពេលយើងលើកឡើងអំពីបញ្ហា «សច្ចៈភាពប្រវត្តិសាស្ត្រ» ។ នៅក្នុងសាលារៀន យើងហាក់មានទំនោរ ឆាប់ជឿការអះអាងនានា ក្នុងសៀវភៅប្រវត្តិសាស្ត្រថាអតីតកាលពិតជាបានកើតឡើងដូច្នោះមែន ។ ទំនោរនេះបានចាប់ផ្តើម នៅចុងសតវត្សរ៍ ១៩ នៅពេលប្រវត្តិសាស្ត្រក្លាយជាមុខវិជ្ជាសិក្សាជាន់ខ្ពស់ ក្នុងកម្រិតសាកលវិទ្យាល័យ ហើយបេសកកម្ម ដែលគេចាត់ទុកថាមានភាពប្រាកដនិយម ក្នុងការរុករកសច្ចៈភាពពីអតីតកាល ក៏ចាប់ផ្តើមដែរ ។ សម័យមុននេះ អ្នកសរសេរចងក្រងពីអតីតកាល មានគោលបំណងក្នុងចិត្តផ្សេងពីនេះ ជាពិសេស សម្រាប់ភាពចាំបាច់ផ្នែកនយោបាយ ពោលគឺ ដើម្បីពង្រឹងការក្តោបក្តាប់អំណាចរបស់រដ្ឋ ឬមនុស្សដែលខ្លួនបម្រើ ។ សព្វថ្ងៃនេះ ប្រវត្តិវិទូជាច្រើន តាំងចិត្តស្មោះត្រង់ចំពោះប្រវត្តិសាស្ត្រដែរ ប៉ុន្តែ ទោះមានវិធីសាស្ត្រច្រើន ដែលអាចយកមកប្រើបានក៏ដោយ ការទម្លុះទម្លាយរកសច្ចៈភាពប្រវត្តិសាស្ត្រនៅតែជាគោលដៅពិបាកសម្រេចបានដដែល ។ អ្នកខ្លះបានរិះគន់ខ្លាំងៗថាគោលដៅនេះ ជាការសន្យាខ្យល់ព្រោះថា កំណត់ត្រាប្រវត្តិសាស្ត្រទាំងអស់តែងតែត្រូវគេបកស្រាយខុសៗគ្នា ហើយតើនរណាជាអាជ្ញាកណ្តាលកាត់សេចក្តីថា ការបកស្រាយណាមួយជាការពិត ឬជាការត្រឹមត្រូវ ?

ដូច្នេះ បើទោះជាមានការផ្លាស់ប្តូរខ្លះ ដោយព្យាយាមឃ្លាតឆ្ងាយពី ទ្រឹស្តីផ្អែកលើភាសាវិទ្យា («ទ្រឹស្តីក្រោយសម័យទំនើបនិយម» (Post-Modernism) និង «វិធីសាស្ត្ររុះរើ»[២០] (Deconstruction)) ដែលបានបញ្ចុះបញ្ចូលយើងថា «គ្មានសច្ចៈភាពអតីតកាលទេ » ហើយថាប្រវត្តិសាស្ត្រប្រៀបដូចជា«អត្ថបទ»មួយដែលអាចត្រូវមនុស្សផ្សេងគ្នាអានហើយមានការយល់ឃើញផ្សេងៗគ្នា, ប្រវត្តិវិទូនានានៅបន្តឆ្លុះបញ្ចាំងលើវណ្ណកម្មរបស់ពួកគេ ។ សៀវភៅគោលនេះព្យាយាមចូលរួមចំណែកក្នុងការឆ្លុះបញ្ចាំងនោះ ប៉ុន្តែ ត្រូវបានរៀបរៀងឡើងវិញសម្រាប់និស្សិតនិងគរុនិស្សិត ឬ និស្សិតក្រោយឧត្តមសិក្សា ដែលកំពុងសិក្សាវគ្គ «ទ្រឹស្តីប្រវត្តិសាស្ត្រ» នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាពេលបច្ចុប្បន្ននេះ ។

ស្របពេលមានទំនោរនិយមគោលការណ៍ ឬ វិធីសាស្ត្រចម្រុះមុខវិជ្ជា កាន់តែកើនឡើង ក៏ដូចជាកំណើនការយកចិត្តទុកដាក់លើដំណើរការសិក្សា និងសរសេរប្រវត្តិសាស្ត្រ វគ្គសិក្សាស្តីពីទ្រឹស្តី វិធីសាស្ត្រ និងការអនុវត្តចងក្រងប្រវត្តិសាស្ត្រ ហាក់ដូចជាមានចំនួនកើនឡើង និងកាន់តែមានសារៈសំខាន់ខ្លាំងឡើងៗ ។ គោលបំណង

[២០] វិធីសាស្ត្រវិភាគស៊ីជម្រៅទៅលើភាសាបែបទស្សនវិជ្ជានិងអក្សរសាស្ត្រ ដែលសង្កត់ធ្ងន់លើដំណើរការខាងក្នុងរបស់ប្រព័ន្ធភាសានិងចិត្តគំនិត, គុណភាពនៃអត្ថន័យដោយអាស្រ័យលើបរិបទនានា, និងការសន្មតកម្ម(អត្ថន័យ)ដែលមិនត្រូវបានស្តែងចេញផ្ទាល់ដោយពាក្យសម្តី ។

ធំរបស់ខ្ញុំនៅទីនេះ គឺចង់ចូលរួមចំណែកក្នុងការជជែកវែកញែកអំពីប្រវត្តិសាស្ត្រ ហើយម្យ៉ាងទៀត ក៏ចង់ផ្តល់ជាឯកសារគោលសម្រាប់និស្សិត និងគរុនិស្សិត ឬនិស្សិតក្រោយឧត្តមសិក្សា ដែលចង់ស្វែងយល់ និងរម្លឹកទ្រឹស្តីប្រវត្តិសាស្ត្រនានាឡើងវិញ ។

ស្របពេលចាប់ផ្តើមដំណើរការកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសប្រវត្តិវិទ្យា នៅដេប៉ាតឺម៉ង់ប្រវត្តិវិទ្យាបានពីរបីជំនាន់មកហើយ ចំណែង កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន(Teaching Upgrading Programme) នៃមហាវិទ្យាល័យអប់រំ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គ្មានពេលណាល្អជាងពេលនេះឡើយ សម្រាប់ការរៀបចំបោះពុម្ពសៀវភៅនេះឡើងវិញ។ ម្យ៉ាងទៀត ថ្នាក់បរិញ្ញាបត្រក៏នឹងត្រូវចាប់ផ្តើមនាបវេសនកាលឆាប់ៗខាងមុខដែរ ។ សៀវភៅនេះ គឺជាឯកសារគោលក្នុងវគ្គសិក្សាខាងលើ ។ តាមពិតទៅ មិនចាំបាច់ដល់តែមានចំណេះដឹងប្រវត្តិសាស្ត្រទើបអាចប្រើសៀវភៅនេះបានឡើយ ។ អ្នកមានចំណាប់អារម្មណ៍លើប្រវត្តិសាស្ត្រ ក៏អាចសាកល្បងស្វែងយល់ផងដែរ ។ ប៉ុន្តែ គ្រាន់តែអ្នកទាំងអស់គ្នាត្រូវបើកចិត្តយល់ថា ប្រវត្តិសាស្ត្រអាចត្រូវយល់ឃើញផ្សេងៗគ្នា ។ ការយល់ឃើញផ្សេងៗគ្នានេះហើយ ជាជំហានឆ្ពោះទៅរកការសិក្សាទ្រឹស្តីប្រវត្តិសាស្ត្រ ។

សៀវភៅនេះ មិនតម្រូវឲ្យអ្នកត្រូវអានឬរៀនតាមលំដាប់ជាបន្តបន្ទាប់ទេ ។ ផ្ទុយទៅវិញបើអ្នកចាប់អារម្មណ៍ ឬចង់ស្វែងយល់ទ្រឹស្តី ឬបំណិនណាមួយ អ្នកអាចបើកវាអានភ្លាមតែម្តង ។ ដោយឡែក សៀវភៅនេះត្រូវបានបែងចែកជា**ពីរជំពូក** ។ ស្របពេលដែលជំពូកទី ១ និយាយពីទ្រឹស្តីប្រវត្តិសាស្ត្រធំៗ ជំពូកទី ២ ពីបំណិនពិសេសៗចាំបាច់សម្រាប់ការសិក្សាប្រវត្តិសាស្ត្រ ។

**ជំពូកទី ១** ចាប់ផ្តើមដោយការពិភាក្សាពីនិយមន័យនៃទ្រឹស្តី, ប្រវត្តិសាស្ត្រ ឬប្រវត្តិវិទ្យា, ទ្រឹស្តីប្រវត្តិសាស្ត្រ និងពាក្យគន្លឹះមួយចំនួនទៀត ។ ប្រធានបទក្នុងផ្នែកទីមួយនៃជំពូកនេះ នឹងសម្លឹងមើលទ្រឹស្តីប្រវត្តិសាស្ត្រសម័យបុរាណ ដូចជាទ្រឹស្តីបិតាប្រវត្តិសាស្ត្រ លោក ហេរ៉ូដូទឹស និងស៊ូស៊ីឌីឌីស ក៏ដូចជាទ្រឹស្តីប្រវត្តិសាស្ត្រសាសនា និងចិនបុរាណ ។ ផ្នែកទីពីរ នឹងពិភាក្សាទស្សនៈរបស់បិតាមុខវិជ្ជាប្រវត្តិសាស្ត្រសម័យទំនើប នោះគឺ លោក ឡេអូផូល វុនរ៉ែងឃ័រ ។ វាជាជំហានដ៏ធំមួយក្នុងវិជ្ជាការសរសេរប្រវត្តិសាស្ត្រ ។ ផ្នែកទីបីនៃជំពូកដដែល នឹងសង្កេតលើទ្រឹស្តីសំខាន់ផ្សេងទៀត ពិសេសទ្រឹស្តីក្រោយសម័យទំនើបនិយម ដែលប្រឹងអះអាងថា គ្មានទេការពិតពីអតីតកាល មានតែ «**ប្រធានវិបស្សនា**» ។

**ជំពូកទី ២** ព្យាយាមបង្ហាត់នូវបំណិន ឬជំនាញចាំបាច់មួយចំនួន សម្រាប់និស្សិតកំពុងសិក្សាវគ្គទ្រឹស្តីប្រវត្តិសាស្ត្រ ។ គន្លឹះក្នុងការកត់ត្រាខ្លឹមសារមេរៀនក្នុងថ្នាក់ វិធីសាស្ត្រសង្ខេបមេរៀន និងល្បិចមើលមេរៀនត្រៀមប្រលង គឺជាចំណងជើង«មេរៀនពិសេស» ក្នុងជំពូកនេះ ហើយវាពិតជាមានសារៈសំខាន់ណាស់ ពិសេសសម្រាប់អ្នកសិក្សាប្រចាំសតវត្សរ៍ទី ២១ ដែលរងសម្ពាធខ្លាំងពីគ្រប់ទិសទី (ការសិក្សាច្រើនមុខជំនាញ ឬកំពុងរៀនផងធ្វើការផង) ។ បំណិនចាំបាច់មួយទៀត គឺវិធីសាស្ត្របែងចែកប្រភពឯកសារ និងការចុះប្រភពឯកសារយោង ក៏ត្រូវបង្ហាញផងដែរ ។ នៅផ្នែកចុងក្រោយបង្អស់ គឺជាឧបសម្ព័ន្ធ ដោយរួមបញ្ចូលផែនទីនិងរូបភាពមួយចំនួនពាក់ព័ន្ធនឹងមេរៀន ។ នៅចុងមេរៀននីមួយៗ ខ្ញុំបានបន្ថែមសំណួរពិភាក្សាក្រុម ឬ លំហាត់សម្រាប់និស្សិត និងគរុនិស្សិត អនុវត្តបំណិនទាំងនោះ ។

ទីបំផុត សៀវភៅនេះត្រូវបានរៀបចំសម្រួលឡើងវិញ ដើម្បីឲ្យនិស្សិត ឬអ្នកអានទូទៅងាយស្រួលយល់ ។ គួរកត់សម្គាល់ថា ការសម្រួលនេះ អាចធ្វើទៅបាន ក្រោយពេលខ្ញុំបាននិងកំពុងប្រើប្រាស់វាសម្រាប់វគ្គសិក្សា«ទ្រឹស្តីប្រវត្តិសាស្ត្រ» ជាងមួយទសវត្សរ៍កន្លងមកហើយ ទាំងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យ

មានជ័យ និង វិទ្យាស្ថានជាតិអប់រំ ។ តាមពិតទៅ សៀវភៅនេះត្រូវបានចងក្រងឡើង ដោយផ្អែកលើបទពិសោធន៍របស់អ្នករៀបរៀង ក្នុងវគ្គបង្រៀនទ្រឹស្តីប្រវត្តិសាស្ត្រ ជាភាសាអង់គ្លេសរបស់ប្រវត្តិវិទូ ជនជាតិអូស្ត្រាលី **អគ្នីស្កា សុបុចិនស្កា** (Agnieszka Sobocinska) ដែលខ្ញុំបានស្ម័គ្រចិត្តជួយបកប្រែអត្ថបទមេរៀន មួយមេរៀនម្តងៗជាភាសាខ្មែរ និងជួយបកប្រែផ្ទាល់មាត់ក្នុងថ្នាក់ផង ដើម្បីពន្យល់និស្សិត នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញកាលពីឆ្នាំ ២០០៧ ។ មួយឆ្នាំបន្ទាប់ ក្រោយពេលគាត់ត្រលប់ទៅអូស្ត្រាលីវិញ ខ្ញុំត្រូវបានលើកបន្ទុកអោយទទួលបង្រៀនមុខវិជ្ជានេះ ជាបន្តបន្ទាប់ ។ នោះហើយជាឱកាសខ្ញុំបានស្វែងយល់ពីតម្រូវការជាក់ស្តែង តាមបរិបទប្រវត្តិសាស្ត្រកម្ពុជា ក្នុងការបន្ថែមខ្លឹមសារមេរៀន ឬបំពេញចន្លោះខ្វះខាតក្នុងឯកសារ ដែលបានប្រើជិតមួយទសវត្សរ៍កន្លងមក ។ យ៉ាងណាក៏ដោយ កំហុសដោយចេតនា ឬអចេតនាក្តីច្បាស់ជាជៀសមិនរួចឡើយ ។ ម្លោះហើយ ខ្ញុំរង់ចាំរាល់មតិរិះគន់ ឬការផ្តល់យោបល់នានា មិនថា តិចឬច្រើនក្តី ។

ថ្ងៃសុក្រ ៣ រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០២១

**ថា លាងអាង**

# បញ្ជីគន្ថនិទ្ទេស

Spiess, R. (2018, January 2). *The Phnom Penh Post*. From Business: https://www.phnompenhpost.com/business/ticket-revenue-angkor-wat-jumps-72-percent-after-price-hike

Nath, C. (1967). *Khmer Dictionary.* Phnom Penh: Buddhist Institute.

Hobsbawm, E. (1996). Towards an Industrial World . In E. Hobsbawm, *The Age of Revolution* (pp. 168-181). New York: Vintage Books.

Benjamin, J. R. (2001). *A Student's Guide to History* . New York: Bedford.

Storey, W. K. (2004). *Writing History: A Guide for Students.* Oxford: The Oxford University Press, Inc.

Royce A. Singleton, Bruce C. Straits, Margaret Miller Straits. (1993). *Approach to Social Research.* Oxford: The Oxford University Press.

Babbie, E. R. (1992). *The Practice of Social Research.* Belmont, California : Wadsworth Pub. Co.

Baker, T. L. (1994). *Doing Social Research.* Singapore: McGraw-Hill.

Staff, T. (2018, June 18). *How To Give Students Specific Feedback That Actually Helps Them Learn.* From Teach Thought: https://www.teachthought.com/pedagogy/how-to-give-students-specific-feedback-that-actually-helps-them-learn/

Peter Claus, John Marriott. (2017). *History: An Introduction to Theory, Method and Practice.* New York: Routledge.

Walker, G. (2003). Psychoanalysis and History. In S. Berger, H. Heldner, & K. Passmore, *Writing History: Theory and Practice* (pp. 118-140). London: Hodder Arnold.

Turkington, C. (2003). *Memory: A Self-Teaching Guide.* Hoboken, New Jersey: John Wiley & Sons, Inc.

Cheng, E. K.-M. (2012). *Historiography: An Introductory Guide.* New York: Continuum International Publishing Group.

Gelina Harlaftis, Nikos Karapidakis, Kostas Sbonias, Vaios Vaiopoulos. (n.d.). *THE NEW WAYS OF HISTORY: Developments in Historiography.*

Bertens, H. (1995). *THE IDEA OF THE POSTMODERN.* New York: Routledge.

Tucker, A. (2009). *A Companion to the Philosophy of History and Historiography.* Oxford: Blackwell Publishing Ltd.

James M. Banner, J. (2012). *Being a Historian: An Introduction to the Professional World of History.* Cambridge : Cambridge University Press.

Marincola, J. (2007). *A COMPANION TO GREEK AND ROMAN HISTORIOGRAPH.* Oxford: Blackwell Publishing Ltd.

Marincola, J. (2003). *Herodotus: The Histories.* London: Penguin Books Ltd.

Carr, E. H. (1987). *What Is History.* London: Penquin Books Ltd.

White, H. (1975). *Metahistory.* Baltimore: The johns Hopkin University Press.

Michael J. Salevouris, Conal Furay. (2015). *The Methods and Skills of History: A Practical Guide.* Pondicherry: John Wiley and Sons, Inc.

Crawley, R. (2013). *Thucydides: The History of The Peloponnesian War.* Project Gutenberg.

Alice Oshima, A. H. (2005). *Writing Academic English.* PEARSON PTR.

TLA